# សេចក្តីខាងដើម

**តក្កសិលា** ជាឈ្មោះរាជធានីមួយដ៏ល្បីល្បាញ ក្នុងបុរាណសម័យនៃរជ្ជគន្ធារៈ ព្រោះមានសាកលមហាវិទ្យាល័យ ដែលក្នុងសម័យមុនហៅថា " **សាលាអាចារ្យ ទិសាបាមោក្ខ** " មានមហាសាស្ត្រាចារ្យ សម្រាប់បង្រៀនសស្ត្រវិជ្ជានិងសាស្ត្រវិជ្ជាចំពោះនិស្សិតទាំងឡាយ ដែលក្នុងសម័យបុរាណ និយមហៅថា " **អាចារ្យទិសាបាមោក្ខ** " ឬ " **ទិសាបាមោក្ខាចារ្យ** " ។

អ្នកប្រទេសដទៃៗ មានអ្នកនគរពារាណសី, សាវត្ថី, វេសាលីជាដើម ទាំងក្សត្រ, ព្រាហ្មណ៍, សេដ្ឋី, គហបតីធំៗ និយមបញ្ជូនបុត្រធីតាឱ្យទៅសិក្សាឯក្រុងតក្កសិលា ក្នុងសំណាកអាចារ្យទិសាបាមោក្ខ ។ កុលបុត្រទាំងឡាយ អាចជ្រើសរើសវិជ្ជាមួយមុខ ឬ ច្រើនមុខ តាមចំណង់សម្រាប់សិក្សាបាន ព្រោះលោកសាស្ត្រាចារ្យ អាចបង្រៀនវិជ្ជាគ្រប់ផ្នែក ចំពោះនិស្សិតឥតទើសទោស ។

ក្រោយពីបញ្ចប់កិច្ចសិក្សារបស់ខ្លួនហើយ កុលបុត្រទាំងឡាយ ក៏ត្រឡប់ទៅកាន់ប្រទេសជាតិមាតុភូមិរបស់ខ្លួនវិញ បានទទួលមុខការនាទីតាមសមត្ថភាពរបស់ខ្លួន ខ្លះជាព្រះរាជបុត្រ ក៏បានទទួលដំណែងជាមហាឧបរាជឬបើរជ្ជទាយាទ ក៏បានទទួលរាជាភិសេកជំនួសព្រះបិតា

កុលបុត្រនិស្សិតក្រៅពីនេះ ខ្លះបានជារដ្ឋមន្ត្រី, ខ្លះជាមេទ័យ, នាយកង, ខ្លះជាសាស្ត្រាចារ្យ,ខ្លះជាវិស្វករ,ស្ថាបនាករ, រចនាករ, ខ្លះជារាជបុរោហិតបណ្ឌិតហោរ, ខ្លះជាវេជ្ជបណ្ឌិត, ខ្លះក៏យកវិជ្ជាមកពង្រីងពង្រីកកិច្ចការជាកេរ្តិ៍មត៌កឱ្យចំរើងឡើង និងតាំងខ្លួននៅក្នុងកិត្តិយសកេរ្តិ៍ឈ្មោះពិរោះល្បី។

ខ្លួនខ្ញុំឈ្មោះ **សុជាត** ជាសេដ្ឋីបុត្រទោលតែម្នាក់ឯង របស់លោក វឌ្ឍនសេដ្ឋី និងទេវីសេដ្ឋិនី លោកបានបញ្ជូនខ្ញុំឱ្យទៅនៅសិក្សាក្នុងសំណាក់អាចារ្យទិសាបាមោក្ខ តាំងពិខ្ញុំមានអាយុ ១០ ឆ្នាំ លុះអាយុ ២០ ឆ្នាំ ខ្ញុំក៏បញ្ចប់ការសិក្សា, បិតាមាតាខ្ញុំ ឱ្យខ្ញុំជ្រើសរើសរៀន **គណនាសប្បៈ** សិល្បៈ ឬ វិជ្ជា ក្នុងការគិតតាមលេខគណិតសាស្ត្រ ខ្ញុំខំរៀនវិជ្ជាផ្នែកនេះ ដោយយកចិត្តទុកដាក់ រហូតមានចំណេះជំនាញជាពិសេស ក្រៅពីគណិតសាស្ត្រ ខ្ញុំក៏បានសិក្សាល្មមប្រើការបានដែរនូវវិជ្ជាដទៃទៀត ដូចៈ

**ធនុសិប្បៈ** វិជ្ជាក្នុងការបាញ់ធ្នូ

**សង្ខានសិប្បៈ** វិជ្ជាក្នុងការពិចារណាដោយប្រាជ្ញាក្នុងឧបទេសគឺនយោបាយ

**កាវេយ្យសិប្បៈ** វិជ្ជាក្នុងកាព្យឃ្លោង

**លោកាយតសិប្បៈ** វិជ្ជាក្នុងផ្លូវលោក មានវិជ្ជាពេទ្យ វិជ្ជាផ្សំធាតុជាដើម

**ខត្តិយវិជ្ជាសិប្បៈ** វិជ្ជានីតិធម្មសាស្ត្រ យុទ្ធសាស្ត្រ ។

លុះបញ្ចប់ការសិក្សាហើយ ខ្ញុំក៏គោរពលាលោកមហាសាស្ត្រាចារ្យ ត្រឡប់មកមាតុភូមិវិញ ជាមួយនិងមិត្តនិស្សិតទាំងឡាយ ។

មាតាបិតារបស់ខ្ញុំ និងក្រុមញាតិ សំដែងសេចក្តីអបអរជាទីរំភើបចិត្តពន់ពេក ។ ក្នុងពិធីទទួលការជុបលៀងជាកិត្តិយសចំពោះខ្ញុំនោះ ព្រាហ្មណ៍, គហបតី, សេដ្ឋី, មន្ត្រី, កុដុម្ពិកៈ ទាំងឡាយ ព្រមទាំងភរិយាបុត្តធីតារបស់ខ្លួន បានមកជួបជុំជាច្រើន តាមសេចក្តីអញ្ជើញ ឱ! ខ្ញុំភ្លេចជំរាប ភ្ញៀវដែលពិសេសនោះ គឺព្រះភិក្ខុសង្ឃចំនួន២៥០អង្គ ដែលមាតាបិតាខ្ញុំបាននិមន្តមកទទួលចង្ហាន់ ព្រមទាំងស្វាធ្យាយព្រះពុទ្ធមន្ត ដើម្បីជាសិរីជយមង្គលផលល្អចំពោះខ្ញុំ តាមសណ្តាប់ធ្នាប់ នៃអ្នកកាន់ព្រះពុទ្ធសាសនា ។ មាតាបិតាខ្ញុំ បាននាំខ្ញុំទៅក្រាបថ្វាយបង្គំព្រះ-សង្ឃ មានព្រះមហាថេរជាប្រធាន ព្រមទាំងទូលលោកឱ្យជ្រាបថា ខ្ញុំជាកូនតែមួយដែលទៅសិក្សាសិល្បសាស្ត្រ ឯនគរតក្កសិលា ទើបនឹងត្រឡប់មកវិញ, ក្រៅពីនេះ បិតាមាតាបាននាំខ្ញុំទៅគោរពភ្ញៀវ ឥស្សរជន និងញាតិមិត្តទាំងឡាយ ។

ក្នុងពិធីនោះ រឿងមួយដែលនាំឱ្យខ្ញុំចាប់អារម្មណ៍ គឺលោកសុធនមហាសេដ្ឋី នាំបុត្រីមួយរបស់លោកទៅក្នុងពិធីនោះដែរ នាងឈ្មោះ **សុន្ទរី** ។ សេដ្ឋីធីតានេះ មានរូបល្អឆើតឆាយគួរឱ្យប្រតិព័ទ្ធណាស់

ខ្លួនខ្ញុំដែលមិនសូវយកចិត្តទុកដាក់នឹងបញ្ហាស្នេហានៅឡើយ ក៏ស្រាប់តែដុះពន្លកពកពន្លឺសេចក្តីស្នេហាចំពោះកញ្ញាសុន្ទរីយ៉ាងលើសលប់ ចង់បាននាងជាគូរជីវិតមិត្តជីវា ។ ខ្ញុំយល់ថា កាលបើនាងមិនទាន់មានគេស្តីដណ្តឹងទេ រឿងស្នេហារបស់ខ្ញុំមិនជាពិបាកពេកឡើយ ព្រោះលោកសុធនមហាសេដ្ឋី និងមាតាបិតាខ្ញុំជាមិត្តភក្ត មានមេត្រីចិត្តមិត្តភាពចំពោះគ្នាណាស់ បើមាតាបិតាខ្ញុំនិយាយស្តីដណ្តឹងនាង លោកមុខជាព្រមស្រុះស្រួលមិនខាន ក្រែងនាងមិនយលព្រម ព្រោះមិនស្រលាញ់ខ្ញុំ ។ ខ្ញុំយល់ថា នាងប្រហែលមិនយល់ទាស់ទេមើលទៅ ព្រោះខ្ញុំជាបុត្តទោលដែលត្រូវទទួលមហាមត៌កពីវង្សត្រកូល, ខ្ញុំជាអ្នកបានទទួលការសិក្សាអប់រំមកហើយ, រូបនិងវ័យរបស់ខ្ញុំក៏នៅក្មេងកម្លោះល្អក់, ចរិយាមារយាទខ្ញុំក៏ល្អគួរសម គឺថា ខ្ញុំមានទាំងទ្រព្យសម្បត្តិ រូបសម្បត្តិ វិជ្ជាសម្បត្តិ ចរិយាសម្បត្តិយ៉ាងសមសួន ទាំងបួនមុខ ល្មមជាផ្ទាក់ទាក់ចិត្តផ្ចិតអារម្មណ៍នៃនាងក្រមុំសុន្ទរីបាន ។

ថ្ងៃក្រោយ ខ្ញុំបាននិយាយរឿងសេចក្តីស្រឡាញ់ពេញចិត្តរបស់ខ្ញុំចំពោះកញ្ញា **សុន្ទរី** ឱ្យលោកឪពុកម្តាយជ្រាប លោកអ្នកដ៏មានគុណទាំងពីរក៏យល់ព្រម ថែមទាំងរីករាយចំពោះបំណងរបស់ខ្ញុំ ដែលសមប្រកបនិងបំណងរបស់គាត់ដែរ តែគាត់មានប្រសាសន៍ថា ការដែលខ្ញុំបានសិក្សាលោកវិជ្ជាទាំងឡាយ ជាមធ្យោបាយសាងទ្រព្យធន ឬ យស

សក្តិ ក៏ល្អមល្ហៃហើយ តែត្រូវបំពេញចិត្តមួយទៀតសិន មុននឹងមានគ្រួសារ គឺបំណាច់កើតទាន់ព្រះពុទ្ធសាសនា ថែមទាំងមានព្រះពុទ្ធអង្គគង់ព្រះជន្មនៅផង ត្រូវបួសសិក្សារអប់រំពុទ្ធសាសនវិជ្ជាយ៉ាងតិចណាស់មួយវស្សាសិន ព្រោះព្រះពុទ្ធសាសនាជាមូលដ្ឋាននៃការប្រព្រឹត្តិ កាយវាចា ចិត្ត ឱ្យឋិតនៅក្នុងផ្លូវត្រឹមត្រូវ ទាំងជាគោលគំនិតក្នុងការកសាងខ្លួនឱ្យជួបជួននឹងប្រយោជន៍ត្រជាក់ត្រជុំក្សេមក្សាន្តក្នុងជីវភាព . . . ។ លោកឪពុកមានប្រសាសន៍បញ្ជប់ថា បើខ្ញុំយលព្រមបួស គាត់នឹងដណ្តឹងសុន្ទរី ទុកឱ្យ ។ ខ្ញុំក៏យល់ព្រមតាមនាក់ដោយរីករាយ ព្រោះចិត្តខ្ញុំក៏មិនជាតក់ក្រហល់ជ្រមុលពុលជ្រមុជអន្ទះអន្ទែងនឹងរឿងស្នេហា រហូតអត់ទ្រាំមិនបាននោះទេ ពិតមែនតែខ្ញុំស្រឡាញ់យ៉ាងខ្លាំងនូវនាងសុន្ទរីក៏ដោយខ្ញុំក៏នៅក្មេងដែរ អាយុជាង ២០ ឆ្នាំប៉ុណ្ណោះ អាយុ ២២-២៣ ឬ ២៤ ២៥ សឹមមានគ្រួសា ក៏ល្អដែរ ឱ្យតែនាងសុន្ទរីបានជាភរិយាខ្ញុំ ក្នុងអនាគត ។

កាលខ្ញុំយល់ព្រមហើយ លោកខ្ញុំពុកម្តាយ ក៏បានទៅទាក់ទងចងជន្លងនឹងសុធនមហាសេដ្ឋី២ ក៏យល់ព្រមដោយសេចក្តីពេញចិត្ត ថែមទាំងបើកសេរីភាពឱ្យខ្ញុំនិងសុន្ទរីបានសន្ទនា ភ្ជាប់សេចក្តីស្រលាញ់ ដឹងចិត្តដឹងថ្លើមគ្នាទៀតផង តែយើងទាំងពីរនាក់ បានរក្សាប្រវេណីយ៉ាងល្អ។

មិនប៉ុន្មានថ្ងៃក្រោយមក ខ្ញុំក៏បានឧបសម្បទាជាភិក្ខុតាមពុទ្ធវិន័យ។

ខ្ញុំធ្វើវត្តប្បដិវត្ត ចំពោះព្រះមហាថេរជាឧបជ្ឈាយ៍ ហើយផ្ដើមសិក្សាវិន័យពីសំណាក់លោក ។ ដោយខ្ញុំធ្លាប់សិក្សាវិជ្ជាផ្លូវលោកមកហើយ លុះមកសិក្សាព្រះពុទ្ធសាសនាដ៏ប្រកបដោយហេតុផលពិត ក៏ឆាប់យល់ឆាប់ចេះចាំ នាំឱ្យរឹងតែភ្លឺស្វាងចំពោះវិជ្ជាដែលខ្ញុំធ្លាប់សិក្សាមកហើយទៀតផង ។ សេចក្ដីរីករាយសប្បាយ និងភេទសមណៈ ព្រមទាំងបានត្រេបរសជាតិព្រះធម៌ នាំឱ្យខ្ញុំមិនសិកក្នុងវស្សាទី ១ នោះទេ ខ្ញុំនៅមួយវស្សាទៀត ដោយតាំងចិត្តនឹងសិកនៅរដូវប្រាំ ព្រោះខ្ញុំមិនបានបួសដោយតាំងចិត្តដើម្បីរកមគ្គផលជាពិសេសនោះទេ បួសដើម្បីជាឧបនិស្ស័យ និងតាំងបំណងរបស់មាតាបិតា តែទោះយ៉ាងហ្នឹងក៏ដោយ ក្នុងរយៈពីរវស្សា ខ្ញុំខំសិក្សា-ប្រតិបត្តិយ៉ាងត្រឹមត្រូវ នឹងបានសេចក្ដីសុខស្ងប់យ៉ាងច្រើន តែចិត្តរបស់បុថុជ្ជន ក៏នៅតែងាករេ បែរទៅរកកាមារម្មណ៍ម្ដងៗ ។

ខ្ញុំប្រុងប្រៀបដោយកំណត់ថ្ងៃចាកសិក្ខាបទហើយ មុនកំណត់មួយថ្ងៃ លោកសេដ្ឋីបិតាខ្ញុំ នាំដំណឹងមកប្រាប់ថា **សុន្ទរី** បានទាក់ទងនឹងសេដ្ឋីបុត្តម្នាក់ ហើយបានលួចលាក់រួមរ័ក្សរហូតមានគភ៌ទៅហើយ ។ ដំណឹងនេះ នាំឱ្យចិត្តខ្ញុំក្ដួលក្ដុកសៀតក្ដៅក្រហាយយ៉ាងខ្លាំងមកពីខ្ញុំសង្ឃឹម និងស្រឡាញ់នាងខ្លាំងនោះឯង ។

សេចក្ដីទុក្ខក្រៀមក្រំនេះ បានញាំញីចិត្តខ្ញុំជាច្រើនថ្ងៃ ខំយកពុទ្ធឱវាទមករំលត់រំលាយក៏បានរសាយខ្លះ ខ្ញុំសម្រេចចិត្តថា ខ្ញុំនឹងកាន់យក

បព្វជិតរហូតមួយជីវិត ហើយនឹងចេញពីក្រុងសាវត្ថី ធ្វើពនេចរបន្លប់ទុក្ខនេះ ទាល់តែអស់ទុក្ខព្រួយសឹមត្រឡប់មកវិញ ។ ដូច្នេះខ្ញុំក៏ផ្ដើមធ្វើដំណើរចេញពីក្រុងសាវត្ថីក្នុងថ្ងៃព្រឹកឡើង ដែលខ្ញុំរៀបរាប់ឱ្យស្ដាប់ដូចតទៅ :

# ខ្លួនពឹងខ្លួន

អ្នកអានទាំងឡាយ! ការទុរយសរបស់សុន្ទរី ធ្វើឱ្យខ្ញុំអស់សេចក្ដីអាល័យក្នុងអ្វីៗទាំងអស់ រួមទាំងជីវិតរបស់ខ្លួនផង ខ្ញុំស្ពាយបាត្រធ្វើពនេចរឆ្ពោះទៅជួបមនុស្សដែលខ្វះវិញ្ញាណ វេលាឆ្លងផុតទៅប៉ុន្មានថ្ងៃ ប៉ុន្មានខែខ្ញុំមិនបាននឹងដល់ រយផ្លូវដែលត្រេចចរមកហើយប៉ុន្មានយោជន៍ ខ្ញុំក៏មិនយកចិត្តទុកដាក់ នាទីរបស់ខ្ញុំគឺការធ្វើដំណើរដើតទៅមុខទៀតរហូតអស់កម្លាំងស្ទង ត្រេចចរទៅយ៉ាងមានសេរីភាព ដូចត្រីហិចហែលតាមចិត្តក្នុងមហាសុទ្រដ៏ធំទូលាយ ដូចបក្សីដែលហិចហើរនានភាកាសដ៏ពិសាល រហូតរយៈផ្លូវដ៏វែងឆ្ងាយដែលកន្លងមក ខ្ញុំបានជួបនិងភូមិប្រទេសប្លែកៗ បានពើបពះប្រទះនឹងសេចក្ដីលំបាកយ៉ាកយ៉ាប់ជាអនេកប្បការ បានជួបនឹងមនុស្សច្រើនជាន់ច្រើនវណ្ណៈ ច្រើនទំនៀមទម្លាប់, ព្រឹត្តិការណ៍ទាំងនេះ ដូចជាឱសថជួយផ្សះរបួសក្នុងបេះដូបរបស់ខ្ញុំឱ្យសន្សឹមៗស្រួលឡើង របស់ដែលចូលមកជំនួសគឺសេចក្ដីស្រឡាញ់ពេញចិត្តក្នុងកាធ្វើដំណើរទស្សនាធម្មជាតិប្លែកៗ ក្នុងលោកដ៏ធំទូលាយ

សេចក្ដីស្រឡាញ់ពេញចិត្តដ៏ត្រជាក់ត្រជំក្នុងធម្មជាតិរបស់ព្រៃភ្នំលំនៅព្រៃដែលប្រាសចាកស្មៀតបោកប្រាស់ផ្សេងៗ ។

ភូមិ ឃុំ ស្រុក ក្រុង តូច ធំរាប់ចំនួនមិនបានដែលខ្ញុំឆ្លងកាត់មកហើយ គ្មានកន្លែងណារីករាយមនោរមស្មើនិងល្អាង, ភ្នំនិងដងព្រៃដ៏ស្ងប់ស្ងៀមនៃជនបទដែលឆ្ងាយ សម្រាប់ខ្ញុំក្នុងវេលានោះផែនថ្មដ៏រាបស្មើនិងព្រក្សជាតិម្លប់ត្រជាក់ មានសេចក្ដីសំដៅត្រូវចិត្តខ្ញុំក្រលែងជាងគ្រឹះស្ថានវិមានប្រាសាទក្នុងទីក្រុង សូរស័ព្ទសំឡេងទឹកហូរច្រោះតាមច្រកក្រហែងថ្ម និងសូរស័ព្ទចង្រិត, ខ្យងហៀន, រៃក្នុងព្រៃស្ដាប់ពិរោះជាងសំឡេងតូរ្យតន្ត្រី ចម្រៀងដែលគេចេញជំប្រគំក្នុងរង្គសាល និង កន្លែងមហោស្រពនានា ពន្លឺព្រះចន្ទនិងតារាករក្នុងរាត្រីកាល ហាក់ដូចជាត្រជាក់ភ្នែកគួរទស្សនាជាងពន្លឺប្រទីបថ្វាលក្នុងព្រះរាជធានី ម្រឹគាម្រឹគីក្នុងព្រៃ បើយើងសេពគប់និងវាដោយចិត្តពេញដោយមេត្តា មើលដូចជាគួរសេពគប់រាប់រកមិនអន់ជាងមនុស្សអ្នកចំរើនដោយវឌ្ឍនធម៌ឡើយ ។

ខណៈដែលត្រេចរង្គាត់ទៅនោះ ខ្ញុំក៏ឆ្លៀតប្រៀនប្រដៅប្រជាជនផង ការប្រៀនប្រដៅអ្នកដទៃ ក៏គឺការប្រៀនប្រដៅខ្លួនឯង ចិត្តរបស់ខ្ញុំល្អឡើងរាល់ៗថ្ងៃដែលកន្លងផុតទៅ កាលដល់លំនៅភូមិស្រុកខ្ញុំក៏ឈប់សម្រាកក្នុងព្រៃជិតៗភូមិស្រុកនោះ ព្រឹកឡើងចូលទៅបិណ្ឌបាតក្នុងភូមិស្រុក បានអាហារល្មមចិញ្ចឹមជីវិតឱ្យប្រព្រឹត្តទៅក្នុងមួយថ្ងៃៗហើយ ក៏

ត្រឡប់មកឆាន់នៅទីសំណាក់វិញ បើមានអ្នកស្រុកតាមកសន្ទនាផង ខ្ញុំក៏សន្ទនានឹងគេ ប្រៀនប្រដៅឱ្យគេយល់ក្នុងគោលធម៌របស់ព្រះបរម-សាស្ដា បើអ្នកស្រុកនិមន្តឱ្យស្នាក់នៅច្រើនថ្ងៃ និងបើបានទទួលសេចក្ដីស្រួលសប្បាយខ្ញុំក៏ស្នាក់នៅយូរ តែមិនដែលនៅទីណាច្រើនជាង ៥ ថ្ងៃ រឿងរបស់អ្នកស្រុកជារឿងរវល់ខ្វល់ខ្វាយគ្មានទីបំផុត បើខ្ញុំនៅយូរជាងនោះ ខ្ញុំក៏នឹងរវល់ខ្វល់ខ្វាយជាមួយនឹងគេផង ដើម្បីរត់ឱ្យផុតពីកង្វល់ខ្វល់ខ្វាយ ខ្ញុំក៏ធ្វើដំណើរតទៅ ។

របស់មួយ ដែលខ្ញុំត្រូវតស៊ូរហូតក្នុងរយៈពេលធ្វើដំណើរ ក៏គឺលទ្ធិជំនឿជឿកាន់របស់ប្រជាជនក្នុងកន្លែងផ្សេងៗ ប្រការខ្លះក៏ជាជំនឿសចាស់ៗ ដែលខ្វះហេតុផល និងងប់ជ្រៅទៅក្នុងខួរក្បាលរបស់អ្នកស្រុកមកជាវេលាច្រើនសតវត្សរ៍ ទម្រាំខ្ញុំពន្យល់បញ្ជាក់ហេតុផលឱ្យគេយល់ចូលចិត្តគោលធម៌ក្នុងព្រះពុទ្ធសាសនាបាន ក៏ត្រូវប្រើពេលវេលា និងសេចក្ដីនឿយហត់មិនតិចទេ ។

មានភូមិស្រុកមួយ តាំងនៅលើឆ្នេរទន្លេគង្គាក្នុងខេត្តមួយនៃ **មគធរដ្ឋ** ខ្ញុំទៅដល់ភូមិស្រុកនេះនាថ្ងៃរសៀលក្នុងថ្ងៃមួយ លុះបានដឹងថាសមណៈប្លែកមុខមកស្នាក់ជិតភូមិស្រុក អ្នកភូមិស្រុកព្រមដោយប្រធានភូមិស្រុកក៏ចេញទៅសន្ទនានឹងខ្ញុំភ្លាម កាលសាកសួរសុខទុក្ខគ្នាតាមសុជីវធម៌ហើយ ការសន្ទនាលទ្ធិ ជំនឿក៏ចាប់ផ្ដើមឡើង :

" ម្នាលឧបាសក លោកអ្នកទាំងឡាយរាប់អានអ្វីជាទីពឹង ?" ខ្ញុំផ្ដើមសួរ នាយស្រុកដែលធ្វើនាទីជាដំណាងអ្នកស្រុកបានឆ្លើយថា

" ពួកយើងខ្ញុំ រាប់អានមុនីទាំង ៧ ជាទីពឹង "

" មុនីទាំង៧ដែលលោកថានោះគឺនរណា? នៅទីណា?" ខ្ញុំសួរ

" មុនីទាំង៧ គឺ **កស្សបៈ, អតរី, ភារទ្វាជៈ, គោតមៈ, វិស្វាមិត្រៈ? ជមទគ្និ, វាសិដ្ឋ** មុនីទាំង ៧ នេះ កើតមុនព្រះវេទទៅទៀត វេលានេះនៅលើស្ថានសួគ៌ ក្នុងយប់ខែងងឹតដែលផ្ទៃមេឃស្រឡះ បើលោកសំលឹងមើលទៅលើមេឃនឹងឃើញផ្កាយ ៧ ដួងនោះរៀងរាយគ្នាជារូបរាងដូចសត្វខ្លាឃ្មុំ នុ៎ះឯងគឺមុនីទាំង ៧ របស់ពួកខ្ញុំ "

" មុនីទាំង ៧ ជាទីពឹងចំពោះពួកលោកបានយ៉ាងណា ? "

"មុនីទាំង៧ចុះមកពិនិត្យមនុស្សលោកម្តង១ បើនរណាមានភក្តីភាពចំពោះលោកយ៉ាងមាំមួន តាំងចិត្តក្រាបសំពះបូជាលោកដោយគោរពលោកក៏បណ្តោយឱ្យអ្នកនោះមានសេចក្តីសុខជួបជោគលាភ កាលស្លាប់ហើយក៏នឹងបានឡើងឋានសួគ៌, ថាហើយនាយក្រុកក៏លើកដៃសំពះព្រះ-អាទិទេពរបស់គេ និងពោលនាមមុនីទាំង ៧ យ៉ាងចាំស្ទាត់ សំដែងឱ្យឃើញគារវភក្តីភាពមាំមួនស្ថិតស្ថាញរបស់គេ បើខ្ញុំបញ្ឆោក់ហេតុផលកាច់បំបាក់ជំនឿជឿកាន់របស់ពួកគេក្នុងខណៈនោះភ្លាមទៅ ពួកគេមុខនាងខឹងនឹងខ្ញុំ ខ្ញុំទើបអង្គុយនៅស្ងៀម ។

" បពិត្រលោកសមណៈ លោករាប់អានអ្វីជាទីពឹង" មេស្រុកសួរខ្ញុំខ្លះ ។

" អាត្មាមិនរាប់អានអ្វីជាទីពឹង មិនរាប់អាននរណាជាទីពឹង អាត្មាទីពឹងខ្លួនឯង ព្រះបរមគ្រូរបស់អាត្មាប្រដៅទុកថា " **អត្តាហិ អត្តនោ នាថោ** " " ខ្លួននោះឯងជាទីពឹងរបស់ខ្លួន " **កោ ហិ នាថោ បរោ សិយា** " អ្នកដទៃណានឹងមកជាទីពឹងបាន " អាត្មាជឿពាក្យប្រៀនប្រដៅព្រះបរមគ្រូទើបកាន់ខ្លួនជាទីពឹងរបស់ខ្លួន " ។

នាយស្រុកធ្វើមុខឆ្ងល់ចំពោះសំដីរបស់ខ្ញុំ ហើយនិយាយឡើង "ក៏លោកជាមនុស្សមិនមានអំណាចបាដិហារ្យអ្វី មិនមានឫទ្ធិតេជៈអ្វី នឹងពឹងខ្លួនឯងបានយ៉ាងណា ? " ។

" ក៏ព្រោះអាត្មាគ្មានឫទ្ធិតេជៈអ្វីនេះឯង ទើបត្រូវគិតពឹងខ្លួន បើអាត្មាមានឫទ្ធិដូចមុនីទាំង ៧ អាត្មាក៏មិនបាច់ពឹងខ្លួនឯង វេលានេះអាត្មាប្រៀបដូចបុរសដែលហែលនៅក្នុងផ្ទៃទន្លេ ព្រោះលិចទូក អាត្មាត្រូវអាស្រ័យដៃជើងនិងកំឡាំងកាយរបស់ខ្លួនឯង ហែលទឹកទៅឱ្យទាល់តែដល់ច្រាំង អាត្មាត្រូវតស៊ូនឹងរលកនឹងក្រពើឆ្លាមមករដោយខ្លួនឯង មិនមាននរណាមកហាមឃាត់រលកទុកបាន មិនមាននរណាមកចាប់ចងឆ្លាមមករក្រពើទុក មិនមាននរណាមកចាប់ដៃចាប់ជើងរបស់អាត្មាឱ្យហែល

ទឹក អាត្មាត្រូវធ្វើខ្លួនឯងគ្រប់យ៉ាង លោកដ៏ធំទូលាយនេះឯង គឺផ្ទៃមហាសាគរ យើងកើតមកក្នុងលោក ក៏ដូចជាធ្លាក់ចុះទៅនៅក្នុងមហា-សាគរ យើងត្រូវតស៊ូដើម្បីជីវិតយើងរស់នៅ យើងត្រូវរកអាហារមកបរិភោគដើម្បីចិញ្ចឹមរាងកាយ យើងត្រូវរកលំនៅមកការពារកំដៅ, ខ្យល់, ភ្លៀង យើងត្រូវរកសំពត់អាវមកស្លៀកពាក់ យើងត្រូវរកថ្នាំការពាររោគកាលមានជម្ងឺ របស់ទាំងនេះ មិនមានព្រះអាទិទេពអង្គណា នាំមកប្រគល់ឱ្យយើងទទេៗ សូម្បីបួងសួងបន់ស្រន់បូជាយ៉ាងណាក៏ដោយ ក៏មិនដែលឃើញថាបានសម្រេចដូចប្រាថ្នាឡើយ ឆ្លាមមករក្រពើ និងរលកក្នុងទន្លេ ក៏គឺសេចក្ដីលំបាកយ៉ាកយ៉ាប់ទាំងឡាយដែលឆ្លងចូលមកក្នុងជីវិតរបស់យើងមួយគ្រាៗដូចជម្ងឺជម្កាត់ផ្សេងៗ ទឹកលិចស្រូវក្នុងស្រែ ឬស្រែគ្មានទឹកកើតរោគអាសន្ន ចោលលួចប្លន់ភ្លើងឆេះផ្ទះ ឧបសគ្គទាំងនេះត្រូវគេស៊ូជួយខ្លួនឯងមុនដទៃ នឹងបួងសួងបន់ស្រន់ឱ្យទេពតាណាមកជួយមិនបាន ” ។

“ សម្រាប់វត្ថុខាងក្រៅ យើងរកខ្លួនឯង ខនេះជាសេចក្ដីពិត”អ្នកស្រុកម្នាក់ពោលឡើង “ តែសម្រាប់សេចក្ដីសុខខាងក្នុងចិត្តនោះ យើងមិនអាចរក្សាខ្លួនឯង សេចក្ដីសុខជាពរពិសេសដែលមុនីទាំង ៧ ប្រទានឱ្យចំពោះអ្នកមានគារវភក្ដិភាពក្នុងលោក ” ។

" **ម្នាលឧបាសក !** សេចក្តីសុខមានពីរយ៉ាង គឺសុខទាក់ទងដោយវត្ថុ បានដល់សុខដែលកើតពីការមានអាហារបរិភោគគ្រប់គ្រាន់ មានគេហដ្ឋាននៅយ៉ាងសប្បាយ មានសំលៀកបំពាក់និងប្រដាប់តាក់-តែងកាយយ៉ាងគ្រប់គ្រាន់ មានថ្នាំសម្រាប់បំបាត់រោគភ័យ ឈឺចាប់, មានបុត្រភរិយាញាតិមិត្ត សម្រាប់ជាទីកក់ក្តៅចិត្តនេះ ១ សេចក្តីសុខមិនអា-ស្រ័យវត្ថុ បានដល់សេចក្តីសុខដែលកើតពីការលះបង់វត្ថុទាំងពួង ចេញទៅបួសជាបព្វជិតនិត្យនៅក្នុងព្រៃដ៏ស្ងាត់ ធ្វើសេចក្តីព្យាយាមកំចាត់កិ-លេសផ្សេងៗ ចេញចាកចិត្តនេះ ១ ដែលលោកថា មុនីទាំង ៧ ឱ្យសេចក្តីសុខដល់លោកនោះ ឱ្យសេចក្តីសុខប្រភេទណា ? " ។

អ្នកស្រុកម្នាក់នោះ ធ្វើអាកប្បកិរិយាស្ទាក់ស្ទើរបន្តិចហើយឆ្លើយ " ខ្ញុំសំដៅដល់សេចក្តីសុខទាំងពីរយ៉ាង " ។

" សំដៅសេចក្តីថា សេចក្តីសុខទាំងពីរយ៉ាង មុនីទាំង៧ជាអ្នកប្រគល់ឱ្យលោកយ៉ាងហ្នឹងឬ ? " ខ្ញុំសួរផ្ទួនទៀត កាលគេឆ្លើយទទួល ខ្ញុំទើបនិយាយតទៅ :

"លោកជ្រាបហើយថា សេចក្តីសុខប្រភេទទី១កើតពីទ្រព្យ កាលមានទ្រព្យគ្រប់គ្រាន់ សុខប្រភេទនេះក៏កើតឡើង លោកព្រមទទួលហើយថា ទ្រព្យទាំងឡាយដែលមាននេះ ព្រោះលោករកខ្លួនឯង ទើបបានមក មិនមែនទេពអង្គណាហុចឱ្យ កាលលោករកទ្រព្យខ្លួនឯង

បានសេចក្ដីសុខដូច្នេះ នឹងថាមុនីទាំង ៧ ជាអ្នកប្រគល់ឱ្យ តើសមហេតុផលឬ ? ” ។

សំនួររបស់ខ្ញុំ ធ្វើឱ្យអ្នកស្រុកភូមិគ្រប់គ្នានៅស្ងៀមស្ងាត់ កាលឃើញបានការ ខ្ញុំទើបបញ្ជាក់ទៅ “ ម្នាលឧបាសក សេចក្ដីសុខប្រភេទទី ២ មិនទាក់ទងនិងវត្ថុជាសុខកើតពីសេចក្ដីបរិសុទ្ធនៃចិត្ត កាលលោកធ្វើចិត្តលោកឱ្យបរិសុទ្ធស្អាត ប្រាសចាកសេចក្ដីហួងហែង សេចក្ដីកង្វល់ សេចក្ដីលោភ សេចក្ដីក្រោធ សេចក្ដីវង្វេងបានយ៉ាងដាច់ខាតហើយ សេចក្ដីស្ងប់-សុខត្រជាក់ត្រជំក៏កើតឡើង ចិត្តរបស់លោកនឹងបរិសុទ្ធបាន ក៏ព្រោះការជំរះសំអាតរបស់លោកខ្លួនឯង លោកត្រូវជំរះដុះខាត់សំអាតចិត្តរបស់លោកខ្លួនឯង កាលដៃរបស់លោកប្រឡាក់របស់ស្មោកគ្រោក លោកត្រូវប្រើទឹកជំរះលាក់ដៃទើបបានស្អាត ទោះលោកធ្វើការបូជាចំពោះព្រះអាទិទេព បន់ស្រន់ឱ្យដៃរបស់លោកស្អាតយ៉ាងណាខន្តីដៃរបស់លោកក៏មិនអាចស្អាតបានឡើយ របស់ស្មោកគ្រោកនោះនឹងមិនប៉ើងហើយចេញទៅពីដៃរបស់លោកជាដាច់ខាត ” ។

**កាលខ្ញុំបញ្ជាក់ហេតុផលតទៅទៀត** អ្នកស្រុកក៏កើតសេចក្ដីជ្រះថ្លា គ្រប់គ្នាប្រគល់កាយថ្វាយខ្លួនជាសិស្សរបស់ខ្ញុំៗ ពន្យល់ថា“ ម្នាលឧបាសកទាំងឡាយ! ឆ្ងាយពីទីនេះទៅផ្លូវបច្ចិមទិស មានក្រុងមួយឈ្មោះសាវត្ថីជារាជធានីរបស់កោសលរដ្ឋ រាជធានីនោះសម្ដេចព្រះបរមសាស្ដា

សម្មាសម្ពុទ្ធជាម្ចាស់គង់នៅ ព្រះអង្គជាព្រះបរមគ្រូរបស់ទេវតានិងមនុស្ស ទាំងឡាយ អាត្មាគ្រាន់តែជាសិស្សរបស់ព្រះអង្គ លោកអ្នកទាំងឡាយ ចូរតាំងចិត្តរលឹកដល់ព្រះអង្គ កាន់យកព្រះអង្គជាគោលប្រចាំចិត្ត និងប្រ-តិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គចុះ លោកអ្នកទាំងឡាយនឹង ជួបប្រទះសេចក្តីសុខតាមសមគួរដល់ការប្រតិបត្តិរបស់ខ្លួន ” ។

**តអំពីនោះ** ខ្ញុំបានបញ្ជាក់ផ្លូវដំណើរជីវិតតាមបែបព្រះពុទ្ធសាសនា ឱ្យជាទីយល់ច្បាស់ដល់ពួកគេ ហើយរំលឹកថា “ កុំភ្លេចថា អ្វីគ្រប់យ៉ាង គ្រប់ប្រការត្រូវធ្វើខ្លួនឯង លោកអ្នកត្រូវធ្វើដំណើរខ្លួនឯង ទើបនឹងបាន ដល់ទិសដៅជាគោលបំណង ។ ព្រះសម្មសម្ពុទ្ធក្តី អាត្មាក្តី អ្នកឯទៀតៗ ក្តី គ្រាន់តែជាអ្នកបញ្ជាក់ចង្អុលប្រាប់ផ្លូវប៉ុណ្ណោះ ” ។ ខ្ញុំស្នាក់នៅទីនោះ ៣ ថ្ងៃ តាមពាក្យនិមន្តរបស់អ្នកស្រុក ហើយក៏ចេញដំណើរធ្វើពនេចរ តទៅ ។

**គ្រាមួយ** ខ្ញុំបានទៅដល់ដំបន់ឈ្មោះកណ្ឌិកគ្រាម ក្នុងដែនមគធៈ ប្រជាជនក្នុងភូមិស្រុកនេះ គោរពរាប់អានព្រះអាទិត្យជាសរណៈនិងជឿមាំ ក្នុងសេចក្តីសក្តិសិទ្ធិ របស់មន្តមួយបទ ដែលហៅឈ្មោះថា **គយាត្រី** គេជឿថា មន្តគយាត្រីនេះសក្តិសិទ្ធិណាស់ សូម្បីទេពតាកាលបានឮមន្ត នេះ ក៏ត្រូវញ័រខ្លួន មនុស្សវណ្ណៈព្រាហ្មណ៍ប៉ុណ្ណោះ ទើបមានសិទ្ធិស្វា-ធ្យាយមន្តបទនេះបាន និងត្រូវស្វាធ្យាយដោយសំឡេងតិចៗ មិនឱ្យមនុស្ស

វណ្ណៈសូទ្រៈបានឮជាដាច់ខាត សូម្បីតែភរិយាក្នុងរោងមានរដូវ ក៏មិនឱ្យបានឮ លុះខ្ញុំទៅដល់គេមកនិយាយប្រាប់សេចក្តីសក្តិសិទ្ធិរបស់គយាត្រីឱ្យខ្ញុំស្តាប់ កាលខ្ញុំសូមឱ្យគេស្វាធ្យាយឱ្យស្តាប់ គេក៏សាកសួរដល់វណ្ណរបស់ខ្ញុំជាការធំ ខ្ញុំប្រាប់គេថាជាបព្វជិត គេយល់សំគាល់ថាខ្ញុំជាព្រាហ្មណ៍ ទើបស្វាធ្យាយមន្តគយាត្រីឱ្យស្តាប់ដូចតទៅនេះ :

**ត័ត សាវិត្រៈ វារេនយ័ម ភារគោ ទេវាសយៈ ធិមហិ ធិយោ យោ នា បរធោ ទយ័ត ។**

" **ពួកយើង** សូមបង្អោននមស្ការនូវស្មើដ៏ខ្ពង់របស់ព្រះសុរិយទេព អ្នកជាធំលើវត្ថុទាំងអស់ អ្នកអាចនាំយើងឱ្យកើតសេចក្តីដឹង សេចក្តីយល់ជាអ្នកដូចដួងនេត្រានាពិតាននៃសួគ៌ " ដូច្នេះ ។

កាលបានស្តាប់មន្តដ៏សក្តិសិទ្ធិរបស់អ្នកស្រុកហើយ ខ្ញុំក៏មើលមិនឃើញថា ពាក្យត្រឹមប៉ុណ្ណោះនឹងធ្វើឱ្យទេពតាខ្លាចបានយ៉ាងណា តែខ្ញុំក៏នៅអង្គុយស្ងៀមសិន មិនបាននិយាយជំទាស់គេឡើយ ។

" លោកមានមន្តសម្រាប់ការពារខ្លួនខ្លះទេ?" អ្នកស្រុកម្នាក់សួរឡើង " បើគ្មានខ្ញុំនឹងបង្រៀនឱ្យ លោកធ្វើដំណើរដើរទៅតែម្នាក់ឯងមានភយន្តរាយនៅជុំវិញ បើគ្មានមន្តការពារខ្លួន ក៏គួរខ្លាចថានឹងមិនរួចពីភយន្តរាយ " ។

" មាន " ខ្ញុំឆ្លើយភ្លាម នឹកសរសើរក្នុងគោលបំណងល្អរបស់គេ " បើលោកចង់ស្គាល់ អាត្មានឹងស្វាធ្យាយឱ្យស្តាប់ " កាលឃើញពួកអ្នកស្រុកសំដែងបំណង់ចង់ស្តាប់ ទើបខ្ញុំលើកយកឱវាទបាដិមោក្ខ ដែលជាភាសិតប្រមូលពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ឬ ពាក្យប្រៀនប្រដៅព្រះ-ពុទ្ធចុះក្នុងឱវាទនេះ មកស្វាធ្យាយ" ។

" **សព្វបាបស្ស អករណំ** ការមិនធ្វើសេចក្តីអាក្រក់គ្រប់យ៉ាង

**កុសលស្សូបសម្បទា** ការធ្វើអំពើល្អគ្រប់យ៉ាង

**សចិត្តបរិយោទបនំ** ការជំរះចិត្តរបស់ខ្លួនឱ្យស្អាត់ផូរផង់ ។

នេះជាមន្តរបស់អាត្មា អ្នកណាប្រតិបត្តិបានតាមនេះ អ្នកនោះនឹងមានសេចក្តីសុខក្សេមគ្រប់កាល " ។

ខ្ញុំបានខំប្រឹងប្រែងសំដែងពន្យល់សេចក្តីសក្តិសិទ្ធិរបស់មន្តខ្ញុំ ឱ្យពួកអ្នកស្រុកស្តាប់ រហូតគ្រប់គ្នាកើតជ្រះថ្លា ជឿនឹងចង់រៀនយកទុកការពារខ្លួន មនុស្សម្នាក់សួរឡើងថា " មន្តនេះ មានវិធីរក្សាយ៉ាងណាខ្លះ ? " ។

" មានវិធីរក្សាដូច្នេះគឺ មុនដែលលោកនឹងគិតអ្វី នឹងនិយាយអ្វី នឹងធ្វើអ្វី សូមឱ្យគិតមើលឱ្យជុំវិញស្រួលបួលជាមុនសិនថា ការធ្វើ ការនិយាយរបស់ខ្លួន ជាការបង្ករបង្កើតសេចក្តីទុក្ខឱ្យដល់ខ្លួននិងអ្នកដទៃឬទេ

បើឃើញថាជាការបង្កទុក្ខបង្កើតទោស ក៏កុំនិយាយ កុំគិត កុំធ្វើអំពើនោះជាដាច់ខាតបើឃើញថាការធ្វើ និយាយ គិត នោះអាចបង្កបង្កើតសេចក្តីស្ងប់-សុខ ចំរើនឱ្យដល់ខ្លួន និងអ្នកដទៃ មិនខុសសីលធម៌និងច្បាប់របស់រដ្ឋក៏ចូរធ្វើចុះ បើរក្សាបានដូច្នេះ មន្តរបស់លោកនឹងខ្លាំងពូកែ តែបើរក្សាមិនបាន មន្តរបស់លោកនឹងសាបរលាប អាត្មាធ្វើដំណើរមកតែម្នាក់ឯងដោយមិនមានអាវុធអ្វីជាប់មកនឹងខ្លួនឡើយ បានពើបពះនឹងសត្វសាហាវខ្មោចបិសាច និងចោរចិត្តឃោរឃៅ តែមន្តនេះជួយឃុំគ្រង ឱ្យអាត្មារួចចាកភ័យជានិច្ចមក ត្រណមដទៃក្រៅពីនេះគ្មានទេ ពួកលោកអាចស្វាធ្យាយដោយសំឡេងខ្លាំងប៉ុន្មានក៏បាន នឹងអាចប្រាប់នរណា ។ តទៅទៀតក៏បាន បើប្រាប់ព្រមទាំងពន្យល់អ្នកដទៃឱ្យយល់ន័យបានច្រើនត្រឹមណា មន្តរបស់លោកក៏ពូកែសក្តិសិទ្ធិច្រើនឡើងត្រឹមនោះ ” កាលខ្ញុំបានបង្រៀនពុទ្ធមន្ត ដល់អ្នកស្រុកកណ្ឌិកគ្រាមហើយ ខ្ញុំក៏ធ្វើដំណើរតទៅ ។

# ស្ត្រីជរា

**លោក-អ្នកអានទាំងឡាយ !** ល្ងាចថ្ងៃមួយ ខណៈកំពុងដើរនៅកណ្តាលព្រៃ ខ្ញុំបានឮសំឡេងទ្រហោយំទួញរៀបរាប់ចេញមកពីក្នុងព្រៃ ទើបឈប់ឈរស្តាប់ដោយយកចិត្តទុកដាក់ សំឡេងនោះ ជាសំឡេងរបស់ស្ត្រី ឮមកយ៉ាងគួរខ្លោចផ្សាពីព្រៃខាង១ផ្លូវ ធ្វើឱ្យសេចក្តីមេត្តាករុណា កើតឡើងក្នុងចិត្តរបស់ខ្ញុំភ្លាម ព្រះពុទ្ធជាម្ចាស់ប្រៀនប្រដៅឱ្យមានសេចក្តីមេត្តាករុណា អាណិតអ្នកដទៃ និងរកផ្លូវជួយអ្នកដទៃ បើល្មមនិងជួយបាន គិតដល់ព្រះពុទ្ធវចនៈ ត្រង់នេះហើយ ទើបកាត់ចិត្តដើររុកព្រៃតម្រង់ទៅត្រង់សំឡេងនោះ ។

ភាពដែលនៅខាងមុខខ្ញុំ គឺស្ត្រីជរាម្នាក់កំពុងអង្គុយយំទួញ នៅជិតគំនរភ្លើងធំ ខ្ញុំអាចកាត់ស្មានបានភ្លាមថា គាត់កំពុងយំរលឹកនឹងដល់បុគ្គលជាទីស្រឡាញ់ណាម្នាក់ដែលស្លាប់ទៅ និងពេលនេះកំពុងត្រូវភ្លើងឆេះនៅលើជើងថ្ករ " អ្នកមីង ! អ្នកមីងកំពុងយំរលឹកដល់នរណា ? "

គាត់ងើបមុខដ៏ទទឹកជោគដោយទឹកភ្នែក សំឡឹងមើលខ្ញុំ ហើយឆ្លើយទាំងខ្សឹបខ្សួល " ខ្ញុំកំពុងយំរលឹកដល់កូន ខ្ញុំមានកូនប្រុសតែម្នាក់ គេក៏ស្លាប់ចោលខ្ញុំទៅ កូនអើយ ! កូនមិនអាណិតម៉ែខ្លះឡើយ " ឆ្លើយប្រាប់ខ្ញុំបានប៉ុណ្ណោះ ស្ត្រីជរាក៏យំរៀបរាប់តទៅដោយសំឡេងខ្លាំងជាងមុន ខ្ញុំបណ្តោយឱ្យគាត់យំទាល់តែឃើញថាគាត់នឿយ ល្វើយ សំឡេងខ្សោះ

ស្អកហើយ ទើបខ្ញុំផ្ដើមសំដែងធម៌លួងលោមគាត់ដោយឧបាយ ។

" អ្នកមីង! អាត្មានឹងនិយាយរឿងចម្លែកឱ្យស្ដាប់ធម៌មួយរឿង បើអ្នកមីងចង់ស្ដាប់ អាត្មាជឿថា កាលបានស្ដាប់រឿងនេះហើយ ជួនកាលអ្នកមីងមាននឹងសប្បាយចិត្តឡើងខ្លះ "

" ព្រះគុណជាម្ចាស់ និយាយអ្វីក៏និយាយមកចុះ " ស្រីជរាឆ្លើយដោយមិនសូវជាយកចិត្តទុកដាក់ នៅតែខ្សឹងខ្សួលអង្គុយមើលកងភ្លើងដោយដួងភ្នែកទទឹកជោគដោយទឹកភ្នែក ខ្ញុំទើបនិយាយរឿងដែលខ្ញុំគិតឃើញឡើងបានក្នុងខណៈនោះថា " ពីម្សិលមិញ ពេលដែលធ្វើដំណើរមកដល់ឆ្នេរទន្លេគង្គា អាត្មាបានជួបស្ត្រីម្នាក់កំពុងឈរយំ ខ្សឹកខ្សួលនៅលើឆ្នេរទន្លេគង្គា ដូចជាអ្នកមីងកំពុងយំក្នុងឥឡូវនេះដែរ អាត្មាបានចូលទៅសួរនាងថា យំធ្វើអ្វី? នាងឆ្លើយថា នាងបានមកឈរនៅច្រាំងទន្លេនេះតាំងតែពីព្រឹក ខំហាមប្រាមទឹកក្នុងទន្លេងមិនឱ្យហូរទៅក្រោម នាងបានលួងលោមអង្វរដោយពាក្យផ្អែមល្ហែមខ្លះ ក៏ហែងគំរាមខ្លះ ជេរប្រទេចខ្លះ តែទឹកក៏មិនស្ដាប់សំឡេងរបស់នាង ចេះតែហូរទៅមិនឈប់ឈរតាមនាទីរបស់ខ្លួន នាងខូចចិត្តដ្បិតហាមទឹកមិនស្ដាប់ ទើបឈរយំកន្ទក់កន្ទេញ អ្នកមីង! បើអ្នកមីងបានជួបស្ត្រីនោះដូចអាត្មា តើអ្នកមីងគិតថា ស្ត្រីនោះជាមនុស្សឆ្កួត ឬមនុស្សមានស្មារតីល្អ? "

" ក៏ឆ្កួតនោះឯង ព្រះគុណម្ចាស់" ស្ត្រីចាស់ឆ្លើយ "វាដែលមានពីណា ទឹកហូរតាមធម្មតាប្រក្រតីរបស់វា នឹងទៅហាមឱ្យវាឈប់ហូរបានដូចម្ដេចកើត បើហាមវាមិនស្ដាប់ ហើយយំខូចចិត្ត ក៏ជាមនុស្សឆ្កួតពិតៗនោះឯង " ។

កាលយាយគាត់បង្ហើបផ្លូវដូច្នេះ ខ្ញុំក៏ផ្ដើមលុកចូលភ្លាម " បើស្ត្រីនោះឆ្កួតអ្នកមីងក៏ឆ្កួតដូចគ្នាដែរ "

" ខ្ញុំឆ្កួតយ៉ាងម៉េច " ស្ត្រីចាស់បែរមកសួរខ្ញុំដោយសេចក្ដីមិនពេញចិត្តភ្លាម ។

ឈប់សិន កុំទាន់ខឹង ស្ដាប់ហេតុផលរបស់អាត្មាសិន មនុស្សយើងគ្រប់គ្នា កើតមកហើយត្រូវស្លាប់មិនមាននរណាហាមសេចក្ដីស្លាប់បាន ព្រោះជាធម្មតារបស់សត្វ, ពូជ និងរបស់ទាំងពួង កាលកើតឡើងមកហើយ ត្រូវប្រែប្រួលសាបសូន្យទៅ មិនមានធម្មជាតិណានៅគង់វង្សរហូតទេ កើតមកហើយក៏ស្លាប់ទៅតាមធម្មតារបស់វា ដូចខ្សែទឹកក្នុងទន្លេងគង្គាដែលហូរទៅមិនឈប់ឈរ កូនប្រុសរបស់អ្នកមីងកើតមកហើយក៏ស្លាប់ទៅតាមធម្មតារបស់គេ អ្នកមីងមិនចង់គេស្លាប់ ព្រោះសេចក្ដីស្រឡាញ់គេ ចង់ឱ្យគេនៅនឹងអ្នកមីងរហូតទៅ តែកាលគេមិននៅនឹងអ្នកមីង គេស្លាប់ចោលទៅ អ្នកមីងក៏យំកន្ទក់កន្ទេញ កាលបើដូច្នេះ

អ្នកមីង ក៏មិនខុសប្លែកអ្វីពីស្ត្រីដែលហាមប្រាមទឹកក្នុងទន្លេគង្គាមិនឱ្យហូរ កាលមិនសម្រេចតាមបំណង ក៏ខូចចិត្តទួញយំ ដូច្នោះអាត្មាទើបពោលថា មីងក៏ឆ្កួតដូចស្ត្រីនោះដែរ ” ។

ហេតុផលរបស់ខ្ញុំ ធ្វើឱ្យស្ត្រីជរាឈប់យំ គាត់អង្គុយឈ្ងោកមុខនៅស្ងៀមដោយប្រើគំនិត តែក៏នៅសឹករល្មឹកខ្សឹកខ្សួលម្តងៗ “ ញោមស្រី ” ខ្ញុំពោលតទៅ “ មនុស្សយើងជាសត្វមានហេតុផល នឹងធ្វើអ្វីទៅគួរគិតឱ្យល្អជាមុនថា អំពើនោះអាចឱ្យប្រយោជន៍ ឬសេចក្តីសុខដល់ខ្លួននិងមនុស្សដទៃឬទេ បើឃើញថាធ្វើទៅហើយគ្មានប្រយោជន៍ក៏មិនគួរធ្វើ ការយំទួញកន្ទក់កន្ទេញដល់កូនដែលស្លាប់ទៅសិនហើយនេះ ញោមស្រីបានប្រ-យោជន៍សុខអ្វីខ្លះ? អាត្មាមិនឃើញញោមបានអ្វីមកឡើយ ទោះញោមស្រីយំឱ្យទាល់តែទឹកភ្នែកក្លាយជាឈាម កូនប្រុសរបស់ញោមក៏មិនត្រ-ឡប់រស់ឡើងវិញដែរ មិនមាននរណាយកមាសពេជ្រកែវកងមកឱ្យញោមព្រោះការយំទួញនេះ ញោមត្រូវខូចទឹកភ្នែក ខូចកម្លាំងចិត្ត ខូចសុខភាពអនាម័យ ការយំទួញមានតែផ្លូវខូចខាតតែម្យ៉ាង មិនមានផ្លូវបានឡើយជាអំពើដែលគ្មានបានអ្វីទាំងអស់ មនុស្សយើង បើធ្វើអ្វីៗ ប្រាសចាកប្រ-យោជនដូច្នេះ នឹងឈ្មោះថាជាសត្វមានហេតុផល មានវិចារណញ្ញាណយ៉ាងណាបាន ! ” ។

"មែនព្រះគុណម្ចាស់" ស្ត្រីជរានិយាយឡើងដោយសំឡេងដែលផ្អើមច្បាស់លាស់ជាប្រក្រតី "ពាក្យនិយាយរបស់ព្រះគុណម្ចាស់ ជួយបន្ធូរបន្ថយសេចក្តីទុក្ខសោកក្នុងចិត្តរបស់ខ្ញុំបានច្រើន ជាព្រះគុណូបការៈយ៉ាងក្រៃលែង ដែលព្រះគុណជួយឱ្យពន្លឺភ្លឺស្វាងដល់ខ្ញុំ តែសម្រាប់កូនប្រុសម្នាក់នេះ ខ្ញុំស្រឡាញ់វាណាស់ កាលវាស្លាប់ទៅ ទើបហួសវិស័យនឹងហាមប្រាមសេចក្តីសោកទុកបាន "

" ញោមស្រី ព្រះពុទ្ធជាម្ចាស់ត្រាស់ថា សេចក្តីសោករមែងកើតពីសេចក្តីស្រឡាញ់ ដែលមិនសមបំណង ស្រឡាញ់ច្រើនក៏សោកច្រើន ស្រឡាញ់តិចក៏សោកតិច បើមិនស្រឡាញ់សោះ ក៏មិនសោកសោះកូនអ្នកដទៃៗ ស្លាប់មួយថ្ងៃៗ ច្រើនៗ នាក់ ញោមស្រីក៏នៅព្រងើយៗព្រោះញោមស្រីគ្មានសេចក្តីស្រឡាញ់នោះឯង បើញាតិឆ្ងាយៗរបស់ញោមស្លាប់ ញោមក៏កើតទុក្ខសោកខ្លះ ព្រោះមានសេចក្តីស្រឡាញ់គេខ្លះ កាលកូនប្រុសរបស់ញោមស្លាប់ ញោមកើតទុក្ខសោកសៅយ៉ាងខ្លាំងបំផុត ព្រោះញោមស្រឡាញ់គេយ៉ាងច្រើនបំផុត ព្រោះដូច្នោះ ព្រះពុទ្ធអង្គទើបប្រៀនប្រដៅមិនឱ្យប្រកាន់មាំក្នុងរបស់អ្វីឱ្យច្រើនកើនពេក មិនឱ្យស្រឡាញ់រហូតវង្វេង មិនឱ្យតាំងសេចក្តីសង្ឃឹមពិតស្និតជាប់ក្នុងរបស់ណា ព្រោះកាលខុសបំណងក៏នាំឱ្យកើតទុក្ខ ញោមនឹងតាំងចិត្តគិតសង្ឃឹមទៅក៏បាន តែត្រូវត្រៀមខ្លួនឱ្យសព្វគ្រប់ទុកសម្រាប់តទល់នឹងផល

ទាំងពីរយ៉ាងរបស់វា គឺសេចក្ដីសមបំណងនិងសេចក្ដីខុសបំណង ការងារគ្រប់យ៉ាងមានគិតជាពីរ គឺបានសម្រេចនិងរលំរលាយ កីឡាគ្រប់យ៉ាងមានផលពីរ គឺចាញ់និងឈ្នះ បើស្រឡាញ់ការលេងកីឡា យើងត្រូវព្រមទទួលផលពីរយ៉ាង មិនមាននរណាបានទទួលតែរសជាតិផ្អែមល្ហែមតែម្យ៉ាង រហូតមួយជាតិទេ ឬជូរចត់តែម្យ៉ាង រហូតមួយជាតិ ត្រូវបានទទួលផលទាំងពីរយ៉ាងផ្លាស់ប្ដូរគ្នាជាដរាបទៅ ត្រូវចេះពិចារណាឱ្យឃើញសភាពនៃសេចក្ដីពិតរឿងនេះ ហើយប្រុងប្រៀបខ្លួនទុកឱ្យស្រេច អ្នកមិនប្រុងប្រៀបខ្លួនទុក កាលជួបប្រទះរសផ្អែមល្ហែមរបស់ជីវិត រមែងឆ្កួតចិត្តឡើងជោរ ព្រោះត្រេកអរសប្បាយ កាលជួបប្រទះរសជូរចត់ ក៏ឆ្កួតទៀត ព្រោះខូចចិត្ត។ អ្នកប្រុងប្រៀបខ្លួនទុករមែងញញឹមជានិច្ច ទាំងក្នុងគ្រាបានសេចក្ដីសុខ ទាំងក្នុងគ្រាជួបទុក្ខ ទាំងក្នុងគ្រាសមបំណងនិងខុសបំណង ចិត្តរបស់គេរឹងប៉ឹងដូចថ្មភ្នំហិមាល័យ ដែលមិនញាប់ញ័រព្រោះខ្យល់បក់បោកមកពីទិសទាំង ៤ ” ។

“ញោមស្រី ធម្មតាមនុស្សយើង កាលស្រឡាញ់គ្នា ក៏រមែងធ្វើល្អចំពោះគ្នា កាលស្អប់គ្នា ក៏រមែងប្រទូសរ៉ាយគ្នា ញោមស្រឡាញ់កូនរបស់ញោម និងប្រាថ្នាល្អចំពោះកូនប្រុសរបស់ញោមមិនមែនឬ ? ”

“មែនពិតហើយ ព្រះគុណម្ចាស់ ខ្ញុំស្រឡាញ់គេក្រៃលែងជាងខ្លួនឯងទៅទៀត បើមានវិធីណាដែលអាចធ្វើឱ្យគេមានសេចក្ដីសុខបាន ខ្ញុំ

នឹងធ្វើឱ្យទាល់តែអស់សមត្ថភាព តែពេលនេះ គេស្លាប់ទៅហើយ ខ្ញុំនឹងជួយគេបានយ៉ាងណា ? " ។

"ញោមស្រី មានផ្លូវជួយបានមួយផ្លូវ ក៏ការឧទ្ទិសកុសលទៅឱ្យគេ ញោមចូរឱ្យទានដល់បដិគ្គាហកៈ ( អ្នកទទួល ) អ្នកានគុណធម៌ ឬតាំងចិត្តរក្សាសីលក្នុងថ្ងៃឧបោសថ ឬធ្វើគុណសេចក្តីល្អយ៉ាងដទៃ ៗ ហើយតាំងចិត្តផ្សាយចំណែកបុណ្យទៅឱ្យកូនប្រុសរបស់ញោម កាលគេបានទទួលហើយ ក៏មានសេចក្តីសុខសមប្រាថ្នារបស់ញោម "

" ព្រះគុណម្ចាស់ដ៏ចំរើន ! ខ្ញុំនៅមិនទាន់ពាក្យនិយាយរបស់ព្រះគុណទេ កូនខ្ញុំស្លាប់ទៅហើយ ទៅនៅទីណាក៏មិនដឹង "

" ញោមស្រី អាចមិនដឹងមែន " ខ្ញុំជជែកឡើង " តែកូនប្រុសរបស់ញោម រមែងដឹងថាជានិច្ចថា ញោមនៅទីណា សន្មតថា ថ្ងៃមួយញោមចេញចាកផ្ទះដោយមិនប្រាប់ឱ្យនរណាដឹងមុន ស្វាមីរបស់ញោមរមែងមិនដឹងថា ញោមទៅនៅទីណា តែញោមខ្លួនឯង ទោះទៅនៅទីណា ឆ្ងាយប៉ុនណា ក៏រមែងដឹងប្រាកដក្នុងចិត្តថា ស្វាមីរបស់ញោមនៅផ្ទះនោះ ភូមិស្រុកនោះ មែនឬមិនមែន ? "

ស្ត្រីជរាឆ្លើយរ៉ាប់រងថា មែន តែក៏នៅសង្ស័យសាកសួរខ្ញុំថា "បើសន្មតថា ខ្ញុំត្រូវការនឹងបញ្ជូនផ្ញើអាហារទៅឱ្យកូនប្រុសខ្ញុំ តើត្រូវធ្វើយ៉ាងណា ? " ។

"ញោមត្រូវឱ្យអាហារជាទានដល់យាចក ស្មូមឬសមណព្រាហ្មណ៍ ហើយក៏ឧទ្ទិសចំណែកបុណ្យទៅឱ្យ " ។

" អេ! " ស្ត្រីជរាឡើងដោយសេចក្តីសង្ស័យ " កាលខ្ញុំយកអាហារទៅថ្វាយសមណព្រាហ្មណ៍ លោកក៏បរិភោគអស់ទៅ ហើយអាហារនឹងទៅដល់កូនប្រុសខ្ញុំបានយ៉ាងណា ? " ។

" អាត្មាមិនបាននិយាយថា អាហារនោះនឹងអណ្តែទៅកាន់កូនប្រុសរបស់ញោម តាមពិតគ្មានវត្ថុអ្វីទៅកាន់កូនប្រុសរបស់ញោមបាន ព្រោះគេបានចាកចេញពីលោកនេះ ទៅលោកមួយទៀត ដែលជាលោកនៃចិត្ត ជាលោកដែលស្អិតសុខុម ទាល់តែមិនអាចនឹងទទួលវត្ថុគ្រាត១ ដុំ១ ដូចអាហាររបស់មនុស្សបាន ព្រោះដូច្នេះ អាហារនិងវត្ថុដទៃមិនអាចនឹងសម្រេចប្រយោជន៍ដល់កូនប្រសុរបស់ញោម ដោយត្រង់បានការដែលអាត្មាណែនាំឱ្យញោមយកអាហារទៅថ្វាយសមណៈ គឺដើម្បីឱ្យអាហារគ្រោតគ្រាតនោះក្លាយជារបស់ល្អិតសុខុមគឺបុណ្យកុសល ដែលចិត្តដ៏ល្អិតសុខុមរបស់កូនប្រុសញោមអាចនឹងទទួលបាន ពិតហើយកាលញោមយកអាហារទៅថ្វាយប្រះសង្ឃ លោកក៏ឆាប់អស់ទៅ តែខាងក្រោយការថ្វាយ ការបរិភោគ និងការអស់ទៅនេះ មានរបស់មួយឡើង របស់នោះគឺ " សេចក្តីល្អ " ឬ "បុណ្យកុសល" ហើយញោមក៏ឧទ្ទិសកុសលនេះឯងឱ្យដល់កូនប្រុសរបស់ញោម សំដៅសេចក្តីថា កូន

របស់ញោមជាវិញ្ញាណល្អិត មិនអាចទទួលរបស់គ្រោតគ្រាតបាន ញោមទើបត្រូវយករបស់គ្រោតគ្រាតទៅផ្លែឱ្យល្អិត បញ្ជូនទៅឱ្យគេ អាត្មានឹងលើកតួយ៉ាងឱ្យស្តាប់ សន្មតថា កូនរបស់ញោមទៅជួបទុក្ខលំបាកនៅទីឆ្ងាយ ញោមអាណិតគេ ប្រាថ្នានឹងបញ្ជូនផ្ទះ ទៅឱ្យគេមួយខ្នង ញោមនឹងបញ្ជូនផ្ទះទាំងខ្នងទៅឱ្យគេរមែងធ្វើមិនបាន ដែលស្រួលនោះ ញោមគួរលក់ផ្ទះនោះ ហើយធ្វើប្រាក់ដែលជារបស់តូចនិងស្រាលជាងទៅឱ្យគេ កាលគេបានទទួលប្រាក់ពីញោមហើយ គេអាចនឹងយកទៅទិញផ្ទះបានតាមបំណង ផ្ទះប្រៀបដូចអាហារវត្ថុ ដែលញោមប្រើធ្វើបុណ្យ ការលក់ផ្ទះគឺការនាំយកអាហារវត្ថុនោះទៅថ្វាយដល់អ្នកមានសីល ប្រាក់ដែលញោមបានពីការលក់ផ្ទះ គឺបុណ្យកុសល ដែលបានចាត់ការធ្វើបុណ្យកុសលនោះ បុណ្យកុសលនោះឯង ញោមអាចបញ្ជូនទៅឱ្យកូនប្រុសរបស់ញោមបាន ព្រោះបុណ្យកុសលជារបស់ល្អិតមិនមានរូបរាង ដូចគ្នា នឹងវិញ្ញាណដ៏ល្អិតនៃកូនប្រុសរបស់ញោម ” ។

“ ខ្ញុំផ្តើមយល់ខ្លះហើយ តែក៏នៅមានចំណុចសង្ស័យខ្លះទៀតសូមសួរផង គឺការផ្ញើប្រាក់ទៅឱ្យបុគ្គលអ្នកមានជីវិតរស់នៅនោះ តាមប្រក្រតីក៏ច្រើនតែមានមនុស្សនាំយកទៅ ព្រោះប្រាក់មាសជារបស់មានរូបមានខ្លួន តែបុណ្យកុសលជារបស់មិនមានខ្លួន យើងនឹងផ្ញើរទៅយ៉ាងណានរណានឹងជាអ្នកនាំទៅឱ្យដល់អ្នកដែលយើងមានបំណងនោះ ? ” ។

" ញោមស្រី ការឧទ្ទិសកុសលទៅឱ្យដល់អ្នកស្លាប់នោះ តាមសភាពសេចក្តីពិតហើយ មិនមានអ្វីទៅមិនមានអ្វីមក មិនមានមនុស្សនាំទៅ អាត្មាប្រៀបនឹងការផ្ញើប្រាក់ ត្រឹមតែដើម្បីឱ្យងាយយល់ប៉ុណ្ណោះ កាលបើដូច្នេះ បុណ្យកុសលទៅដល់អ្នកស្លាប់បានយ៉ាងណា អាត្មានឹងអធិប្បាយប្រៀបធៀបឱ្យស្គាល់ ។

សន្មតថាញោមបញ្ជូនកូនប្រុសរបស់ញោមទៅកាន់សំណាក់អាចារ្យទិសាបាមោក្ខនៃក្រុងតក្កសិលា ដើម្បីឱ្យសិក្សាសិល្បវិទ្យា ញោមស្រឡាញ់កូនប្រុសនោះណាស់ គិតដល់គេជានិច្ច យកចិត្តទុកដាក់រង់ចាំស្តាប់ដំណឹងពីគេរាល់ថ្ងៃ តមកញោមបានដំណឹងថា កូនប្រុសរបស់ញោមផ្ទុយពីតាំងចិត្តសិក្សារៀនសូត្រ បែរទៅប្រព្រឹត្តផ្តេសផ្តាសដោយប្រការផ្សេងៗ រហូតអាចារ្យទិសាបាមោក្ខដេញចេញចាញសាលាមិនឱ្យនៅសិក្សាតទៅទៀត កាលបានដំណឹងដូច្នេះ តើញោមមានអារម្មណ៍យ៉ាងណា ជាសុខ ឬជាទុក្ខ ? "

" ខ្ញុំមានអារម្មណ៍ជាទុក្ខច្រើន " ស្ត្រីជរាឆ្លើយ

" ញោមស្រី ! អ្វីហ្នឹងធ្វើឱ្យញោមកើតទុក្ខ? "

" ការប្រព្រឹត្តិអាក្រក់របស់កូនប្រុសខ្ញុំនោះឯង "

" ឥឡូវសន្មតថា តមកញោមបានដឹងដំណឹងថ្មីថាកូនប្រុសរបស់ញោមកែប្រែខ្លួនបានហើយ គេបានចូលរកអាចារ្យសូមសេចក្តីអភ័យ

ទោស ហើយតាំងចិត្តសិក្សារៀនសូត្រដោយល្អ ប្រព្រឹត្តត្រឹមត្រូវរហូតបានជាទីស្រឡាញ់របស់អាចារ្យនិងមិត្តភក្តិទូទៅ នរណា។ ក៏នាំគ្នាលើកដំកើនសរសើរកូនប្រុសរបស់ញោម កាលបានទទួលដំណឹងដូច្នេះ ញោមទទួលអារម្មណ៍យ៉ាងណា ជាសុខឬជាទុក្ខ ? "

" ជាសុខព្រះគុណម្ចាស់ "

" អ្វីហ្ន៎ ធ្វើឱ្យញោមជាសុខ ? "

" ព្រោះកូនប្រុសរបស់ខ្ញុំ ត្រឡប់ខ្លួនជាមនុស្សល្អបាននោះឯង "

" ញោមស្រី ការធ្វើល្អឬអាក្រក់នៃកូនប្រុសរបស់ញោមដែលនៅឆ្ងាយដល់ក្រុងតក្កសិលា អាចឱ្យសុខនិងទុក្ខដល់ញោមបានយ៉ាងណា ការធ្វើល្អនិងអាក្រក់របស់ញោមក្នុងលោកនេះ អាចឱ្យសុខនិងទុក្ខដល់កូនប្រុសរបស់ញោមនៅក្នុងលោកដទៃបានយ៉ាងនោះ បើញោមគិតដល់កូនប្រុសដែលស្លាប់ទៅហើយ ប្រាថ្នាឱ្យមានសេចក្តីសុខ ក៏ចូរធ្វើតែសេចក្តីល្អ ហើយតាំងចិត្តឧទ្ទិសទៅឱ្យគេ ការតាំងចិត្តឧទ្ទិសចំពោះគេជាពិធីការសំដែងថា ញោមនៅគិតរលឹកនឹកដល់គេ នៅទុកគេជាកូនជាចៅ, សេចក្តីពិត ត្រឹមតែញោមធ្វើសេចក្តីល្អប៉ុណ្ណោះ គេក៏ជាសុខល្មមហើយ តែបើគេដឹងថាញោមធ្វើល្អ ដើម្បីគេដោយចំពោះ គេមុខជាត្រេកអរ និងរីតតែមានសេចក្តីសុខក្រៃលែងឡើង " ។

" ព្រះគុណម្ចាស់ដ៏ចំរើន ! លោកបានឱ្យសេចក្ដីភ្លឺស្វាងដ៏ធំក្រៃលែងចំពោះខ្ញុំដោយពិត លោកជាអ្នកបញ្ជាក់ផ្លូវដល់ខ្ញុំដែលកំពុងវង្វេងផ្លូវ ជាអ្នកស្ទួយខ្ញុំឡើងមកពីរណ្ដៅនៃសេចក្ដីល្ងង់និងសេចក្ដីទុក្ខសោក ខ្ញុំនឹងតាំងចិត្តប្រតិបត្តិតាមពាក្យ ណែនាំរបស់លោកតទៅរហូតអវសានជីវិត ព្រះគុណដ៏រើន ខ្ញុំមិនមានអ្វីបូជាគុណរបស់លោកក្រៅពីរបស់បន្តិចបន្តួចនេះ " ។

ថាហើយស្ត្រីជរាក៏លូកទៅក្នុងអាវ យកគ្រឿងប្រដាប់កាយធ្វើដោយមាសចំនួនមួយហុចមកឱ្យខ្ញុំភ្លាមហើយពោលថា "អលង្ការនេះមានតម្លៃច្រើន ខ្ញុំថែរក្សាទុកតាំងចិត្តនឹងឱ្យកូនប្រុស តែកាលគេស្លាប់ទៅហើយខ្ញុំសូមថ្វាយដល់ព្រះគុណម្ចាស់ សូមមេត្តាប្រោសទទួលយកចុះ " ។

"ញោមស្រី ! អាត្មាជាសមណៈអ្នកលះបង់ហើយនូវលោកិយទ្រព្យទាំងពួង អាត្មាមិនត្រូវការអ្វីក្រៅពីអាហារចិញ្ចឹមជីវិតត្រឹមមួយថ្ងៃ ៗ និងសំពត់បិទបាំងរាងកាយប៉ុណ្ណោះ ដូច្នោះអាត្មាទើបមិនទទួលរបស់ញោមបាន យកទុកវិញចុះញោម "។

ស្ត្រីជរាមិនព្រមស្ដាប់ បង្ខំខ្ញុំឱ្យទទួលទាល់តែបាន " ខ្ញុំបានកាត់ចិត្តដាច់ខាងហើយ ដែលនឹងថ្វាយរបស់នេះចំពោះព្រះគុណម្ចាស់ ដើម្បីឧទ្ទិសភាគកុសលដល់កូន បើមិនឃើញដល់ខ្ញុំក៏ចូរឃើញដល់កូនរបស់ខ្ញុំ

ផងចុះ ” ។

“ បើយ៉ាងនោះ ចូរដាក់ទុកលើដីខាងមុខអាត្មាមកចុះ ” ស្រីជរាលើករបស់នោះបន្ទូលលើក្បាលអធិដ្ឋានអ្វីហើយ ក៏ដាក់ចុះតាមខ្ញុំបង្គាប់ ។

អាត្មាទទួលយកទាន់របស់ញោមស្រីហើយ បុណ្យកុសលផលទានកើតដល់ញោមហើយ ចូរឧទ្ទិសចំណែកកុសលនេះ ដល់កូនប្រុសរបស់ញោមចុះ ញោមស្រី ទាក់ទងនឹងមានចំនួននេះគ្មានប្រយោជន៍អ្វីសម្រាប់អាត្មា ព្រោះដូច្នោះអាត្មាសូមឱ្យជាទានបង្ខិលដល់ញោម និងសូមឧទ្ទិសចំណែកកុសលនេះ ចំពោះកូនប្រុសរបស់ញោមផង ”

កាលទេសនាប្រៀនប្រដៅស្ត្រីជរារហូតវេលារសៀលហើយ ខ្ញុំក៏លាគាត់ចេញធ្វើដំណើរតទៅ ។

# អគ្គិភ័យ

**លោកអ្នកអានទាំងឡាយ!** គ្រាមួយ ខ្ញុំទៅនៅចាំវស្សានាស្រុក **កោកិលាគ្រាម** តំនប់មួយនៃក្រុងរាជគ្រឹះ អ្នកស្រុកបានអើពើជួយធ្វើកុដិតូចមួយខ្នងឱ្យខ្ញុំ នៅជើងភ្នំជិតធារទឹក ខាងក្រោយកុដិជាកំពូលភ្នំខ្ពស់ឡើងទៅ ខាងមុខកុដិមានលានថ្មធំទូលាយរាបស្មើល្អ បរិ-វេណជុំវិញមានដើមឈើផ្សេងៗធំៗ លាតមែកបែកសន្លឹកគ្របបាំងពីលើ ធ្វើឱ្យផែនថ្មមានម្លប់ត្រជាក់គួរអង្គុយសម្រាកពន់ពេកណាស់ រម្លងផែនថ្មនេះចុះទៅជាលានដីទូលាយល្មមប្រមាណ ទីលានដីនេះ មានកុដិតូចមួយខ្នងសម្រាប់ជាទីនៅរបស់ឧបាសកម្នាក់ ដែលអ្នកស្រុកចាត់ឱ្យមកនៅចាំបំរើខ្ញុំ តអំពីនោះទៅជាជុំថ្មខ្ពស់ខ្លះទាបខ្លះរៀងរាយតគ្នាចុះទៅដូចជាជណ្តើរធម្មជាតិរហូតដល់ផ្លូវទឹក ដែលផ្លូវទឹកនេះមានដើមឈើខ្នាតធំមួយដើមដួលរលំដោយកំឡាំងខ្យល់កាលយូរមកហើយ ទៅគងនឹងត្រើយម្ខាងផ្លូវទឹកក្លាយជាស្ពានធម្មជាតិ សម្រាប់ឆ្លងទៅបិណ្ឌបាតក្នុងភូមិស្រុកដែលនៅឆ្ងាយប្រមាណ ៥០០ ជួរធ្នូ, បរិវេណនោះឧត្តមសម្បូណ៌ដោយសត្វព្រៃប្រភេទនានា តាំងពីសត្វតូចៗ ដែលយំសំឡេងមុតយាមរាត្រីរហូតដល់មានព្រៃនិងទទាដែលតែងដើរកចំណើរស៊ីជិត ៗ កុដិខ្ញុំ ដោយមិនបានសំដែងសេចក្តីតក់ស្លុតរន្ធត់ខ្លាចអ្វីឡើយ វាប្រហែលដឹងថា ខ្ញុំ

សមណៈ អ្នកវៀរដាច់ខាតហើយនូវការបៀតបៀនសត្វដទៃ អ្នកមានចិត្តពេញប្រៀបដោយមេត្តាធម៌ ខ្ញុំបាចបាយដែលសល់ពីឆាន់ទៅខាងៗបណ្តោយឱ្យសត្វទាំងនោះមកចឹកស៊ីតាមសប្បាយ ក្នុងវេលាថ្ងៃ ទីនៅរបស់ខ្ញុំពេញដោយជីវិតជីវា តែក្នុងវេលារាត្រីក៏ស្ងៀមស្ងាត់ដូចព្រៃខ្មោចទោះដូច្នោះ ក៏មិនធ្វើឱ្យខ្ញុំហួតហែងចំបែងចិត្តគិតខ្លាចអ្វីទេ ឧបាសកម្នាក់ មាន់ព្រៃ ទទា រៃ និងព្រឹក្សជាតិដ៏មានម្លប់ត្រជាក់គ្រប់គ្រាន់ហើយសម្រាប់ឱ្យសេចក្តីកក់ក្តៅដល់ចិត្តក្នុងវេលានោះ អ្នកស្រុកគ្រប់គ្នាកាលមកឃើញលំនៅរបស់ខ្ញុំ នាំគ្នាលាន់មាត់សរសើរថាស្ងប់-សប្បាយគួរនៅ ខ្ញុំឆ្លើយប្រាប់ថា រូងភ្នំលំនៅព្រៃគឺស្រុកដើមរបស់មនុស្ស កាលមនុស្សបានត្រឡប់មកឃើញស្រុកដើមម្តងទៀត ទើបដឹងថាគួរនៅ ។

ក្នុងរវាងកណ្តាលវស្សានោះឯង ហេតុការណ៍ដ៏គួរសោកសៅមួយបានកើតឡើង យប់ជ្រៅនៃរាត្រីមួយ ខណៈដែលខ្ញុំកំពុងពិចារណាធម៌នៅលើផែនថ្មមុខកុដិខ្ញុំ បានសង្កេតឃើញអណ្តាតភ្លើងឆេះសន្ធោសន្ធៅក្រហមឆ្អៅឡើងត្រង់ភូមិស្រុកកោកិលាគ្រាម ព្រមដោយសំឡេងស្រែកវ៉ូសវ៉ាសរបស់អ្នកស្រុកឮឡើង ខ្ញុំគិតក្នុងចិត្តថាមុខជាមានកើតអគ្គិភ័យឡើងនៅផ្ទះនរណាម្នាក់ពិតប្រាកដ ភ្លើងឆេះសន្ធោសន្ធៅវេលាជាយូរទើបស្ងប់បាត់អណ្តាត ថ្ងៃព្រឹកឡើងមេស្រុកបានមករកខ្ញុំព្រមដោយទឹកភ្នែកហើយរាយការណ៍ថា " លោកម្ចាស់ដ៏ចំរើន! យប់មិញបានកើតភ្លើង

ឆេះផ្ទះរបស់ខ្ញុំ ផ្ទះនិងទ្រព្យសម្បត្តិត្រូវភ្លើងឆេះបំផ្លាញអស់រលីងហើយ ខ្ញុំក្លាយជាទុគ៌តខ្សត់ក្រហើយ ព្រះគុណម្ចាស់មេត្តាជួយខ្ញុំផង ” ។

“កុំព្រួយបារម្ភអី អាត្មានឹងជួយយ៉ាងពេញសមត្ថភាព ”

“ សូមទានមេត្តាជួយឱ្យបានឆាប់ផង បើមិនដូច្នោះ ខ្ញុំនិងប្រពន្ធកូន មុខជាអត់ស្លាប់មិនខាន ” មេស្រុកពោលយ៉ាងក្រវល់ក្រវាយចិត្ត ។

“អាត្មានឹងផ្ដើមជួយឥឡូវនេះឯង តែសូមឱ្យឧបាសកស្ងប់ចិត្តបំភ្លេចរឿងឆេះផ្ទះទុកមួយគ្រាសិន ” មេស្រុកអង្គុយឈ្ងោកមុខ ដោយអាការៈសង្រួមដ៏ល្អ ហើយខ្ញុំក៏ផ្ដើមជួយគេដោយធម្មឱសថឬធម្មទានដូចតទៅនេះ

“ **ម្នាលឧបាសក !** ចូលតាំងចិត្តឱ្យស្ងប់រម្ងាប់ ហើយប្រុងស្ដាប់រឿង អាត្មានឹងនិយាយឱ្យស្ដាប់ ក្នុងរវាងដែលអាត្មាធ្វើដំណើរមកដោយលំដាប់នោះ ថ្ងៃមួយបានទៅស្នាក់នៅក្នុងភូមិមួយព្រឹកឡើងក៏ចូលទៅបិណ្ឌបាតក្នុងស្រុកតាមវិស័យសមណៈ ខណៈដែលកំពុងដើរទៅតាមផ្លូវបានសង្កេតឃើញហ្វូងមនុស្សកំពុងចោមរោមមើលអ្វីជាហ្វូងធំ ទើបដើរឆៀងចូលទៅជិតៗ ដើម្បីនឹងមើលថា មានរឿងអ្វីកើតឡើង អាត្មាបានឃើញមនុស្សពីរបីនាក់ កំពុងចាប់មនុស្សប្រុសម្នាក់ទាញចេញមកពីកុម្ភការដ្ឋានរបស់កុម្ភការី ( ស្មូនឆ្នាំង ) ម្នាក់ បុរសដែលត្រូវទាញអូសមកក៏ខំរើបម្រះតស៊ូត្រឡប់ចូលទៅរោងធ្វើឆ្នាំងនោះវិញ ព្រមទាំងស្រែកថា

ខ្ញុំមិនទៅ! ខ្ញុំមិនទៅ ! នេះកុម្ភការដ្ឋានរបស់ខ្ញុំ ទ្រព្យសម្បត្តិគ្រប់យ៉ាងជារបស់ខ្ញុំ ខ្ញុំនឹងទៅធ្វើម៉េច ។ ចំណែកមនុស្សទាំងឡាយមិនស្តាប់គាត់នោះ ខំប្រទាញប្រទង់គេចេញទៅ ព្រមទាំងស្រែកថា ឯងជាមនុស្សឆ្កួតៗ ។

បានឃើញហេតុការណ៍ដ៏ចម្លែកនោះហើយ អាត្មាទើបសួរបុរសម្នាក់ថាកើតរឿងរ៉ាវអ្វី? គេនិយាយឱ្យស្តាប់ថា បុរសម្នាក់ដែលត្រូវគេអូសទាញចេញមកនោះជាមនុស្សប្លែកមុខមកពីណាក៏មិនដឹង កាលពីយប់មិញបានទៅសូមសំណាក់នៅនឹងនាយស្ទូនឆ្នាំង ប្រាប់ថាព្រឹកឡើងក៏នឹងសូមលាធ្វើដំណើរតទៅ សូមអាស្រ័យនៅតែមួយយប់ប៉ុណ្ណោះ, នាយស្ទូនឆ្នាំងក៏ពេញចិត្តចាត់ទីស្នាក់ឱ្យដោយអធ្យាស្រ័យមេត្រី រករបស់ប្រើប្រាស់ផ្សេងៗមកឱ្យ លុះព្រឹកឡើងបុរសប្លែកមុខនោះ បែរជាកៀបក្រាញថាកុម្ភការដ្ឋាននិងអ្វីៗ គ្រប់យ៉ាងខាងក្នុងនោះជាទ្រព្យសម្បត្តិរបស់ខ្លួន មិនព្រមចេញពីកុម្ភការដ្ឋានរបស់នាយស្ទូនឆ្នាំង អ្នកស្រុកគិតថាគាត់នោះឆ្កួតហើយ ទើបនាំគ្នាចាប់អូសទាញចេញមកដូចដែលបានឃើញនេះ ” ។

“ **ម្នាលឧបាសក!** បើលោកទៅជួបហេតុការណ៍ដូច្នោះ លោកនឹងគិតយ៉ាងណា លោកគិតថាបុរសនោះ ជាមនុស្សឆ្កួតឬមនុស្សជា? ”។

មេស្រុកឆ្លើយភ្លាមថា " បុរសនោះ ប្រាកដជាមនុស្សឆ្កួត ព្រោះទៅម៉ៅយករបស់គេថាជារបស់ខ្លួន ទាំងដែលខ្លួនមិនមានសិទ្ធិអ្វីឡើយ"។

"បើបុរសនោះឆ្កួត មនុស្សទូទៅក៏ឆ្កួតដែរ អាត្មានិងបញ្ជាក់ហេតុផលឱ្យស្តាប់ លោកនេះកុម្ភការដ្ឋានរបស់នាយស្ទូនផ្លាំង មនុស្សគ្រប់គ្នាជាអ្នកមកសូមអាស្រ័យនៅមួយដងមួយគ្រា ក្នុងមិនយូរ ក៏ត្រូវបែកឃ្លាតទៅ យើងមកកាន់លោកនេះ ដោយខ្លួនទទេ សម្បត្តិមួយចំណិតតូចក៏គ្មានជាប់តាមខ្លួនមក ទ្រព្យសម្បត្តិផ្សេងៗ ដូចផ្ទះសម្បែង ស្រែចំការ ច្បារដំណាំ ប្រាក់កាស យើងទើបនឹងរកពេលក្រោយ កាលដល់គ្រាយើងនឹងចេញចាកលោកនេះទៅ យើងត្រូវចោលទ្រព្យសម្បត្តិទាំងនេះទុកខាងក្រោយ ទោះមានច្រើនមានតិចត្រឹមណា ក៏យកទៅជាមួយផងមិនបាន បើសន្មតថា គ្រប់មនុស្សស្លាប់អស់ ទ្រព្យសម្បត្តិនឹងនៅក្នុងលោកនេះឯង វាក៏ត្រឡប់ទៅរកលោកដែលជាម្ចាស់ដើមរបស់វា មនុស្សយើងគ្រប់គ្នា មិនមែនជាម្ចាស់របស់ យើងជាអ្នកមកសូមអាស្រ័យនៅមួយផងមួយគ្រា ក្នុងមិនយូរត្រូវបែកឃ្លាតទៅ ចោលរបស់ផ្សេងៗឱ្យអ្នកមកអាស្រ័យក្រោយប្រើប្រាស់តទៅ កាលសេចក្តីពិតមានដូច្នេះ ទ្រព្យរបស់យើងនៅទីណា? របស់យើងមិនមាន តែមនុស្សភាគច្រើន ក៏និយមយ៉ាងស្និតស្នាញថា ផ្ទះរបស់យើង ប្រាក់មាសរបស់យើង សំលៀកបំពាក់របស់យើង ស្រែចំការរបស់យើង ជាប់នៅនឹងវត្ថុទាំងនេះ មិនចង់ឱ្យ

ខ្លួនព្រាត់ចាករបស់ទាំងនេះ មិនចង់ឱ្យរបស់ទាំងនេះព្រាត់ចាកពីខ្លួន កាលកើតការព្រាត់ប្រាសនិរាសហើយ ក៏កើតសេចក្តីសោកសៅ ខូចចិត្តក្រៀមក្រំរៀបរាប់រាំរ៉ៃ ដូចគ្នានិងបុរសប្លែកមុខ ដែលចូលទៅសូមស្នាក់ក្នុងកុម្ភ-ការដ្ឋានរបស់កុម្ភការី ហើយកៀចក្រាញថាជារបស់ខ្លួន ត្រូវគេអូសទាញចេញក៏មិនព្រមចេញ ដូច្នេះអាត្មា ទើបពោលថា មនុស្សចំណែកច្រើនក៏ឆ្កួតដូចមនុស្សប្លែកមុខនោះ ។

**ម្នាលឧបាសក !** កុំខូចចិត្តឡើយដែលលោកត្រូវសូន្យបង់នូវផ្ទះសម្បែងនិងទ្រព្យសម្បត្តិព្រោះហេតុត្រូវភ្លើងឆេះ ព្រោះរបស់ទាំងនេះមិនមែនជារបស់យើង យើងខ្ចីគេមកប្រើមួយរយៈកាលប៉ុណ្ណោះ ឥឡូវនេះដល់វេលាដែលគេនឹងត្រូវហៅរករបស់គេវិញ យើងក៏គួរប្រគល់ឱ្យគេដោយសេចក្តីត្រេកអរ ក្នុងកាលជីវិតរាងកាយរបស់យើងនៅមាន យើងក៏រកជាថ្មី ដូច្នេះកុំសោកសៅខូចចិត្តអី ធ្វើចិត្តឱ្យរឹងប៉ឹង ក្នុងមិនយូរលោកអាចសាងឋានៈរបស់លោកឱ្យស្តុកស្តម្ភបានដូចមុន ” ។

មេស្រុកអង្គុយត្រិះរិះអស់វេលាដ៏យូរ ទើបក្រាបសំពះខ្ញុំ ហើយពោលដោយសំឡេងច្បាស់លាស់ជាងមុន “ លោកម្ចាស់ដ៏ចំរើន ! ធម្ម-ទេសនារបស់លោកឱ្យពន្លឺភ្លឺស្វាងច្បាស់លាស់ដល់ចិត្តខ្ញុំច្រើន ខ្ញុំមិនធ្លាប់បានស្តាប់ហេតុផលដូច្នេះ មកពីមុនឡើយ ទើបសំគាល់ដាច់ខាតថា ទ្រព្យ

ទាំងឡាយជារបស់ខ្លួនពិត១ តែដែលពិតវាគ្រាន់តែជាវត្ថុធាតុ ដែលយើងសូមខ្ចីប្រើមួយដងមួយគ្រា ក្នុងរវាងដែលមកអាស្រ័យនៅក្នុងលោកនេះប៉ុណ្ណោះឯង កាលចូលចិត្តយល់ហេតុផលនេះហើយ ធ្វើឱ្យខ្ញុំស្រាលស្រាកចាកទុក្ខ បានសុខសប្បាយចិត្តច្រើនឡើង ” ថាហើយគេក៏ក្រាបសំពះខ្ញុំដោយសេចក្ដីគោរពម្ដងទៀត ។

“ **ម្នាលឧបាសក !** មនុស្សសាមញ្ញគ្រប់គ្នា រមែងធ្លាក់នៅក្រោមអំណាចនៃមោហៈ គឺសេចក្ដីវង្វេង សេចក្ដីភ័ន្តច្រឡំ គេយល់ឃើញមួយយ៉ាងផ្សេងទៅវិញ ហើយក៏ប្រកាន់មាំថាជារបស់ពិត តាមសេចក្ដីយល់សំគាល់ខុសរបស់ខ្លួននោះ គេសំគាល់ខុសក្នុងរឿងអ្វីខ្លះ ? គេសំគាល់ខុសក្នុងរឿងទ្រព្យថា ទ្រព្យជារបស់ខ្លួនពិត១ ទាំងដែលទ្រព្យត្រឹមតែជាវត្ថុធាតុ មាននៅក្នុងលោកប៉ុណ្ណោះ កាលគិតថាទ្រព្យជារបស់ខ្លួន ក៏ជាប់នៅក្នុងទ្រព្យក្រវល់ក្រវាយនៅនឹងទ្រព្យ ធ្វើអាក្រក់ព្រោះទ្រព្យហើយក៏កើតទុក្ខព្រោះទ្រព្យ មនុស្សខ្លះបានយសហើយក៏វង្វេងនឹងយសគិតថាយសជារបស់គង់វង្សពិតប្រាកដ ជាប់ស្អិតនៅក្នុងយស ក្រវល់ក្រវាយព្រោះយស ធ្វើអាក្រក់ព្រោះយសហើយក៏បានទុក្ខព្រោះយសនោះ, តាមសេចក្ដីពិតយសបណ្ដាសក្តិ គ្រាន់តែជារបស់ដែលសន្មតគ្នាឡើង មិនមែនកើតឡើងដោយខ្លួនឯង ស្ងួនឆ្នាំងអាចយកដីទៅស្ងួនជា

ឆ្មាំង ចាន ចង្ក្រាន ពែង ប៉ាន់ ជារូបសត្វផ្សេងៗ ទៀត តែក្នុងទីបំផុត វាក៏ទៅជាដីតាមដើមនោះឯង មនុស្សយើង គេអាចសន្មតឱ្យជាព្រាហ្មណ៍ ជាវេស្សៈ ជាសូទ្រៈ ជាចណ្ឌាល ជាមេស្រុក ជាទាហាន ជាសេនាបតី ជាព្រះរាជា និងជាអ្វីដទៃៗ ទៀត តែក្នុងទីបំផុតគេជាមនុស្សម្នាក់ ដូចមនុស្សទាំងឡាយក្នុងលោក ដែលត្រូវកើតចាស់ ឈឺ ស្លាប់ផងគ្នា យសទាំងឡាយត្រឹមតែជាការសន្មតិ យសដែលពិតរបស់មនុស្សគ្រប់គ្នា ក៏គឺ "សត្វលោក" ដែលស្រឡាញ់ជីវិត មិនគិតចង់ស្លាប់ ប្រាថ្នាសេចក្តីសុខសប្បាយ ស្អប់ជិនណាយសេចក្តីទុក្ខ បើមនុស្សយើងគិតជានិច្ចថា ខ្លួនត្រឹមតែជា " សត្វលោក " មួយ គេនឹងមិនវង្វេង នឹងយសក្តិខាងក្រៅដែលមនុស្សសន្មតឱ្យ គេនឹងមិនក្រអឺតឡើងក្រអោងប៉ោងចិត្ត គេនឹងឃើញចិត្តឃើញថ្លើមមិត្តមនុស្សជាតិ ហើយក៏ធ្វើតែសេចក្តីល្អ ផលគឺសេចក្តីសុខស្ងប់ក៏កើតមានឡើងក្នុងសង្គមមនុស្ស ។

**ម្នាលឧបាសក !** ក្រៅពីទ្រព្យសម្បត្តិនិងយសដែលពោលហើយ មនុស្សយើងនៅវង្វេងច្រឡំចូលចិត្តខុសក្នុងរបស់ដទៃៗទៀតច្រើនណាស់ តែល្មមនឹងសរុបបានថា អ្នកណាមានរបស់អ្វី ក៏ច្រើនតែវង្វេងច្រឡំក្នុងរបស់នោះ មួរម៉ៅក្តៅក្រហាយនឹងរបស់នោះ "។

"លោកម្ចាស់ដ៏ចំរើន ! " មេស្រុកនិយាយឡើង " ហេតុផលរបស់ព្រះគុណម្ចាស់ឱ្យសេចក្តីភ្លឺស្វាងដល់ខ្ញុំ ច្រើនណាស់ ខ្ញុំនៅវង្វេង

ច្រឡំអ្វីៗ ច្រើនទៀត សូមមេត្តាសំដែងបញ្ជាក់វិធីកែសេចក្ដីវង្វេងដល់ខ្ញុំផង ” ។

“ **ម្នាលឧបាសក !** វិធីកែសេចក្ដីវង្វេងច្រឡំអាចធ្វើបាន មិនជាពិបាកណាស់ណាទេ កាលលោកដឹងខ្លួនថាជាអ្នកវង្វេងហើយដូច្នេះ ក៏កាន់តែងាយនឹងកែ ដូចបុរសដែលវង្វេងផ្លូវ បើដឹងថាខ្លួនវង្វេងផ្លូវ មុខជារកឃើញផ្លូវត្រូវក្នុងពេលមិនយូរ បើមិនដឹងថាខ្លួនវង្វេងផ្លូវ ក៏ចេះតែដើរតាមផ្លូវខុសជានិច្ចទៅ មិនមានថ្ងៃដល់គោលដៅចុងបំផុតបានឡើយ។

លោកជ្រាបហើយថា សេចក្ដីវង្វេងគឺការមិនដឹងសេចក្ដីពិត ហើយចូលចិត្តខុស ហេតុដែលមិនដឹងសេចក្ដីពិត ព្រោះមានចិត្តងងឹតងងល់ ព្រោះមានអ្វីខ្លះ ចូលជ្រៀតជ្រែកនៅក្នុងចិត្ត ដូចទឹកដែលពេញដោយធូលីកករល្អក់ រមែងមិនថ្លាល្អ ឬដូចមនុស្សដែលសម្រាមចូលភ្នែក ធ្វើឱ្យឈឺឱ្យស្រវាំងភ្នែក មើលអ្វីមិនឃើញច្បាស់ហើយក៏សំគាល់ខ្សែថាជាពស់ ខ្សែគឺសេចក្ដីពិត ពស់គឺសេចក្ដីមិនពិត ធ្វើយ៉ាងណា យើងទើបដឹងសេចក្ដីពិត ? ចម្លើយគឺថា យើងអាចធ្វើបានដោយវិធីពីរ វិធីមួយដោយការសិក្សាពិសោធសាកសួររបស់ដែលយើងចូលចិត្តថាជាពស់នោះយ៉ាងល្អិតល្អន់គ្រប់គ្រាន់ ដោយយកឈើឆ្កឹះមើលខ្លះ យកឈើសូកលើកឡើងខ្លះ បើឃើញថាមិនកម្រើកយើងនឹងកើតសេចក្ដីដឹងថ្មីថាពស់ស្លាប់ធម្មតាពស់ស្លាប់ហើយ រមែងចឹងនរណាៗ មិនបាន បើដឹងដូច្នេះ យើង

ក៏ចាប់មកពិសោធមើលដោយដៃស្ទាបមើល ក្នុងទីបំផុតសេចក្តីដឹងច្បាស់លាស់ ដែលកើតឡើងក្នុងចិត្តនោះគឺខ្សែ លុះដឹងថាជាខ្សែត្រឹមប៉ុណ្ណោះ សេចក្តីខ្លាចសេចក្តីសង្ស័យស្ទាក់ស្ទើរក៏បាត់អស់រលីង ។ វិធីទី ២ ដោយយកសម្រាមចេញពីភ្នែកជាមុន ព្រោះកាលសម្រាមចេញពីភ្នែកហើយ ការស្រវាំងក៏បាត់ទៅ ដួងភ្នែកក៏ថ្លាជ្រះ មើលឃើញអ្វីបានច្បាស់ តាមសេចក្តីពិតជានិច្ច វិធីនេះល្អជាងវិធីទី ១ ព្រោះជាការកែរដើមហេតុដ៏ពិត កាលភ្នែកថ្លាជ្រះស្រឡះហើយ អាចនឹងមើលអ្វីឃើញច្បាស់ទាំងអស់ មិនធ្វើឱ្យកើតសេចក្តីចូលចិត្តខុសទៀត, វិធីដំបូងជាវិធីកែចុងហេតុ ទោះចូលចិត្តត្រូវក្នុងរឿងពស់ក៏អាចនឹងសំគាល់ខុសបាន ក្នុងរបស់ដទៃទៀត ត្រូវពិសោធសាកសួរទៀត មិនមានវេលាចប់បាន តែសូម្បីយ៉ាងនោះក៏នៅល្អជាងមិនធ្វើសោះដែរ ។

**ម្នាលឧបាសក!** មនុស្សភាគច្រើនដែលវង្វេងច្រឡំនូវអ្វីផ្សេងៗរាល់ថ្ងៃនេះ ព្រោះដួងភ្នែកគឺចិត្តរបស់គេ ពេញដោយធូលី ធ្វើឱ្យចិត្តកករល្អក់មួហ្មងមើលអ្វីមិនឃើញច្បាស់ ទើបសំគាល់យល់ខុស កាលសំគាល់យល់ខុស ក៏ធ្វើខុស និយាយខុសទៅផង ផលដែលកើតខុសក៏គឺទុក្ខ កាលចូលចិត្តខុសហើយ នៅមិនដឹងថាខ្លួនខុស មិនគិតពិសោធរកសេចក្តីពិត ហើយក៏ដើរតាមផ្លូវខុសជានិច្ចទៅ, ធូលីដែលធ្វើចិត្តឱ្យ

កករល្អក់ខ្វក់ខ្វល់នោះគឺអ្វី? លោកគួរជ្រាបលក្ខណៈរបស់ចិត្តជាមុន ចិត្តរបស់មនុស្សយើងក្នុងវេលាប្រក្រតីមានលក្ខណៈថ្លា ត្រជាក់ស្ងប់ នឹងគិតអ្វីក៏ផ្លុះផ្លាយ ជាគំនិតដែលល្អ បើនិយាយអ្វីចេញមកក្នុងខណៈនោះ ក៏ជាសំដីដែលល្អ ធ្វើការងារអ្វី ក៏ជាការងារដែលល្អ កាលគិតល្អ និយាយល្អ ធ្វើល្អ ផលល្អក៏កើតឡើង ។

**ម្នាលឧបាសក !** វេលាសេចក្ដីចង់បាន សេចក្ដីក្រហល់ក្រហាយ នឹងចូលមកជ្រៀតជ្រែកចិត្តធ្វើឱ្យចិត្តក្រវល់ក្រវាយអន្ទះអន្ទែង ប្រហែលនិងខ្លាស្គមដែលជាប់នៅក្នុងទ្រុង , ជួនកាលកំហឹងខាងក្រោធចូលមកជ្រៀតជ្រែកចិត្ត ធ្វើឱ្យចិត្តមួម៉ៅក្ដៅផ្សាដូចត្រូវចាក់ដោយដែកស្រួច, ជួនកាលតម្រេកត្រេកត្រអាលចូលមកគ្រប់គ្រងចិត្ត ធ្វើចិត្តឱ្យននះននាលដូចដំរីចុះប្រេងដែលភ្នែកខ្វាក់ ចំណង់, កំហឹង សេចក្ដីឫស្យា សេចក្ដីត្រេកត្រអាល សេចក្ដីសោកជាដើម ទាំងនេះគឺធូលីរបស់ចិត្ត ធ្វើចិត្តឱ្យងងឹតមួហ្មង មើលអ្វីឃើញមិនច្បាស់ ដូចធូលីឬសម្រាមចូលភ្នែក ។

**វិធីកែ** ត្រូវមានសតិ ភ្ញាក់ខ្លួន ប្រើសតិជាអ្នកយាមល្បាត មើលចិត្តរបស់ខ្លួន ត្រួតត្រាពិនិត្យមើលចិត្តជានិច្ចថា ជ្រះស្អាតថ្លាជាប្រក្រតីកករល្អក់ បើកករល្អក់ព្រោះមានអ្វីមកជ្រៀតជ្រែក សេចក្ដីក្រោធឬសេចក្ដីក្ដីស្អប់ សេចក្ដីលោភ ឬសេចក្ដីធុញថប់ សេចក្ដីឫស្យាឬសេចក្ដីស្រឡាញ់

កាលដឹងថាអារម្មណ៍ប្រភេទណាមួយកំពុងគ្រប់គ្រងចិត្ត ដូចសេចក្ដីក្រោធ ឱ្យតាំងស្មារតីទុកឱ្យមាំមួន កុំបណ្ដោយជាប់តាមសេចក្ដីប្រព្រឹត្តិទោសរបស់វា គ្រប់ខណៈថាសេចក្ដីក្រោធនោះ ឡើងមកដល់រណ្ដាប់ណាហើយ ខឹងបន្តិច១ ត្រឹមថ្នាំងថ្នាក់អាក់អន់ឬក៏មួរម៉ៅក្ដៅក្រហាយអន្ទះអន្ទែងពេញទី បើឃើញថាក្ដៅក្រហាយពេញទិ ត្រូវសង្កត់ចិត្តទុក កុំឱ្យចិត្តគិតព្រោះចិត្តដែលពេញដោយកំហឹង រមែងគិតក្នុងផ្លូវអាក្រក់ សង្កត់មាត់ទុកកុំឱ្យមាត់និយាយ បើមាត់និយាយក្នុងខណៈចិត្តកំពុងក្រោធ ពាក្យសំដីដែលនិយាយ ក៏ជាពាក្យសំដីដែលអាក្រក់ សង្កត់ដៃជើងទុកកុំឱ្យធ្វើការ បើធ្វើការក៏ជាការអាក្រក់ ផលដែលហុចមកគឺសេចក្ដីទុក្ខ សេចក្ដីអន្តរាយ ក្ដៅក្រហាយស្ដាយក្រោយ, បើមានសតិដឹងខ្លួនជុំវិញយ៉ាងនេះ ក្នុងមិនយូរសេចក្ដីក្រោធ នឹងរម្ងាប់រលាយចិត្តនឹងត្រឡប់ជ្រះស្អាតតាមដើមតពីនោះ នឹងគិត និងនិយាយនឹងធ្វើអ្វី ក៏គិត និយាយ ធ្វើមិនបានផលអាក្រក់អ្វីឡើយ ។

**ម្នាលឧបាសក!** អារម្មណ៍ប្រភេទដទៃ១ ដូចសេចក្ដីលោភ សេចក្ដីឬស្យាជាដើម ក៏អាចនិងរម្ងាប់បានដោយវិធីនេះដូចគ្នា មនុស្សចំនួនច្រើនខ្វះសតីគ្រប់គ្រងចិត្ត កាលសេចក្ដីក្រោធជាដើម កើតឡើងហើយ ក៏បណ្ដោយឱ្យវារុករានទន្ទ្រានតទៅបានតាមស្រួល តាំងតែពីចិត្តរហូតដល់កាយ ចិត្តដែលត្រូវសេចក្ដីក្រោធគ្រប់សង្កត់ រមែងក្ដៅរោល

រាលនិងផឹតងងល់ មិនឃើញហេតុផលអ្វីទាំងអស់ក្លាយជាចិត្តយក្សចិត្តមារ ចិត្តដូច្នេះបង្គាប់ឱ្យមាត់ជេរ បង្គាប់ឱ្យកាយវាយដំច្រំធាក់ សម្លាប់កាប់សម្លេះយ៉ាងទារុណ ជួនកាលសម្លាប់បានរហូតមាតាបិតាបង្កើតខ្លួនថែមទៀត ជួនកាលក៏ទម្លាយវាយសំពងទ្រព្យរបស់ដ៏មានតម្លៃ ដែលខ្លួនធ្លាប់ស្រឡាញ់ កាលសេចក្តីក្រោធស្ងប់ កាលហេតុផលត្រឡប់មករកចិត្តហើយ នុ៎ះឯង គេនឹងខ្ទួចចិត្តគិតស្តាយក្រោយយ៉ាងពន់ពេក ខ្ទួចចិត្តគិតស្តាយក៏គ្មានប្រយោជន៍ ព្រោះជ្រុលជ្រួលហួសទៅហើយ នេះគឺទោសរបស់ការខ្វះសតិគ្រប់គ្រងចិត្ត អាចបង្កទុក្ខទោសច្រើនប្រការ,

**ម្នាលឧបាសក!** កាលលោកជ្រាបដូច្នេះហើយ ចូរព្យាយាមត្រួយត្រាចិត្តជានិច្ច មានសតិប្រចាំចិត្ត ក្នុងកាលមានអារម្មណ៍ផ្សេង ។ ជ្រែកចូលមក ព្យាយាម រក្សាចិត្តឱ្យនៅក្នុងសភាពផូរផង់ស្អាត ហើយលោកនឹងបានសុខសប្បាយចិត្តជាដរាប ” ។

ខ្ញុំបានទេសនា ប្រៀនប្រដៅមេស្រុកឱ្យមានចិត្តជ្រះថ្លា រសាយសេចក្តីសោកសៅហើយ ក៏ឃ្លុំចីពរចូលទៅក្នុងស្រុកជាមួយមេស្រុកភាពដែលបានឃើញកាលមកដល់ភូមិស្រុក ក៏គឺផ្ទះរបស់មេស្រុក បានក្លាយជាធ្យូង-ផេះអស់ទៅហើយ កូនប្រពន្ធរបស់មេស្រុកកំពុងអង្គុយយំសំឡឹងមើលគំនរធ្យូង ផេះ នៅក្រោមម្លប់ឈើជិតៗ នោះ មានអ្នកស្រុក

មកមើលហេតុការណ៍ និងសំដែងសហគតទុក្ខ និងមេស្រុកយ៉ាងច្រើន ។

" លោកនាយ " អ្នកស្រុកម្នាក់និយាយឡើង " ខ្ញុំបានខូចចិត្ត ណាស់ ក្នុងគ្រោះកម្មរបស់លោក តែនឹងធ្វើយ៉ាងណាបាន ណ្ហើយចុះ លោកមិនត្រូវព្រួយបារម្ភអ្វី ពួកយើងពេញចិត្តនឹងជួយទំនុកបំរុងលោក" ។

"អរគុណច្រើន ដែលមានបំណងល្អចំពោះខ្ញុំ" មេស្រុកបែរទៅ និយាយនិងគេដោយសំឡេងប្រក្រតី " តែមិនត្រូវខូចចិត្ត ខូចថ្លើមទេ ព្រោះវាជារបស់ធម្មតា ផ្ទះនេះមិនមែនរបស់យើង ប្រាក់មាសនិងទ្រព្យ សម្បត្តិគ្រប់យ៉ាង ដែលត្រូវភ្លើងឆេះជាមួយនិងផ្ទះនេះ ប្រាក់មាសនិងទ្រព្យ យើង យើងខ្ចីលោកមកប្រើមួយដងមួយគ្រា ក្នុងរវាងដែលយើងមកស្នាក់ អាស្រ័យនៅក្នុងលោកនេះប៉ុណ្ណោះ ម្ចាស់របស់គេគឺផែនដី គេត្រូវការ យករបស់គេទៅវិញ គេទើបប្រើភ្លើងមកយក យើងក៏ប្រគល់ឱ្យគេវិញ ទៅហើយ នឹងនៅរវល់ខូចចិត្តខូចថ្លើមធ្វើអ្វី ជីវិតនៅមាន ក៏រកបានថ្មី ទៀតនោះឯង " ។

ពាក្យនិយាយដ៏គួរស្តាប់របស់មេស្រុក ធ្វើឱ្យពពួកមហាជន ដែល មកមើលហេតុការណ៍ ស្តាប់ភាំងទាំងអស់គ្នា " លោកនាយ! ប្រ- សាសន៍លោកនិយាយគួរស្តាប់ចាប់ចិត្តណាស់ " កូនស្រុកម្នាក់និយាយ ទម្លាយសេចក្តីស្ងៀមស្ងាត់ឡើង ។

" មិនមែនសំដីរបស់ខ្ញុំទេ ជាសំដីរបស់លោកម្ចាស់នៃយើងទាំង-ឡាយអង្គនេះ " មេស្រុកនិយាយព្រមទាំងចង្អុលមកខ្ញុំ ។

" មិនមែនសំដីរបស់អាត្មា" ខ្ញុំនិយាយឡើងខ្លះ " តែជាព្រះវាចារបស់ព្រះបរមសាស្តាសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គជាអ្នកត្រាស់ដឹងសេចក្តីពិត ធម្មតារបស់សេចក្តីពិត រមែងគួរស្តាប់ជានិច្ច " ខ្ញុំបានទេសនាណែនាំអ្នកស្រុកក្នុងសាមគ្គីធម្ម ល្មមសមគួរហើយ ក៏វិលត្រឡប់ទៅកុដិវិញ ។

**គតិពេចន៍**

| | | |
|---|---|---|
| -សុខនិងទុក្ខ | មាននិងក្រ | ជាគូគ្នា |
| ជួបវេលា | គ្រាបានសុខ | កុំជឿស៊ប់ |
| ថាសុខពិត | និត្យនឹងនួន | រាប់រយកប្ប |
| គង់ក្រឡាប់ | ប្រែក្រឡាស់ | ជាទុក្ខវិញ ។ |
| -យើងត្រូវប្រាស់ | និងរាសព្រាត់ | សត្វសង្ខារ |
| ទីស្នេហា | អនិច្ចា | កុំសង្ស័យ |
| ដឹងខ្លួនមុន | ជាគុណគាប់ | មិនសង្រៃ |
| ដល់សម័យ | ថ្ងៃដែលទៅ | ទៅតាមកាល។ |

ឱម_ណាគ្រី

# អហឹសាធម៌

**លោកអ្នកអានទាំងឡាយ!** រហូតវេលាបីខែដែលនៅស្រុកកោកិណគ្រាម ខ្ញុំបានជួបប្រទះនឹងហេតុការណ៍ជាច្រើន សូម្បីជាភូមិស្រុកតូចប្រកបដោយគ្រួសារមិនច្រើនជាងចំនួនរយ តែពេញដោយមនុស្សប្រើគំនិត មានបុរសចាស់ម្នាក់ឈ្មោះ **កុម្ភក:** អាយុប្រមាណ ៦០ ឆ្នាំ នៅក្នុងភូមិស្រុកនេះ កាលវ័យកម្លោះធ្លាប់ទៅនៅក្រុងរាជគ្រឹះដែលជានគរសម្បូណ៌ដោយមេលទ្ធិម្ចាស់សាសនាច្រើនឆ្នាំ ពេលក្រោយបានមកតាំងទីកន្លែងនៅស្រុកភូមិនេះ **កុម្ភក:** បានទទួលសេចក្តីគោរពរាប់អានយ៉ាងខ្ពស់អំពីអ្នកស្រុក ព្រោះសំដីថ្វីមាត់ប្រាជ្ញារបស់គាត់ **កុម្ភក:** ជាអ្នកនាំផ្លូវចិត្តរបស់អ្នកស្រុក កាលខ្ញុំធ្វើដំណើរមកដល់ភូមិស្រុកនេះនិងនៅប្រចាំរហូត ៣ ខែនៃវស្សាកាល គាត់ក៏បានក្លាយជាគូសន្ទនាគួរខ្លាចរបស់ខ្ញុំភ្លាម **កុម្ភក:** ព្រមដោយក្មួយប្រុសគាត់ម្នាក់ ចូលចិត្តទៅរកខ្ញុំស្ទើរគ្រប់ថ្ងៃរសៀល ហើយក៏សន្ទនាគ្នាក្នុងបញ្ហាផ្លូវធម៌ រហូតល្ងាចត្រជាក់ទើបលាត្រឡប់ទៅផ្ទះ ។

ក្នុងដើមដំបូងដែលខ្ញុំទៅដល់ **កុម្ភក:** សំដែងអាការ:មើលងាយក្រអឺតក្រអោងដាក់ខ្ញុំយ៉ាងច្បាស់លាស់ ព្រោះធម្មតាមនុស្សចាស់ដែលមានប្រាជ្ញា កាលឃើញមនុស្សកម្លោំងប្រហែលកូនប្រហែលក្មួយដូចរូបខ្ញុំ រមែងគិតវាយតម្លៃបន្ថោកមុនជាដរាប ដោយគិតអានស្មានថាមិនដល់ខ្លួន

តែក្រោយពីបានសន្ទនានឹងខ្ញុំតមកជាវេលាប្រហែលកន្លះខែ គាត់ក៏កើតសេចក្ដីស្រឡាញ់និងគោរពខ្ញុំយ៉ាងពិតប្រាកដ ទាំងនេះមិនមែនព្រោះខ្ញុំបានប្រើកលកិច្ចល្បិចឧបាយអ្វីឬក៏និយាយអែបអបសម្របចាក់បណ្ដោយអ្វី តែព្រោះខ្ញុំនិយាយសេចក្ដីពិត តាមក្រមក្រឹត្យពុទ្ធធម៌ នឹងគេប៉ុណ្ណោះ តាមពិតសេចក្ដីត្រូវផ្លូវប្រសើរមានជាដរាប តែមនុស្សមិនយល់មិនស្គាល់សេចក្ដីពិត ទើបជជែកប្រកែកគ្នា ខ្ញុំមិនជជែកប្រកែកប្រកាន់នឹង **កុម្ពកៈ** ខ្ញុំមិនសរសើរបញ្ចោរ **កុម្ពកៈ** ព្រោះការជជែកប្រកែកនិងជំទាស់ កើតពីការប្រកាន់ទិដ្ឋិមានះ ខ្ញុំមិនសរសើរបញ្ចោរគេ ព្រោះសេចក្ដីសរសើរបញ្ចោរកើតពីការខ្លាច តែខ្ញុំនិយាយទៅតាមសេចក្ដីពិត នេះគឺគោលសន្ទនាធម៌ដែលព្រះពុទ្ធអង្គទ្រង់អនុវត្តមក ។

" ព្រះគុណម្ចាស់ " បុរសជរា **កុម្ពកៈ** ផ្ដើមសន្ទនានឹងខ្ញុំក្នុងថ្ងៃរសៀលមួយ " ការសម្លាប់សត្វតើបាបឬទេ ? " សំនួររបស់គាត់ឱ្យខ្ញុំនឹងប្លែកក្នុងចិត្ត ព្រោះគាត់មិនគួរនឹងសួរប្រស្នាងាយៗ យ៉ាងនេះការសម្លាប់សត្វនរណាៗ ក៏រមែងឃើញថាជាបាបទាំងអស់ តែជួនកាលអាចជារណ្ដៅធ្លាក់ ទាក់ខ្ញុំឱ្យធ្លាក់ក៏អាចថាបាន ព្រោះ **កុម្ពកៈ** វាងវៃណាស់ មនុស្សក្នុងភូមិស្រុក មិនមាននរណាហ៊ានជជែកយកឈ្នះគាត់បានឡើយ តែក្នុងទីបំផុតខ្ញុំក៏ឆ្លើយទៅតាមគោលថា " ការសម្លាប់សត្វជាអំពើបាបពិតប្រាកដ " ។

" សន្មតថា យើងមិនបានចុះដៃសម្លាប់ខ្លួនឯង តែប្រើឱ្យអ្នកដទៃសម្លាប់ តើបាបឬទេ ? " ។

" បាបដូចគ្នា "

" សន្មតថា យើងមិនបានសម្លាប់ខ្លួនឯង ទាំងមិនប្រើឱ្យនរណាសម្លាប់ តែយើងធ្វើការខ្លះដែលជាអំពើទំនុកបំរុងឱ្យគេសម្លាប់ដោយផ្លូវអមយ៉ាងនេះ តើបាបឬទេ ? "

" បាបដូចគ្នា " ខ្ញុំឆ្លើយ

**កុម្ភកៈ** ញញឹមយ៉ាងបានការ ហើយក៏ពោលយ៉ាងម៉ឺងម៉ាត់ថា "បើយ៉ាងនោះ លោកម្ចាស់ក៏ធ្វើបាប់រាល់ថ្ងៃនោះឯង "

" អាត្មាធ្វើបាបយ៉ាងម៉េច ? " ខ្ញុំសួរយ៉ាងមិនយល់

" ក៏លោកជាអ្នកបរិភោគសាច់សត្វរាល់ថ្ងៃនេះឯង "

" ការបរិភោគសាច់សត្វជាបាបផងឬ ?

" ជាបាបយ៉ាងពិតប្រាកដ "

"បាបយ៉ាងណា អធិប្បាយឱ្យអាត្មាស្ដាប់បន្តិចមើល អាត្មាបរិភោគសាច់មកយូរហើយ តែមិនធ្លាប់គិតសោះឡើយថាជាអំពើបាប " ។

"លោកម្ចាស់ ក៏ព្រមរ៉ាប់រងហើយមិនមែនឬថាការសម្លាប់សត្វខ្លួនឯងក្ដី ប្រើឱ្យគេសម្លាប់ក្ដី ក៏សុទ្ធតែបាប ការបរិភោគសាច់សត្វនេះជាការជួយទំនុកបំរុងឱ្យគេសម្លាប់សត្វយ៉ាងពិតប្រាកដ " **កុម្ភកៈ**

និយាយយ៉ាងមុតមាំប្រាកដក្នុងចិត្ត ។

" អាត្មានៅមើលមិនឃើញសោះឡើយថា ជាការជួយទំនុកបំរុងគេឱ្យសម្លាប់ " ។

បុរសចាស់សើចយ៉ាងបានផ្លូវ ហើយពោល " ក៏លោកម្ចាស់មិនគិតឬទេថា ព្រោះមានការស៊ីទើបមានការសម្លាប់ ព្រោះលោកឆាន់សាច់ទើបគេសម្លាប់ បើគ្មានអ្នកស៊ី ក៏គ្មានអ្នកសម្លាប់ ព្រោះដូច្នោះ ការស៊ីទើបជាការទំនុកបំរុងការសម្លាប់ ដូច្នេះលោកម្ចាស់ដែលឆាន់សាច់សត្វក៏ឈ្មោះថាធ្វើបាបដែរ " ។

" ម្នាលឧបាសក! ក្នុងរឿងនេះ មានមនុស្សទាក់ទងគ្នា ៣ នាក់ គឺអ្នកសម្លាប់ម្នាក់ អ្នកទទួលទិញយកទៅស៊ីម្នាក់ អ្នកទទួលតពីនោះយកទៅស៊ីម្នាក់ សូមហៅងាយៗថា មនុស្សទី ១ មនុស្សទី ២ មនុស្សទី ៣ បើមនុស្សទី ៣ ទៅប្រាប់ប្រងព្រមព្រៀងមនុស្សទី ២ មនុស្សទី ២ ទៅប្រាប់ប្រងព្រមព្រៀងនឹងមនុស្សទី ១ យ៉ាងនេះ មនុស្សទាំង ៣ នាក់ បាបពិតប្រាកដ ព្រោះព្រមព្រៀងគ្នាយ៉ាងច្បាស់លាស់ តែបើមនុស្សទី២ ទៅទំនុកបំរុងឱ្យមនុស្សទី ១ សម្លាប់សត្វ ហើយទិញយកសាច់នោះមកធ្វើស៊ីជាចំណែកខ្លួននិងគ្រួសារ មនុស្សទី៣ មិនដឹងរឿងរ៉ាវអ្វី ដើរ។ ទៅមនុស្សទីពីរឃើញនឹងអាណិត ទើបបែងសាច់នោះមកឱ្យទានខ្លះ មនុស្សទី ៣ ក៏ទទួលទៅបរិភោគល្មមរស់មួយពេល យ៉ាងនេះ អាត្មា

និង ព្រះភិក្ខុទាំងឡាយក្នុងព្រះពុទ្ធសាសនា ប្រៀបបាននឹង មនុស្សទី ៣ ក្នុងវេលាព្រឹក អាត្មាស្ពាយបាត្រដើរទៅតាមចន្លោះផ្ទះ ដោយតាំងចិត្តថា នឹងទទួលអាហារពីអ្នកចិត្តបុណ្យមកបរិភោគ ល្មមញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅមួយថ្ងៃៗ អ្នកស្រុកនាំអាហារប្រភេទណាមកដាក់ក្នុងបាត្រ ក៏ទទួលយកដោយការសង្រួម មិនដែលគិតថា សូមឱ្យអ្នកស្រុកនាំអាហារប្រភេទនោះៗ មកដាក់បាត្រ កាលបានអាហារល្មមសមគួរហើយ ក៏ត្រឡប់ចេញមកឆាន់ បានរបស់ណាក៏ឆាន់របស់នោះ បានអាហារល្អក៏មិនត្រេកអរ បានអាហារអាក្រក់ក៏មិនខូចចិត្ត តាំងចិត្តបរិភោគតែល្មមកែសេចក្ដីស្រេកឃ្លាន ព្រះពុទ្ធជាម្ចាស់ត្រាស់ថា សេចក្ដីឃ្លានជារោគធំមួយ ថ្នាំកែរោគឃ្លាន ក៏គឺអាហារ អាត្មាបរិភោគអាហារដូចគ្នានឹងបរិភោគថ្នាំ កាលរោគឃ្លានបាត់ហើយក៏ឈប់ភ្លាម ។

អាត្មាមិនដឹង មិនឃើញ មិនបានឮឡើយថា គេសម្លាប់សត្វនៅទីណា ពីកាលណា ទាំងមិនបានគិតថា គេនឹងសម្លាប់ដើម្បីអាត្មាដោយចំពោះ កាលអាត្មាបានឃើញគេសម្លាប់ បានឮគេសម្លាប់និងដឹងថាគេសម្លាប់ដើម្បីអាត្មាដោយចំពោះ អាត្មានឹងមិនបរិភោគដោយដាច់ខាត់ បើនៅតែបរិភោគនឹងខុសពុទ្ធប្បញ្ញត្តិពិតប្រាកដ កាលអាត្មាប្រតិបត្តិខ្លួនដូច្នេះ និងហៅថា បាបយ៉ាងណា ? ” ។

“ ណេក្ខ៎យចុះ សូម្បីលោកម្ចាស់ មិនទាក់ទងនឹងបាប ព្រោះមិន

បានធ្វើបាបដោយកាយ វាចា ចិត្ត ដោយត្រង់ក៏ដោយ លោកម្ចាស់ក៏ត្រូវឈ្មោះថាបាបក្នុងការបរិភោគរបស់ដែលមិនបរិសុទ្ធ " បុរសចាស់ ក៏នៅការពារកៀបក្រាញ និងយោបល់របស់គាត់ ។

" របស់មិនបរិសុទ្ធយ៉ាងម៉េច ? " ខ្ញុំសួរ

" សន្មតថា បុរសម្នាក់ទៅប្លន់សម្លាប់ម្ចាស់ទ្រព្យយករបស់គេ មកប្រគេនលោកម្ចាស់ លោកម្ចាស់ក៏ដឹងហើយថារបស់នោះ គេបានមកពីការប្លន់ មិនបរិសុទ្ធតែលោកក៏នៅតែទទួលរបស់មិនបរិសុទ្ធនោះយ៉ាងនេះ និងឈ្មោះថា លោកប្រតិបត្តិប្រពៃឬ? លោកម្ចាស់នឹងរួចចាក បាបឬ?"។

" បើដឹងថា របស់នោះគេប្លន់សម្លាប់ម្ចាស់ទ្រព្យ នាំយកមកឱ្យហើយនៅតែទទួលដោយចិត្តត្រេកអរក៏មិនរួចពីបាប ព្រោះប៉ុនគ្នានិងការជួយទំនុកបំរុងចោរកម្ម ត្រេកអរក្នុងបាបកម្មនោះ " ។

" បើយ៉ាងនោះ ការដែលលោកម្ចាស់បរិភោគសាច់ក៏បាប ព្រោះថារបស់មិនបរិសុទ្ធ ជារបស់បានមកពីការប្លន់ សម្លាប់ជីវិតរាងកាយរបស់សត្វដទៃ មិនមានសត្វណាព្រមប្រគល់សរីរៈរាងកាយរបស់ខ្លួន ឱ្យដល់មនុស្សងាយៗ កាលមនុស្សនឹងសម្លាប់វាបាន វាខំតស៊ូ រើបំរះរហូតអស់សមត្ថភាព កាលទ្រាំនឹងកម្លាំងរបស់មនុស្សមិនបាន ទើបព្រមស្លាបដោយកំហឹង ដោយគំនុំព្យាបាទចងអាឃាតប្រចាំចិត្តយ៉ាងខ្លាំងក្លា ព្រោះដូច្នោះ សាច់សត្វគ្រប់ប្រភេទ ដែលលោកបរិភោគ ទើបឈ្មោះថា

បានមកដោយការប្លន់ ជារបស់មិនបរិសុទ្ធ កាលលោកម្ចាស់ឆាន់របស់មិនបរិសុទ្ធដូច្នោះ នឹងមិនឈ្មោះថាបាបដូចម្ដេចកើត ? ” ។

ហេតុផល របស់បុរសចាស់មុះមុតគួរស្ដាប់ណាស់ តែបើមិនធ្លាប់គិតពីមុនមក ក៏អាចនិងទាល់ច្រកចំពោះហេតុផលរបស់គាត់បាន តែបញ្ហាដូច្នេះ ជាទីច្បាស់លាស់ចំពោះខ្ញុំមកយូរហើយ ទើបឆ្លើយទៅគាត់បានយ៉ាងងាយស្រួល ។

**ម្នាលឧបាសក!** បាបឬបុណ្យនៅនឹងចិត្តជាសំខាន់ បើចិត្តមិនត្រេកអរក្នុងបាប សូម្បីត្រូវតែបង្គាប់បង្ខំឱ្យធ្វើបាប ក៏មិនជាបាបឬបាបតិចចុះ តែបើចិត្តត្រេកអរក្នុងបាប សូម្បីមិនធ្វើបាបខ្លួនឯង បានដឹងដំណឹងថាគេធ្វើបាបហើយត្រេកអរតាមគេ ក៏ជាបាបដែរ ។

ពិតមែនហើយ សាច់ដែលអាត្មាបរិភោគជារបស់បានមកពីការប្លន់រិបជាន់ជីវិតគេ ជារបស់ចោរ អាត្មាក៏ដឹងហើយថា គេប្លន់មកពីសត្វ តែអាត្មាមិនដែលត្រេកអរក្នុងការបានទទួលសាច់នោះ មិនដែលត្រេកអររីករាយចិត្តក្នុងការបរិភោគសាច់នោះ ទាំងមិនដែលពេញចិត្តចំពោះការដែលគេសម្លាប់យកសាច់នោះមកបាន មិនដែលពេញចិត្តគិតសរសើរអ្នកសម្លាប់ ផ្ទុយទៅវិញអាត្មាតែងនឹកអាណិតសត្វដែលជាម្ចាស់សាច់នឹកគត់ស្លុតរន្ធត់រំភើបចំពោះការធ្វើទារុណកម្មរបស់អ្នកសម្លាប់ តែត្រូវ

បរិភោគដោយសេចក្តីចាំបាច់ បរិភោគដោយសេចក្តីសង្វេគស្លុតចិត្តដូចមាតាបរិភោគសាច់កូនរបស់ខ្លួនក្នុងកន្តារមាគ៌ា ។

**ម្នាលឧបាសក!** អាត្មានឹងនិទានរឿងមួយឱ្យស្តាប់ ក្នុងអតីតកាល មានប្តីប្រពន្ធពីរនាក់ធ្វើដំណើរឆ្លងកាត់សមុទ្រខ្សាច់ ច្រើនថ្ងៃកន្លងផុតទៅ ក៏មិនមានផ្លូវនឹងឆ្លងផុតសមុទ្រខ្សាច់សោះ ស្បៀងអាហារក៏អស់រលីង សេចក្តីស្រេកឃ្លានព្រោះគ្មានអាហារចូលពោះបានគ្រប់សង្កត់ ធ្វើឱ្យបុរសជាបិតាគិតនឹងសម្លាប់កូនរបស់ខ្លួនសុិ កាលពិគ្រោះពិភាក្សានឹងភរិយា។ ក៏ជំទាស់យ៉ាងម៉ឺងម៉ាត់ព្រោះមាតាចិត្តទន់អាណិតកូនមិនហ៊ានធ្វើដូច្នោះ សូម្បីខ្លួនត្រូវស្លាប់ក៏ដោយចុះ តែគំលានមិនអាចធ្វើឱ្យស្វាមីអត់ធនតទៅទៀតបាន យប់មួយកាលភរិយាដេកលក់លង់ហើយ បុរសប្តីបានសំឡាប់កូនតូចអារសាច់ទុក កាលភរិយាភ្ញាក់ឡើងឃើញកូនតូចបាត់ទៅ នឹងឃើញសាច់យ៉ាងច្រើនក៏តក់ស្លុតរន្ធត់ចិត្ត មើលទៅជុំវិញខ្លួន មិនឃើញកូន ឃើញតែសមុទ្រខ្សាច់ដាច់កន្ទុយភ្នែក នាងក៏ដឹងបានភ្លាមថា ស្វាមីបានសម្លាប់កូនតូចទៅហើយ នាងក៏ទៅជាខ្យល់ដួលសន្លប់ភ្លាម កាលភ្ញាក់ឡើង ក៏យំរៀបរាប់ដល់កូនស្ទើរដាច់ខ្យល់ស្លាប់ ដំបូងនាងមិនព្រមប៉ះសាច់កូន ស្វាមីបរិភោគតែម្នាក់ឯង កាលត្រូវគំលានគ្របសង្កត់ខ្លាំងទើបព្រមសុិ តែគ្រប់គ្រាដែលលើកសាច់កូនមកនឹងសុិនាងក៏

យំរៀបរាប់បណ្ដើរ ដោយសេចក្ដីស្រឡាញ់អាណិតអាល័យកូន ស៊ីសាច់កូនដោយទឹកភ្នែកគ្រប់គ្រា រហូតឆ្លងផុតសមុទ្ទខ្សាច់ ។

**ម្នាលឧបាសក!** ក្នុងខណៈ ដែលបរិភោគសាច់ អាត្មាបណ្ដុះការដឹងច្បាស់កើតឡើងដូចគ្នា នឹងការដឹងរបស់ម្ដាច់ ដែលស៊ីសាច់កូនក្នុងសមុទ្ទខ្សាច់នោះបរិភោគដោយសេចក្ដីអាណិតសង្វេគ បរិភោគដោយសេចក្ដីចាំបាច់ខានមិនបានពិតៗ កាលបើដូច្នេះ ចិត្តរបស់អាត្មាក៏មិនត្រេកអរក្នុងបាបសូម្បីតូចមួយ តើឱ្យអាត្មាទទួលបាបយ៉ាងម៉េច ? ”

ពាក្យអធិប្បាយ ព្រមទាំងនិទានរបស់ខ្ញុំបានផល បុរសចាស់យល់ឃើញស្របភ្លាម “ ខ្ញុំមិនដែលស្ដាប់អត្ថាធិប្បាយប្រកបដោយហេតុផលច្បាស់លាស់ងាយយល់យ៉ាងនេះ មកពីមុនទេ ទើបសំគាល់យល់យ៉ាងស្និតស្នាញថា ការស៊ីសាច់សត្វសុទ្ធតែបាតដោយប្រការទាំងពួង តែដែលពិតនោះស៊ីឱ្យបាបក៏បាន ស៊ីមិនឱ្យបាបក៏បាន វាសំខាន់នៅត្រង់ចិត្តនេះឯង ” តាំងពីនោះមក **កុម្ភកៈ** បុរសជរាអ្នកនាំផ្លូវចិត្តរបស់អ្នកស្រុក **គោកិលាគ្រាម** ក៏បែរមកគោរពគប់រកខ្ញុំដោយសុទ្ធចិត្ត ។

# ចាកកោកិលាគ្រាម

**លោកអ្នកអានទាំងឡាយ!** ក្នុងទីបំផុតខ្ញុំក៏ចេញចាក ភូមិស្រុក **កោកិលាគ្រាម** ពួកអ្នកស្រុកតាមជូនដំណើរខ្ញុំអស់រយៈផ្លូវប្រមាណកន្លះយោជន៍ ហើយក៏លាត្រឡប់ទៅវិញ គ្រប់គ្នាមានទឹកភ្នែកហូរជោកមុខ ដោយសេចក្ដីរលឹកនឹកអាល័យដល់ខ្ញុំ តាមពិត ខ្ញុំមិនមែនជាញាតិសាលោហិតបងប្អូនពង្សផៅរបស់គេទេ តែមនុស្សគ្រប់គ្នាក្នុងភូមិស្រុកនេះក៏ស្រឡាញ់គោរពរាប់អាន់ខ្ញុំដោយសុទ្ធចិត្ត មិនព្រមឱ្យខ្ញុំចេញចាកឃ្លាតពីគេ ចង់ឱ្យខ្ញុំនៅជាមួយរហូតអវសានជីវិត តែខ្ញុំនៅនឹងពួកគេរហូតទៅមិនបាន ព្រោះនាទីរបស់ខ្ញុំ គឺការធ្វើដំណើរទៅក្នុងលោកដ៏ធំទូលាយដូចបក្សីតូចដែលហើរទៅក្នុងនភាកាស ដូចត្រីហែលមុជទៅមកក្នុងមហាសមុទ្ទ សេរីភាពក្នុងការធ្វើដំណើរត្រេចពនេចរ គឺកំពូលសេចក្ដីប្រាថ្នារបស់ខ្ញុំ សេចក្ដីក្លាហានដាច់ខាតមិនខ្លាចស្លាប់ គឺជាពាហនៈ ( យានជំនិះ ) នាំខ្ញុំទៅ, " សេចក្ដីល្អ " ជាគ្រឿងក្រោះ ឬអាវុធ ដែលខ្ញុំប្រើការពារខ្លួនរហូតមក ព្រោះ " សេចក្ដីល្អ " នេះឯងមនុស្សដែលមកស្គាល់ខ្ញុំ ទើបស្រឡាញ់ខ្ញុំ សុខកាយសប្បាយចិត្តកាលខ្ញុំនៅជាមួយផង អាល័យស្រឡាញ់កាលខ្ញុំបែកឃ្លាតទៅ សេចក្ដីល្អនៅទីណា? សេចក្ដីល្អនៅក្នុងខ្លួនមនុស្សគ្រប់គ្នា សេចក្ដីអាក្រក់ក៏នៅក្នុងខ្លួនយើងគ្រប់គ្នា គ្រប់មនុស្សមានសេចក្ដីល្អ សេចក្ដីអាក្រក់ប៉ុនគ្នា តែ

ហេតុអ្វី ទើបមនុស្សនេះល្អ ? មនុស្សនេះអាក្រក់? ព្រោះមនុស្សល្អ គេឆ្លាត គេលាក់ទុកសេចក្តីអាក្រក់ ហើយគេយកតែសេចក្តីល្អចេញមកប្រើ យកតែសេចក្តីល្អចេញមកអួតអ្នកដទៃ គេគិតល្អចំពោះអ្នកដទៃ និយាយល្អចំពោះអ្នកដទៃ ធ្វើល្អចំពោះអ្នកដទៃ អ្នកដទៃទើបស្រឡាញ់គេ, មនុស្សអាក្រក់ជាមនុស្សល្ងង់ គេលាក់សេចក្តីល្អទុក យកតែសេចក្តីអាក្រក់សាមាន្យបញ្ចេញមកប្រើ បញ្ចេញតែសេចក្តីអាក្រក់មកអួតអ្នកដទៃ គិតអាក្រក់ចំពោះអ្នកដទៃ និយាយអាក្រក់ចំពោះអ្នកដទៃ ធ្វើអាក្រក់ចំ-ពោះអ្នកដទៃ មនុស្សទាំងឡាយទើបស្អប់ខ្ពើមគេ គេក្លាយជាបន្លាក្នុងសង្គមមនុស្ស ។

**លោកអ្នកអាន!** មនុស្សគ្រប់គ្នាចង់ឱ្យអ្នកដទៃស្រឡាញ់ខ្លួន ចង់ឱ្យអ្នកដទៃនិយមសរសើរចូលចិត្តខ្លួន ហើយក៏ធ្វើឱ្យគេស្រឡាញ់ខ្លួន និ-យមខ្លួនដោយវិធីផ្សេងៗ ប្រើអំណាចបង្គាប់បង្ខំខ្លះ ប្រើទ្រព្យល្បួងលោមខ្លះ ប្រើគាថាអាគមបង្គាប់ខ្លះ បួងសួងទេពតាអាទិទេពឱ្យជួយបណ្តាលវិធីខាងក្រៅ តែមិនបានលទ្ធផលដោយបរិបូណ៌ទេ ព្រោះវិធីនោះ ជាវិធីខាងក្រៅ សេចក្តីស្រឡាញ់ដែលកើតពីវិធីទាំងនោះ ជាសេចក្តីស្រ-ឡាញ់សើៗ ស្រាយៗ ឃ្លេងឃ្លោង មិនគង់វង្សបឹងថេរ, វិធីដែលល្អយ៉ាងបំផុត គឺ " **សេចក្តីល្អ** " គិតល្អចំពោះគេ និយាយល្អចំពោះគេ ធ្វើល្អចំពោះគេ ហើយគេនឹងស្រឡាញ់ គោរពរាប់អានយើងយ៉ាង

ជ្រាលជ្រៅ និងនៅស្ថិតស្ថេរជរាបទៅ ខ្ញុំប្រើសេចក្តីល្អនេះឯងជាអាវុធការពារខ្លួន បានទទួលសិរីជ័យមង្គលលទ្ធផលល្អរហូតមក ផ្លូវដ៏យូរនិងវែងឆ្ងាយ ដែលខ្ញុំឆ្លងកាត់ត្រេចចរមក ។

**លោកអ្នកអាន !** កាលបែកឃ្លាតពីអ្នកស្រុកកោកិលាគ្រាមមក ខ្ញុំក៏នៅគិតដល់ពួកគេ ទាំងនេះក៏ព្រោះ " **សេចក្តីល្អ** " របស់ពួកគេនោះឯង តែទោះយ៉ាងហ្នឹងក៏ដោយ ខ្ញុំក៏ខំសង្កត់ចិត្តបំភ្លេចពួកគេ ព្រោះសេចក្តីអាល័យគិតដល់ មិនថាគិតដល់មនុស្ស គិតដល់ទីកន្លែង ឬគិតវត្ថុ រមែងធ្វើចិត្តឱ្យស្វិតស្រពោនក្រៀមក្រំ មិនសប្បាយ ក្នុងទីបំផុតពាក្យថា " កោកិលាគ្រាម " ក៏សន្សឹមៗ ហើរបាត់ទៅពីសេចក្តីទ្រទ្រង់ចាំ ខ្ញុំធ្វើដំណើរតទៅយ៉ាងមានសេរីភាព បែរមុខសំដៅទៅកាន់នគររាជគ្រឹះ ជាព្រះរាជធានីនៃមគធរដ្ឋក៏ល្បីល្បាញ ។

ក្នុងរវាងផ្លូវ ខ្ញុំបានជួបនិងមនុស្សច្រើនចំពូក ខ្ញុំបានឈប់សន្ទនានិងគេ សំដែងពុទ្ធធម៌ដល់គេ ញ៉ាំងគេឱ្យរីករាយក្នុងសម្មាបដិបត្តិ ហើយក៏ធ្វើដំណើរតទៅ ។

**ព្រះអាទិត្យជ្រេបន្តិច** ថ្ងៃមួយក្នុងដើមរដូវគិម្ហន្តនោះឯង ខណៈដែលខ្ញុំកំពុងធ្វើដំណើរទៅយ៉ាងប្រញិបប្រញាប់ ដើម្បីឱ្យដល់ភូមិស្រុកមុនវេលាព្រលប់, អាកាសក្តៅពន់ពេក ដូចជាព្រះអាទិត្យបន្ថែមចំ-

នួន ៣ ដួងទៀត សូម្បីនខ្យល់បក់បោកមកខ្លះ ក៏ជាខ្យល់ពេញដោយចំហាយក្តៅរបស់កំដៅព្រះអាទិត្យ ព្រមទាំងការស្រេកទឹកធ្វើឱ្យអស់កម្លាំងខ្លាំងណាស់ ទើបគេចូលទៅសម្រាកនៅក្រោមម្លប់ឈើក្បែរផ្លូវ លុះអង្គុយមិនយូរប៉ុន្មានក៏ងោកងុយអង្គុយលក់ទៅ ដោយខ្សោយកម្លាំង កាលភ្ញាក់ឡើងក៏ដឹងថាថ្ងៃល្ងាចណាស់ហើយ ក្រោកឡើងមើលទៅជុំវិញខ្លួន ក៏បានឃើញភាពដ៏គួរតក់ស្លុតរន្ធត់ខ្លាចនៅចំពោះមុខតែម្តង គឺខ្លាធំ មួយកំពុងក្រាបហាមាត់នៅខាងមុខខ្ញុំ ចំហាយប្រហែលបីម៉ែត្រប៉ុណ្ណោះ ។

**លោកអ្នកអានជាទីមេត្រី!** ខ្ញុំប្រាប់មិនកើតដែលថា វេលានោះខ្ញុំមានសតិអារម្មណ៍យ៉ាងណា តែដែលពិតយ៉ាងបំផុតនោះ ក៏គឺតក់ស្លុតរន្ធត់ខ្លាច ទាល់តែរឹតខ្លួន អាវុធតូចមួយក៏គ្មានជាប់នឹងខ្លួន នឹងរត់គេចទៅក៏មិនទាន គិតថាវារៈចុងបំផុងរបស់ខ្ញុំមកដល់ហើយ ក្នុងទីបំផុតនៅក្នុងមាត់ខ្លានេះឯង ខ្លាធំនោះអង្គុយហាមាត់សំឡក់សំឡឹង មើលខ្ញុំយ៉ាងស្រេកឃ្លាន កាលមិនឃើញមានផ្លូវដទៃ ដែលនឹងយករួចខ្លួនបាន ទើបខ្ញុំប្រើវិធីដែលព្រះអរិយបុគ្គលទាំងឡាយ ប្រតិបត្តិ ត១គ្នាមក ខ្ញុំខំប្រមូលប្រមុំផ្តុំសេចក្តីរឹងប៉ឹងទាំងអស់មកទុកនៅក្នុងចិត្ត តាំងចិត្តនឹងនួនហើយអធិដ្ឋានក្នុងចិត្តថា " ខ្ញុំលះភេទឃរាវាស ចេញបួសក្នុងព្រះពុទ្ធ-

សាសនា ឧទ្ទិសចំពោះព្រះបរមសាស្តា ខ្ញុំលះបង់ហើយនូវរបស់គ្រប់យ៉ាងរួមទាំងជីវិតរាងកាយនេះ បើក្នុងជាតិមុន ខ្ញុំធ្លាប់សាងកម្មជាប់ពៀរនឹងខ្លាធំនេះ សូមឱ្យខ្លាធំនេះ ចូលត្របាក់កាច់កខ្ញុំស៊ីជាអាហារចុះ ខ្ញុំពេញចិត្តធ្វើពលិកម្មជីវិតសងបំណុលចាស់ឱ្យអស់ទៅ តែបើថា ខ្ញុំមិនធ្លាប់មានកម្មមានពៀរទាក់ទងនិងខ្លានេះពីជាតិមុន សូមឱ្យខ្លានេះ ចូរគេចវៀសភៀសទៅតាមផ្លូវរបស់ខ្លួន ខ្ញុំក៏នឹងតាមផ្លូវរបស់ខ្ញុំតទៅ ” ។

**លោក-អ្នកអានប្រិយមិត្តទាំងឡាយ!** លុះខ្ញុំអធិដ្ឋានចប់ត្រឹមប៉ុណ្ណោះ ខ្លាធំនោះ ក៏លោតបាត់ទៅក្នុងព្រៃដូចជាអស្ចារ្យណាស់ ខ្ញុំដកដង្ហើមធូរដោយសេចក្តីត្រេកអរ ដូចមានអ្នកមកយកភ្នំធំចេញពីខ្លួនខណៈនោះ ខ្លួនខ្ញុំដូចជាស្លាប់ហើយកើតថ្មីទៀត ស្រវាបានបាត្រមកស្ពាយហើយ ខ្ញុំក៏ប្រញាប់ធ្វើដំណើតទៅ ដោយមិនបែរមើលខាងក្រោយឡើយ នេះជាគ្រាដំបូងដែលខ្ញុំបានជួបប្រទះសត្វសាហាវ និងយក្សរួចខ្លួនបានយ៉ាងមហាស្ចារ្យ តែក្នុងវេលាតមក ការពើបពះប្រទះភ័យដូច្នេះ ក៏ក្លាយជារឿងធម្មតាសម្រាប់ខ្ញុំ ។

កាលខ្ញុំមកដល់តំបន់មួយ ក៏ជាវេលាព្រលប់ហើយ ដោយសេចក្តីហត់នឿយ ខ្ញុំក៏កាត់ចិត្តស្នាក់នៅមួយយប់ក្នុងភូមិស្រុកនេះ មានខ្ទមដីមួយខ្នង តាំងនៅក្បែរផ្លូវខាងស្តាំដៃ មានពន្លឺភ្លើងចាំងចេញមកតាមទ្វារដែលបើក ខ្ញុំដើរតម្រង់ទៅកាន់ខ្ទមនោះ ដើម្បីសុំទឹកឆាន់បំបាត់

សម្រេក ហើយនឹងទៅរកទីស្នាក់ខាងក្រៅភូមិ បុរសម្ចាស់ខ្ទមអាយុកណ្ដាលមនុស្ស ឬកពារបែបក្មេងក្លាងបន្តិច តែគាត់ទទួលខ្ញុំដោយសេចក្ដីទន់ភ្លន់ពន់ពេក " សូមនិមន្តលោកម្ចាស់ ចូលមកសម្រាកខាងក្នុងសិន ខ្ញុំពេញចិត្តនឹងទទួលលោកតាមមានតាមបាន សូមនិមន្តគង់លើគ្រែនេះ ខ្ញុំនឹងទៅចាត់ចែងអ្វីមកទទួលលោក " ថាហើយគេក៏ដើរបាត់ទៅខាងក្រោយខ្ទម ហើយក៏ត្រឡប់មកព្រមដោយថាសអាហារ ។

"សូមលោកបរិភោគអាហារទាំងនេះតាមសប្បាយ" គេថាហើយក៏ដាក់ថាអាហាខាងមុខខ្ញុំ " ខ្ញុំមិនមានឱកាសបានទទួលសមណព្រាហ្មណ៍មកយូរហើយ រាប់ថាជាជោគដ៏ប្រសើររបស់ខ្ញុំ ដែលលោកចូលមកកាន់ខ្ទមខ្ញុំ " ។

" អរគុណច្រើនឧបាសក! តែលោកប្រហែលមិនជ្រាបទំនៀមទម្លាប់របស់សមណៈទេ ធម្មតាសមណៈរមែងមិនបរិភោគអាហារក្នុងវេលាវិកាល គឺតាំងថ្ងៃត្រង់រហូតថ្ងៃរះឡើយ អាត្មាជាសមណៈ ទើបមិនអាចបរិភោគអាហារឆ្លងសទ្ធារបស់លោកបាន ក្នុងវេលាយប់ដូច្នេះ " ។

បុរសម្ចាស់ផ្ទះ សំឡឹងមើលខ្ញុំយ៉ាងមិនពេញចិត្ត ហើយពោលថា "តែលោកក៏នឿយហត់នឹងឃ្លានច្រើន ខ្ញុំគិតថាទោះលោកបរិភោគអាហារក៏មិនជាខុសទាស់ខូចខាតអ្វីឡើយ " ។

"ពរមែន! ការបរិភោគអាហារ មិនមានសេចក្តីខូចខាងអន្តរាយអ្វី សេចក្តីខូចខាតមានត្រង់ថា អាត្មាល្មើសវិន័យរបស់សមណៈ ដែលព្រះ-បរមសាស្តាទ្រង់បញ្ញត្តិទុកមក " ។

" លោកម្ចាស់ដូចជាម៉ឺងម៉ាត់ចំពោះរបៀបវិន័យហួសពេកហើយ" ម្ចាស់ផ្ទះពោលញើម១ " តឹងរ៉ឹងពេញទៅក៏ធ្វើឱ្យខ្លួនឯងលំបាកណាស់លោក ខ្ញុំយល់ថា គ្រាចាំបាច់ដូច្នេះ គួរបន្ធូរបន្ថយវិន័យខ្លះ " ។

" **ម្នាលឧបាសក!** មនុស្សក្នុងលោកមានពីរជំពូក ជំពូកមួយទាញយករបៀបវិន័យចូលមករកខ្លួនប្រកាន់ខ្លួនជាសំខាន់ជាងរបៀបវិន័យ កាលខ្លួនប្រាថ្នានឹងធ្វើអ្វី ក៏ធ្វើទៅដោយមិនបាននឹងដល់របៀបវិន័យ មនុស្សជំពួកនេះ ជាអ្នកបំផ្លាញរបៀបរៀបរយ ច្បាប់ទម្លាប់ក្រឹត្យក្រមផ្សេង១ ដែលលោកបញ្ញត្តិតែងតាំងទុក ដើម្បីសេចក្តីសុខស្ងប់ក្នុងសង្គមមនុស្ស ក៏ត្រូវពួកនេះប្រទាញបំផ្លិចបំផ្លាញអស់ តែរាប់ថាជាគ្រោះល្អច្រើន ដែលមនុស្សជំពួកនេះមានចំនួនតិច បើមានច្រើន ច្បាស់ទម្លាប់ ក្រមក្រិត្យស្រុក ប្រទេស មុខជារលំរលាយអស់ ស្រុក ប្រទេស នឹងក្លាយជាផ្ទះដែលគ្មានផ្ទោងផ្ទាន សេចក្តីក្តៅក្រហាយចលាចលមុខជាកើតមានឡើងសង្គមមនុស្ស ។ មនុស្សមួយជំពូកចូលចិត្តបង្អោនខ្លួនចូលទៅរករបៀបវិន័យ កាន់របៀបវិន័យជាសំខាន់ជាងខ្លួន កាលនឹងធ្វើនឹងនិយាយអ្វី ត្រូវ

គិតមើលយ៉ាងសព្វគ្រប់ជាមុនថា ការធ្វើ ការនិយាយនោះ តើខុសទាស់នឹងរបៀបវិន័យត្រង់ណាឬទេ បើឃើញថាខុស គេមិនធ្វើជាដាច់ខាត សូម្បីខ្លួនបានទទួលសេចក្ដីលំបាកយ៉ាងណាក៏ព្រម, មនុស្សជំពូកនេះចាត់ជាអ្នកសាង ជាអ្នករក្សារបៀបរបស់សង្គម សង្គមណាមានមនុស្សប្រភេទនេះច្រើន សង្គមនោះនឹងមានតែសេចក្ដីត្រជាក់ត្រជំសុខស្ងប់រហូតទៅ ម្នាលឧបាសក! អាត្មាជាមនុស្សជំពួកក្រោយនេះ ការបរិភោគអាហារក្នុងវេលាវិកាលជាការជំទាស់វិន័យរបស់ព្រះបរមសាស្ដា ព្រោះដូច្នោះអាត្មាទើបមិនអាចធ្វើបាន បើនិយាយពីឃ្លានអាត្មាក៏ឃ្លានពន់ប្រមាណ តែពេញចិត្តជ្រើសរើសយកសេចក្ដីស្លាប់ល្អជាងការប្រព្រឹត្តិល្មើស ព្រះវិ-ន័យរបស់ព្រះបរមសាស្ដាចារ្យ ” ។

បុរសម្ចាស់ផ្ទះ អង្គុយនៅស្ងៀមអស់វេលាជាយូរ សំដីរបស់ខ្ញុំធ្វើឱ្យគេគិតរកហេតុផលខ្លះ “ លោកសមណៈដ៏ចំរើន! ” គេពោលឡើងក្នុងទីបំផុត “ កាលបានដឹងសេចក្ដីតាំងចិត្ត ដាច់ខាតរបស់លោកដែលនឹងរក្សាព្រះវិន័យក្រៃលែងជាងជីវិតដូច្នេះ ធ្វើឱ្យខ្ញុំកើតសេចក្ដីគោរពកោតក្រែងលោកឡើងជាទ្វេគុណ ខ្ញុំសូមអភ័យទោសដែលបានណែនាំបបួលឱ្យលោកបរិភោគអាហារ ព្រោះការមិនដឹងថា លោកជាមនុស្សម៉ឺងម៉ាត់ម្នាក់ដែលខ្ញុំបានជួបមក ” ។

**ម្នាលឧបាសក!** មនុស្សយើងកាលបានកាត់ចិត្តថានឹងរៀរអ្វីហើយ គួររៀរឱ្យប្រាកដ ទើបបានការ បើធ្វើលេងៗ ឆ្អិន! ឆៅៗ យកជាការមិនបានទេ អាត្មាបានសម្រេចចិត្តហើយថា ជាព្រះភិក្ខុ ក្នុងព្រះពុទ្ធសាសនា ក៏ត្រូវជាព្រះភិក្ខុដែលពិតប្រាកដ របៀបវិន័យ ក្រិត្យក្រមដែលធ្វើឱ្យខ្លួនជាព្រះភិក្ខុមានប៉ុន្មាន ត្រូវប្រតិបត្តិតាមឱ្យគ្រប់ទាំងអស់ទើបនឹងបានឈ្មោះថា ជាព្រះភិក្ខុពេញទី បើប្រតិបត្តិបានខ្លះ មិនបានខ្លះ អ្នកនោះ ក៏មិនឈ្មោះថាភិក្ខុបរិបូណ៌ឡើយ អ្នកណាប្រកាសខ្លួនថាជាព្រះភិក្ខុដែលបរិបូណ៌ ទាំងដែលខ្លួនធ្វើតាមរបៀបវិន័យក្រមក្រិត្យរបស់ព្រះភិក្ខុមិនបានពេញទីអ្នកនោះឈ្មោះថាកំពុងលលួងបោកបញ្ឆោតមហាជន ” ។

“ លោកសមណៈដ៏ចំរើន! ខ្ញុំយល់ស្របនឹងលោកគ្រប់ប្រការ តែនៅសង្ស័យថា របៀបវិន័យដែលព្រះភិក្ខុក្នុងព្រះពុទ្ធសាសនា ដូចលោកគប្បីប្រតិបត្តិនោះមានចំនួនប៉ុន្មានទៅ ? ” ។

“វិន័យដែលព្រះពុទ្ធអង្គទ្រង់បញ្ញត្តិទុកសម្រាប់ព្រះភិក្ខុ មាន២២៧សិក្ខាបទ ” បុរសម្ចាស់ផ្ទះ សំដែងសេចក្ដីប្លែកក្នុងចិត្តហើយថា “ ពីររយម្ភៃប្រាំពីរសិក្ខាបទ ! វិន័យអីច្រើនម្ល៉េះ ហើយលោកនឹងប្រតិបត្តិតាមឱ្យគ្រប់បរិបូណ៌បានយ៉ាងដូចម្ដេចទៅ ? ” ។

" អាត្មាប្រតិបត្តិតាមបានគ្រប់បរិបូណ៌យ៉ាងស្រួលងាយ កុំថាតែវិន័យត្រឹម ២២៧ សិក្ខាបទឡើយ សូម្បីនច្រើនជាងនោះដល់ ១០០ ដង អាត្មាក៏គង់ប្រតិបត្តិតាមបានទាំងអស់យ៉ាងសប្បាយងាយស្រួល " ។

" លោកសមណៈដ៏ចំរើន! លោកធ្វើឱ្យខ្ញុំកើតសេចក្តីសង្ស័យក្រៃលែងឡើង អាណិតប្រាប់ខ្ញុំផងថា លោករក្សាបានយ៉ាងណា ខ្ញុំជាឃរាវាសរក្សាសីលត្រឹម ៥ សិក្ខាបទ ក៏រក្សាសឹងមិនបាន " ។

" **ម្នាលឧបាសក!** សម្រាប់មនុស្សដែលតាំងចិត្តនឹងរក្សាហើយ ទោះមានប៉ុន្មានរយប៉ុន្មានពាន់សិក្ខាបទ គេក៏រក្សាទុកបាន តែសម្រាប់មនុស្សដែលមិនតាំងចិត្តនឹងរក្សា កុំថាតែប្រាំសិក្ខាបទឡើយ សូម្បីតែសិក្ខាបទមួយ ក៏រក្សាទុកមិនបាន, " **សេចក្តីតាំងចិត្តដែលនឹងរក្សា**" ឬ " **សេចក្តីតាំងចិត្តដែលនឹងវៀរ** " នេះឯង គឺតួ " **សីល** " តាមពិត ចំណែកសេចក្តីអាក្រក់ទាំងឡាយដែលលោកចែកទុកជា ៥ យ៉ាងខ្លះ ៨យ៉ាងខ្លះ ១០យ៉ាងខ្លះ ២២៧យ៉ាងខ្លះនោះ មិនមែនតួសីល គ្រាន់តែជាប្រភេទរបស់សេចក្តីអាក្រក់ ដែលលោកបរិយាយទុកឱ្យដឹងថានឹងត្រូវវៀរចាកអ្វីខ្លះប៉ុណ្ណោះ តួសីលដែលពិត គឺសេចក្តីតាំងចិត្តដែលនឹងវៀរចាកសេចក្តីអាក្រក់ផ្លូវកាយផ្លូវវាចា ឬដែលហៅថា " **វិរតិចេតនា** " ។ អាត្មានឹងប្រៀបធៀបឱ្យឃើញដូចតទៅនេះ សន្មតថា លោកជា

នាយគោបាល ចិញ្ចឹមគោតុក២២៧ តួ បើលោកត្រូវការរក្សាគោទាំងនេះទុកឱ្យនៅរួមគ្នាជាពួកក្នុងទីកន្លែងតែមួយ លោកអាចនឹងធ្វើបានពីរវិធី

**វិធីទីមួយ**- លោកត្រូវកាន់រំពាត់ ឬដំបងឈរយាមល្បាតចាំមើលថា គោណាកំពុងនឹងបែកចេញពីហ្វូង កាលឃើញហើយ លោកត្រូវរត់យ៉ាងប្រញាប់ទៅគៀងគោនោះឱ្យត្រឡប់ចូលហ្វូង ខណៈដែលគោនេះ ត្រឡប់ចូលហ្វូង គោដទៃទៀត ក៏ផ្ដើមចេញទៀត លោកត្រូវប្រញាប់រត់ទៅគៀងគោនោះ ជួនកាលក៏ចេញចាកហ្វូងម្ដងៗ ច្រើនៗ លោកត្រូវធ្វើការធូន់ រត់ទៅមកៗ ជុំវិញហ្វូងគោមិនបានឈប់ឈរ ។

**វិធីទីពីរ**-លោកមិនបាច់ទៅដេញគៀងគោមួយៗ ឱ្យលំបាកគ្រាន់តែបោះបង្គោលមួយធំយ៉ាងជាប់មាំរឹងប៉ឹង ហើយយកខ្សែចំណងគោទាំង២២៧ នោះមករួមចងទុកក្នុងកន្លែងតែមួយ ដោយវិធីនេះ លោកមិនរវល់រត់ទៅរត់មកគៀងគោនោះទេ លោកគ្រាន់តែឈរមើលនៅនឹងបង្គោលនោះម្ដងៗ ដរាបណាដែលបង្គោលនៅមាំមួនរឹងប៉ឹង ដរាបនោះគោមិនអាចទៅណាបានផ្ដេចផ្ដាសាដាច់ខាត ។

**ម្នាលឧបាសក!** គោដែលនិយាយមកអម្បាញមិញនេះប្រៀបដូចសីលឬរបៀវិន័យមួយយ៉ាងៗ គោលដែលចងគោតុកប្រៀបដូច "សេចក្ដីតាំងចិត្តវៀរចាកសេចក្ដីអាក្រក់ " ដែលហៅថា " វិរតិចេតនា"

បើលោកមានវិរតិចេតនាហើយមិនថា សីលនឹងមានប៉ុន្មានយ៉ាង លោកអាចរក្សាសីលនោះបានទាំងអស់ ដូច្នោះវិធីរក្សាសីលតាមពិតក៏គឺរក្សាចិត្តរបស់លោកខ្លួនឯង ចិត្តដែលត្រេកអរក្នុងបុណ្យក្នុងកុសល ស្អប់ខ្ពើមនឿយណាយចំពោះសេចក្ដីអាក្រក់គ្រប់ប្រភេទនោះឯង គឺចិត្តដែលមានសីល គោលឬបេះដូងសីលនៅត្រង់នេះឯង បើនឹងរក្សាសីលត្រូវរក្សានូវគោលឬបេះដូងរបស់សីលនេះ ក្នុងផ្លូវរដ្ឋប្រទេសព្រះមហាក្សត្របានទ្រង់ចេញព្រះរាជក្រិត្យព្រះរាជក្រមច្បាប់ ទុករក្សាសេចក្ដីសុខស្ងប់របស់ប្រទេសជាតិ បើនឹងរាប់ជាមាត្រាប្រការក៏មានចំនួនជារយជាពាន់មាត្រាជួនកាលប្រជារាស្ត្រ មិនទាំងដឹងថាមានច្បាប់អ្វីខ្លះផង មានប៉ុន្មានមាត្រាតែគេក៏អាចរស់នៅមួយគ្នាបានយ៉ាងស្ងប់ រាជបុរសនឹងមកចាប់គេទៅដាក់ពន្ធនាគាមិនបាន ព្រោះគេប្រតិបត្តិតាមច្បាប់ត្រឹមត្រូវ សេចក្ដីពិតជួនកាលគេមិនទាំងដឹងថា ច្បាប់មានអ្វីខ្លះ តែហេតុអ្វីទើបប្រតិបត្តិបានត្រូវ? ព្រោះគេប្រតិបត្តិត្រូវគោល ឬបេះដូងរបស់ច្បាប់ ច្បាប់ទាំងអស់មានគោលធំតែត្រឹម ប៉ុណ្ណោះគឺ “ **សុចរិត** ” និង “ **យុត្តិធម៌** ” កាលធ្វើអ្វី និយាយអ្វី សូមឱ្យសុចរិតនិងយុត្តិធម៌ចុះ ទោះលោកមិនដឹងមិនចេះច្បាស់អ្វីសោះ ក៏មិនមានថ្ងៃខុសច្បាស់ឡើយ ។

កាលខ្ញុំអធិប្បាយមកបានត្រឹមប៉ុណ្ណេះ បុរសម្ចាស់ផ្ទះ ក៏កើតសេចក្ដីគោរពជ្រះថ្លាចំពោះខ្ញុំយ៉ាងពិតប្រាកដ គេនិមន្តឱ្យខ្ញុំស្នាក់នៅមួយយប់

ក្នុងផ្ទះរបស់គេ ខ្ញុំឃើញថាគេនៅតែម្នាក់ឯង គ្មានប្រពន្ធកូនទើបព្រមព្រៀងស្នាក់នៅនឹងផ្ទះរបស់គេ ។

ក្នុងយប់ជ្រៅ យើងបានសន្ទនាគ្នាទៀតក្នុងបញ្ហាផ្សេងៗ បុរសម្ចាស់ផ្ទះបាននិយាយរឿងរ៉ាវជីវិតរបស់គេឱ្យខ្ញុំស្តាប់ ជីវិតគេលិចអណ្តែតសែតអញ្ចង់ លង់កញ្ចើ ច្រងាប់ច្រងិលណាស់ ខ្ញុំបានលួងលោមចិត្តគេដោយធម្មៈ ធ្វើឱ្យគេមានកម្លាំងចិត្តក្នុងការតស៊ូដើម្បីសេចក្តីរស់នៅដោយផ្លូវប្រពៃតទៅ គេបាននិយាយសភាពរបស់ភូមិស្រុកឱ្យខ្ញុំស្តាប់ផង ។

" លោកម្ចាស់ដ៏ចំរើន! ខ្ញុំព្រះករុណាឃើញថា នឹងនៅក្នុងភូមិស្រុកនេះតទៅទៀតមិនបានទេ, ខ្ញុំព្រះករុណាតាំងចិត្តថានឹងទៅនៅទីដទៃៗ ក្នុងពេលឆាប់ៗ នេះ " ។

" ម៉េចអញ្ចឹង ឧបាសក?" ខ្ញុំសួរ " របររកចិញ្ចឹមជីវិតនៅទីនេះក្រែងស្រួលបួលមិនមែនឬ? " ។

" ស្រួលបួលច្រើន ចំរើនគួរសម តែទោះដូច្នោះ ខ្ញុំព្រះករុណាក៏ត្រូវតែចេញទៅ ព្រោះមានព្រឹត្តិការណ៍ខ្លះ ដែលខ្ញុំព្រះករុណាមិនពេញចិត្តនៅភូមិស្រុកនេះ នឹងខ្ញុំព្រះករុណាមិនមានផ្លូវយកជ័យជំនះព្រឹត្តិការណ៍នោះបានផង " គេពោលហើយ យកដៃស្ទាបថ្ងាសយ៉ាងប្រើគំនិតសង្កេតមើលគេក៏នាំឱ្យមានចំណង់ចង់ដឹងរឿងតឹងចិត្តឆ្អិតឆ្អូវ ដែលជាហេតុឱ្យគេចង់ចេញពីទីនេះ ។

" ឧបាសក! បើលោកគិតថា អាត្មាជាអ្នកដែលល្មមទំនុកទុកចិត្តបាន ក៏សូមនិយាយឱ្យអាត្មាស្តាប់ផងជួនាលអាត្មាអាចមានមធ្យោបាយជួយដោះស្រាយបាន " ។

" អរគុណយ៉ាងខ្ពស់ ក្នុងគោលបំណងល្អរបស់លោកម្ចាស់ " ថាហើយគេក៏ខិតចូលមកជិតគ្រែខ្ញុំហើយនិយាយរឿងរបស់គេ ឱ្យខ្ញុំស្តាប់ដោយសំឡេងតិចៗ " លោកម្ចាស់ ! របស់មួយដែលខ្ញុំមិនចូលចិត្តក្នុងភូមិស្រុកនេះគឺ ខ្លួនមេស្រុកនោះឯងគេជាមេស្រុកស្តុកស្តម្ភ មានស្រែចំការច្រើន អ្នកស្រុកភូមិទាំងអស់ អាស្រ័យស្រែគេប្រកបរបរចិញ្ចឹមជីវិត ដោយបែងផលិតផលឱ្យគេបាក់កណ្តាលរាល់ៗឆ្នាំ ឆ្នាំខ្លះមានការធ្វើស្រែមិនបានផល អ្នកស្រុកត្រូវនៅក្នុងឋានៈលំបាក ព្រោះខ្វះស្រូវអង្ករទទួលទាន ត្រូវទៅខ្ចីបុលស្រូវអង្ករមេស្រុកមកចិញ្ចឹមប្រពន្ធកូនលុះដល់ឆ្នាំមុខផលិតផលស្រូវ ដែលបានមកក៏ល្មមតែសម្រាប់សងបំណុលមេស្រុកប៉ុណ្ណោះ អ្នកស្រុកខ្លះ បានក្លាយជាទាសៈ ( បាវព្រាវ ) របស់មេស្រុកយ៉ាងដាច់ថ្លៃ លោកម្ចាស់ដ៏ចំរើន! មេស្រុករបស់យើងខ្ញុំជាមនុស្សចិត្តសាហាវខ្មៅងងឹត ឥតមេត្តាករុណាអាណិតនរណាឡើយ គេក្រអឺតក្រអោងថា គេមានអំណាចនឹងមានទ្រព្យ មិនបាច់ពឹងពាក់អាស្រ័យនរណា គេចង់ធ្វើអ្វី ក៏ធ្វើតាមបំណងរបស់ខ្លួន មិនរវល់គិតថាពួកអ្នកស្រុកកើតទុក្ខក្តៅក្រហាយយ៉ាងណា ឱ្យតែខ្លួនគេស្តុកស្តម្ភសប្បាយ

ក៏ហើយគ្នា វេលានេះខ្ញុំព្រះករុណាដូចជាប់នៅក្នុងទ្រុង ឆ្នាំមុខសូមឱ្យមេឃភ្លៀងគ្រប់គ្រាន់ផងចុះ ខ្ញុំធ្វើស្រែបានស្រូវល្មមនឹងសងជំពាក់នាយស្រុកអស់ហើយ ខ្ញុំនឹងប្រញាប់ចេញទៅពីស្រុកនេះភ្លាម ” ។

រឿងរបស់បុរសម្ចាស់ផ្ទះ ធ្វើឱ្យខ្ញុំត្រូវប្រើគំនិតគិតយ៉ាងធ្ងន់មួយគ្រាទៀត ខ្ញុំនឹងអាណិតគេនឹងអ្នកស្រុកគ្រប់គ្នាជាខ្លាំង ចង់នឹងជួយពួកគេឱ្យរួចចាកសភាពការណ៍ដ៏គួរអាណិត តែគំនិតមួយ ក៏ឃើញថា វាជារឿងធម្មតារបស់គ្រហស្ថ យើងលាងដៃចាករបស់ទាំងនេះហើយ មិនគួរនាំខ្លួនចូលទៅប្រឡូកប៉ូកប៉ាក់ប្រឡាក់ប្រឡូសផង តែសេចក្តីអាណិតមានកំឡាំងខ្លាំងក្លា ទើបខ្ញុំសម្រេចចិត្តគិតជួយពួកគេតាមដែលអាចជួយបាន ។

**ម្នាលឧបាសក!** អាត្មាអាណិតលោកពេកណាស់អាត្មានឹងខិតខំរកផ្លូវជួយសង្គ្រោះដោះទុក្ខលោកនិងអ្នកស្រុកទាំងឡាយ តែនឹងជួយដោះស្រាយដោយវិធីណានោះ ចាំអាត្មាគិតមើលសិន ” តពីនោះ ខ្ញុំក៏សិងគិតរកឧបាយ បុរសម្ចាស់ផ្ទះ ក៏ដេកលក់លង់ទៅ ព្រោះយប់កាន់តែជ្រៅណាស់ហើយ ។

# មេរៀនពីក្មេងតូច

រសៀលថ្ងៃស្អែកឡើងនោះឯង ខ្ញុំក៏ផ្ដើមធ្វើការ តាមនយោបាយដែលបានគិតទុក ខាងមុខផ្ទះរបស់មេស្រុក មានលានទូលាយ មានដើមឈើជាម្លប់ត្រជាក់ ក្មេងៗ កូនអ្នកស្រុកអ្នកភូមិ ចូលចិត្តនាំគ្នាទៅលេងនៅទីលាននោះ មេស្រុកក៏ចូលចិត្តទៅអង្គុយទៀតទ្វាររបងភូមិមើលកូនក្មេងលេង ថ្ងៃនោះមានក្មេងម្នាក់ ទៅលេងមុនមិត្តភ័ក្ត វាយកដុំឥដ្ឋទៅកជារូបស្តូបខ្ពស់ឡើងទៅត្រឹមកវា ហើយក៏យកឥដ្ឋពិសេសមួយដុំទៅបន្តុបពីលើធ្វើជាកំពូលរបស់ស្តូបនោះស្រេចហើយ ក៏អង្គុយសំឡឹងមើលផលការងាររបស់ខ្លួនដោយសេចក្ដីពេញចិត្ត មួយសន្ទុះ ក៏យកដៃទាញដុំឥដ្ឋពីរបីដុំដែលនៅខាងក្រោមចេញ ភ្លាមនោះឯង ឥដ្ឋដែលនៅខាងលើរួមទាំងឥដ្ឋដែលជាកំពូល ក៏ធ្លាក់ធ្លាយរលាយរូបស្តូបនោះ ហើយក្មេងនោះ ក៏ផ្ដើមសាងស្តូបឡើងជាថ្មីទៀត ហើយក៏ទម្លាយចោលដោយដកឥដ្ឋនៅខាងក្រោមចេញ ក្មេងតូចសាងនិងទម្លាយចោលដដែលៗ ដូចជាមិនចេះហត់នឿយ មេស្រុកអង្គុយសំឡឹងមើលការលេងរបស់ក្មេងនោះ ដោយយកចិត្តទុកដាក់ ។

---

១-ស្តូប= ចេតិយតូចទាបដែលមានរាងស្រដៀងនឹងសណ្ឋាន អកកំបោរ ឬសណ្ឋានចេតិយខ្សាច់ ។ គំនរឬពំនូតដីជាដើម ដែលមានប៉ែកខាងលើស្រួច ។ ( វចនានុក្រមខ្មែរ ភាគ ២ ) ។

ខណៈដែលក្មេងនោះ កំពុងលេងយ៉ាងភ្លើតភ្លើននោះឯង ខ្ញុំក៏ដើរទៅត្រង់នោះ ហើយចូលទៅឈប់សម្រាកក្រោមម្លប់ឈើជិតក្មេងនោះ ដោយធ្វើជាមិនឃើញមេស្រុក ដែលអង្គុយនៅទៀតទ្វារភូមិ ខ្ញុំរង់ឱកាសទាល់តែក្មេងកស្តូបដោយដុំឥដ្ឋហើយស្រេចរៀបរយ ទើបខ្ញុំសួរថា "នាង! ឯងកំពុងធ្វើអ្វី ? " ។

" ខ្ញុំលេងកសាងព្រះស្តូប " ក្មេងតូចឆ្លើយហើយក៏ដាក់ដុំឥដ្ឋពិសេសទុកជាកំពូលរបស់ព្រះស្តូបយ៉ាងប្រយ័ត្នប្រយែង ។

" ហេតុអ្វីបានជានាងដាក់ដុំឥដ្ឋមួយនោះ ទុកលើដំបូលព្រះស្តូប? ខ្ញុំសួរ

" ខ្ញុំសន្មតទុកថា ជាព្រះរាជាគង់លើបល្លង្ក ទើបត្រូវដាក់លើដំបូលស្តូបជាកំពូលលើឥដ្ឋឯទៀត ! "

" ឯងចេះលេងល្អច្រើនអានាង បើឥដ្ឋមួយដុំនៅលើដំបូលជាព្រះរាជា ដុំឥដ្ឋទាំងឡាយដែលនៅបន្ទាប់បន្តខាងក្រោម ក៏ប្រៀបដូចសេនារាជបរិវារ និងពលរដ្ឋរបស់ប្រទេសមែនទេ ? " ខ្ញុំសួរជាទំនងជួយឱ្យវានិយាយ ។

" បាទ យ៉ាងហ្នឹងមែន ! " ក្មេងតូចនិយាយយ៉ាងគួរស្រឡាញ់ ហើយក៏អង្គុយសំឡឹងផលការងាររបស់ខ្លួន កាលមើលមួយសន្ទុះហើយ វាក៏ទាញដុំឥដ្ឋខាងក្រោមចេញមួយដុំ ធ្វើឱ្យដុំឥដ្ឋទាំងឡាយដែលនៅ

ខាងលើរលំធ្លាក់ចុះមកភ្លាម ។

" អើអានាង ហេតុអ្វីក៏ស្តូបរបស់ឯង ធ្លាក់ចុះមកអស់រលីង ព្រះរាជាដែលស្ថិតនៅលើជាក់កំពូលមិនធ្លាក់ចុះទៅផងឬ ? " ខ្ញុំសួរដោយសំឡេងខ្លាំងជាងប្រក្រតីបន្តិច ។

" ព្រះរាជាក៏ត្រូវតែធ្លាក់ចុះមកផង " ក្មេងតូចឆ្លើយហើយសើចយ៉ាងរីករាយ " ព្រោះខ្ញុំទាញដកដុំឥដ្ឋ ដែលរកទទួលនៅខាងក្រោមចេញដុំឥដ្ឋដែលនៅខាងលើ ៗ ក៏ត្រូវធ្លាក់ចុះមកទាំងអស់ " ។

" អានាងអើយ ការលេងរបស់ឯង មានគតិល្អពិត១ អាត្មាបានទទួលការចេះដឹងថ្មី ពីការលេងរបស់នាងហើយ គឺថាដុំឥដ្ឋដែលឯងសន្មតឱ្យជាព្រះរាជា អាចឋិតនៅលើកំពូលស្តូបបានក៏អាស្រ័យដុំឥដ្ឋ ដែលនៅខាងក្រោមជាគ្រឿងទ្រទទួលទុក កាលណាដុំឥដ្ឋដែលនៅខាងក្រោមមិនទ្រទប់ទេ ឥដ្ឋដែលនៅខាងលើ ក៏ធ្លាក់រលំចុះមកកាលនោះ ព្រោះដូច្នោះឥដ្ឋគ្រប់១ ដុំត្រូវពឹងពាក់អាស្រ័យគ្នា និងគ្នា ទើបនឹងទ្រទ្រង់រូបជាស្តូបនៅបាន បើដុំឥដ្ឋខ្ពស់បំផុតចូលចិត្តគិតយល់ថា ខ្លួនរឹងខ្លាំងជាងថ្មដទៃ១ ទាំងអស់ ជាព្រះរាជារបស់ដុំឥដ្ឋដទៃ១ មិនបាច់ពឹងអាស្រ័យនរណា ដូច្នេះជាការចូលចិត្តយល់ខុសស្រឡះ អានាងអើយ ការលេងរបស់ឯង ជាគ្រឿងប្រៀបប្រដៅចិត្តអាត្មាបានល្អយ៉ាងពិសេស ។

ការលេងរបស់ឯង ធ្វើឱ្យអាត្មាយល់សភាពរបស់សង្គមមនុស្សបាន

ច្បាស់លាស់ល្អឡើង យ៉ាងច្រើន អាត្មាទើបដឹងអម្បាលមិញនេះឯងថាមនុស្សខ្លះ មានអំណាច មានទ្រព្យ មានយសសក្តិខ្ពស់ជាងអ្នកដទៃ ក៏ច្រើនតែចូលចិត្តគិតខុសថា ខ្លួនវិសេសយ៉ាងបំផុតហើយ មិនត្រូវពឹងពាក់ទាក់ទងនិងនរណា ខ្លួនគិតចង់ធ្វើអ្វី ក៏ធ្វើដោយមិនបាននឹកដល់ទ្រូងអ្នកដទៃ អ្នកដទៃនឹងលំបាកយ៉ាកយ៉ាប់យ៉ាងណាដោយសារខ្លួនក៏មិនរវល់ សូមឱ្យតែខ្លួនបានសប្បាយក៏ហើយគ្នា ដូចដុំឥដ្ឋដែលនៅលើកំពូលស្តូបបាន ព្រោះអាស្រ័យឥដ្ឋច្រើនដុំនៅទ្រពីខាងក្រោមដូច្នោះ ” ក្មេងតូចអង្គុយស្តាប់ខ្ញុំស្វាធ្យាយនិយាយ យ៉ាងយកចិត្តទុកដាក់ តែគោលបំណងរបស់ខ្ញុំមិនមែនដៅទៅនឹងក្មេងតូចនោះទេ តែដៅទៅរកមេស្រុក ដែលអង្គុយនៅត្រង់ទ្វារភូមិជិតនោះច្រើនជាង ។

” អានាងអើយ មនុស្សដែលស្តុកស្តម្ភដោយទ្រព្យច្រើនកើតចិត្តក្រអឺតទ្បឺតក្រអោងប៉ោងឬកនឹថាខ្លួនស្តុកស្តម្ភហើយ មិនបាច់យកចិត្តថ្លើមនរណា មិនបាច់ពឹងពាក់នរណា ទាំងដែលខ្លួនកំពុងពឹងពាក់អ្នកដទៃ គ្រប់ផ្នែកមែកធាង ។ ពឹងយ៉ាងណា ? មនុស្សដែលស្តុកស្តម្ភនោះឯង បើយើងចាប់គេ ទៅដាក់ក្នុងសំពៅ ព្រមដោយមាសប្រាក់ទ្រព្យសម្បត្តិទាំងអស់ដែលមាន ហើយនាំគេទៅលែងចោលក្នុងមហាសមុទ្រឱ្យនៅតែម្នាក់ឯង រហូតអវសានជីវិត តើគេព្រមឬទេ ? មិនព្រមយ៉ាងដាច់ខាត ! ព្រោះបើនៅក្នុងមហាសមុទ្ទតែម្នាក់ឯង ប្រាក់មាសចំនួនកោដិ

ក៏ក្លាយជារបស់ឥតប្រយោជន៍ ព្រោះបើបោះចុះទៅក្នុងទឹក ត្រីក៏មិនយកចិត្តទុកដាក់ បើបោះទៅលើអាកាសបក្សីក៏មិនត្រូវការ កាលគ្មាននរណាធានាតម្លៃរបស់ប្រាក់មាសហើយ ប្រាក់មាសក៏ក្លាយជាសំណល់លោហៈដែលគ្មានតម្លៃ ប្រាក់មមាសមានតម្លៃទៅកើត មនុស្សស្តុកស្តម្ភបាន ក៏ព្រោះមនុស្សទាំងពួង ព្រមទទួលធានាគុណភាពរបស់ប្រាក់ ដូច្នោះ មនុស្សយើងនឹងស្តុកស្តម្ភតែម្នាក់ឯងពុំបាន ត្រូវអាស្រ័យការធានារ៉ាប់រងពីអ្នកដទៃ ទើបឈ្មោះថាត្រូវអាស្រ័យអ្នកដទៃ ទាក់ទងនឹងអ្នកដទៃដោយពិត ។

**អានាងតូច !** អ្នកណាបានលាភបានយសហើយស្រវឹងវង្វេងសំគាល់យល់ថាខ្លួនប្រសើរវិសេសជាងអ្នកដទៃ ហើយក៏បៀតបៀនអ្នកតូច អ្នកនោះទុកដូចជាពំពុងទម្លាយបំផ្លាញមូលដ្ឋានធានារ៉ាប់រងរបស់ខ្លួនឯង ក្នុងពេលមិនយូរ ខ្លួននឹងដាំទីង រលាយរលុះជ្រុះចុះមក ដូចដែលអានាងដកដុំឥដ្ឋដែលនៅខាងក្រោមចេញ ហើយដុំឥដ្ឋដែលនៅខាងលើៗ ក៏ធ្លាក់ចុះមកដូច្នោះ ។ អ្នកណាបានលាភបានយស បានខ្ពស់មុខហើយមិនស្រវឹងវង្វេង យកលាភយសនោះ មកជួយទំនុកបំរុងសង្គ្រោះដល់អ្នកតូច អ្នកនោះ ក៏ដូចជាសាងមូលដ្ឋានរបស់ខ្លួនឱ្យមាំមួនរឹងប៉ឹង មនុស្សទាំងឡាយនឹងលើកដំកើនឱ្យគេនៅ ក្នុងដំណែងដ៏ខ្ពង់ខ្ពស់នោះរៀងរាបទៅ ” ។

**លោកអ្នកអានទាំងឡាយ !** កាលខ្ញុំសន្ទនានឹងក្មេងតូច បានត្រឹមប៉ុណ្ណេះ មេស្រុកបានក្រោកពីទីអង្គុយ ដើរតម្រង់ចូលមករកខ្ញុំភ្លាម គេអង្គុយ ហើយក្រាបទៀបបានជើងរបស់ខ្ញុំ ហើយក៏ឈ្ងោកមុខយំខ្សឹកខ្សួល។

"កើតរឿងអ្វី ឬ ឧបាសក" ខ្ញុំសួរដោយសេចក្ដីរំភើបចិត្ត ត្បិតមិនដឹងដើមហេតុ មេស្រុកមិនបានឆ្លើយថាអ្វី នៅតែអង្គុយយំតទៅ ដូចជាកំពុងខូចចិត្តខូចថ្លើមយ៉ាងធំមហិមា ។

" មានរឿងអាសន្នអន់ក្រអ្វីកើតឡើងឬ? សូមប្រាប់ឱ្យអាត្មាដឹងដោយរួសរាន់ចុះ ឧបាសក អាត្មាពេញចិត្តនឹងជួយសង្គ្រោះលោក ឱ្យទាល់តែអស់សមត្ថភាព " ខ្ញុំបង្ខំឱ្យគាត់ប្រាប់ មេស្រុកងើបមុខដ៏ទទឹកជោគដោយទឹកភ្នែក សំឡឹងមើលខ្ញុំយ៉ាងអង្វរ ហើយក៏ពោលយ៉ាងរអាក់រអួលថា :

" **បពិត្រលោកម្ចាស់ដ៏ចំរើន !** សំដីដែលលោកសំដែងចំពោះក្មេងអម្បាញមិញនេះ ធ្វើឱ្យខ្ញុំដឹងខ្លួនភ្ញាក់រលឹកឡើងបាន ព្រមជាមួយគ្នានឹងសេចក្ដីខូចចិត្តដ៏ធំមហិមាក៏កើតឡើង ទើបខ្ញុំមិនអាចទប់ទឹកភ្នែកទុកបាន ព្រោះខ្ញុំជាអ្នកស្រវឹងក្នុងលាភយស និយមយល់ថា ខ្លួនវិសេសយ៉ាងបំផុតហើយ មិនបាច់ពឹងពាក់អាស្រ័យអ្នកណា ខ្ញុំបានប្រើទ្រព្យនិង

យសរបស់ខ្លួនបៀតបៀនរិបជាន់សង្កត់សង្កិន ក្នុងស្រុកយ៉ាងសាហាវយង់ឃ្នង តែខ្ញុំមនបានគិតថាជាអំពើយង់ឃ្នងឃោរឃៅទេ ទៅជាសប្បាយរីករាយថែមទៀត ដែលបានឃើញសេចក្ដីលំបាកយ៉ាកយ៉ាប់របស់អ្នកស្រុក និងឃើញទ្រព្យសម្បត្តិហូរចូលមករកខ្ញុំយ៉ាងងាយ ខ្ញុំគ្រប់គ្រងជីវិតលើទឹកភ្នែកញើសឈាមរបស់អ្នកដទៃយ៉ាងពិតប្រាកដ កាលបានស្ដាប់ហេតុផល ដែលលោកពន្យល់ក្មេងចប់ហើយ សេចក្ដីស្រវឹងវង្វេងក្នុងចិត្តរបស់ខ្ញុំក៏បានរលំរលាយពាយអស់ទៅ ខ្ញុំដឹងខ្លួនភ្លាមថា ខ្លួនបានធ្វើអំពើអាក្រក់អ្វីខ្លះ លោកម្ចាស់បានជួយស្ទួយលើកខ្ញុំចេញទីរណ្ដៅនៃសេចក្ដីអាក្រក់យ៉ាងពិតប្រាកដ ” មេស្រុកយំខូចចិត្តតទៅទៀត មួយសន្ទុះទើបពោលឡើង “ **លោកម្ចាស់ដ៏ចំរើន !** ឥឡូវនេះ ខ្ញុំដឹងខ្លួនដូចទើបភ្ញាក់ពីយល់សប្តិអាក្រក់ ។លរលឹកនឹកដល់អពើក្នុងអតីត: ខ្ញុំសង្វេគស្លុតចិត្តឥតឧបមា ខ្ញុំសូមប្ដេជ្ញាចំពោះលោកម្ចាស់ថា តាំងពីពេលនេះតទៅ ខ្ញុំនឹងមិនធ្វើដូច្នោះរៀត ខ្ញុំនឹងលើកលាការជំពាក់ទាក់ទាមទាំងអស់ដែលអ្នកស្រុកមានចំពោះខ្ញុំ ឱ្យរួចហើយគ្នាទៅ ខ្ញុំនឹងបែងដីស្រែប្រគល់ឱ្យសម្បត្តិផ្ទាល់ខ្លួនរបស់គេគ្រប់ៗគ្រួសារ ខ្ញុំនឹងជួយទំនុកបំរុងផ្គងផ្គើមគេដោយល្អតទៅ ” ។

“ **ម្នាលឧបាសក !** អាត្មាមិននឹងនាសោះឡើយថា សំដីដែលអាត្មានិយាយលេងៗ នឹងក្មេង អាចផ្លាស់ចិត្តគំនិតរបស់លោកបានដូច្នេះ

អាត្មានិយាយទៅតាមគោលដោយគ្មានចេតនានឹងប្រដៅនរណា ដូចជាមើលមិនឃើញលោកច្បាស់ផង តែអាត្មាក៏ត្រេកអររីករាយសប្បាយចិត្ត ដែលពាក្យនិយាយរបស់ខ្លួនអាចធ្វើឱ្យលោកភ្ញាក់កំណើតកើតគំនិត ត្រឡប់ខ្លួនជាមនុស្សល្អបាន កុំយំសោកខូចចិត្តធ្វើអ្វីឧបាសក អតីតកាលដែលកន្លងមកហើយ ក៏សូមឱ្យហើយគ្នាទៅចុះ នៅមិនទាន់ជ្រុលជ្រួសហួសកែនោះទេ លោកអាចនឹងធ្វើសេចក្ដីល្អលុបលាងសេចក្ដីអាក្រក់បាន ព្រះបរមសាស្ដារបស់អាត្មាត្រាស់ទុកថាៈ

" មនុស្សពួកខ្លះ ងងឹតមកហើ្យ ក៏ងងឹតទៅ គឺធ្វើអាក្រក់ពីមុនមកហើយ ក៏ធ្វើអាក្រក់តទៅទៀត ពួកនេះមិនបានការ ។

មនុស្សពួកខ្លះ ភ្លឺស្វាងមកហើយ ក៏ងងឹតទៅវិញ គឺពីមុនមកធ្វើល្អ ពេលក្រោយត្រឡប់ទៅធ្វើអាក្រក់ទៅវិញ ពួកនេះក៏មិនបានការ ។

មនុស្សពួកខ្លះ ភ្លឺស្វាងកហើយ ក៏ភ្លឺស្វាងតទៅ គឺធ្វើល្អរហូត ពួកនេះល្អបំផុត ។

មនុស្សពួកខ្លះ ងងឹតមកហើយ ក៏ភ្លឺស្វាងវិញ គឺធ្វើអាក្រក់មកពីមុន ពេលក្រោយកែខ្លួនបានហើយ តាំងផ្ដើមធ្វើសេចក្ដីល្អ ពួកនេះក៏បានការ " ។

**ម្នាលឧបាសក!** លោកចាត់ជាមនុស្សចុងក្រោយនេះ ក្នុងកាលកន្លងមកហើយ លោកបានដើរក្នុងផ្លូវងងឹតងងល់ ឥឡូវនេះលោកបានដល់ផ្លូវដ៏ភ្លឺស្វាងហើយ ចូរផ្ដើមធ្វើសេចក្ដីល្អតទៅ " ។

លោកមេស្រុក ឱនក្បាលក្រាបសំពះខ្ញុំម្ដងទៀតដោយសេចក្ដីជ្រះ-ថ្លា ខ្ញុំបានទេសនាប្រៀនប្រដៅគេឱ្យរីករាយក្នុងសម្មាបដិបត្តិ នឹងបញ្ចប់ដោយសុភាសិតថា :

" **ឧត្តមគ្គនិវាតេន សូរំ ភេទេន និដ្ឋយេ និចំ អប្បកទា នេន វិធមេន សមំ ជយេ ។**

ឈ្នះអ្នកថ្កើង ដោយត្រុនបន្ទន់ប្រាណ

ឈ្នះអ្នកក្លាហាន ដោយការទម្លាយ

ឈ្នះអ្នកខ្សត់ ដោយឱ្យសម្លបាយ

ឈ្នះអ្នកស្មើកាយដោយសេចក្ដីព្យាយាម[១] ។

ហើយខ្ញុំ ក៏លាត្រឡប់ទៅខ្ទមសំណាក់ បុរសម្ចាស់ខ្ទមសួរខ្ញុំយ៉ាងប្រញាប់ថា ទៅធ្វើការបានផលយ៉ាងណាខ្លះ ? ខ្ញុំថា " រង់ចាំមើល ក៏ហើយគ្នា តែអាត្មាបានធ្វើនាទីរបស់ខ្លួនល្អយ៉ាងបំផុតហើយ" ។

ថ្ងៃស្អែកឡើង មេស្រុកក៏ហៅប្រជុំអ្នកស្រុកទាំងឡាយនៅវាលមុខផ្ទះរបស់ខ្លួន កាលអ្នកស្រុកជួបជុំគ្នាហើយ មេស្រុកក៏ក្រោកឡើង មុខ

មាត់របស់គេមុតមាំម៉ឺងម៉ាត់ជាងមុន ធ្វើឱ្យអ្នកស្រុកគ្រប់គ្នាមិនសប្បាយចិត្ត ព្រោះទោះយ៉ាងណាថ្ងៃនេះ មេស្រុកកំណាចមុខជារកផ្លូវបឺតឈាមអង្កៀមឆ្អឹងពួកគេទៀតមិនខាន ប៉ុន្តែផ្ទុយវិញ គ្រប់គ្នាក៏នឹងចម្លែកប្លែកក្នុងចិត្ត ស្ទើរតែមិនជឿត្រចៀកខ្លួនឯង ព្រោះមេស្រុកបានប្រកាសឡើងថា :

" **បងប្អូនទាំងឡាយ!** ខ្ញុំសូមប្រកាសឱ្យអ្នកទាំងឡាយជ្រាបថា គ្រប់គ្នាដែលជំពាក់ទាក់ទាមបំណុលខ្ញុំ ជាចំនួនប៉ុន្មានៗ ក៏ដោយខ្ញុំមិនជាប់ចិត្តគិតយកសំណងពីអ្នករាល់គ្នាទេ សូមឱ្យអ្នកទាំងឡាយ រួចចាកការជំពាក់បំណុលទាំងអស់មានសេរីភាពគ្រប់ៗគ្នាចុះ មួយទៀតបណ្ដាដីស្រែ ដែលខ្ញុំជួលឱ្យអ្នកទាំងឡាយធ្វើនោះ ខ្ញុំសូមលើកឱ្យជាសម្បត្តិរបស់អ្នកទាំងឡាយ ដូច្នេះ អ្នកណាធ្វើស្រែរបស់ខ្ញុំចំនួនប៉ុន្មានសូមឱ្យគ្រប់គ្រងជាកម្មសិទ្ធិក្នុងដីស្រែចំនួនប៉ុណ្ណោះ តាំងពីថ្ងៃនេះជាដើមទៅ ក្នុងពេលមុន ខ្ញុំបានធ្វើអំពើសង្កត់សង្កិន ធ្វើទុក្ខបុកម្នេញពួកអ្នកទាំងឡាយឱ្យក្ដៅក្រហាយលំបាក ឥឡូវនេះ ខ្ញុំដឹងខ្លួនហើយក្នុងកំហុសទាំងនោះ ខ្ញុំក្រៀមក្រំខ្លូចចិត្តថ្លើមយ៉ាងខ្លាំង សូមអ្នកទាំងឡាយមេត្តាអត់ឱនទោសឱ្យខ្ញុំផង ខ្ញុំសូមរ៉ាប់រងចំពោះមុខព្រះសុរិយទេពថា តាំងពីពេលនេះតទៅ ខ្ញុំមិនធ្វើដូច្នោះទៀតជាដាច់ខាត ខ្ញុំតាំងចិត្តគ្រប់គ្រងពួកអ្នកទាំងឡាយដោយយុត្តិធម៌តទៅ " ។

កាលមេស្រុកប្រកាសចប់ហើយ សេចក្ដីស្ងៀមស្ងាត់បានគ្របដណ្ដប់បរិវេណនោះ ព្រោះគ្មាននរណាគិតអានស្មានយល់សប្ដិ៍ថា បានស្ដាប់សំដីបែបនោះពីលោកមេស្រុកកំណាចនេះឡើយ ទើបនាំគ្នាធឹង-ងោងនៅស្ងឹងឈឹងស្ងៀម ទាល់តែមេស្រុកក្រោកឈរឡើង សំដែងសុទ្ធចិត្តរបស់ខ្លួនម្ដងទៀត អ្នកស្រុកទាំងឡាយទើបចុះចិត្តជឿ ភ្លាមនោះឯង អ្នកស្រុកគ្រប់គ្នា ក៏មានទឹកភ្នែកហូរចេញមកដោយបីតិប្រាមោទ្យ ពួកគេដើរចូលទៅចាប់មេស្រុកលីលើស្មា ហើយនាំគ្នាហែហមទៅតាមផ្លូវក្នុងស្រុក បន្លឺជយឃោសន៍ប្រែកហ៊ោឱ្យពរជ័យមេស្រុកឮខ្ទរញ័រប្រឹថពី ។ មុនព្រលប់ បុរសម្ចាស់ខ្ទមត្រឡប់ពីទីប្រជុំ ចូលមកក្រាបថ្វាយបង្គំទៀបបាទជើងរបស់ខ្ញុំ ហើយពោលសរសើរនិងអរគុណខ្ញុំជាអនេកប្រការ ។

ព្រឹកថ្ងៃស្អែក មេស្រុកព្រមដោយអ្នកស្រុកទាំងឡាយ បាននាំគ្នាមកអារាធនាឱ្យខ្ញុំនៅប្រចាំក្នុងភូមិស្រុកនោះ តែខ្ញុំមិនព្រមទទួល ព្រោះនាទីរបស់ខ្ញុំ គឺពនេចរ ត្រេចរង្គាត់រសាត់អណ្ដែតទៅរហូតអស់ដង្ហើមចេញចូល ព្រោះដូច្នោះ ខ្ញុំទើបចំរើនពរលោកអ្នកស្រុក ធ្វើដំណើរតទៅតាមផ្លូវទិសបូព៌ា បែរមុខសំដៅទៅកាន់ក្រុងរាជគ្រឹះ ។

# ឆ្នេរស្ទឹងនេរញ្ជរា

**លោកអ្នកអានទាំងឡាយ!** ពីរថ្ងៃក្រោយពីនោះ ខ្ញុំក៏នាំខ្លួនឯងទៅដល់ឆ្នេរស្ទឹងនេរញ្ជរា ខណៈដែលខ្ញុំទៅដល់ជាវេលារសៀលកំពុងក្តៅខ្លាំងណាស់ ទើបចូលទៅអង្គុយសម្រាកក្រោមដើមស្វាយធំក្បែរឆ្នេរស្ទឹងមានតែខ្សាច់ពណ៌ស ដែលកំពុងក្តៅដោយអណ្តាតកំដៅស្ទើរមើលមិនបាន នេរញ្ជរា គួរនឹងបានឈ្មោះថា " **មេខ្សាច់** " ច្រើនជាងស្ទឹង ទោះជាវេលាអាកាសក្តៅខ្លាំងចាំងថែស តែក្រោមដើមស្វាយធំ ក៏មានម្លប់ត្រជាក់សប្បាយស្រួលណាស់ ខ្ញុំទម្រេតកាយសម្រាកលើផ្ទៃខ្សាច់ដ៏ទន់និងត្រជាក់ ហើយក៏បញ្ជូនចិត្តរលឹកនឹកដល់ព្រះបរមសាស្តា ព្រោះព្រះ-អង្គបានប្រថាប់ក្រោមម្លប់ពោធិព្រឹក្ស លើឆ្នេរស្ទឹងនេរញ្ជរានេះហើយបានត្រាស់ដឹងព្រះសម្មាសម្ពោធិញ្ញាណកាលយូរមកហើយ ខណៈដែលខ្ញុំកំពុងនិងសម្រាកកាយយ៉ាងសប្បាយនោះឯង បុរសចាស់ម្នាក់ក៏ចេញហ្វូងពពែចូលមក គេបណ្តោយឱ្យពពែចូលដេកសម្រាកក្រោមម្លប់ឈើជិតៗ នោះ ហើយគេក៏ដើរតម្រង់ចូលមករកខ្ញុំ ។

" **បពិត្រលោកសមណៈ !** លោកមកពីណាហើយនឹងទៅណា? គាត់សួរហើយលើកជាយសំពត់ជូតញើសនៅថ្ងាស ។

" អាត្មាមកពីក្រុងសាវត្ថី តាំងចិត្តនឹងទៅក្រុងរាជគ្រឹះ "

"មកពីក្រុងសាវត្ថី!" គាត់បន្លឺដោយសំឡេងខ្លាំងដោយនឹកចម្លែក

ក្នុងចិត្ត " បើយ៉ាងនោះលោកក៏ធ្វើដំណើរមកឆ្ងាយច្រើន ខ្ញុំមិនធ្លាប់ទៅសាវត្ថីឡើយ តែបានដឹងដំណឹងថានៅឆ្ងាយណាស់ លោកសមណៈមកតែមួយអង្គឯង ឬមានមិត្តភ័ក្តមកជាមួយផង " ។

"អាត្មាធ្វើដំណើរមកតែម្នាក់ឯង"ខ្ញុំឆ្លើយ បុរសចាស់សំឡឹងមើលខ្ញុំ តាំងពីក្បាលរហូតចុងជើងហាក់នឹងប្រាប់ថា មិនជឿក្នុងចម្លើយរបស់ខ្ញុំ តែក៏សួរថា " ធ្វើដំណើរមក តមួយអង្គឯងដូច្នេះមិនខ្លាចឬ ? "

" តើត្រូវខ្លាចអ្វី ? " ខ្ញុំសួរវិញ

" ក៏ខ្លាចអន្តរាយផ្សេងៗ ដូចចោរ សត្វព្រៃជាដើម "

" អាត្មាមិនខ្លាចអ្វីទាំងអស់ មិនខ្លាចចោរ ព្រោះគ្មានទ្រព្យសម្បត្តិអ្វី នឹងឱ្យគេលួចប្លន់ មានតែបាត្រនិងចីពរប៉ុណ្ណោះ បើគេត្រូវការអាត្មាក៏ពេញចិត្តនឹងឱ្យ អាត្មាមិនខ្លាចសត្វព្រៃ ព្រោះគ្មានអ្វីឱ្យសត្វសាហាវទាំងនោះ ដណ្តើមមានតែសរីរៈរាងកាយនេះប៉ុណ្ណោះ សូម្បីរាងកាយនេះ បើសត្វសាហាវទាំងនោះត្រូវការអាត្មាក៏ពេញចិត្តលះឱ្យដែរ " ។

ចម្លើយរបស់ខ្ញុំ ធ្វើឱ្យបុរសចាស់អង្គុយស្ងៀម គាត់សំឡឹងមើលខ្ញុំយ៉ាងពិនិត្យពិនិស្ស័យក្រៃលែងឡើងហើយពោលថា " បពិត្រសមណៈ បើលោកមិនខ្លាចរបស់ទាំងនេះ លោកក៏ជាមនុស្សក្លាហានយ៉ាងបំផុតដែលខ្ញុំធ្លាប់ជួបមក " ។

**ម្នាលឧបាសក!** មនុស្សយើងគ្រប់គ្នាខ្លាចចំពោះអន្តរាយភ័យវិបត្តិផ្សេងៗ កំពូលរបស់អន្តរាយក៏គឺសេចក្តីស្លាប់ បើមិនខ្លាចសេចក្តីស្លាប់ហើយ អន្តរាយដទៃក៏គ្មានបញ្ហា ” ។

“ បើយ៉ាងនេះ លោកមិនខ្លាចសេចក្តីស្លាប់ទេឬ ? ”។

“ អាត្មាមិនដែលខ្លាចសេចក្តីស្លាប់ទេ ” ។

“ ព្រោះហេតុអ្វីលោកសមណៈ ? ” បុរសចាប់សួរហើយ ក៏ខិតជិតចូលមកទៀត ។

“ ព្រោះអាត្មាធ្លាប់ជិតជិតស្និទ្ធស្នាលនិងសេចក្តីស្លាប់ហើយ ” ។

“ សំដៅសេចក្តីថា លោកធ្លាប់ស្លាប់មកហើយច្រើនដង ទាល់តែថ្មីកហើយ យ៉ាងនោះឬ ? ” ។

“ មិនមែនយ៉ាងនោះទេ ក្នុងជីវិតនេះ អាត្មាមិនទាន់ដែលស្លាប់ តែធ្លាប់បានធ្វើសេចក្តីជីងស្និទ្ធស្នាលនឹងសេចក្តីស្លាប់ទុក ដោយការរលឹកនឹកដល់វាជានិច្ចថា ជីវិតរបស់យើង កំពុងឈានចូលទៅកាន់សេចក្តីស្លាប់ ដូចគ្នានឹងខ្សែទឹកក្នុងស្ទឹងហូរទៅកាន់ទន្លេ យើងហាមទឹកមិនឱ្យហូរទៅមិនបានយ៉ាងណា យើងក៏ហាមជីវិតមិនឱ្យស្លាប់មិនបានយ៉ាងនោះដែរ តែយើងមុខជាស្លាប់ ព្រោះជីវិតគឺការធ្វើដំណើរទៅកាន់សេចក្តីស្លាប់ ថ្ងៃយប់ដែលកន្លងទៅ គឺមួយជំហានៗ ដែលនាំយើងចូលទៅជិតសេចក្តីស្លាប់គ្រប់ខណៈ សេចក្តីស្លាប់ គឺសេចក្តីពិតនៃជីវិត កាលជីង

សេចក្ដីពិតដូច្នេះហើយ អាត្មាទើបមិនខ្លាចចំពោះសេចក្ដីស្លាប់ ” ។

“ អ៊ី គួរស្ដាប់ណាស់ ! ” បុរសចាស់ម្នាស់ពពែបន្លឺសំឡេងងក់ក្បាលសំដែងសេចក្ដីយល់ឃើញស្របផង តែនៅសួរតទៅទៀតថា “ត្រឹមតែរលឹកនឹកដល់សេចក្ដីស្លាប់រឿយៗ ដូច្នេះ ធ្វើឱ្យបាត់សេចក្ដីខ្លាចស្លាប់បានឬ ខ្ញុំនៅគិតមិនឃើញសោះថា នឹងធ្វើឱ្យបាត់ខ្លាចបានយ៉ាងដូចម្ដេច ? ” ,

“ បើគិតរឿយៗ ទាល់តែជិតស្និទ្ធស្នាលនឹងសេចក្ដីស្លាប់ ឃើញសេចក្ដីស្លាប់ជារឿងធម្មតាសាមញ្ញហើយ ក៏បាត់ខ្លាចបានយ៉ាងពិតប្រាកដ អាត្មាសូមសួរបន្តិចចុះថា កាលលោកនៅក្នុងវ័យក្មេងនោះ លោកធ្លាប់ខ្លាចនរណាខ្លះទេ ” ។

បុរសចាស់អង្គុយគិតមួយសន្ទុះ ក៏ឆ្លើយ “ ធ្លាប់ខ្លាដែរ ខ្ញុំធ្លាប់ខ្លាចបុរសចាស់ម្នាក់ ដែលមានមុខមាត់ឬកពារគួរខ្លាចច្រើន គាត់ចូលចិត្តលបន្លាចឱ្យក្មេងខ្លាចផង ខ្ញុំហៅគាត់ថា មា ព្រោះថាញាតិខាងឪពុក ផ្ទះរបស់យើងនៅជិតគ្នា វេលាខ្ញុំយំម្ដាយខ្ញុំច្រើនបំភ័យបញ្ឆោតថា “ មាមកហើយ មាមកហើយ ” ខ្ញុំឈប់យំភ្លាម ព្រោះខ្លាចមាមកមែន ” ។

“ ក្នុងរវាងវេលានោះ លោកហ៊ានទៅមករកមារបស់លោកទេ?”

“ មិនហ៊ានទេ លោកសមណៈ ត្រឹមតែឮសំឡេងគាត់ខ្ញុំក៏រត់

បាត់ទៅហើយ ណានឹងហ៊ានទៅជួបមុខគាត់ ! ” ។

“ ហើយលោកខ្លាចមាររបស់លោករៀងមក ឬពេលក្រោយបាត់ខ្លាច ? ” ។

“ ពេលក្រោយ សេចក្តីខ្លាចក៏បាត់អស់ទៅ តែទម្រាំនឹងបាត់ខ្លាច ក៏ស៊ីវេលាជាច្រើនឆ្នាំ ” ។

“ លោកអាចរលឹកនឹងកបានឬទេថា ព្រោះហេតុអ្វីទើបលោកបាត់ខ្លាច់គាត់ ? ” ។

“ អេ! លោកសមណៈនេះ ចូលចិត្តដេញដោលរឿងរ៉ាវក្នុងអតីតកាលរបស់ខ្ញុំធ្វើអ្វី ? ” បុរសចាស់ថា ព្រមទាំងសំដែងទឹកមុខមិនពេញចិត្ត ខ្ញុំលួងលោមគាត់ដោយការញញឹម ហើយនិយាយដោយសំឡេងទន់ភ្លន់ “ អាត្មាគ្មានចេតនាដេញដោលជីវប្រវត្តិរបស់លោកលេងៗ ទេឧបាសក អាត្មាចង់ពន្យល់បញ្ជាក់ឱ្យលោកឃើញច្បាស់លាស់ប៉ុណ្ណោះឯង ថាការរលឹកដល់សេចក្តីស្លាប់រឿយៗ ធ្វើឱ្យមិនខ្លាចសេចក្តីស្លាប់យ៉ាងណា បើលោកប្រាប់អាត្មាបានថា ហេតុអ្វីទើបបាត់ខ្លាចមា អាត្មានឹងប្រាប់លោកដូចគ្នាថា ហេតុអ្វី ទើបបាត់ខ្លាចចំពោះសេចក្តីស្លាប់ដូច្នោះ បើលោកល្មមនឹងឃើញ ក៏សូមប្រាប់អាត្មាមកចុះ ថាហេតុអ្វីលោកទើបបាត់ខ្លាចមាររបស់លោក ? ” ។

" ប៉ុនដែលចាំបាន ដូចជាព្រោះហេតុនេះគឺ គ្រាមួយមារបស់ខ្ញុំកើតខ្យល់ដួល ម្ដាយទើបនាំខ្ញុំទោសួរគាត់ ដំបូងក៏នៅខ្លាច តែក្រោយពីទៅរឿយៗ សេចក្ដីខ្លាចក៏សន្សឹមៗ បាត់ទៅ រហូតក្នុងទីបំផុតក៏មិននឹកខ្លាចឡើយ " ។

" **ម្នាលឧបាសក!** សេចក្ដីស្លាប់ប្រៀបដូចមារបស់លោកកាលនៅក្មេងលោខ្លាចមាយ៉ាងណា មនុស្សទាំងពួងក៏ខ្លាចចំពោះសេចក្ដីស្លាប់យ៉ាងនោះ លោកមិនហ៊ានទៅមករកមា ត្រឹមតែបានឮសំឡេងក៏រត់គេចទៅ មនុស្សទាំងពួងក៏ដូច្នោះ, គេមិនហ៊ានរលឹកនឹកដល់សេចក្ដីស្លាប់ ត្រឹមតែបានឮពាក្យថា " ស្លាប់ " ឬឃើញមនុស្សដទៃស្លាប់ ក៏រហូតដល់កើតសេចក្ដីស្ញិទ្ធស្នាលយ៉ាងណា មនុស្សយើង រលឹកនឹកដល់សេចក្ដីស្លាប់ញយៗ រហូតស្និទ្ធស្នាលនឹងសេចក្ដីស្លាប់ ហើយនឹងមិនខ្លាចចំពោះសេចក្ដីស្លាប់យ៉ាងនោះ " ។

បុរសចាស់សំឡឹងមើលខ្ញុំដោយធ្មេញញឹមៗ ហើយពោលសរសើរ "លោកឆ្លាតនិយាយប្រៀបធៀបគួរស្ដាប់ណាស់ ខ្ញុំជឿលោកព្រមព្យាយាមរៀនធ្វើតាមលោក " គាត់បែរសំឡឹងមើលហ្វូងពពែដែលដេកនៅស្ងបស្ងៀមក្រោមដើមឈើ ហើយក៏បែរមកសន្ទនានិងខ្ញុំតទៅ " តែខ្ញុំនៅសំឡឹងរំពឹងមើលមិនឃើសោះថា ការរលឹកដល់សេចក្ដិស្លាប់នឹង

បានប្រយោជន៍អ្វីខ្លះ ខ្ញុំធ្លាប់រលឹកនឹកដល់សេចក្ដីស្លាប់មួយដងមួយគ្រាដែរ តែគ្រប់គ្រាន់ដែលរលឹកដល់សេចក្ដីស្លាប់ វាធ្វើឱ្យចិត្តក្រៀមក្រំ កើតសេចក្ដីរួញរាអស់កម្លាំងក្នុងកិច្ចការទាំងពួង ចង់តែដេរង់ចាំ ស្លាប់តែម្យ៉ាង ហេតុនេះ ខ្ញុំមិនចង់គិតដល់វា បណ្ដោយឱ្យជីវិតភ្លើតភ្លើនទៅក្នុងមួយថ្ងៃៗ ស្លាប់កាលណា ក៏ស្លាប់ចុះ គិតយ៉ាងនេះចិត្តក៏សប្បាយឡើយខ្លះ " ។

" **ម្នាលឧបាសក !** ប្រៀបធៀបថា បុរសម្នាក់កំពុងជិះទូកឆ្លងកាត់មហាសាគរ ខណៈដែលកំពុងឆ្លងទៅ ក៏មើលឃើញថា ទឹកកំពុងចូលមកតាមស្នាមធ្លុះ គេដឹងថា ទូកមុខជាលិចលង់ក្នុងមហាសាគរមិនខាន កាលគិតថា ទូកមុខជាលិច ក៏កើតសេចក្ដីសោកសៅក្រៀមក្រំ អស់សេចក្ដីអាល័យក្នុងជីវិត ព្រោះគ្មានផ្លូវអាស្រ័យទូកនៅដល់ច្រាំងនោះបាន ទើបមិនគិតដល់ការលិចរបស់ទូក ឈរច្រៀងរាំសប្បាយក្នុងទូក ទាល់តែទូកលិចទៅហើយ គេក៏ធ្លាក់ទឹកលង់ស្លាប់ ។ លោកឃើញថា មនុស្សនោះ ឆ្លាត ឬល្ងង់? "

" ល្ងង់ខ្លៅ គ្មានបញ្ញាអ្វីសោះ " បុរសចាស់ឆ្លើយ ។

" ព្រោះហេតុអ្វី ? ខ្ញុំសួរ ។

" ព្រោះដឹងខ្លួនហើយថា ខ្លួនជិះទូកធ្លុះ មុខជាត្រូវលិចលង់ក្នុងមហាសាគរ ហើយនៅធ្វេសប្រហែសស្រែកយំច្រៀងកើត ធ្លាក់ទឹកលង់

ស្លាប់ ក៏សមមុខសមមាត់ហើយ ” កាលឃើញគាត់បើកផ្លូវឱ្យដូច្នោះ ខ្ញុំក៏ផ្ដើមរុកចូល “ បើយ៉ាងនោះលោកក៏ល្ងង់ខ្លៅដែរ ” ។

“ ខ្ញុំល្ងង់ខ្លៅយ៉ាងណា?” គាត់សួរឡើង ដោយសំឡេងសំដែងសេចក្ដីមិនពេញចិត្ត ។

“ អាត្មានឹងបញ្ជាក់ឱ្យស្ដាប់ថា លោកល្ងង់ខ្លៅយ៉ាងណា រាងកាយរបស់យើងប្រៀបដូចទូកធ្លុះ ឱយសង្សារ ដែលលោកនឹងត្រូវវិលស្លាប់កើតតទៅប្រៀបដូចមហាសាគរ ត្រើយខាងនោះ ប្រៀបដូចព្រះនិព្វាន លោកកំពុងជិះទូកធ្លុះ គឺរាងកាយឆ្លងឱយសង្សារទៅកាន់ច្រាំងគឺព្រះនិព្វាន តែទូកគឺសង្ខាររាងកាយរបស់លោកកំពុងនឹងលិច មុនលោកទៅដល់ច្រាំង ឬ ត្រើយ ដែលនៅឆ្ងាយទាល់តែសែនឆ្ងាយមើលមិនឃើញ ទាំងទូកជូនជាលិចថែមទាំងដឹងហើយថា នឹងត្រូវលង់ស្លាប់ហើយនៅធ្វេសប្រហែសស្រែកច្រៀងរាំងចាក់ក្បាច់ព្រងើយយ៉ាងនេះ មិនល្ងង់ខ្លៅទេឬអ្វី ? ” ។

ខ្ញុំឈប់មួយសន្ទុះ សង្កេតអាកប្បកិរិយារបស់បុរសចាស់ កាលឃើញគាត់នៅស្ងៀម ទើបនិយាយតទៅ “ ម្នាលឧបាសក! បើជាអាត្មា អាត្មានឹងមិនធ្វើយ៉ាងនោះ កាលដឹងថាខ្លួនជិះទូកលិចឆ្លងមហា-សាគរមិនដល់ត្រើយពិត អាត្មាក៏មិនកើតសេចក្ដីរួញរាចិត្តទេ ទាំងមិនច្រៀងរាំចាក់ក្បាច់ ដើម្បីនឹងបន្លប់ចិត្តខ្លួនឯងឱ្យភ្លេចថានឹងលិចនោះឡើយ តែត្រូវប្រញាប់ត្រៀមស្បៀង ឧបករណ៍-ពោងទុកក្នុងទូក ខណៈ

ដែលទូកទៅ ក៏ត្រូវគិតជានិច្ចថា ទូកនឹងលិច កាលទូកលិចហើយ អាត្មាប្រញាប់ចាប់យកស្មៀង-ពោង មកប្រើពឹងហែលតទៅរហូតយដល់ច្រាំង ធ្វើយ៉ាងនេះ លោកឃើញថា ជាការធ្វើដោយឆ្លាតឬល្ងង់ ? " ។

"ឆ្លាតច្រើន១" បុរសចាស់ឆ្លើយ ព្រមទាំងញញឹមយ៉ាងពេញចិត្ត ហើយពោលផ្ទួនរឿងរ៉ាប្រៀបធៀបរបស់ខ្ញុំតិច១ ថា " សរីរៈរាងកាយប្រៀបដូចទូកផ្ទះ វដ្តសង្សារប្រៀបដូចមហាសាគរ ច្រាំង ឬ ត្រើយនោះប្រៀបដូចដែនក្សេម គឺព្រះនិព្វាន ហើយស្មៀងនោះ លោកសមណៈប្រៀបនឹងអ្វី ? " ។

" ស្មៀងប្រៀបដូចបុណ្យកុសល ព្រោះកាលស្លាប់ហើយ លោកនឹងនាំទ្រព្យសម្បត្តិណា១ យកទៅជាមួយខ្លួនផងមិនបាន សូម្បីតែសរីរៈរាងកាយ ក៏ត្រូវដុតឬកប់ចោល ទ្រព្យសម្បត្តិក្តី សរីរៈរាងកាយក្តី ជាវត្ថុដ៏គ្រោតគ្រាត យើងបានមកពីលោកគឺផែនដីនេះ វេលាចេញចាកលោកនេះទៅ យើងក៏ចោលទុកនៅលើផែនដីនេះ របស់ដែលលោកនាំទៅបរលោកបាន គឺបុណ្យកុសល លោកនឹងបានអាស្រ័យបុណ្យកុសលនេះឯងជាស្មៀង ហែលឆ្លងភពឆ្លងជាតិទៅកាន់ត្រើយនោះ គឺព្រះ-និព្វាន ម្នាលឧបាស! តើលោកបានធ្វើបុណ្យកុសលអ្វីទុកខ្លះ ហើយឬទេ? "

" មិនធ្លាប់ធ្វើឡើយលោកសមណ: " បុរសចាស់ឆ្លើយដោយមុខក្រៀម " ខ្ញុំរវល់ខ្វល់ខ្វក់នឹងរឿងព្រះពន្ធកូនខ្លះ ស្រែចំការខ្លះ ពពែខ្លះ ការងារក្នុងផ្ទះខ្លះ ទាល់តែមិនមានពេលទំនេរល្មមនឹងធ្វើបុណ្យកុសល "

"បើយ៉ាងនោះ ក៏គួរអាណិតច្រើន មែនហើយការងារចិញ្ចឹមជីវិតត្រូវតែធ្វើ ដើម្បីរស់ តែក៏មិនត្រូវភ្លេចបុណ្យកុសល លោកព្រមប្រគល់ខ្លួនជាមនុស្សបំរើស្មោះត្រង់របស់ពពែខ្លះ របស់ស្រែចំការខ្លះ របស់ការងារខ្លះ តែកាលមរណភ័យមកដល់ កាលទូកគឺសរីរៈរបស់លោកលិចលង់ របស់ទាំងនេះជួយអ្វីលោកមិនបានឡើយ លោកនឹងត្រូវទៅជួបប្រទះនឹងសេចក្ដីងងឹតងងល់ខាងក្រោយសេចក្ដីស្លាប់ កាលនោះឯងលោកនឹងឃើញគុណតម្លៃរបស់ការជួយខ្លួនឯង បើលោកមិនបានធ្វើបុណ្យកុសលទុក លោកនឹងទៅយ៉ាងក្រខ្សត់អត់ឃ្លាន មិនមានស្បៀងអាហារឬអាវុធណាៗ ជាប់តាមខ្លួនទៅផង លោកនឹងត្រូវពើបពះ ប្រទះនឹងសេចក្ដីពិបាកយ៉ាកយ៉ប់ អត់ឃ្លានយ៉ាងសហ័ស្ស ដូចបុគ្គលដែលគ្មានស្បៀង-ពោង កាលទូកលិចលងហើយ ត្រូវអើតកក្នុងផ្ទៃមហាសាគរដែលពេញដោយក្រពើឆ្លាមមករ នឹងខ្យល់ព្យុះព្យោមាដូច្នោះ " ។

សង្កេតមើលបុរសជរា មានមុខស្ងួតក្រៀមក្រំជាងមុន គាត់ប្រហែលគិតខូចចិត្តក្នុងសេចក្ដីធ្វេសប្រហែស ដែលកន្លងមកហើយរបស់ខ្លួន ទើបខ្ញុំនិយាយលួងលោម ណែនាំថា :

" កុំខូចចិត្តអីឱបាសក! វេលានេះនៅមិនទាន់ហួសជ្រុលនៅឡើយទេ ដែលនឹងស្វែងរកស្បៀង គឺបុណ្យកុសលទុក តាំងពីថ្ងៃនេះទៅ សូមឱ្យធ្វើបុណ្យកុសល ដោយការឱ្យទានដល់សមណព្រាហ្មណ៍ និងទុគ្គតជនខ្លះ រក្សាសីល ៥ ឱ្យបរិសុទ្ធជានិច្ច ព្យាយាមអត់សង្កត់កំចាត់សេចក្តីលោភ សេចក្តីក្រោធ សេចក្តីស្រវឹងវង្វេង ដែលកើតឡើងក្នុងចិត្តម្តងមួយគ្រានោះចោលខ្លះ សរុបដោយខ្លី ក៏គឺ ចូរគិតល្អ និយាយល្អ ធ្វើល្អគ្រប់កាលគ្រប់ទីកន្លែង សេចក្តីល្អនោះឯង គឺបុណ្យកុសលដែលនឹងបញ្ជូនលោកទៅកាន់សុគតិពិភព ខាងក្រោយទូកលិចលង់ ដូច្នោះចូរកុំធ្វេសប្រហែស " ។

ខ្ញុំខំទេសនា ប្រៀនប្រដៅបុរសចាស់ រហូតព្រះអាទិត្យជិតលិច ទើបចំរើនពរលាគាត់ធ្វើដំណើរឆ្លងស្ទឹងនេរញ្ជរាតទៅ ។

# គ្រូពេទ្យអ្នកអាន

**លោកអ្នកអានជាទីមេត្រីទាំងឡាយ!** ខណៈដែលធ្វើដំណើរកាន់តែខិតជិតដល់ក្រុងរាជគ្រឹះនោះ ខ្ញុំបានសង្កេតឃើញថា ភូមិប្រទេសជាស្រែចំការច្រើនជាងព្រៃ ផែនដីដូចជាឧត្តម សម្បូណ៌ល្អ ព្រោះដើមស្រូវក្នុងស្រែកន្លែងខ្លះដែលអ្នកស្រែច្រូតកាត់មិនទាន់ហើយ ប្រាកដជាល្អច្រើន គុម្ពធំ គ្រាប់ថ្លោស ។ ថ្ងៃមួយ ខ្ញុំធ្វើដំណើរដើរកាត់ភូមិស្រុកធំៗ ច្រើនកន្លែង សំដែងថាម្ដុំនោះ មនុស្សនៅច្រើនកុះករ តាមវាលស្រែមានកសិករ ទាក់ទងផ្ទុំគ្នាជាពួកៗ ពួកខ្លះក៏សន្ទនាគ្នា លលេងគ្នាសើចក្អាកក្អាយយ៉ាងសប្បាយ ពួកខ្លះក៏មានការច្រៀងរាំងប្រគំតូរ្យតន្ត្រីប្រុសស្រីច្រៀងឆ្លើយឆ្លងគ្នា ដូចជាសប្បាយរីករាយណាស់ គិតមើលក៏គួរប្លែក ដែលពួកគេធ្វើការកណ្ដាលកំដៅព្រះអាទិត្យ មានញើសហូរជោកខ្លួន នៅញញឹមញញែមរីករាយបាន ផ្ទុយទៅវិញមហាសេដ្ឋីដែលនៅលើប្រាសាទប្រាំពីរជាន់ក្នុងមហានគរ ដូចជាចង្អៀតចង្អល់ក្រ — វល់ក្រវាយចិត្តមិនបានរីករាយ ធ្វើឱ្យកើតសេចក្ដីសង្ស័យថា នរណាបានសេចក្ដីសុខពិត ? គិតទៅគិតមកក៏ល្ហមរាវរកឃើញចម្លើយថា សេចក្ដីសុខនៅត្រង់សេចក្ដីពេញចិត្ត សេចក្ដីល្ហមចិត្ត កសិករដែលធ្វើកសិកម្មងូតញើសតាងទឹក បើល្ហមចិត្តក្នុងភាវៈជាអ្នកស្រែរបស់គេ ក៏ជាសុខសូម្បីជាមហាសេដ្ឋីមានប្រាក់៨០កោដិ នៅក្នុងប្រាសាទបើនៅមិនល្ហម

ចិត្តក្នុងភាវៈដូច្នោះ នៅក្រវិនក្រតើនក្រសាវក្រសោប ស្មុះរុលត្បុល ដើម្បីភាវៈយ៉ាងដទៃ ក៏រកសេចក្ដីស្ងប់ចិត្តមិនបាន ដូច្នោះ នឹងយកទ្រព្យខាងក្រៅជាគ្រឿងវាស់សេចក្ដីសុខរបស់មនុស្ស មិនបានគ្រប់គ្រាន់ឡើយ ។

ដើរតទៅទៀតមិនយូរ ខ្ញុំក៏សំឡឹងឃើញកំពូលភ្នំពណ៌ទឹកប្រាក់ចាស់ តាំងនៅពីមុខផ្លូវតទិសបូព៌ា នោះគឺរឿងសំដៅនៃមហានគររាជគ្រឹះ រាជធានីនៃមគធរដ្ឋរបស់ព្រះបាទពិម្ពិសារ រាជគ្រឹះមាននាមមួយទៀតថា **បញ្ចគីរីនគរ** ព្រោះមានភ្នំ ៥ គឺ វេភារៈ, វេបុល្លៈ, គិជ្ឈកូដ, ឥសិគិលិ និងសោណៈ តាំងរឿងរាយនៅជុំវិញក្រុង ជាកំពែងធម្មជាតិ ដ៏រឹងប៉ឹងមាំមួនដែលពួកបច្ចាមិត្តមិនហ៊ានចូលចោមរាយ ខ្ញុំអង្គុយចុះក្រោមម្លប់ដើមឈើធំហើយ សំឡឹងមើលជាយទន្លេ ស្រូវកំពុងទំលឿងច្រាលងាកទៅមើលកំពែងយក្សនៃក្រុងរាជគ្រឹះ ដោយសេចក្ដីត្រេកអរ ព្រោះដឹងថាខ្លួនធ្វើដំណើរមកដល់ចុងផ្លូវគោលដៅរបស់ខ្លួនមួយខណ្ឌហើយ ។

ខណៈដែលអង្គុយសប្បាយនឹងអារម្មណ៍នោះឯង មានបុរសចាស់ម្នាក់ស្ពាយយាមដើមឆ្លងកាត់មក កាលងាកមកឃើញខ្ញុំអង្គុយក្រោមម្លប់ឈើខាងផ្លូវ គាត់បានវៀសចូលមកអង្គុយសម្រាកផង កាលដាក់យាមលើផ្ទៃដីហើយ គេក៏ផ្ដើមសួរខ្ញុំថាមកពីណាទៅណាតាមទំនៀម គេប្រាប់ថាខ្លួនគេជាគ្រូពេទ្យ ដើររក្សាព្យាបាលអ្នកជម្ងឺតាមគាមនិគមជនបទផ្សេងៗ

ហើយក៏បរិយាយដល់សមត្ថភាព ក្នុងការរក្សាអ្នកជម្ងឺរបស់គេឱ្យខ្ញុំស្តាប់យ៉ាងហូរហែ ក្នុងខណៈដែលអួតអាងលើកដំកើនខ្លួនឯងយ៉ាងលើសលុប គាត់ក៏តិះដៀលពេទ្យដទៃៗ យ៉ាងធ្ងន់ផង គាត់និយាយហាក់ដូចជាថា ក្នុងលោកនេះ គាត់វិសេសជាងនរណា ៗ ទាំងអស់ ឆ្លាតដឹងយល់គ្រប់បែបគ្រប់យ៉ាងមិនមានអ្វីដែលគាត់មិនចេះ ទាក់ទងនឹងការអួតអាងខ្លួនរបស់គាត់ ខ្ញុំក៏ដឹងបានភ្លាមថា បុរសចាស់នោះ កំពុងត្រូវទិដ្ឋិមានៈគ្រប់សង្កត់ កំពុងស្រវឹងវិជ្ជា ទាល់តែសំគាល់យល់ថា ខ្លួនជាអ្នកវិសេសតែម្នាក់ឯងក្នុងលោក ខ្ញុំគិតថាបើមិនបង្ក្រាបឱ្យមនុស្សនេះអស់ព្យសន៍ នាទីការប្រៀនប្រដៅមនុស្សរបស់ខ្ញុំត្រូវតក់ឆ្គង ទើបខ្ញុំដើរនយោបាយកែទិដ្ឋីមានៈរបស់គាត់ដោយការផ្តើមសន្ទនាថា " ម្នាលឧបាសក ! អាត្មាកើតមកក្នុងលោកនេះ ក៏ច្រើនឆ្នាំហើយទាំងបានធ្វើដំណើរដើរត្រេចសឹងជុំវិញដែនដីមធ្យមប្រទេស តែមិនដែលជួបប្រទះពេទ្យណាម្នាក់ ដែលមានចំណេះចេះជំនាញ ពេញដោយសមត្ថភាពដូចយ៉ាងលោកឡើយ លោកជាគ្រូវពេទ្យដ៏ជំនាញបំផុត ជាងគ្រូពេទ្យទាំងឡាយដែលអាត្មាធ្លាប់ជួបប្រទះមក " ។

បុរសចាស់ញញឹមយ៉ាងពេញចិត្ត ហើយពោលយ៉ាងរីករាយ "ត្រូវហើយលោកសមណៈ បើនឹងនិយាយតាមពិតហើយ មិនមានថ្នាំប្រភេទ

ណាដែលខ្ញុំមិនដឹង មិនមានរោគប្រភេទណា ដែលខ្ញុំព្យាបាលមិនបាន នេះនិយាយគ្នាតាមពិត មិនមែននិយាយអួតលើកខ្លួនឯងទេ ”។

“អាត្មា ជឿលោក” ខ្ញុំថ្លែងសរសើរគេតទៅ “ រាប់ថាជាជោគប្រសើររបស់អាត្មាដែលបានមកជួបលោក ព្រោះអាត្មាមានញាតិម្នាក់នៅក្នុងក្រុងរាជគ្រឹះមានជម្ងឺឈឺជាទម្ងន់ ចង់អញ្ជើញលោកទៅត្រួតមើលសមុដ្ឋានរោគ ហើយប្រកបផ្សំថ្នាំព្យាបាលឱ្យផង បើលោកព្យាបាលបានសះជា អាត្មានឹងជូនរង្វាន់យ៉ាងគាប់ចិត្ត ”។

“ ទុកចិត្តខ្ញុំចុះ លោកសមណៈ ” បុរសចាស់ពោលហើយសើចយ៉ាងជឿមាំក្នុងខ្លួនឯង “ខ្ញុំពេញចិត្តនឹងរក្សាព្យាបាលមនុស្សជម្ងឺ ដោយមិនកីរិតថ្លៃ សូមប្រាប់អាការៈរោគរបស់គេមកចុះ ខ្ញុំនឹងស្រាវជ្រាវសមុដ្ឋានរោគ ហើយផ្សំថ្នាឱ្យឥឡូវនេះ ”។

កាលបានលលួងគ្រូពេទ្យវិសេសធ្លាក់រណ្ដៅហើយ ខ្ញុំក៏ផ្ដើមចងភ្លាម “ អាការៈរោគរបស់គេជាយ៉ាងនេះ គឺកាលមុនគេក៏រឹងប៉ឹងល្អដូចជាអាត្មាដែរ ដែលពេលក្រោយត្រឡប់ក្លាយជាមនុស្សអន់ទន់ខ្សោយយ៉ាងគួរអាណិត សាច់ស្បែកដែលធ្លាប់តែតឹងហាប់ ក្លាយជាជ្រីវជ្រិតស្វិតយុរយារសព្វសាពាង្គកាយ សក់ដែលធ្លាប់ខ្មៅស្រិល ក្លាយជាសដូចសំឡីដួងភ្នែកដែលធ្លាប់ភ្លឺថ្លា បែរជាល្អក់ងងឹតមើលមិនឃើញ ត្រចៀកដែលធ្លាប់បានឮសំឡេងច្បាស់ ក្លាយជាហ៊ឹងស្លង់ ស្ដាប់អ្វីមិនបានការ ធ្មេញ

ដែលធ្លាប់សរឹងពេញមាត់ ក៏សណ្ដកបាត់ទៅម្ដងមួយៗទាល់តែអស់រលីង ខ្នងដែលធ្លាប់ត្រង់ល្អ ក៏បែរជាកោងគមទៅខាងមុខ ត្រូវប្រើឈើច្រត់វេលាដើរ សតិដែលធ្លាប់ល្អ ក៏ទៅជាភ្លេចៗ មនុស្សទាំងឡាយហៅថា គេកើត **រោគជរា** វេលានេះមានអាការធ្ងន់ធុនដាបណាស់ហើយ សូមលោកមេត្តាអញ្ជើញទៅរក្សាព្យាបាលគេ ឱ្យជាប្រក្រតីដូចដើមវិញផងចុះ” ។

លុះខ្ញុំនិយាយចប់ ពេទ្យវិសេសក៏ផ្ទុះសំណើចយ៉ាងខ្លាំងហើយនិយាយថា “ រោគយ៉ាងនេះ គេមិនព្យាបាលទេលោកសមណៈ ព្រោះវាជាធម្មតារបស់សង្ខារ ” ។

“ មិនរក្សារោគយ៉ាងនេះ នឹងទៅរក្សារោគអ្វីវិញ ? ” ខ្ញុំសួរ

“ ក៏រក្សារោគដទៃៗ ដូចរោគឈឺក្បាល ឈឺពោះ ឈឺធ្មេញជាដើម ” ។

“ទាំងនេះជារោគតូចៗ តិចៗ នរណាព្យាបាលក៏បាន តែរោគជរានេះ ជារោគខ្លាំងក្លាយ៉ាងបំផុត កើតនឹងមនុស្សពេញពិភពលោក ពេទ្យដទៃៗមិនព្យាបាល ព្រោះគេមិនពូកែដូចលោក លោកពូកែជាងពេទ្យទាំងអស់ លោកគួរនឹងព្យាបាលបាន បើលោកព្យាបាលរោគប្រភេទនេះសះជា លោកនឹងជាពេទ្យស្ដុកស្ដម្ភយ៉ាងបំផុតក្នុងលោក ថាយ៉ាងណាលោកទទួលរក្សាព្យាបាលទេ ? ” ។

" ខ្ញុំរក្សាព្យាបាលនបាន " ពេទ្យវិសេសពោលដោយសំឡេងខ្សោយចុះ ។

" បើលោករក្សាព្យាបាលរោគប្រភេទនេះឱ្យសះជាមិនបាន លោកក៏មិនប្រសើរវិសេសជាងពេទ្យទាំងឡាយដទៃៗទៀតទេ ការដែលលោកនិយាយអួងអាងថា លោកជាពេទ្យជំនាញ មានសមត្ថភាពជាងពេទ្យទូទៅ គឺការនិយាយលើសសេចក្ដីពិតព្រោះអំណាចទិដ្ឋីមានះប៉ុណ្ណោះឯង " ។

ពេទ្យវិសេសអង្គុយឈ្ងោកមុខ ដោយសេចក្ដីអៀនខ្មាស មិនបានតបតនឹងខ្ញុំថាយ៉ាងណា យកដៃគូសដីទៅមក " ម្នាលឧបាសក! " ខ្ញុំកាន់ឱកាសប្រៀនប្រដៅតទៅ " រោគកំណាចកាចសាហាវដែលបំផ្លាចសេចក្ដីសុខរបស់មនុស្សមាន ៣ ប្រការគឺ រោគចាស់ រោគឈឺ រោគស្លាប់ រោគចាស់និងរោគស្លាប់ លោករក្សាព្យាបាលមិនបានទេ និងគ្មានពេទ្យសាមញ្ញាណារក្សាព្យាបាលឱ្យសះជាបាន, រក្សាព្យាបាលបានខ្លះ តែចំពោះរោគឈឺថ្កាត់តែម្យ៉ាងប៉ុណ្ណោះ ជម្ងឺឈឺថ្កាត់ខ្លះលោកក៏រក្សាព្យាបាលមិនបាន ជាការសមគួរហើយឬ ដែលលោកសំគាល់ថាខ្លួនជាពេទ្យវិសេសបំផុតក្នុងលោក ? ។

**លោកគ្រូពេទ្យ!** ក្នុងលោកនេះ មានសិល្បសាស្ត្រច្រើនពន់ពេក ដែលមនុស្សរាវរកជួបនឹងសិក្សាក្នុងជម្ពូទ្វីប បើរួមមក ក៏មានដល់

១៨ ប្រការ វេជ្ជសាស្ត្ររបស់លោកត្រឹម ១ ក្នុង ១៨ ប៉ុណ្ណោះ សូម្បីតែវេជសាស្ត្រមួយ ក៏មានច្រើនផ្នែកបែកជាមែកធាងធំទូលាយហួសសមត្ថ-ភាពដែលលោកនឹងសិក្សាឱ្យចប់សព្វគ្រប់ទាំងអស់បាន បាប់ពោលថ្វីដល់សាស្ត្រវិជ្ជាដទៃៗ មិនមាននរណាអាចនឹងសិក្សាឱ្យចេះចាំទាល់តែចប់សព្វសិល្បសាស្ត្រទាំងពួងបាន ព្រោះនឹងប្រើពេលវេលាជាពាន់ៗឆ្នាំ តែអាយុរបស់មនុស្ស មានកំណត់យ៉ាងយូរណាស់ត្រឹមមួយរយឆ្នាំប៉ុណ្ណោះ ទើបមិនគ្រប់គ្រាន់ល្មម ដែលនឹងសិក្សាឱ្យចេះសព្វសិល្បសាស្ត្រទាំងពួងបាន ។

**លោកគ្រូពេទ្យ!** វត្ថុទាំងពួងក្នុងសាកលចក្កវាឡមានប្រភេទរាប់ចំនួនសែន តែលោកដឹងរឿងវេជ្ជសាស្ត្រត្រឹមតូចមួយប៉ុណ្ណោះ សេចក្តីចេះដឹងរបស់លោក ទើបមានត្រឹមតែមួយក្នុងចំនួយសែនប៉ុណ្ណោះ រាប់ថាជាការចេះដឹងតិចតួចណាស់ សមគួរហើយឬ ដែលលោកដើរអួតអាងថាលោកប្រសើរវិសេសជាងអ្នកដទៃ ! ” ។

“ **លោកមសណៈដ៏ចំរើន !** ខ្ញុំទើបនឹងដឹងខ្លួនអម្បាញមិញនេះឯងថា ខ្លួនមានចំណេះចេះដឹងក្នុងរឿងវេជ្ជសាស្ត្រត្រឹមបន្តិចបន្តួចប៉ុណ្ណោះ ខ្ញុំនឹកអៀនខ្លួនពន់ពេក ដែលបាននិយាយអួតអាងប្រាប់គេប្រាប់ឯងថាខ្លួនជាមនុស្សវិសេស ដោយអំណាចសេចក្តីស្រវឹងវង្វេងចេះគិតខុសថា

ខ្លួនជាអ្នកវិសេសក្នុងលោក តទៅខ្ញុំនឹងមិនធ្វើដូច្នោះទៀត ” ថាហើយ គេក៏ក្រាបសំពះយ៉ាងឱនលំទោន ។

**លោកគ្រូពេទ្យ!** មនុស្សល្ងង់ កាលបានទទួលការសិក្សាត្រឹមបន្តិចបន្តួច រមែងកើតសេចក្ដីក្អេងក្អាងក្នុងវិជ្ជារបស់ខ្លួន សំគាល់ថាខ្លួនវិសេសវិសាល ហើយដើរនិយាយអួតអាងកាងក្រទាប្រាប់អ្នកដទៃ ដើរកំហែងគម្រាមអ្នកដទៃ ជាមនុស្សរឹងត្អឹង ក្រអឺតក្រអោង កោងព្រហើម មិនព្រមទន់ភ្លន់ចំពោះនរណា មិនដឹងថាខ្លួនកំពុងអួតសេចក្ដីល្ងង់របស់ខ្លួន ។

មនុស្សបែបនោះ លោកប្រៀបដូចកង្កែបចាស់នៅតែក្នុងរណ្ដៅតូច មិនដែលទៅឃើញស្ទឹងទន្លេ និងមហាសមុទ្ទម្ដងសោះ ក៏យល់ថារណ្ដៅតូចរបស់ខ្លួន ធំបំផុតក្នុងលោក ដើរនិយាយអួតអាងប្រាប់គេ តែកាលណាកង្កែបនោះបានឱកាសចេញទៅឃើញស្ទឹង ទន្លេ ឬ សមុទ្ទ វានឹងដឹងសេចក្ដីពិតថា តាមពិតរណ្ដៅរបស់វាតូចមួយប៉ុណ្ណោះ តូចយ៉ាងគ្មានសេចក្ដីសំដៅអ្វីឡើយ វានឹងនឹកអៀនចិត្ត ដែលធ្លាប់ដើរអួតអាងរណ្ដៅតូចមួយរបស់ខ្លួន វានឹងក្លាយជាកង្កែបស្ងប់ស្ងៀម មិនក្អេងក្អាងតទៅទៀត ។

**លោកគ្រូពេទ្យ!** កង្កែបចាស់ ដែលបានទៅឃើញ ស្ទឹង ទន្លេង មហាសមុទ្ទ រមែងឃើញរណ្ដៅរបស់ខ្លួនតូច ទាល់តែណាស់យ៉ាងណា

លោកអ្នករៀនចេះដឹងច្រើនៗ រមែងឃើញថាខ្លួនចេះដឹងតិចៗ ទៅដូច្នោះ រៀនចេះដឹងច្រើនឡើង ក៏មើលដូចជាខ្លួនចេះតិច កាន់តែល្ងង់ទៅ ព្រោះអ្វីដែលត្រូវរៀនមានច្រើនលើសពន់ប្រមាណ រហូតអាយុ និងសមត្ថភាព ផ្លូវប្រាជ្ញារបស់មនុស្សមិនគ្រប់គ្រាន់ នឹងរៀនឱ្យចេះចប់ទាំងអស់បាន ព្រោះហេតុនោះ លោកអ្នកមានសេចក្តីចេះដឹងច្រើនមែនៗ ទើបជាមនុស្សទន់ភ្លន់ គួរគោរពរាប់អាន មានចិត្តទូលំទូលាយ រមែងព្រមទទួលថា ខ្លួនមិនដឹងក្នុងវិជ្ជាដែលមិនទាន់បានរៀន នឹងព្រមទទួលកំហុសកាលខ្លួននិយាយខុស ធ្វើខុស ចំណែកអ្នករៀនចេះដឹងបន្តិចបន្តួចច្រើនស្រវឹងវង្វេង ក្រអឺតក្រអោងក្នុងសេចក្តីចេះដឹងនោះ សំគាល់ថាខ្លួនឆ្លាតយ៉ាងបំផុត ពូកែយ៉ាងបំផុត ល្អយ៉ាងបំផុតក្នុងកណ្តាលជំនុំជន កើតទិដ្ឋិមានះប្រកាន់ខ្លួន ក្រអឺតក្រអោងសំគាល់ថា គ្រប់យ៉ាងដែលខ្លួនគិតនិយាយ ធ្វើសុទ្ធតែត្រូវជានិច្ច សូម្បីអ្នកដទៃឃើញខុស ក៏នៅកៀបក្រាញថាខ្លួនត្រូវ បើគ្មានផ្លូវតស៊ូនឹងគេពិតៗ ក៏លើកកំហុសឱ្យអ្នកដទៃ មនុស្សប្រភេទនេះ មិនព្រមសារភាពថាខ្លួនល្ងង់ ទាំងដែលខ្លួនកំពុងល្ងង់ខំអួតឆ្លាត ទាំងដែលខ្លួនគ្មានសេចក្តីឆ្លាត ប្រហែលនឹងមនុស្សយកមាសប្លមទៅដើរពាយនាយលក់ ប្រាកដជាលក់បានតែម្តងប៉ុណ្ណោះ ពេលក្រោយ កាលគេដឹងសេចក្តីពិតហើយ មុខជាគ្មាននរណាទិញឡើយ” ។

" **លោកសមណៈដ៏ចំរើន!** ហេតុផលរបស់លោក ដូចជាដួងប្រទីបដ៏ភ្លឺត្រចះត្រចង់ឆេះឡើយក្នុងចិត្តដ៏ងងឹតងងល់ ដោយមោហៈរបស់ខ្ញុំ ធ្វើឱ្យខ្ញុំកើតសេចក្តីយល់ច្បាស់ក្នុងបញ្ហាជីវិតយ៉ាងសំខាន់ ដែលមិនធ្លាប់ដឹងពីមុនមក លោកបានធ្វើឧបការគុណដ៏ធំក្រៃលែងចំពោះខ្ញុំ ខ្ញុំគ្មានរបស់អ្វីនឹងបូជាគុណរបស់លោក តែបើលោកប្រាថ្នា ខ្ញុំត្រេកអរនឹងបង្រៀនសិល្បសាស្ត្ររបស់ពេទ្យ ដែលខ្ញុំចេះដឹងទាំងអស់ដល់លោក ដើម្បីលោកនឹងបានមានវិជ្ជា សម្រាប់រកចិញ្ចឹមជីវិតតទៅ ។

"សូមអរគុណក្នុងបំណងល្អរបស់លោក តែអាត្មាមិនប្រាថ្នានឹងសិក្សាវិជ្ជាវេជ្ជសាស្ត្រអំពីលោកទេ ព្រោះអាត្មាឯងជាគ្រូពេទ្យស្រាប់ហើយ " ។

បុរសចាស់ សំឡឹងមើលមុខខ្ញុំយ៉ាងនឹងប្លែកក្នុងចិត្ត ហើយថា "លោកក៏ជាគ្រូពេទ្យដែរឬ លោកមានការជំនាញក្នុងការរក្សាព្យាបាលរោគអ្វី ? " ។

" អាត្មាជាគ្រូពេទ្យដែរ តែមិនមែនពេទ្យព្យាបាលរោគកាយ ជាពេទ្យារក្សារោគចិត្ត អ្នកណាមិនសប្បាយចិត្ត ព្រោះលោភៈ ទោសៈ មោហៈ អាត្មាព្យាបាលឱ្យបាត់បាន ថ្នាំរបស់អាត្មា គឺការដឹងស្គាល់យល់ក្នុងសេចក្តីពិត មនុស្សឈឺចិត្តកាលបានទទួលថ្នាំ គឺការដឹងស្គាល់យល់ក្នុងសេចក្តីពិត មនុស្សកើតរោគចិត្ត កាលបានទទួលថ្នាំ គឺសេចក្តីដឹងពីអាត្មាហើយ នឹងមានចិត្តស្អាតសុខស្ងប់ ត្រជាក់ត្រជំ រីករាយ

រៀងរាបទៅ រោគកាយដែលលោកព្យាបាល មនុស្សខ្លះក៏ជា ខ្លះក៏មិនជា តែគ្រប់មនុស្សកើតរោគចិត្តគ្រប់គ្នាទាំងអស់ ដូច្នោះ អ្នកជម្ងឺរបស់អាត្មាទើបមានពេញពិភពលោក អាត្មាត្រេចចររក្សាព្យាបាលរៀងរាបមក”

“លោកជាគ្រូពេទ្យដែលឆ្លាតបំផុត មានអ្នកជម្ងឺច្រើនបំផុត ខ្ញុំគិតថា លោកគង់នឹងបានថ្លៃឈ្នួលរង្វាន់ច្រើនបំផុតផង ” ។

“ ត្រូវហើយ អាត្មាបានរង្វាន់ច្រើនបំផុត តែរង្វាន់របស់អាត្មា គឺសេចក្ដីសុខសប្បាយចិត្ត ដែលបានធ្វើប្រយោជន៍ដល់មិត្តមនុស្សជាតិមិនមែនកែវកង ពេជ្រ មាស ប្រាក់ ព្រោះរបស់ទាំងនេះ ឱ្យសេចក្ដីសុខបន្តិចបន្តួច មួយដងមួយគ្រាប៉ុណ្ណោះ តែសេចក្ដីសុខចិត្តដែលបានពីការជួយសង្គ្រោះដោះទុក្ខអ្នកដទៃ ឱ្យសេចក្ដីសុខដល់អាត្មាជានិរន្តកាល ” ។

បុរសចាស់ ក្រាបសំពះខ្ញុំយ៉ាងឱនលំទោនជាគ្រាចុងបំផុត ហើយក៏លាបែកទៅ ខ្ញុំតាមមើលគេទាល់តែផុតកន្ទុយភ្នែក នឹងសប្បាយរីករាយត្រជាក់ចិត្ត ដែលបានជួយរក្សាព្យាបាលគេឱ្យសះជាចាករោគ គឺសេចក្ដីស្រវឹងវិជ្ជា ដែលធ្វើចិត្តគេឱ្យងងឹតងងល់មកយូរហើយ ខ្ញុំនៅសម្រាកក្នុងទីនោះ ល្មមដល់សេចក្ដីត្រូវការហើយ ក៏ស្ពាយបាត្រចេញធ្វើដំណើរតទៅទៀត ។

# គណៈល្ខោន

**លោកអ្នកអានជាទីមេត្រី !** មុនព្រលប់ថ្ងៃនោះឯង ខ្ញុំក៏បានដល់ទ្វារក្រុងរាជគ្រឹះផ្នែកខាងជើង ដែលជាច្រករវាងភ្នំវេភារៈ និងវេបុល្លៈ ជិតជើងភ្នំវេបុល្លៈខាងក្រៅក្រុង មានអណ្តូងទឹកក្តៅខ្នាតធំ ហូរចេញមកពីក្រោមផែនដី ហើយហូរឆ្លងកាត់តាមទំនាបរវាងភ្នំចូលទៅក្នុងក្រុង អ្នកស្រុកហៅស្ទឹងខ្នាតតូចនេះថា **តបោតាទនី** ។ អ្នកក្រុងរាជគ្រឹះតាំងពីព្រះបាទពិម្ពិសារចុះមក និយមមកស្រងនិងងូតស្នានកាយនាអណ្តូងទឹកក្តៅនេះ ព្រោះហេតុដែលទឹកក្តៅ ហូរចេញមកពីក្រោមផែនដី មនុស្សទូលទៅទើបជឿថា ខាងក្រោមអណ្តូងទឹកក្តៅនោះ ជាទីនៅរបស់លោហកុម្ភីនរក ខ្ញុំដាក់បាត្រចុះពីស្មាហើយ ក៏អង្គុយសម្រាកនៅក្រោមម្លប់ឈើ ក្នុងរយៈឆ្ងាយសំឡឹងមើលពួកប្រជាជន ដែលកំពុងងូតទឹកយ៉ាងសប្បាយ ។

ខណៈដែលកំពុងអង្គុយភ្លើតភ្លើននោះ មានមនុស្សមួយក្រុម ប្រមាណ ៨ នាក់ សែងរបស់របរខ្លួន ចូលមកអង្គុយសម្រាកនិងខ្ញុំ លុះទុកដាក់ ប្រដាប់ប្រដារៀបរយហើយ ប្រាំពីរនាក់ក្នុងចំនួននោះ ក៏ផ្លាស់សំពត់ចុះទៅងូតទឹក នៅសល់តែម្នាក់សម្រាប់ចាំមើលប្រដាប់ប្រដាមើលទៅអាកប្បកិរិយាឃើញថា គេប្រយ័ត្នប្រយែងរបស់គេណាស់ ។

"ឧបាសក! បើលោកបង់ទៅងូតទឹក ក៏ទៅចុះអាត្មានឹងជួយមើលប្រដាប់ប្រដាឱ្យ " ខ្ញុំពោលនឹងគេដោយសេចក្តីអើពើ គេដើរចូលមកអង្គុយខាងមុខខ្ញុំ លើកដៃសំពះហើយឆ្លើយ " អរគុណលោកច្រើន តែខ្ញុំមិនងូតទឹកឥឡូវនេះទេ " ។

" ពួកលោកទៅណាមកណា មើលទៅប្រដាប់ប្រដាដូចជាច្រើនណាស់ " ។

"ពួកខ្ញុំជាពួកលេងល្ខោន មកពីក្រុងបាដលីបុត្ត ដើរសំដែងល្ខោនរកប្រាក់តាមគាមនិគមផ្សេងៗ តើលោកមកពីណាដែរ ? " ។

" អាត្មាមកពីក្រុងសាវត្ថី រាជធានីនៃកោសលរដ្ឋ ដែលនៅឆ្ងាយទៅទិសខាងលិច អាត្មាជាពួកល្ខោនដែរ ដើរសំដែងល្ខោនទៅតាមគាមនិគមផ្សេងៗ រហូតដល់ក្រុងរាជគ្រឹះក្នុងថ្ងៃនេះ " ។

បុរសនោះ សំឡឹងមើលខ្ញុំយ៉ាងសង្ស័យ ហើយសួរ " លោកមកតែម្នាក់ឯង ឬមានចិត្តរួមដំណើរមកផង ខ្ញុំឃើញលោកអង្គុយតែម្នាក់ឯង " ។

" អាត្មាមកតែម្នាក់ឯង " ខ្ញុំឆ្លើយ គេសើចហើយនិយាយថា "បើយ៉ាងនោះ គណល្ខោនរបស់លោកក៏មានមនុស្សតែម្នាក់ប៉ុណ្ណោះ លោកសំដែងល្ខោនម្នាក់ឯងបានយ៉ាងណា ខ្ញុំឆ្ងល់ណាស់ " ។

" ល្ខោនរបស់អាត្មា អាចនឹងផ្សេងពីល្ខោនរបស់លោកខ្លះ អាត្មាសូមសួរបន្តិចថា វិធីការសំដែងល្ខោនរបស់លោកជាយ៉ាងណា ដើម្បីនឹងបានប្រៀបធៀបនឹងវិធីការរបស់អាត្មា " ។

" លោកសមណៈនេះ ប្រហែលមិនធ្លាប់មើលល្ខោនទេ ខ្ញុំនឹងពន្យល់ឱ្យស្តាប់ " គេនិយាយយ៉ាងរីករាយ " កាលនឹងសំដែងល្ខោននៅទីណា ពួកខ្ញុំក៏នាំគ្នាសាងរោងឡើងជាមុន យកវាំងននចងបាំងចំកណ្តាលរោង បែងរោងជាឆាកមុខសំរាប់សំដែងល្ខោន និងឆាកក្រោយសម្រាប់ជាទីស្នាក់ កាលប្រឹក្សាព្រមព្រៀងគ្នាថានឹងសំដែងរឿងអ្វីហើយ ក៏មានការតែងតាំងគ្នាជាព្រះមហាក្សត្រខ្លះ ជាព្រះរាជិនីខ្លះ ជាសេនាបតីខ្លះ ជាបុរោហិតចារ្យខ្លះ ជាមេទ័ពខ្លះ ជាចោរខ្លះ ជាស្រីប្រុសអ្នកបំរើខ្លះ តាមសាច់រឿង តពីនោះក៏ចេញមកសំដែងលើវេទិកា ចំពោះមុខមហាជនតាមបទបាទរបស់ខ្លួន " ។

" បើយ៉ាងនោះ ល្ខោនរបស់ពួកលោក ក៏ជារឿងភរបញ្ឆោតគ្នាយ៉ាងច្បាស់លាស់នោះឯង " ខ្ញុំនិយាយកាត់រឿង ធ្វើឱ្យបុរសនោះ សំ-ឡឹងមើលខ្ញុំដោយសេចក្តីមិនពេញចិត្តភ្លាម " ភរបញ្ឆោតយ៉ាងម៉េច ? " គេសួរ ។

" ភរបញ្ឆោតយ៉ាងនេះ គឺរឿងដែលលោកសំដែងនោះ មិនមែនរឿងពិតជារឿងដែលកវីសរសេរឡើងតាមចិន្តនាការ ឬមនោគតិរបស់

គេ ក្នុងវេលាសំដែង ជួនកាលលោកអាចបានទទួលសន្មតជាក្សត្រ តែនោះ ក៏ត្រឹមជាការភរបញ្ឆោត ព្រោះលោកមិនមែនជាក្សត្រពិតៗ នរ-ណាៗ ក៏ដឹង ជួនកាលក៏ធ្វើជាក្រេវក្រោធខ្លះ សើចខ្លះ តែនោះ ក៏ត្រឹមតែជាការក្លែងធ្វើ ជួនកាលក៏សំដែងជាកើតសឹកសង្គ្រាម តែមិនមែនជាសង្គ្រាមពិត ជួនកាលលោកអាចធ្វើជាត្រូវអាវុធស្លាប់ តែមិនមែនស្លាប់ទេ ព្រោះបើស្លាប់ឡពិតលោកមិនអាចមកអង្គុយនិយាយនឹងអាត្មា ក្នុងទីនេះបានទេ កាលបើយ៉ាងដូច្នេះ មិនមែនល្ខោនភរបញ្ឆោតឬ! ” ។

បុរសអ្នកលេងល្ខោនអង្គុយឈ្ងោកមុខនៅស្ងៀម ដោយទល់ចំពោះហេតុផលរបស់ខ្ញុំ ទើបខ្ញុំពោលតទៅថា “ កាលលោកភរបញ្ឆោត ប្រ-ជាជនដែលមើលក៏វង្វេង គឺយល់ខុសថាជាពិតមែនតាមនោះ ហើយកើតអារម្មណ៍ផ្សេងៗ ដូចសោកសៅខ្ទួចចិត្តខ្លះ ខឹងស្អប់ខ្ពើមខ្លះ អាណិតឃើញចិត្តឃើញថ្លើមខ្លះ កើតការអស់សំណើចសើចសប្បាយខ្លះ ស្រេចតែសាច់រឿងលោកសំដែង តែស្រេចហើយ ក៏គ្មានផលអ្វីកើតឡើងក្រៅពីអារម្មណ៍ផ្សេងៗប៉ុណ្ណោះឯង ” ។

“ ខ្ញុំយល់ស្របតាមលោក” គេពោលឡើងក្រោយពីអង្គុយស្ងៀមយូរ “ តែគួរឱ្យប្លែកដូចគ្នាដែរលោកសមណៈ ពួកអ្នកមើលទោះដឹងថាល្ខោនរបស់ខ្ញុំ ជារឿងភរបញ្ឆោតហើយប្រជាជនក៏នៅតែចូលចិត្តមើលពន់ពេក ” ។

" នោះជាសេចក្តីពិត ព្រោះមនុស្សល្ងង់ខ្លៅចូលចិត្តការលលួងភរបញ្ឆោតផ្សេងៗ នោះឯង អាត្មានឹងពិសោធឱ្យឃើញឥឡូវនេះក៏បានថាមនុស្សយើងចូលចិត្តការលលួងភរបញ្ឆោតយ៉ាងណា " ជួនជាពេលនោះ មានបុរសម្នាក់ អាយុប្រមាណ ៦០ ឆ្នាំ ដើរកាត់មក ខ្ញុំបានហៅឱ្យគេចូលមកអង្គុយសម្រាកក្រោមដើមឈើ ហើយក៏សន្ទនាសាកសួររឿងផ្សេងៗ " ម្នាលឧបាសក លោកអាយុប៉ុន្មានហើយ " ។

" ៦០ ឆ្នាំហ្វើ លោកសមណៈ " បុរសចាស់ឆ្លើយ ។

"អាត្មាដូចជាមិនចង់ជឿថាលោកអាយុដល់៦០ឆ្នាំ ព្រោះមើលថាថាងលោកនៅក្មេងច្រើន បើឱ្យអាត្មាទាយ អាត្មានឹងទាយថា ៤០ ឆ្នាំជាយ៉ាងច្រើន "។

លុះនិយាយចប់ប៉ុណ្ណោះ បុរសចាស់ក៏ញញឹមដោយសេចក្តីត្រេកអរពេញចិត្តភ្លាម ងាកសំឡឹងមើលតាមសរីរៈរូបដ៏ទ្រុឌទ្រោមរបស់ខ្លួន គាត់និយាយនិងខ្ញុំដោយសេចក្តីរីករាយ សប្បាយជាងដើម ក្នុងទីបំផុតគាត់ក៏និមន្តឱ្យខ្ញុំចូលទៅឆាន់ភត្តាហារក្នុងផ្ទះរបស់គាត់ថែមទៀត ។

"ឃើញទេឧបាសក!" ខ្ញុំពោលនិងបុរសអ្នកលេងល្បែងនកាលបុរសចាស់នោះ ក្រោកទៅបាត់ហើយ "បុរសចាស់នោះអាយុ ៦០ ឆ្នាំ សង្ខាររាងកាយរបស់គាត់ទ្រុឌទ្រោមគ្រាំគ្រាគ្រប់ចំណែកទៅហើយ គាត់

ក៏ដឹងខ្លួនច្បាស់ តែលុះអាត្មាលលួងថា គាត់នៅក្មេងប៉ុណ្ណោះ ក៏សំដែងអាការថា ពេញចិត្តពេញថ្លើមយ៉ាងចេញមុខចេញមាត់ នេះសំដែងឱ្យឃើញថា មនុស្សល្ងង់រមែងចូលចិត្តការភរបញ្ឆោតលលួង " ។

" ចុះល្ខោនរបស់លោកនោះ លោកសមណៈ លោកមានវិធីការសំដែងយ៉ាងដូចម្តេច ? " ។

" ល្ខោនរបស់អាត្មាជាល្ខោនពិត សំដែងរឿងពិត ធ្វើឱ្យអ្នកស្តាប់បានដឹងសេចក្តីពិតកើតបញ្ញានិងគំនិតថ្មី យកទៅប្រតិបត្តិដើម្បីប្រយោជន៍សុខដល់ខ្លួន និងអ្នកដទៃ កាលនៃទៅសំដែងទីណា មិនចាំបាច់សាងវេទិកា ព្រោះអាត្មាប្រើវេទិកាពិត លោកនេះទាំងមូល គឺវេទិកាល្ខោនរបស់អាត្មា ជួនកាលអ្នកស្តាប់មានត្រឹមតែម្នាក់ ជួនកាលក៏មានច្រើននាក់ អាត្មាសំដែងល្ខោនដោយការអធិប្បាយបញ្ហាជីវិតផ្សេងៗ ឱ្យគេស្តាប់ បន្ធូរបន្ថយសម្រាលសោកសៅរបស់អ្នកកំពុងសោក សម្រាលបន្ធូរសេចក្តីក្រោធ របស់អ្នកកំពុងក្រោធ សម្រាលសេចក្តីស្រវឹងវង្វេងរបស់អ្នកកំពុងស្រវឹងវង្វេង បន្ថយសេចក្តីអាក្រក់ របស់អ្នកកំពុងធ្វើអា-ក្រក់ បន្ថែមសេចក្តីល្អរបស់អ្នកកំពុងធ្វើល្អ អ្នកស្តាប់ល្ខោនរបស់អាត្មាមកហើយ បានទទួលសេចក្តីដឹង សេចក្តីយល់ ភ្ញាក់កំណើតកើតគំនិតយ៉ាងប្រសើរគ្រប់គ្នា " ។

" ល្ខោនរបស់លោកប្លែកណាស់ " បុរសនោះពោលយ៉ាងប្រើ

គំនិត " មិនបាច់ប្រើមនុស្សច្រើន មិនបាច់សាងវេទិកា ហើយលោកគិតយកឈ្នួលពីអ្នកមើល អ្នកស្តាប់យ៉ាងណា ? " ។

" អាត្មាមិនបានយកថ្លៃឈ្នួល ពីអ្នកស្តាប់ជាមាសជាប្រាក់ឬវត្ថុអ្វី ៗ ព្រោះមាសប្រាក់មកហើយក៏ប្រើអស់ទៅ ផលតបស្នងសងវិញដែលអាត្មាបានទទួល គឺសេចក្តីក្សេមក្សាន្ត ដែលខ្លួនបានធ្វើប្រ-យោជន៍ដល់អ្នកដទៃ សេចក្តីត្រជាក់ត្រជុំក្សេមក្សាន្តចិត្ត ដែលមិនអាចរកបានពីមាសប្រាក់ " ។

" បើយ៉ាងនោះ អ្នកដែលសំដែងល្ខោនបែបលោកបាន ត្រូវជាអ្នកមានចិត្តលះបង់យ៉ាងពិតប្រាកដ " ។

" យ៉ាងហ្នឹងពិតមែនហើយ អ្នកដែលនៅឃើញដល់ខ្លួនឬពួកបក្សរបស់ខ្លួន រមែងសំដែងល្ខោនបែបនេះមិនបាន ត្រូវមានចិត្តទូលំទូលាយក្លាហាន និងមានមេត្តាករុណាប្រចាំចិត្តជានិច្ច ត្រូវគិតដល់អ្នកដទៃមុនខ្លួនឯង កាលមានផលប្រយោជន៍កើតឡើង ត្រូវគិតឱ្យអ្នកដទៃបានទទួលផលប្រយោជន៍នោះមុនខ្លួនឯង តែកាលសេចក្តីទុក្ខយ៉ាកលំបាកកើតឡើង ត្រូវទទួលមុនអ្នកដទៃ ។

ខណៈដែលយើងទាំងពីរនាក់ កំពុងសន្ទនាគ្នានោះ គណៈល្ខោនទាំង ៧ នាក់ ដែលទៅងូតទឹកក៏ត្រឡប់មកហើយ បានប្រាប់គូសន្ទនារបស់ខ្ញុំឱ្យទៅងូតទឹក តែគេឆ្លើតថា " មិនងូតទឹកទេថ្ងៃនេះ កំពុង

សន្ទនា នឹងលោកសមណៈសប្បាយស្រួល ពួកយើងមករួមសន្ទនាជាមួយគ្នាចុះ នឹងបានសចក្តីចេះដឹងប្លែកៗល្អៗ ” ។

“ លោកសមណៈ! បើសន្មតថា មនុស្សក្នុងមគធរដ្ឋនេះ ជាអ្នកឃើញដល់ចំណែករួម ច្រើនជាងខ្លួនឯង ព្រមលះប្រយោជន៍ខ្លួនសុខរបស់ខ្លួនអ្នកដទៃ ព្រមទទួលសេចក្តីទុក្ខលំបាក ជំនួសអ្នកដទៃដូចលោកថា ស្រុកទេសនឹងទៅជាយ៉ាងណា ? ” ។

“ សេចក្តីសុខស្ងប់នឹងផ្សព្វផ្សាយទូទាំងស្រុកទេសនោះ ប្រជាជននឹងគ្រប់គ្រងជីវិតនៅដោយសន្តិសុខយ៉ាងពិតប្រាកដ ” ។

“ ហើយស្រុកប្រទេសយ៉ាងដែលថានេះ មានដែរឬ ឬថាគ្រាន់តែសេចក្តីយល់សប្តិប៉ុណ្ណោះ បើមាននៅទីណា ? ” ។

“ មានឧបាសក! ក្រុងដែលថានេះឈ្មោះសន្តិនគរ នៅក្នុងហិមវន្តប្រទេស ជានគរតូច មានប្រជាជនមិនច្រើនណាស់ណា តែមានព្រះមហាក្សត្រគ្រប់គ្រងដូចនគរទាំងឡាយ សន្តិនគរតាំងនៅក្នុងច្រកភ្នំដ៏ឧត្តមសម្បូណ៌ ពេញដោយធម្មជាតិដ៏ល្អស្រស់គួរទស្សនា ព្រះ-រាជាដែលសោយរាជ្យ ទ្រង់ស្ថិតនៅក្នុងទសពិធរាជធម៌ យ៉ាងម៉ឺងម៉ាត់ ទ្រង់ទុកប្រជារាស្ត្រគ្រប់គ្នាដូចជាបុត្រធីតារបស់ព្រះអង្គផ្ទាល់ រាជបុរសអ្នកធ្វើការរាជការតាំងព្រះនេត្រព្រះពណ៌ ធ្វើការតាមនាទីដោយសុចរិត មិនបាំងប្លុងឆរាស្ត្រ មិនធ្វើជាត្រីងៀត ឆ្កៀតពង គឺមិនធ្វើស្រែ លើ

ខ្លួនរាស្ត្រ ប្រជាជនគ្រប់ជាន់វណ្ណៈ ប្រកបអាជីវកម្មរបស់ខ្លួនដោយព្យាយាមឃ្មាតខ្មី និងដោយសុចរិត ក្នុងនគរនេះ គ្មានចោរលួចប្លន់ គ្មានក្តីក្តាំងឡើងសាលា គ្មានពន្ធនាគារ ព្រោះគ្មានអ្នកទោស គ្មានការប្រទូសរ៉ាយបៀតបៀនគ្នាដោយប្រការផ្សេងៗ មនុស្សគ្រប់គ្នាបានទទួលការអប់រំឱ្យមានចិត្តមេត្តាករុណា អើពើផ្សព្វផ្សាយចំពោះគ្នា ស្រឡាញ់គ្នាដូចបងប្អូន ជួយគ្នាធ្វើប្រយោជន៍សាធារណៈ ជួយគ្នារក្សាសាធារណសម្បត្តិអ្វីដែលឈ្មោះថា ជារបស់សាធារណៈ ដើម្បីប្រយោជន៍រួមហើយគេរក្សាការពារដោយម៉ឺងម៉ាត់ជាងរបស់ផ្ទាល់ខ្លួនទៅទៀត ឧបាសកអើយ! បើនឹងឱ្យពណ៌នាសេចក្តីល្អរបស់នគរនេះ មួយថ្ងៃក៏មិនចប់ផង " ។

" គួរអស្ចារ្យមែន! " នាដករទាំង ៨ នាក់ បន្លឺសំឡេងឡើងព្រមគ្នា ។

" ខ្ញុំចង់ទៅនៅក្នុងសន្តិនគរនោះណាស់ លោកសមណៈ"នាដករម្នាលពោលឡើងយ៉ាងជាការងារ " លោកមេត្តាប្រាប់ផ្លូវដល់ខ្ញុំផងចុះ "។

" មានមនុស្សម្ភំនេះជាច្រើន ធ្លាប់ទៅនៅក្នុងនគរនោះ តែក្នុងទីបំផុតនៅមិនបាន ត្រូវវិលត្រឡប់មកវិញខ្លួនឯងខ្លះ អ្នកនគរនោះគេបណ្តេញឱ្យមកខ្លះ " ។

" ព្រោះហេតុអ្វី ? " ។

" ព្រោះមនុស្សទាំងនេះ មិនចេះសម្របសម្រួលខ្លួនឯងឱ្យចូល

នឹងសភាពរបស់នគរនោះ កាលនៅឯណោះធ្លាប់ប្រព្រឹត្តយ៉ាងណា កាលទៅនៅឯណោះក៏ប្រព្រឹត្តដូចដើម គេនាំយកសេចក្តីឃើញដល់ខ្លួន( អត្តទត្ថៈ ) សេចក្តីល្មោភ ទុច្ចរិតវៀចវេរនឹងនិស្ស័យអាក្រក់ដទៃៗទៀតទៅជាមួយ ក្នុងទីបំផុត ទើបនៅមិនបាន, ដូច្នោះ បើលោកចង់ទៅនៅក្នុងសន្តិនគរនោះ មុនដទៃត្រូវប្រុងប្រៀបរៀបចំខ្លួនឯងជាមុន លោកត្រូវកំចាត់សេចក្តីឃើញដល់ខ្លួនចេញចាកខន្ធសន្តាន កុំសាងសេចក្តីសុខឱ្យដល់ខ្លួនដោយបង្ករសេចក្តីទុក្ខក្តៅក្រហាយឱ្យដល់អ្នកដទៃ បើលោកធ្វើបានដូច្នេះ ឬបើមនុស្សគ្រប់គ្នាធ្វើបានដូច្នេះ លោកមិនចាំបាច់ទៅនៅក្នុងសន្តិនគរ ព្រោះគ្រប់ស្រុកគ្រប់ប្រទេសនឹងក្លាយជាសន្តិនគរទាំងអស់ ” ។

ខ្ញុំទេសនាប្រៀនប្រដៅគេរហូតព្រលប់ ញ៉ាំងគេឱ្យកើតសេចក្តីក្លាហានក្នុងសម្មាបដិបត្តិ ហើយក៏ចុះទៅងូតទឹកក្នុងតបោតានទី ក្នុងពេលដែលគណៈល្ខោនចូលទៅក្នុងក្រុង យប់នោះខ្ញុំស្នាក់នៅក្រោមម្លប់ឈើក្បែរឆ្នេរតបោតានទីនោះឯង សូម្បីបរិយាកាសស្ងៀមស្ងាត់ រងាត្រជាក់តែចិត្តរបស់ខ្ញុំក៏កក់ក្តៅដោយក្សេមក្សាន្តចិត្ត ដ្បិតបានធ្វើប្រយោជន៍ដល់អ្នកដទៃ ។

# វេឡុវេនុវន

**អ្នកអានទាំងឡាយ!** ក្នុងថ្ងៃព្រឹកឡើង កាលទ្វារក្រុងបើក ខ្ញុំក៏ចូលទៅបិណ្ឌបាតក្នុងនគររាជគ្រឹះ កាលបានអាហារល្មមមួយឆ្អែតហើយ ក៏ចេញទៅឆាន់នៅវេឡុវនារាមដ៏ជាឧទ្យានឫស្សី ដែលព្រះបាទពិម្ពិសារ ព្រះមហាក្សត្រនៃមគធរដ្ឋ ទ្រង់លើកថ្វាយចំពោះព្រះភិក្ខុទាំង-ឡាយ មានព្រះសម្មាសម្ពុទ្ធជាប្រធាន ព្រះវេឡុវនារាមជារមណីយដ្ឋានក្រៃលែងជាងអារាមដទៃ ដែលខ្ញុំបានជួបប្រទះមក ផ្ទៃផែនដីខាងក្រោមរាបស្មើ បានទទួលការបោសសំអាតរលីងជានិច្ច ផ្ទៃខាងលើគ្របដណ្តប់ដោយស្លឹកឫស្សីដ៏ក្រាសជាដំបូងធម្មជាតិ ធ្វើឱ្យបរិយាកាសខាងក្រោមត្រជាក់សប្បាយជានិច្ច ។ ព្រះភិក្ខុសាមណេរក្នុងព្រះអារាម មានចំនួនត្រឹមបន្តិចបន្តួច ព្រោះចំនួនច្រើនបានចេញចារិកទៅក្នុងទិសផ្សេងៗទើបមានកុដិទំនេរនៅច្រើន ក្រោយពីប្រគល់ខ្លួនចំពោះព្រះមហាថេរជាប្រធានហើយ ខ្ញុំក៏បានទៅនៅកុដិតូចមួយខ្នង ដែលជ្រៅចូលទៅក្នុងព្រៃឫស្សីតាំងចិត្តថា ក្រោយពីធ្វើដំណើរដើរផ្លូវមកជាយូរយា ក៏នឹងឈប់សម្រាកអប់រំចិត្តឱ្យស្ងាត់ស្ងប់ខ្លះ ។

**តមកមិនយូរ** ព្រះមហាថេរឃើញថាខ្ញុំមានវស្សាចាស់ មានការចេះដឹងធម៌វិន័យ សមគួរនឹងគ្រប់គ្រងព្រះភិក្ខុសាមណេរជំនួសលោកបាន ទើបប្រគល់ព្រះអារាមឱ្យខ្ញុំ ហើយព្រះអង្គលោកក៏លានិមន្តចារិក

ទៅ កាលបានទទួលការប្រគល់នាទីហើយ ខ្ញុំក៏តាំងបរិហារដោយល្អត មក ក្នុងការគ្រប់គ្រងអ្នកនៅក្រោមបង្គាប់ ខ្ញុំបានលាតត្រដាងមេត្តា ករុណា និងសេចក្តីយុត្តិធម៌ទុកជាមូលដ្ឋានរបស់ចិត្ត ប្រកាន់សេចក្តីត្រឹម ត្រូវជាគោល លើកដំកើនអ្នកដែលគួរលើកដំកើន ប្រកាន់សេចក្តីត្រឹម គួរតិះដៀល មិនលំអៀងចូលខាងនោះ ចេញខាងនេះ ព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះខ្លាច ឬព្រោះល្ងង់ខ្លៅ ខ្ញុំបានសង្កេតឃើញថា អ្នក តូចក្រោមការគ្រង់គ្រងរបស់ខ្ញុំ មានពីរប្រភេទ ប្រភេទទី ១ ជាអ្នកមាន សមត្ថភាព ព្យាយាមយកល្អដោយការងារ, ប្រភេទទី ២ ជាអ្នកមាន សមត្ថភាព ព្យាយាមយកល្អគាប់គួរ ដោយការអែបបអប្រចុកប្រចែង ទាំងពីរពួកនេះ ច្រើនជាសត្រូវនឹងគ្នា អ្នកធំដែលអន់ទន់ខ្សោយច្រើនលំ-អៀងចូលខាងពួកប្រចុបប្រចែង ព្រងើយកន្តើយចំពោះពួកការងារ ធ្វើ ឱ្យពួកការងារអស់កម្លាំងចិត្តក្នុងការធ្វើការងារ កាលបើដូច្នេះសាមគ្គីធម៌ ក៏រលំរលាយ គណៈទ្រុឌទ្រោម។ អ្នកធំប្រៀបដូចបង្គោល អ្នកតូចប្រៀប ដូចគោច្រើនដែលចងទុកនឹងបង្គោល បើបង្គោលមិនរឹងប៉ឹងមាំមួន គោ ទាញរហូតដួល-សណ្តក កាលបង្គោលដួលសណ្តក គោដ៏បែកគ្នារប៉ាត់ រប៉ាយ បង្គោលគឺអ្នកធំ អាចនឹងមាំរឹងគង់វង្ស ព្រោះអាស្រ័យយុត្តិធម៌ ជាសំខាន់ ប្រកាន់ផលការងារជាគោល ពិចារណាសេចក្តីត្រឹមត្រូវ មិន មែនសេចក្តីប្រចុបប្រចែងអែបអប ។

**លោកអ្នកអានជាទីមេត្រី!** អ្នកធំដែលខ្វះមេត្តាជាមូលដ្ឋានរបស់ចិត្ត ច្រើនកាចសាហាវធ្វើទុក្ខបុកម្នេញចំពោះអ្នកតូច ប្រើការជេរដៀលវាយដំជាឧបករណ៍ ធ្វើឱ្យអ្នកតូចខ្លបខ្លាចជាងសេចក្តីគោរព ក្នុងសេចក្តីខ្លាចនោះ មានសេចក្តីស្អប់កប់នៅជាមួយផង អ្នកតូចធ្វើតាមតែចំពោះមុខ កំបាំងមុខគេនឹងនិន្ទា បើបើកឃ្លាតទៅ ឬស្លាប់បាត់ទៅ គេនឹងអនុមោទនាត្រេកអរថា ទៅឱ្យស្រឡះទៅចុះ ។

អ្នកធំដែលខ្វះ**ករុណា** ជាមូលដ្ឋានរបស់ចិត្ត ច្រើនជាមនុស្សកំណាញ់ បានបច្ច័យលាភផលអ្វីមកក៏សន្សំលាក់ទុកចំពោះតែខ្លួនឯង មិនបែកចែកគ្នា អ្នកធំដូច្នេះ មិនអាចបណ្តុះសេចក្តីស្រឡាញ់ ឱ្យកើតក្នុងចិត្តរបស់អ្នកតូចបាន ។

អ្នកធំដែលខ្វះ**មុទិតា**ជាមូលដ្ឋានរបស់ចិត្ត ច្រើនតែជាមនុស្សច្រណែនឫស្យា មិនលើកដំកើងឱ្យតម្លៃសេចក្តីល្អប្រសើររបស់អ្នកតូច ខ្លាចគេខ្ពស់មុខខ្ពស់មាត់ ឬ កាត់មុខ កាត់មាត់ខ្លួន រកផ្លូវទម្លាយបំផ្លាញរាំងរាកាលអ្នកតូចបានល្អ អ្នកធំដូច្នេះ ឈ្មោះថា បង្ក្រិនជំទាស់សេចក្តីចំរើនរបស់អ្នកតូច ។

អ្នកធំដែលខ្វះ**ឧបេក្ខា** ជាមូលដ្ឋានរបស់ចិត្ត ច្រើនជាមនុស្សឈ្លេងឈ្លោង ធ្ងន់ម្ខាងៗ ប្រោសប្រាណចំពោះអ្នកតូចដែលរូបល្អ មានអាមិសឬវត្ថុឱ្យខ្លួនច្រើនៗ ឬមានឥទ្ធិពលផ្លូវដទៃៗ ពូកែប្រចុបប្រចែងអែបអប

សូម្បីពួកនេះធ្វើខុសក៏មិនធ្វើជាដឹង បើធ្វើល្អត្រឹមបន្តិចបន្តួច ក៏លើកដំកើងសរសើរ អ្នកធំដូច្នេះ ប្រៀបដូចបង្គោលដែលដោតនៅលើពំនូកខ្សាច់ ។

**លោកអ្នកអានទាំងឡាយ!** ក្នុងការបរិហារពួកគណៈជំនួសព្រះមហាថេរ ខ្ញុំខំតាំងខ្លួនទុកក្នុងមេត្តាស្រឡាញ់អ្នកតូចដូចកូនចៅ, ករុណាអាណិតសង្គ្រោះដោយបច្ច័យលាភតាមមានតាមបាន, មុទិតា ត្រេកអរសរសើរអ្នកតូចដែលបានល្អ, ឧបេក្ខា ទុកដាក់ខ្លួនជាកណ្តាល អាស្រ័យយុត្តិធម៌ជាគោល អ្នកតូចស្រឡាញ់គោរពខ្ញុំទាំងចំពោះមុខនិងកំបាំងមុខប្រតិបត្តិតាមឱវាទរបស់ខ្ញុំដោយសេចក្តីពេញចិត្ត សាមគ្គីមូលមិត្តគ្នាដោយល្អ ញ៉ាំងការងារឱ្យសម្រេចយ៉ាងរៀបរយរៀងរាបមក ។

**ក្នុងថ្ងៃធម្មស្សវនៈ** ខ្ញុំត្រូវសំដែងធម៌ចំពោះពុទ្ធបរិស័ទជំនួសព្រះថេរៈ អាស្រ័យខ្លួនជាអ្នកចេះដឹងនូវធម៌ និងយល់ក្នុងវិធីទេសនាខ្លះ ទើបមានប្រជាជននិយមចូលចិត្តក្នុងធម្មទេសនារបស់ខ្ញុំច្រើន ចំនួនពុទ្ធបរិស័ទដែលមកស្តាប់ទេសន៍ ចេះតែកើនថែមឡើងរាល់ថ្ងៃ ក្នុងមិនយូរកិត្តិគុណរបស់ខ្ញុំ ក៏លាន់ឮខ្ទរខ្ទាយផ្សាយទូទៅពេញក្រុងរាជគ្រឹះ កាលឈ្មោះសំឡេងល្បីល្បាញហើយ លាភ យស ក៏ហូរតាមមក បច្ច័យ ៤ មានអាហារជាដើម ផ្តើមហូរកើតកើនចំរើនឡើងចំពោះខ្ញុំ តែខ្ញុំមិនបានស្រវឹងវង្វេងជាប់នៅនិងវត្ថុធាតុទាំងនោះទេ ខ្ញុំយកទុកតែល្មមឆាន់មួយឆ្អែត

ក្នុងមួយថ្ងៃ ហើយក៏ចែកចាយដល់ភិក្ខុសាមណេរទូទៅ ខ្ញុំកាន់ឧត្តមគតិថា "ស៊ីល្មមឱ្យតែត្រឹមជីវិតរស់នៅ នឹងរស់នៅដើម្បីប្រព្រឹត្តសេចក្តីល្អនិងធ្វើការងារប៉ុណ្ណោះ " ថ្ងៃយប់កន្លងទៅតាមលំដាប់ ខ្ញុំអាស្រ័យក្នុងព្រះ-វេឡុវនារាមប្រកបដោយសេចក្តីសុខក្សេមក្សាន្តទាំងកាយចិត្ត ទីកន្លែងអាកាសនិងមនុស្សក្នុងព្រះវេឡុវនជាទីត្រូវអាធ្យាស្រ័យរបស់ខ្ញុំពន់ពេក ខ្ញុំតាំងចិត្តនឹងនៅក្នុងព្រះវេឡុឱ្យយូរលង់ទៅទៀត ឬ ក៏នៅរហូតអវសានជីវិត ។

ខ្ញុំនៅបរិហារគណៈសង្ឃនិងប្រៀនប្រដៅតទៅ នៅព្រះវេឡុនារាមនោះឯង ការងារដើម្បីប្រយោជន៍រួមរបស់ខ្ញុំបានសម្រេចផលយ៉ាងល្អក្រៃលែង ជនជាអនេក បានត្រូវនាំចេញចាកសេចក្តីងងឹតគឺមោហៈ ទៅកាន់ដែននៃសេចក្តីភ្លឺស្វាង គឺបញ្ញា ចាកការប្រឡាក់ស្មោកគ្រោកដោយអកុសលទៅកាន់ដែនដ៏ស្អាតបរិសុទ្ធ គឺកុសល ខ្លួនខ្ញុំដូចជាដួងប្រទីបដ៏រុងរឿង សម្រាប់បំភ្លឺផ្លូវជីវិតនៃអ្នកនគររាជគ្រឹះនិងមគធរដ្ឋ ប្រយោជន៍ដែលខ្ញុំបានធ្វើឱ្យដល់ពលលោក មានច្រើនលើសគណនា តែការងារដើម្បីប្រយោជន៍រួមនេះឯង បានក្លាយជាកំពែងមហិមារាំងខាំងខ្ញុំទុកមិនឱ្យមានឱកាសបំពេញព្យាយាមដើម្បីសម្រេចមគ្គផល ដែលជាចំណុះខ្ពស់បំផុតក្នុងព្រះពុទ្ធសាសនា ។

# នៅល្អាងសុករខាតា

**លោកអ្នកអានទាំងឡាយ!** រវាងដែលនៅក្នុងព្រះវេឡុវនារាម បានមានហេតុការណ៍ច្រើនយ៉ាង ឯខ្ញុំក៏មានចំណែកចូលទៅទាក់ទងផង នឹងនាំមកនិយាយឱ្យស្តាប់ចំពោះរឿងខ្លះល្អមជាគ្រឿងប្រដាប់សតិបញ្ញា ។ ថ្ងៃមួយ ខ្ញុំបានឡើងទៅធ្វើការសម្ងាត់សតិអារម្មណ៍នៅនាល្អាងសុករខាតា ភ្នំគិជ្ឈកូដ គឺភ្នំមានសណ្ឋានដូចក្បាលត្មាត លើភ្នំនេះ មានល្អាងឈ្មោះ សុករខាតា ជាល្អាងជ្រៅ មានប្រវត្តិថា ពីដើមមាត់ល្អាងនោះ មានដីបិទជិតគ្មាននរណាដឹងថាជាល្អាង ថ្ងៃមួយ សុករៈ (ជ្រូក) មកឈ្ងូសដីត្រង់នោះ គ្រាតមក ភ្លៀងច្រោះដី ស្នាមនៃល្ងាងក៏ប្រាកដឡើង នាយព្រានម្នាក់បានសង្កេតឃើញ ក៏សន្និដ្ឋានថា ប្រហែលជាល្អាងរកសេចក្តីស្ងប់ស្ងាត់នៃអ្នកមានសីលក្នុងកាលមុន ទើបនាំយកដីចេញ តាក់តែងបរិវេណ រៀបចំឱ្យសមរម្យ ហើយថ្វាយដល់ព្រះដ៏មានព្រះភាគ ល្អាងនោះឈ្មោះ **សុករខាតា** ( ដែលជ្រូកឈ្ងូស ) តាំងពីគ្រានោះមក ។ ខ្ញុំចូលចិត្តកន្លែងនោះណាស់ ព្រោះជាទីស្ងាត់ស្ងៀមសមដល់ការបំពេញព្យាយាម ក្រៃលែងជាងនោះកាលយើងឈរនៅមាត់ល្អាង ហើយសំឡឹងមើលមកខាងក្រោម នឹងបានឃើញអគារ សំណង់ ផ្លូវ និងមនុស្សដើរទៅមក ក្នុងផ្លូវនៃក្រុងរាជគ្រឹះ បានយ៉ាងច្បាស់លាស់ របស់ទាំងនេះកាលសំឡឹងមើលពីទីខ្ពស់ដូច្នោះ នឹងឃើញជារបស់តូចៗ ដូចរបស់ក្មេង

លេង ខ្ញុំចូលចិត្តសំឡឹងមើលភាពដូច្នោះ ព្រោះវាធ្វើឱ្យឃើញមនុស្ស ជាសត្វលោក និងឃើញអគារផ្ទះសម្បែងទាំងនោះក្នុងឋានៈជាគ្រឿង លេងរបស់ពលលោក ។

ថ្ងៃជ្រេបន្តិចនៃថ្ងៃមួយ ខណៈដែលកំពុងអង្គុយសម្រាកនៅនា-លានថ្ម ជិតមាត់ល្អាង ខ្ញុំសង្កេតឃើញស្ត្រីក្រមុំម្នាក់កំពុងដើរឡើងភ្នំមក អំពីចម្ងាយ នាងឡើងមកតាមផ្លូវចង្អៀតចុះជើងមនុស្សតែម្នាក់ មិន ប្រាកដថាមាននរណាមកជាមួយផងឡើង ធ្វើឱ្យខ្ញុំនឹងសង្ស័យថា នាង ជានរណាទៅណាមកណាតែម្នាក់ឯង ដើម្បីអ្វី? ខ្ញុំអង្គុយរង់ចាំមើល ដោយអាការៈស្ងប់ ស្ត្រីចម្លែកនោះចេះតែឡើងមកដោយមិនឈប់សម្រាក ដែលខ្ញុំមើលទៅឃើញថា នាងហត់នឿយណាស់ កាលឡើងមកដល់ លានថ្មក្រោមម្លប់ឈើ ឆ្ងាយពីកន្លែងដែលខ្ញុំអង្គុយទៅខាងក្រោមបន្តិច នាងបានអង្គុយសម្រាក នាងផ្អែកខ្នងនឹងដើមឈើធំ ហើយក៏សណ្ដូកជើង ទៅខាងមុខ សូម្បីមុខរបស់នាងក្រៀមក្រំមួហ្មងទទឹកជោកដោយញើស ក៏នៅមានពន្លឺសម្រស់លំអបង្ហាញឱ្យឃើញថា នាងជានារីល្អឆើតម្នាក់ មិនចាញ់នារីឆើតឆាយ ដែលខ្ញុំធ្លាប់ជួបប្រទះមកហើយ លក្ខណៈទំនង ដំណើរ ពណ៌សម្បុរនិងគ្រឿងតែងកាយ សំដែងឱ្យឃើញថា នាងមិន មែនជាមនុស្សជាន់ទាប វេលានោះ នាងក្រមុំចម្លែកនោះ មិនទាក់ឃើញ ខ្ញុំ បើនាងឃើញខ្ញុំ នឹងឃើញថា ខ្ញុំកំពុងសំឡឹងមើលនាង នាងប្រហែល

ជាអៀនខ្មាសខ្ញុំហើយមើលទៅ ខ្ញុំទើបបែរមុខទៅទិសដទៃក្លែងធ្វើជាមិនឃើញនាង មួយសន្ទុះខ្ញុំបែរមកមើលនាងទៀត ម្តងនេះខ្ញុំបានទទួលសេចក្តីងឿងឆ្ងល់ប្លែកក្នុងចិត្ត កាលឃើញនាងក្រមុំនោះ កំពុងយំយ៉ាងគួរអាណិតពន់ពេក សំដែងឱ្យឃើញសេចក្តីចុកសៀតចង្អៀតចង្អល់ណាមួយតាមប្រក្រតី ខ្ញុំជាមនុស្សមានចិត្តពេញព្រៀបដោយករុណា កាលឃើញនរណាមានអាកប្បកិរិយាជាទុក្ខ ខ្ញុំមិនអាចអង្គុយមើលចំណាំងបាន ច្រើនចូលទៅប្រស្រ័យសាកសួររឿងរ៉ាវផ្សេងៗ រហូតដឹងរឿងរ៉ាវច្បាស់លាស់ហើយ ក៏រកផ្លូវជួយសង្គ្រោះដោយវត្ថុខ្លះ ដោយធម៌ខ្លះ តាមសមគួរ ។

**លោកអ្នកអាន!** ភាពដែលនៅខាងមុខខ្ញុំខណៈនេះ ធ្វើឱ្យខ្ញុំកើតសេចក្តីអាណិតយ៉ាងខ្លាំង កាលមិនអាចទ្រាំអង្គុយស្ងៀមបាន ទើបខ្ញុំគ្រហែមឡើងតិចៗ ដើម្បីជាសញ្ញាឱ្យនាងក្រមុំនោះដឹងថា ក្នុងបរិវេណនោះ មិនមែនមានតែនាងម្នាក់ឯងទេ នាងបែរមករកខ្ញុំភ្លាម លើកជាយសំពត់ជូតទឹកភ្នែក ខណៈនាងកំពុងភាំងនោះឯង ខ្ញុំក៏ដើរចុះទៅឈរនៅក្នុងរយៈឆ្ងាយពីនាងប្រមាណពីរម៉ែត្រ ហើយក៏ផ្តើមសួរនាង ។

" **ម្នាលកុលធីតា !** នាងមានធុរៈសំខាន់អ្វីទីណា ទើបឧស្សាហ៍ឡើងភ្នំមកតែម្នាក់ឯងដូច្នេះ ? " ។

ផ្ទុយពីឆ្លើយចំពោះសំនួររបស់ខ្ញុំ នាងក្រមុំបែរជាយំខ្សឹកខ្សួលខ្លាំងឡើង ទើបខ្ញុំនិយាយតទៅ :

" កុលធីតាអើយ! នាងប្រហែលមានទុក្ខចុកណែនអ្វីម្យ៉ាងហើយ នាងអាចកំពុងទៅសម្លាប់ខ្លួនទេដឹង ? " ។

" **ត្រូវហើយ !** ខ្ញុំករុណានឹងទៅលោតសម្លាប់ខ្លួន " នាងក្រមុំឆ្លើយភ្លាម សំឡឹងមើលខ្ញុំដោយនឹកចម្លែកក្នុងចិត្ត ដែលខ្ញុំទាយគោលបំណងរបស់នាងត្រូវ" ព្រោះមិនអាចធន់ទ្រាំងចំពោះសេចក្ដីទុក្ខរបស់ជីវិតនេះបាន " ។

" ទុក្ខរបស់នាងធំណាស់ហើយមិនទៅ សូមនិយាយឱ្យអាត្មាស្ដាប់ផងចុះថា រឿងរ៉ាវយ៉ាងដូចម្ដេចខ្លះ ? អាត្មាដូចជាអាណិតនិងយើញចិត្តឃើញថ្លើមនាងណាស់ " ។

នាងក្រមុំបាននិយាយរឿងរ៉ាវរបស់នាងឱ្យខ្ញុំស្ដាប់ដោយទឹកភ្នែកថា ទុក្ខធំរបស់នាង កើតពីសេចក្ដីថ្លោះខុសបំណងក្នុងរឿងស្នេហា កាលមុននេះមិនយូរ មាតាបិតារបស់នាងបានបង្គាប់ឱ្យនាងរៀបការនិងព្រាហ្មណ៍ចាស់ស្ដុកស្ដម្ភម្នាក់ តែនាងមិនព្រមទើបរត់ទៅរកប្រុសកម្លោះម្នាក់ ដែលនាងស្រឡាញ់ តែនាងក៏បានជួបប្រទះនឹងសេចក្ដីខុសសង្ឃឹម ព្រោះបុរសកម្លោះនោះ បានរៀបការនឹងស្ត្រីដទៃទៅហើយ មុនដែលនាងទៅដល់ត្រឹមមួយថ្ងៃប៉ុណ្ណោះ នាងមិនព្រមត្រឡប់ទៅផ្ទះរបស់ខ្លួន ព្រោះសេចក្ដីខូចិត្ត ចេះតែដើរពនេចរទៅយ៉ាងមនុស្សដែលប្រាសចាកសតិអស់វេលាដល់ ៣ ថ្ងៃ កាលមិនអាចទ្រាំចំពោះសេចក្ដីទុក្ខតឹងចិត្តឆ្អិតទ្រូងបាន

ទើបគាត់ចិត្តនឹងលោតទៅក្នុងជ្រោះសម្លាប់ខ្លួន ។

" រឿងរបស់នាងជារឿងដែលគួរឃើញចិត្តច្រើន, ខ្ញុំនិយាយកាលស្តាប់រឿងរបស់ស្ត្រីក្រមុំចប់ហើយ ។

" នរណាក៏ដោយ បើធ្លាក់នៅក្នុងភាវៈដូចនាងក៏គង់នឹងកាត់ចិត្តសម្លាប់ជីវិតដូចយ៉ាងនាង ទុក្ខកាយជារឿងដែលល្មមអត់ទ្រាំងបាន តែទុក្ខចិត្ត ទ្រាំងបានដោយលំបាកណាស់ វិធីកែទុក្ខចិត្តមាន ២ ប៉ុណ្ណោះ គឺសម្លាប់ខ្លួនឱ្យស្លាប់ស្រឡះទៅ នឹងអត់ទ្រាំងទាល់តែទុក្ខនោះរលត់។មនុស្សជាច្រើន បានជ្រើសរើសយកវិធីសម្លាប់ខ្លួន តែដែលជ្រើសរើសយកវិធីអត់ធន់ ក៏មានមិនតិចដែរ តើនាងជ្រើសរើសយកវិធីណា? " ។

" ជ្រើសរើសយកវិធីស្លាប់ " នាងក្រមុំឆ្លើយយ៉ាងដាច់ខាត ។

" នាងជឿពិតឬថា កាលនាងស្លាប់ហ្មែនឹងរួចចាកទុក្ខ ? " ។

" ខ្ញុំជឿយ៉ាងនោះ " នាងក្រមុំឆ្លើយយ៉ាងមិនប្រាកដក្នុងចិត្ត ។

"នាងចូលចិត្តខុសហើយ នាងកំពុងនឹងបំផ្លិចបំផ្លាញខ្លួនឯងដោយសេចក្តីយល់ខុស ទុក្ខរបស់នាងមិនបាននៅត្រង់ជើង ដៃ ទ្រូង ស្មា បេះដូង លលដ៏ក្បាល ឬផ្នែកនណាមួយរបស់រាងកាយ តែនៅនឹងចិត្ត រាងកាយត្រឹមតែជាវត្ថុគ្រោតគ្រាត មិនដឹងរឿងរ៉ាវអ្វីទាំងអស់ ចិត្តទេតើជាអ្នកទទួលទុក្ខ កាលរាងកាយស្លាប់ ចិត្តនៅមានការចាប់កំណើតកើតទៀត អាចនាំសេចក្តីសុខសេចក្តីទុក្ខ ដូច្នោះ សេចក្តីស្លាប់ ទើប

មិនមែនទីបំផុតរបស់សុខឬទុក្ខ សេចក្ដីសៅហ្មង ឬសេចក្ដីបរិសុទ្ធទៅជាមួយផងបាន ការសម្លាប់ខ្លួនដោយការទម្លាយរាងកាយដែលមិនដឹងរឿងរ៉ាវអ្វីឡើយឱ្យស្លាប់ទៅយ៉ាងឥតប្រយោជន៍ ការសម្លាប់ខ្លួន ដើម្បីឱ្យរួចចាកទុក្ខជាការកែឬរំដោះទុក្ខខុសទំនង ដូចបុរសម្នាក់ត្រូវគេជេរស្ដី កើតសេចក្ដីឈឺចាប់ចិត្តក្ដៅក្រហាយ ចង់រួចចាកទុក្ខក៏យកភ្លើងទៅដុតផ្ទះរបស់ខ្លួន ទាល់តែផ្ទះឆេះខ្ទេចខ្ទី កាលផ្ទះដែលមិនដឹងរឿងរ៉ាវអ្វី ដោយក្លាយជាធ្យូងជាផេះទៅហើយ គេរួចចាកទុក្ខឬ? ទេ ! គេបែរជាមានទុក្ខធ្ងន់ឡើង ព្រោះទុក្ខមិនមែននៅនឹងផ្ទះសម្បែង តែទុក្ខនៅក្នុងចិត្តរបស់គេនោះឯងដូច្នោះ កាលចិត្តកើតទុក្ខ ត្រូវកែត្រង់ចិត្ត កុំទៅទម្លាយរាងកាយដែលមិនដឹងរឿងរ៉ាវអ្វីផង ” ។

កាលសង្កេតឃើញស្ត្រីក្រមុំនៅអង្គុយស្ងៀម ខ្ញុំក៏សួរឡើងថា "កុលធីតា! កាលសេចក្ដីស្លាប់មិនអាចធ្វើឱ្យនាងរួចចាកទុក្ខបានដូច្នេះហើយ ការសម្លាប់ខ្លួនឯង ក៏គ្មានប្រយោជន៍ គួរស្ដាយណាស់ដែលនាងមកសម្លាប់ខ្លួនដូច្នេះ អត់ទ្រាំតទៅទៀត មិនបានឬ? ” ។

“ អត់ទ្រាំមិនបានទេ ” នាងក្រមុំឆ្លើយយ៉ាងល្វើយ ។

“ នាងជួបទុក្ខធ្ងន់នេះមកជាវេលាប៉ុន្មានថ្ងៃហើយ ? ” ។

“ បីថ្ងៃហើយ ” ។

" នាងប្រាប់ថាអត់ទ្រាំងមិនបាន តែនាក៏អត់ទ្រាំមកបានបីថ្ងៃហើយ បើនាងអត់ធ្មត់សង្កត់ចិត្តតទៅបីថ្ងៃទៀត ទុក្ខរបស់នាងក៏នឹងសង្ស៊ឹម១ថយចុះ ហើយក្នុងទីបំផុត ក៏នឹងបាត់ទៅឯង " ។

" លោកគ្រាន់តែនិយាយយ៉ាងនោះ១ នរណា១ក៏អាចនិយាយបានដែរ "នាងក្រមុំប្រកែក" ខ្ញុំអត់ទ្រាំមក ៣ ថ្ងៃ ក៏សឹងមិនបានទៅហើយ សេចក្ដីទុក្ខរបស់ខ្ញុំ គ្មានផ្លូវនឹងថយចុះទៅ មានតែកើនទ្វេថែមឡើង១ ខ្ញុំជឿថាមិនមានថ្ងៃស្រុតស្រកថយចុះជាដាច់ខាត " ។

" កុលធីតាអើយ! ក្មេងនៅវ័យខ្ចីនិងជីងក្ដិតចទើបកើតមកកាន់លោកត្រឹមរយៈវេលាដ៏ខ្លី កាលឃើញព្រះអាទិត្យរះលេចឡើងលើផ្ទៃពិភពលោក ហើយសន្សឹមខ្ពស់ឡើងទៅក្នុងផ្ទៃមេឃ ជាមួយនឹងការបញ្ចេញរស្មីក្ដៅឡើង១ គ្រប់ខណៈក៏តក់ស្លុតរន្ធត់ខ្លាច ព្រោះយល់ថាព្រះអាទិត្យនិងខ្ពស់ឡើងទៅមិនឈប់ឈរ មិនមានវេលានឹងចុះទាបរស្មីដ៏ក្ដៅក៏មុខជាបន្ថែមឡើង១រហូតអ្វី១ក្នុងលោក នឹងត្រូវឆេះខ្ទេចខ្ទីជាធូលីអស់មិនខាន កាលក្មេងនោះ កើតសេចក្ដីភ័យខ្លាចចំពោះព្រះអាទិត្យហើយក៏រកផ្លូវចេញទៅដោយការសម្លាប់ខ្លួនឱ្យស្លាប់ជាមុន យ៉ាងនេះគួរស្ដាយនិងគួរអាណិតសង្វេគ ព្រោះបើវាអត់ទ្រាំតទៅទៀតបន្តិច វាក៏នឹងជួបថាកាលព្រះអាទិត្យឡើងដល់កំរិតខ្ពស់បំផុត ពាក់កណ្ដាលមេឃហើយ ក៏

សន្សឹមៗជ្រេទេទាបចុះ រស្មីក៏សន្សឹមៗអន់ខ្សោយទៅ រហូតក្នុងទីបំផុតក៏លិចលិបបាត់ទៅក្នុងជើងមេឃ គំនិតដែលគេគិតស្មានថានឹងត្រូវកំដៅព្រះអាទិត្យដុតបំផ្លាញឱ្យស្លាប់នោះ ក៏មិនកើតឡើង គេសាងទុក្ខសោកឡើងបញ្ឆោតខ្លួនឯងពិតៗ ។

កុលធីតាអើយ! ព្រះអាទិត្យយ៉ាងណា ខ្លួនរបស់នាងក៏យ៉ាងនោះ នាងអត់ទ្រាំមក ៣ ថ្ងៃហើយ តែនៅមិនឃើញថាទុក្ខស្រុតស្រកធូរថយសោះ នោក៏ព្រោះវានៅមិនទាន់ឡើងដល់ចំណុខ្ពស់បំផុតរបស់វា ដូចព្រះអាទិត្យដែលមិនទាន់ត្រង់ ដូចព្រះចន្ទដែលមិនទាន់ពេញវង់ តែក្នុងមិនយូរក៏នឹងដល់ចំណុចខ្ពស់បំផុត ហើយក៏ផ្ដើមខ្សោយចុះ ដូចព្រះអាទិត្យក្នុងវេលារសៀល ដូចព្រះចន្ទខងរនោច ដូចខ្សែទឹកចុងរដូវភ្លៀង ។

កុលធីតាអើយ! ចូរជ្រាបសេចក្ដីពិតចុះថា អ្វីគ្រប់យ៉ាងគ្រប់ប្រការមិនថាជាវត្ថុឬនាមធម៌ កាលកើតឡើងនិងចំរើនឡើងខ្ពស់បំផុតហើយរមែងទ្រុឌទ្រោមរញមចុះនិងរលត់លោយបាត់ទៅក្នុងទីបំផុតនេះ គឺគោលនៃសេចក្ដីពិតក្នុងធម្មជាតិ ដែលគ្មានអ្វីរារាំងបាន យើងទាំងពីរនាក់ដែលកំពុងសន្ទនាគ្នានេះ មិនប៉ុន្មានឆ្នាំទៀត ក៏នឹងរលាយជាផេះបន្ថែមបរិមាណផែនដីនគររាជគ្រឹះដ៏រុងរឿងនេះ ថ្ងៃណាមួយទៅអនាគត ក៏នឹងក្លាយជាព្រៃ លំនៅរបស់ទន្សាយ ទន្សោង ប្រើសរមាំង. . . ព្រោះការកើត

និងការរលត់ជាគូនឹងគ្នា កាលមានកើតក៏រមែងមានស្លាប់ របស់ណាមាន កើត របស់នោះ ត្រូវមានរលត់ដូចគ្នាទាំងអស់ ផ្សេងគ្នាតែត្រង់ឆាប់និង យូរប៉ុណ្ណោះ របស់ខ្លះកើតហើយឆាប់រលត់ របស់ខ្លះកើតហើយមិនងាយ រល់ត តែទោះយូរត្រឹមណា ក៏ត្រូវរលត់ទៅក្នុងទីបំផុត ។

កុលធីតា! អាត្មាខ្លួនឯងក៏ជួបប្រទះទុក្ខបែបដូចនាងដែរ កាលនៅ ក្រុងសាវត្ថី អាត្មាកើតសេចក្ដីស្រឡាញ់នឹងមានសេចក្ដីសង្ឃឹមមាំក្នុងកុល ស្ត្រីម្នាក់ តមកមានប្រុសដទៃមកប្រណាំងប្រជែងដណ្ដើមយកនាងទៅពី អាត្មា ទុក្ខដ៏ធំក្រៃលែងបានកើតឡើងសង្កត់សង្កិនចិត្តអាត្មាស្ទើរទ្រាំមិន បាន អាត្មាបានគេចចេញចាកក្រុងសាវត្ថីធ្វើពនេចរ ដោយគ្មានគោលដៅ អាស្រ័យសេចក្ដីអត់ធន់នឹងបានជួបប្រទះហេតុការណ៍ផ្សេងៗ ក្នុងការធ្វើ ដំណើរដ៏វែងឆ្ងាយនិងយូរយា ទុក្ខរបស់អាត្មាក៏សន្សឹមៗបាត់ទៅ សូម្បី មិនបាត់រលីងក៏ធ្វើឱ្យសប្បាយចិត្តច្រើនឡើង ។

កុលធីតាអើយ! ទុក្ខរបស់នាងជាទុក្ខធំ ទើបងំយូរមិនងាយរលត់ តែនឹងត្រូវរលាយរលត់បាតទៅយ៉ាងពិតប្រាកដ ដូច្នោះ នាងមិនបាច់ធ្វើ អ្វីទាំងអស់ គ្រាន់តែអត់សង្កត់ចិត្តសិនប៉ុណ្ណោះ រង់រហូតដល់ទុក្ខរបស់ នាងនឹងដល់ចំណុចរលត់ តអំពីនោះ នាងក៏នឹងសប្បាយចិត្តដូចដើម ”។

“ ទម្រាំទុក្ខរបស់ខ្ញុំរលាយរលត់ ខ្ញុំមុខជាបែកទ្រូងស្លាប់ប៉ុណ្ណោះ” ស្ត្រីក្រមុំជជែកឡើង ក្រោយពីអង្គុយស្ដាប់ខ្ញុំមកជាយូរ ។

" អាត្មាកើតមកក្នុងលោកជាង ៣០ ឆ្នាំហើយ ក៏មិនធ្លាប់ឃើញ និងមិនធ្លាប់បានឮថា មាននរណាស្លាប់ព្រោះបែកទ្រូងស្លាប់ឯង១ នោះទេ តែដែលស្លាប់ព្រោះម្ចាស់ខ្លួនយកសស្ត្រាវុធទម្លាយឱ្យវាបែកនោះធ្លាប់ឃើញមានច្រើនដែរ ដូច្នោះ អាត្មាសូមធានាថា ទ្រូងរបស់នាងប្រាកដជាមិនបែកទេ ហើយនាងក៏គ្មានថ្ងៃស្លាប់ព្រោះបែកទ្រូងដែរ វៀរតែនាងចាកទម្លាយវាឱ្យធ្លាយប៉ុណ្ណោះ " ។

**អ្នកអានទាំងឡាយ!** កាលខ្ញុំនិយាយមកដល់ត្រង់នេះ នាងក្រមុំដែលក្រៀមក្រំធំដោយទុក្ខ ហាក់ដូចជាបានស្មារតីមកវិញខ្លះ នាងនិ-យាយរាយការណ៍ប្រាប់ទុក្ខរបស់នាងចំពោះខ្ញុំថា" ខ្ញុំខូចចិត្តឆ្អិតទ្រូងលើសលុប រហូតឃើញថាជីវិតនេះជារបស់ឥតតម្លៃ ខ្ញុំដូចជាស្លាប់ទៅហើយពាក់កណ្តាល នៅសល់តែរាងកាយនិងដង្ហើមចេញចូលប៉ុណ្ណោះ" ។

"កុលធីតាអើយ! ហេតុដែលនាងខូចចិត្តច្រើននោះ ក៏ព្រោះនាងមិនយល់ធម៌អនិច្ចំទើបសំឡឹមើលឃើញរបស់ផ្សេង១ ក្នុងផ្នែកល្អតែម្យ៉ាង ប្រគល់សេចក្តីទុកចិត្ត សេចក្តីស្រឡាញ់ សេចក្តីសង្ឃឹមទុកក្នុងរបស់ណាមួយឬបុគ្គលណាម្នាក់ កាលរបស់នោះឬបុគ្គលនោះសំដែងសេចក្តីមិនទៀតចេញមក តាមកាលវេលារបស់វា នាងក៏ខុសបំណង ខូចចិត្ត កើតទុក្ខធំសណ្ធិឱរា ដូចវេលានេះ សន្មតថាមានប្រាក់ ១០០ កហាបណៈ ហើយយកទៅផ្ញើនិងមិត្តប្រុស ១៥ កហាបណៈ និងប្អូន

២៥ កហាបណៈ និងមិត្តស្រី ២៥ កហាបណៈ និងបង ២៥កហាបណៈ បើសិនជាមិត្តប្រុសវៀចវេរយកប្រាក់របស់នាងទៅ នាងក៏អស់ទៅត្រឹម ២៥ កហាបណៈប៉ុណ្ណោះ ៧៥ កហាបណៈទៀតដែលនៅសល់ បើសន្មតថា មិត្តស្រីបោកយកទៅទៀត ២៥ កហាបណៈ នាងក៏នៅសល់ ៥០ កហាបណៈដែរ បើបងប្រុសបោកយកទេទៀត ២៥ កហាបណៈ នាងក៏នៅសល់នឹងប្អូន ២៥ កហាបណៈ តែកាលប្អូនស្រីយកទៅទៀត នោះនាងទើបសូន្យអស់ទ្រព្យរលីង តែការដែលមនុស្សទាំង ៤ នាក់ ធ្វើការបោកបញ្ឆោតយកប្រាក់ទៅព្រមគ្នានោះ ជារឿងដែលមិនអាចប្រព្រឹត្តទៅបាន ការផ្ញើរប្រាក់បែបនេះ ជាវិធីឆ្លាត បើនាងយកប្រាក់ទាំង ១០០ កហាបណៈ ទៅផ្ញើរនឹងមនុស្សតែម្នាក់ បើគេវៀចវេរយកបាត់ទៅ នាងក៏ត្រូវខូចខាតប្រាក់ទាំង ១០០ កហាបណៈព្រមគ្នាតែម្តង ជាការខូចខាតដែលគួរស្តាយជាវិធីការដែលមិនឆ្លាតឡើយ ។

កុលធីតា! ទឹកចិត្តរបស់នាង ក៏ដូចគ្នាដែរ បើនាងយកទឹកចិត្តទាំងមូលប្រគល់ឱ្យនរណាម្នាក់ បើគេមិនស្មោះត្រង់ចំពោះនាង នាងក៏ខូចចិត្តទាំងមូលអស់សេចក្តីសុខ អស់សេចក្តីសង្ឃឹម រស់នៅដូចមនុស្សគ្មានចិត្ត ដូចជារូបនាងនោះឯង ផ្លូវដែលត្រូវនាងគួរបែងចិត្តជាផ្នែក១ដូចបែកប្រាក់ មួយចំណែកប្រគល់ឱ្យគូរស្នេហា មួយចំណែកប្រគល់ឱ្យមាតាបិតា មួយចំណែកប្រគល់ឱ្យបងប្អូន មួយចំណែកប្រគល់ឱ្យមិត្តភ័ក្ត មួយ

ចំណែកប្រគល់ឱ្យពួកញាតិ មួយចំណែកប្រគល់ឱ្យគ្រូអាចារ្យជាដើម សំដៅសេចក្តីថាឱ្យស្រឡាញ់គេបន្តិច១ ទៅសិន បើគូស្រឡាញ់កើតទុឃ៉ិសចំពោះយើង យើងក៏កើតទុក្ខខូចចិត្តតិច តែលុះជឿពិត ឃើញពិតថា គេស្មោះត្រង់ចំពោះយើងមែន សឹមស្រឡាញ់គេដោយទឹកចិត្តទាំងមូល ” ។

“លោកនិយាយដូចជាថាទឹកចិត្តរបស់មនុស្ស ជាវត្ថុដែលនឹងបែងចែកចាយបានងាយ១យ៉ាងនោះឬ? សេចក្តីពិត មិនអាចធ្វើបានទេលោក មនុស្សយើងកាលបានស្រឡាញ់នរណាហើយ ពិបាកនឹងហាមប្រាមទប់ចិត្តមិនឱ្យស្រឡាញ់ច្រើនបាន បើយើងស្រឡាញ់គេតែបន្តិចបន្តួច គេក៏មិនពេញចិត្តយើង បើថាយើងមិនស្រឡាញ់គេពិតហើយ សេចក្តីស្រ-ឡាញ់នឹងរីករាយបានយ៉ាងណា? ” ស្ត្រីក្រមុំឱ្យហេតុផលជំទាស់ដោយមានមុខមាត់ស្រស់បស់ច្រើន ។

“ កុលធីតា! អាត្មានឹងលើកតួយ៉ាងឱ្យស្តាប់ សន្មតថា មានចោរម្នាក់ចូលមកអាស្រ័យនៅក្នុងផ្ទះរបស់នាង ដោយមានចេតនាអាក្រក់ចំពោះនាង នាងក៏ដឹងច្បាស់ថា គេជាចោរនិងមានចេតនាអាក្រក់ចំពោះនាង តែព្រោះអាស្រ័យដែលចោរនោះ ព្យាយាមធ្វើសេចក្តីល្អគ្រប់យ៉ាងដើម្បីឱ្យនាងស្រឡាញ់ ដោយសង្ឃឹមថា កាលនាងស្រឡាញ់គេច្រើន១ហើយនឹងជាឱកាសឱ្យគេប្រទូសរ៉ាយនាងបានងាយក្រៃលែងឡើង តមក

នាងក៏កើតសេចក្តីពេញចិត្តចំពោះគេ ព្រោះសេចក្តីល្អរបស់គេ តែក្នុងវេលាជាមួយគ្នា ក៏នឹងក្រែងរអែងគេថាយ៉ាងនេះយ៉ាងនោះ កាលបើយ៉ាងនេះ នាងរមែងស្រឡាញ់គេត្រឹមបន្តិចបន្តួចប៉ុណ្ណោះ មិនអាចនឹងស្រ-ឡាញ់គេយ៉ាងបំផុតចិត្តបាន ព្រោះនៅមិនទាន់ទំនុកទុកចិត្តគេ យ៉ាងនេះមែនឬទេ ? ” ។

“ មែន! ” នាងក្រមុំឆ្លើយទទួល ។

“ហេតុម៉េច ទើបមិនស្រឡាញ់គេឱ្យអស់ពីពោះពីពុង ? ” ខ្ញុំសួរតទៅ ។

“ក៏ព្រោះខ្ញុំដឹងច្បាស់ថា គេមានចេតនាអាក្រក់ចំពោះខ្ញុំ ការធ្វើល្អរបស់គេ ត្រឹមតែជាការក្លែងធ្វើ ដើម្បីបោកបញ្ឆោតឱ្យខ្ញុំស្លាប់ចិត្តបើកឱកាសឱ្យគេប្រទូសរ៉ាយខ្ញុំ បានងាយប៉ុណ្ណោះ ខ្ញុំអាចនឹងនឹកពេញចិត្តចំពោះគេខ្លះ ក្នុងប្រការដែលគេធ្វើល្អចំពោះខ្ញុំ តែមិនអាចនឹងស្រឡាញ់គេឱ្យដល់ទីបំផុតចិត្តទេ ព្រោះនៅសង្ស័យរអែងក្រែងប្រចាំចិត្ត ” ។

“ កុលធីតា! នេះក៏បង្ហាញឱ្យឃើញថា ទឹកចិត្តជារបស់អាចបែងបាន យើងអាចនឹងស្រឡាញ់នរណាតិចក៏បាន ច្រើនក៏បាន បើយើងសំឡឹងមនុស្សដែលយើងស្រឡាញ់ក្នុងគុណសម្បត្តិនិងគុណវិបត្តិ យើងនឹងស្រឡាញ់គេត្រឹមបន្តិចបន្តួច ស្រឡាញ់គេព្រោះឃើញក្នុងគុណសម្បត្តិរបស់គេ និងរអែងក្រែគេ ព្រោះសំឡឹងគេក្នុងគុណវិបត្តិទោះ

បីគេមិនសំដែងគុណវិបត្តិមកឱ្យឃើញក៏ដោយ អ្នកលិ្ខតល្អន់ក៏ត្រូវសំ-ឡឹងគេក្នុងផ្លូវគុណវិបត្តិទុកដែរ កាលគេសំដែងក្រឡាសាររបស់គេចេញមក យើងក៏មិនខូចចិត្តឥតរំភើបអ្វី ព្រោះជាបញ្ហាដែលយើងបានគាតអានស្មានទុកហើយ បើយើងសំឡឹងគេក្នុងផ្នែកល្អតែម្យ៉ាង យើងភ្លើតភ្លើនស្រឡាញ់គេយ៉ាងអស់ពីពោះពីពុង កាលគេសំដែងបញ្ចេញផ្នែកអា-ក្រក់មក ទើបនាំឱ្យខូចចិត្តច្រើន ពុំបានគិតឡើយថា គេនឹងមិនពេញចិត្តយើង ព្រោះយើងមិនស្រឡាញ់គេ យើងស្រឡាញ់គេពិត១ តែថាស្រឡាញ់តិចទៅខ្លះ ទាំងនេះក៏ដើម្បីសេចក្តីរួចភ័យរបស់យើង កាលណាគេអាចពិសោធឱ្យឃើញបានដោយការប្រព្រឹត្តិថា ស្មោះត្រង់ចំពោះយើងពិត១ យើងក៏ព្រមស្រឡាញ់គេយ៉ាងពេញចិត្ត ប្រគល់ចិត្តទាំងអស់ឱ្យ” ។

**លោកអ្នកអានជាទីមេត្រី!** កាលនិយាយដល់ត្រង់នេះ នាងក្រមុំក៏ផ្តើមសំឡឹងមើលខ្ញុំ ដោយដួងភ្នែកសំដែងសេចក្តីទុកចិត្តនិងសេចក្តីគោរពរាប់អានច្រើឡើង នាងនិយាយដោយសំឡេងច្បាស់លាស់ថា “ត្រូវណាស់! ត្រូវណាស់! ព្រះតេជគុណ ខ្ញុំភ្លើតភ្លើនទុកចិត្តគូស្រឡាញ់ណាស់ពេកទៅ ទើបបានប្រគល់ជីវិតចិត្តទាំងអស់ឱ្យគេ កាលគេក្បត់ទៅរៀបការនឹងស្ត្រីដទៃ បានជានាំឱ្យខូចចិត្តកើតទុក្ខធំ ” ។

**កុលធីតា!** ការភ្លាំងភ្លាត់ខុសបំណងរបស់នាងក្នុងគ្រានោះ ជា

មេរៀនដ៏មានតម្លៃ ប្រៀនប្រដៅឱ្យនាងសំឡឹងមើលលោកទាំងពីរផ្លូវ " ខ្ញុំប្រៀនប្រដៅតទៅ " គ្រប់យ៉ាងគ្រប់ប្រការ រមែងមានពីរផ្លូវជានិច្ច មានងងឹតត្រូវមានភ្លឺ មានត្រជាក់ត្រូវមានក្តៅ មានខ្ពស់ត្រូវមានទាប មានល្អត្រូវមានអាក្រក់ មានសុខត្រូវមានទុក្ខ មានឈ្នះត្រូវមានចាញ់ មានសមបំណង មានខុសបំណង យើងត្រូវសំឡឹងឱ្យឃើញទាំងពីរផ្នែក បើមើលតែផ្នែកល្អម្យ៉ាង មិនប្រុងប្រៀបខ្លួនទុកទទួលផ្នែកអាក្រក់ផង កាលជួបប្រទះប៉ះទង្គិច ក៏លិចលង់ក្នុងទុក្ខ បើសំឡឹងមើលតែមួយចំ-ណែក មិនត្រៀមខ្លួនទទួលផ្នែកល្អ ក៏មិនរួចខ្លួនទៀត អ្នកដែលលេងកីឡា ត្រូវត្រៀមខ្លួនទទួលទាំងចាញ់និងឈ្នះ អ្នកប្រឡងប្រណាំងប្រជែងត្រូវប្រុងប្រៀបទទួលការជាប់និងការធ្លាក់ អ្នកដែលប្រាថ្នាអ្វី ត្រូវប្រុងប្រៀបទទួលទាំងការសមបំណងនិងខុសបំណង អ្នកមើលឃើញលោកទាំងពីរផ្លូវ ប្រុងប្រៀបរៀបខ្លួនគ្រប់កាល រមែងញញឹងជានិច្ចទាំងគ្រាចាញ់និងឈ្នះ ទាំងគ្រាខុសបំណងនិងសមបំណង ទាំងគ្រាសុខនិងទុក្ខ មានចិត្តរឹងប៉ឹងមាំមួន រមែងបានប្រៀបគ្រប់កាល និងគ្រប់ទីកន្លែង ។

កុលធីតាអើយ! ព្រោះនាងសំឡឹងមើលលោក ក្នុងផ្នែកល្អតែម្យ៉ាង ទើបត្រូវជួបប្រទះមហន្តទុក្ខក្នុងគ្រានេះ តទៅនាងគួរសំឡឹងមើលលោកក្នុងផ្នែកទាំងពីរជានិច គ្រានេះបាននាងដួលទៅហើយ ភ្លាត់ទៅហើយ ចូរប្រញាប់ក្រោកឡើងដើរតទៅ កាលឃើញថាខ្លួនដួលហើយ ទៅជា

ដេកព្រងើយមិនក្រោកឡើងនោះ មិនមែនជាអំពើឆ្លាតទេ ” ។

ឥឡូវនេះ ហេតុផលបានវិលត្រឡប់មកកាន់ស្ត្រីក្រមុំបានយ៉ាងបរិបូណ៌ នាងក្រាបសំពះទៀបបាទជើងរបស់ខ្ញុំ ដោយសេចក្ដីជ្រះថ្លាសទ្ធា ហើយពោលថា :

“ **ព្រះគុណដ៏រុងរឿងដោយបញ្ញា !** ពាក្យដឹកនាំរបស់ព្រះ-គុណម្ចាស់ ចាប់ចិត្តច្បាស់លាស់ចំពោះខ្ញុំពន់ពេក ដូចជាឱសថវិសេសជប់ជីវិតរបស់ខ្ញុំ ឱ្យរស់រានមានជីវិតឡើងវិញ បើគ្មានព្រះគុណម្ចាស់ខ្ញុំនឹងស្លាប់ជាខ្មោចក្នុងជ្រោះភ្នំទៅហើយ តាំងពីពេលនេះតទៅ ខ្ញុំនឹងមិនគិតធ្វើយ៉ាងល្ងង់ៗ ដូច្នេះទៀត នឹងកំណត់កត់ចាំពាក្យណែនាំរបស់ព្រះ-គុណទុក នាំទៅប្រៀនប្រដៅអ្នកដែលគិតសម្លាប់ខ្លួនឱ្យភ្លឺស្វាងដូចខ្ញុំម្ចាស់ដែរ ” ។

**លោក_អ្នកអានជាទីមេត្រី!** កាលបានទេសនាប្រៀនប្រដៅស្ត្រីក្រមុំឱ្យមានចិត្តមាំក្នុងហេតុផលល្អហើយ នាងក្រមុំក៏លាខ្ញុំដើរចុះភ្នំត្រឡប់ទៅផ្ទះដោយអាការប្រក្រតី ខ្ញុំត្រេកអររីករាយ ដែលបានជួយជីវិតមនុស្សម្នាក់ឱ្យរួចពីសេចក្ដីស្លាប់ ខ្ញុំត្រឡប់ទៅកាន់ល្អាងសូករខាតា ហើយក៏បំពេញព្យាយាមភាវនាតទៅ ។

# និទានិចសរសេរ

**លោក-អ្នកអានជាទីមេត្រី!** ទោះល្អាងសុករខាទា លើភ្នំគិជ្ឈ-កូដ ជាទីត្រូវអធ្យាស្រ័យរបស់ខ្ញុំត្រឹមណា ខ្ញុំក៏មិនអាចនៅប្រចាំជានិច្ចបាន ព្រោះការទាក់ទងនិងការបរិហារគ្រប់គ្រងពួកគណៈ ធ្វើឱ្យខ្ញុំត្រូវវិលត្រ-ឡប់ទៅកាន់វត្តព្រះវេឡុវនវិញ ការបាននៅកណ្ដាលពួកគណៈ ដែលនៅរួមគ្នាដោយធម៌ ស្រឡាញ់មូលមិត្តគ្នាដោយល្អ គ្រប់មនុស្សសំដែងតែសេចក្ដីល្អចំពោះគ្នា ចាត់ថាជាសេចក្ដីសុខម្យ៉ាង ការបាននៅជួបជុំក្នុងសង្គមឬគណៈ ទោះគ្រាខ្លះ បានជួបប្រទះក្ដីក្ដៅក្រហាយរំខានខ្លះ តែក្នុងផ្នែកជំរៅរបស់ចិត្តខ្ញុំ ក៏ដូចជាកក់ក្ដៅ ការនៅតែម្នាក់ឯងតាមព្រៃភ្នំក្រំថ្ម ទោះស្ងៀមស្ងាត់ល្អ ជួនកាលក៏ធ្វើឱ្យកើតសេចក្ដីស្រងេះស្រងោចសោកសៅក្រៀមក្រំចិត្តយ៉ាងច្រើន ធ្វើឱ្យឃើញសេចក្ដីសំខាន់របស់គណៈសង្គមឡើងភ្លាម សង្គមឬពួកគណៈរមែងមានឥទ្ធិពលលើចិត្តរបស់បុគ្គលជាយ៉ាងច្រើន យើងបានប្រយោជន៍ច្រើនយ៉ាងពីការនៅរួមពួកគណៈ គឺកាលកើតហេតុចាំបាច់ឡើង ពួកគណៈរមែងជួយសង្គ្រោះយើងបាន ទ្រព្យរបស់យើង យសសក្ដិរបស់យើងអាចមានតម្លៃ ហុចគុណប្រយោជន៍ដល់យើងបានពេញលេញ ក៏ព្រោះពួកគណៈ ឬសង្គមរ៉ាប់រង បើសង្គមមិនរ៉ាប់រង ទ្រព្យនិងយសនោះក៏គ្មានតម្លៃ ព្រះរាជាដែលមានកិត្តិយសខ្ពស់បំផុតនោះ បើព្រះអង្គទៅគង់នៅក្នុងព្រៃតែ

មួយអង្គឯងកណ្ដាលហ្វូងស្វា កិត្តិយសនោះក៏គ្មានតម្លៃ ថ្លៃប្រសើរអ្វីឡើយ ប្រការចុងបំផុត ការនៅក្នុងពួកគណៈ សង្គមនីមួយៗ ធ្វើឱ្យកើតសេចក្ដីសុខចិត្ត កក់ក្ដៅចិត្ត, សេចក្ដីពិតចំណុចត្រង់នេះ យើងមិនសូវដឹងព្រោះធ្លាប់ជិនថ្នឹក តែកាលត្រូវព្រាត់ឃ្លាតទៅចាកពួកគណៈនោះ ទើបដឹងច្បាស់ ដូច្នោះ ការនិរទេសអ្នកធ្វើខុសចេញពីសង្គមឬពួកគណៈ ទើបនិយមថាចាការដាក់ទោសម្យ៉ាង ដែលធ្វើឱ្យអ្នកត្រូវទោសបានទទួលទុក្ខច្រើន មនុស្សខ្លះប្រថុយរត់រៀសគៀសរត់ត្រឡប់មកនៅក្នុងពួកគណៈទៀត សូម្បីខ្លួននឹងស្លាប់ក៏ព្រម សូមឱ្យបានស្លាប់កណ្ដាលពួកគណៈក៏នៅល្អប្រសើរជាងស្លាប់ម្នាក់ឯង ។

**លោក_អ្នកអាន!** កាលយើងបានទទួលប្រយោជន៍ច្រើនប្រការពីការនៅរួមសង្គមដូច្នេះ ពួកគណៈក៏ឈ្មោះថា មានបុណ្យគុណចំពោះយើងយ៉ាងខ្ពស់ អ្នកណាស្រឡាញ់ពួកគណៈ ឃើញដល់ពួកគណៈមានចិត្តទូលំទូលាយធ្វើប្រយោជន៍ដល់ពួកគណៈ អ្នកនោះឈ្មោះថាដឹងគុណរបស់ពួកគណៈ ផ្ទុយទៅវិញ អ្នកណានៅក្នុងពួកគណៈបានទទួលផលប្រយោជន៍ដូចពោលហើយពីពួកគណៈ តែឃើញតែប្រយោជន៍ខ្លួន ។មនចិត្តចង្អៀតចង្អល់ កើបកោយការក្រសាក្រសោបយលផលប្រយោជន៍ឱ្យដល់ខ្លួន មិនបាននឹងដល់ទ្រូងអ្នកដទៃ បង្កើតសេចក្ដីក្ដៅក្រហាយរំខានឱ្យដល់ពួកគណៈជានិច្ច អ្នកនោះឈ្មោះថាជាអ្នកនេរគុណចំពោះពួកគណៈ

ជាអ្នកជំទាស់សេចក្ដីចំរើនរបស់ពួកគណៈ ជាបញ្ញើរក្អែកដែលចាំតែបឹតស្រូបស៊ីឈាមអង្គៀមឆ្អឹងរបស់ពួកគណៈ ។

**លោក_អ្នកអាន!** ខ្ញុំបានខំណែនាំ ប្រៀនប្រដៅ ព្រះភិក្ខុសាម-ណេរ និងភិក្ខុនី ដែលនៅក្នុងការគ្រប់គ្រងរបស់ខ្ញុំ ឱ្យឃើញសេចក្ដីសំខាន់របស់ពួកគណៈ គ្រប់គ្នាក៏តាំងនៅក្នុងឱវាទរបស់ខ្ញុំជាយ៉ាងល្អ តែនៅមានភិក្ខុថ្មីមួយរូបមកពីត្រកូលសេដ្ឋីដ៏ស្ដុកស្ដម្ភម្នាក់ ក្នុងក្រុងរាជគ្រឹះ ភិក្ខុរូបនេះ មានឈ្មោះថា **វរាហៈ** មាននិស្ស័យក្រអឺតក្រអោងប្រកាន់ខ្លួន មិនព្រមទទួលពាក្យណែនាំប្រៀនប្រដៅរបស់អ្នកណា ព្រោះប្រកាន់ថា ត្រកូលរបស់ខ្លួនស្ដុកស្ដម្ភ **ព្រះសុភូតៈ** បាននាំរឿងរ៉ាវរបស់ភិក្ខុរូបនេះមកនិយាយឱ្យខ្ញុំស្ដាប់ ថ្ងៃមួយខ្ញុំបានហៅ **វរាហភិក្ខុ** មកជួប ហើយសួរថា :

" **ម្នាលលោកវរាហៈ !** ខ្ញុំមានសេចក្ដីយល់ឃើញម្យ៉ាងថាបុគ្គលខ្លះ ដែលមានកំណើតកើតចេញពីត្រកូលខ្ពស់ មានការសិក្សាខ្ពស់រមែងមានការប្រព្រឹត្តិប្រតិបត្តិខ្លួនត្រឹមត្រូវ មានការនិយាយត្រឹមត្រូវ មានការគិតត្រឹមត្រូវ មិនមានតក់ឆ្គងភ្លាំងភ្លាត់សូម្បីត្រឹមបន្តិចបន្តួច ជាអ្នកធ្វើត្រូវ គិតត្រូវ គ្រប់ប្រការ គ្រប់ទីកន្លែង គ្រប់កាលវេលា ខ្ញុំមានសេចក្ដីយល់ឃើញយ៉ាងនេះ តើលោកយល់ឃើញយ៉ាងណា ? " ។

" **ព្រះមហាថេរដ៏ចំរើន!** ខ្ញុំព្រះករុណាទើបមកថ្មីកាន់ធម៌វិន័យនេះ នៅមិនទាន់ចេះដឹងយល់ក្នុងអត្ថនិងធម៌ ដូចព្រះគុណម្ចាស់ តែតាមដែលខ្ញុំករុណាបានជួបប្រទះមកហើយក្តី បានឮបានស្តាប់មកក្តី ប្រាកដថាសាមញ្ញជនគ្រប់គ្នា តែងតែមានឱកាសដែលនឹងធ្វើភ្លាំងភ្លាត់បាន បើមិនច្រើនក៏តិច មិនមាននរណាឡើយ ដែលធ្វើនិយាយគិតអ្វី បានត្រឹមត្រូវគ្រប់គ្រាន់គ្រប់យ៉ាងនិងគ្រប់កាលនោះទេ " ។

" សំដៅសេចក្តីថា សាមញ្ញជនគ្រប់គ្នា រមែងមានការខុសឆ្គងភ្លាំងភ្លាត់ ប្រចាំខ្លួនជានិច្ច បើមិនច្រើន ក៏តិចមិនមែនឬ ? "ខ្ញុំសួរផ្ទួនថែមទៀត ។

" ត្រូវហើយទានប្រោស ! " វរាហភិក្ខុ ឆ្លើយយ៉ាងប្រាកដក្នុងចិត្ត ។

" បើយ៉ាងនោះ លោកក្តី ខ្ញុំក្តី ក្នុងឋានៈដែលជាសាមញ្ញជន ក៏រមែងមានការខុសឆ្គងភ្លាំងភ្លាត់ប្រចាំខ្លួនជានិច្ចដូចគ្នាមែនទេ ? " ។

" ករុណាមែន! ខ្ញុំករុណា ក៏អាចមានការភ្លាំងភ្លាត់ ខុសឆ្គងដូចគ្នានឹងអ្នកដទៃ " ភិក្ខុវរាហៈព្រមទទួលយ៉ាងច្បាស់លាស់ កាលឃើញថាបានដេញដោលលោកមកដល់ជ្រុងដ៏សមទំនងហើយ ខ្ញុំក៏ផ្តើមលែងអាវុធរបស់ខ្ញុំភ្លាម ។

" **ម្នាលវរាហៈ!** កាលមាននរណា២ ពោលថាដាស់តឿនក្រើនរំលឹកលោក បញ្ជាក់ចង្អុលប្រាប់ការខុសឆ្គងភ្លាំងភ្លាត់របស់លោកដោយមានបំណងល្អ ដើម្បីលោកនឹងបានកែខៃលៃលកប្រព្រឹត្តខ្លួនឱ្យល្អឡើង ហេតុអ្វីក៏លោកខឹងនឹងគេទៅវិញ ? " ។

ភិក្ខុកម្លោះ អង្គុយស្ងៀមមួយសន្ទុះ ហើយក៏ពោលឡើងដោយទិដ្ឋិមានៈថា " តាមពិត ខ្ញុំព្រះករុណា ក៏មិនបានធ្វើខុសអ្វី តែភិក្ខុអ្នកបួសចាស់ ចេះតែចាប់ទោសអូសដំណើរឱ្យកំហុសខ្ញុំព្រះករុណាទាល់តែបាន គឺជាមនុស្សចូលចិត្តតិះដៀលអ្នកដទៃណាស់ពេកទៅ " ។

" **ម្នាលវរាហៈ!** មនុស្សយើងរមែងមើលមិនឃើញ រាងកាយរបស់ខ្លួនបានគ្រប់ចំណែកទេ សូម្បីឈរឡើងហើយឱនមើល ក៏ឃើញតែផ្នែកមុខប៉ុណ្ណោះ ផ្នែកខាងក្រោយមើលមិនឃើញទេ ក្នុងផ្នែកនៃការប្រព្រឹត្តិក៏ដូចគ្នា យើងច្រើនមើលឃើញក្នុងផ្នែកល្អរបស់យើង ផ្នែកអាក្រក់មើលមិនសូវឃើញ ហើយក៏យល់ថា ខ្លួនល្អហើយ ត្រឹមត្រូវហើយ សមរម្យហើយ លុះមានអ្នកដទៃមើលមកឃើញការតក់ឆ្គង ភ្លាំងភ្លាត់របស់យើង គេចង្អុលបង្ហាញឱ្យយើងមើល យើងមិនពេញចិត្ត ព្រោះសេចក្ដីប្រកាន់ខ្លួន អ្នកដទៃសំឡឹងមើលឃើញខ្លួនយើងបានច្បាស់លាស់ជាងខ្លួនយើងយ៉ាងណា គេក៏ឃើញសេចក្ដីប្រព្រឹត្តិរបស់យើងបានល្អជាង

យើងយ៉ាងនោះ កាលលោកព្រមទទួលថា ខ្លួននៅមានខុសតក់ឆ្គងភ្លាំងភ្លាត់ កាលអ្នកដទៃចង្អុលបង្ហាញឱ្យឃើញការខុសឆ្គង ក៏មិនគួរខឹងនឹងគេទេ ផ្ទុយទៅវិញ គួរសំដែងសេចក្ដីអរគុណគេថែមទៀត ព្រោះកាលយើងឃើញកំហុសនឹងការភ្លាំងភ្លាត់របស់យើងហើយ នឹងបានកែប្រែរៀបចំខ្លួនយើងឱ្យល្អឡើង ។

**ម្នាលវរាហ:!** សន្មតថា មានបុរសម្នាក់ មានរបស់ស្មោកគ្រោកប្រឡាក់មុខ តែខ្លួនឯងមើលមិនឃើញ សំគាល់ថា មុខរបស់ខ្លួនស្អាតផូរផង់ល្អហើយ ទើបដើរទៅតាមផ្លូវ ខណ:នោះ មានបុរសម្នាក់ដើរមកជួប ឃើញស្នាមប្រឡាក់នៅនឹងមុខរបស់បុរសទី ១ ទើបចង្អុលប្រាប់ឱ្យដឹង និងណែនាំឱ្យគេទៅលាងចោលចេញ តែបុរសមុខប្រឡាក់បែរជាខឹងថា គេមើលងាយខ្លួន មិនយកចិត្តទុកដាក់នឹងស្នាមប្រឡាក់របស់ខ្លួន ដើរអួតមុខប្រឡាក់របស់ខ្លួនតទៅ លោកឃើញថា បុរសនេះធ្វើត្រូវឬខុស ? " ។

" គេធ្វើខុសយ៉ាងពិតប្រាកដ ព្រះគុណម្ចាស់ "

" ផ្លូវដែលត្រូវ គេគួរធ្វើយ៉ាងណា? "

" គេគួរពិនិត្យមើលខ្លួនឯងជាមុនសិន បើឃើញស្នាមប្រឡាក់ពិតប្រាកដតាមដែលអ្នកដទៃប្រាប់ ក៏គួរអរគុណគេ ហើយក៏ប្រញាប់ទៅលាងរបស់ស្មោកគ្រោកនោះចេញ ខ្លួននឹងបានមានមុខស្អាតដូចដើម " ។

" **ម្នាលវរាហៈ!** ពាក្យប្រាប់ប្រេងរបស់អ្នកដទៃ ធ្វើឱ្យមុខរបស់បុរសនោះស្អាតបានយ៉ាងណា ពាក្យតិះដៀលរបស់អ្នកដទៃ ក៏អាចធ្វើឱ្យយើងល្អឡើងយ៉ាងនោះដែរ ធម្មតាបណ្ឌិតរមែងឃើញពាក្យតិះដៀលមានតម្លៃខ្ពស់ជាងពាក្យសរសើរ ព្រោះពាក្យតិះដៀលធ្វើឱ្យមនុស្សល្អឡើង តែពាក្យសរសើរអាចធ្វើឱ្យមនុស្សអាក្រក់ ឬស្មើៗ ។ បើជាការសរសើរតាមសេចក្តីពិត អ្នកត្រូវសរសើរ ក៏នឹងត្រេកអរនៅក្នុងសភាពដូច្នោះ ពេញចិត្ត ឆ្អែតចិត្តនៅក្នុងថ្នាក់ប៉ុណ្ណោះ មិនគិតនឹងកែខៃឆ្លៃខ្លួនឱ្យល្អក្រៃលែងឡើង បើជាពាក្យសរសើរប្រភេទបញ្ចោរ ដែលមិនមែនជាសេចក្តីពិត ដូចមុខយើងប្រឡាក់ប្រឡូសអ្វី តែគេបញ្ចោរថា ស្អាតល្អ ហើយដូច្នេះ ក៏នឹងធ្វើឱ្យយើងត្រេកអរ ពេញចិត្តនៅនឹងមុខដែលប្រឡាក់កខ្វក់នោះ មិនគិតជូតលារបស់ស្មោកគ្រោកចេញ មុខរបស់យើងក៏នៅតែប្រឡាក់ប្រឡូសយ៉ាងនេះជានិច្ចទៅ ដូច្នោះ លោកមិនគួរខឹង កាលត្រូវអ្នកដទៃបន្ទោស តិះដៀល និងមិនគួរត្រេកអរ ជោរ ពេញចិត្ត ក្នុងកាលបានទទួលពាក្យសរសើរ " ។

**លោក_អ្នកអាន!** ពាក្យណែនាំរបស់ខ្ញុំ បានផលទាន់ភ្នែក គឺតាំងតែពីថ្ងៃនោះជាដើមមក ភិក្ខុវរាហៈ បានក្លាយជាស្ងប់ស្ងៀម មិនក្រអឺតក្រអោង មិនប្រកាន់ខ្លួន ត្រេកអរទទួលស្គាល់ពាក្យណែនាំប្រាប់

ពន្យល់ពីមិត្តសហធម្មិកយ៉ាងពេញចិត្ត ព្រះវេឡុវនារាម ក៏អស់ចម្រូងបន្លា មានតែសន្តិសុខគ្រប់ទិវារាត្រី ។

**ប្រិយមិត្តទាំងឡាយ!** មនុស្សភាគច្រើន មិនបានសិក្សាមើលខ្លួនឯងឱ្យល្អិតដោយចិត្តជាធម៌ទេ មិនបានប្រៀនប្រដៅខ្លួនឯងនិងអ្នកដទៃដោយគំនិតយុត្តិធម៌ ទើបច្រើនចូលចិត្តថា ខ្លួនល្អប្រសើរជាងអ្នកដទៃត្រូវ សមរម្យ ជាអ្នកដទៃ គំនិតនឹងគិតដូច្នេះមានស្ទើរតែគ្រប់មនុស្ស មនុស្សខ្លះក៏សំដែងចេញមកដោយការនិយាយអួតអាង ខ្លះក៏សំដែងចេញមកដោយឫកពា ខ្លះក៏សំដែងចេញមកធ្វើជាអង្គុយស្ងៀម ខ្លះក៏មិនសំដែងអាការៈអ្វីៗ ឱ្យឃើញ ហាក់ដូចជា គេមិនបាននឹងគិតដូច្នោះឡើយ តែតាមពិតហើយ គេមានសេចក្តីនឹកគិតថា "ខ្លួនល្អ" ដូចគ្នានឹងមនុស្សដែលសំដែងចេញមកត្រង់ៗ យើងអាចនឹងពិសោធមើលបានដោយការក្លែងបញ្ចោរគេ ថាគេល្អយ៉ាងនោះពូកែយ៉ាងនេះ ស្រស់យ៉ាងនោះឆើតយ៉ាងនេះ គេមុខជាសំដែងសេចក្តីពេញចិត្តចេញមកយ៉ាងច្បាស់ ព្រោះហេតុអ្វី? ក៏ព្រោះពាក្យបញ្ចោររបស់យើង ត្រូវនឹងគំនិតគិតចង់របស់គេ គេសំគាល់យល់ថា គេល្អស្រាប់ហើយ កាលយើងទៅសរសើរគេទើបកើតសេចក្តីពេញចិត្ត ទាំងដែលពាក្យលើកដំកើងបញ្ចោរ ជួនកាលក៏គ្មានមូលនៃសេចក្តីពិតឡើយ ផ្ទុយទៅវិញ បើយើងទៅដៀលត្មះគេ ទោះពាក្យតិះដៀលរបស់យើងជាសេចក្តីពិត គេក៏ខឹង ព្រោះគេគិតថា គេល្អ

ប្រសើរទៅហើយ កាលយើងទៅតិះដៀលគេ ទើបជាការជំទាស់ ឬកាត់ចោលសេចក្តីនឹងគិតរបស់គេ ធ្វើឱ្យគេកើតសេចក្តីមិនពេញចិត្តហើយចងកំហឹងនិងយើង រកផ្លូវបំផ្លាញសងសឹកអ្នកតិះដៀលនោះ នេះជាមូលហេតុឱ្យកើតសេចក្តីលំបាក ប្រឡូកប៉ូកប៉ាក់ច្រឡំបល់ក្នុងជំនុំជន ។

**លោក_អ្នកអាន!** មានសេចក្តីពិតមួយថា អ្នកធំជាគណបា-មោក្ខ មានអំណាចបរិហារពួកគណៈ រមែងជាទីគោរពកោតខ្លាចរបស់អ្នកតូច សេចក្តីគោរពកោតខ្លាចនេះឯង ធ្វើឱ្យអ្នកតូចរអែងក្រែងញញើតមិនហ៊ានជំទាស់ មិនហ៊ានដាស់តឿនក្រើនរំលឹក កាលឃើញកំហុសភ្លាំងភ្លាត់របស់អ្នកធំ មានតែលើកដំកើងសរសើរជាចំណែកមួយ កាលអ្នកធំបានទទួលតែពាក្យសរសើរលើកដំកើងជានិច្ចដូច្នេះ ក៏លង់ឡើយកើតសេចក្តីសំគាល់យល់ថា ខ្លួនជាបុគ្គលពិសេស ធ្វើអ្វី និយាយអ្វី មិនខុស មានតែត្រូវទាំងអស់ ទើបជាហេតុឱ្យធ្វើអ្វី និយាយអ្វី តាមសេចក្តីគិតឃើញរបស់ខ្លួនម្នាក់ឯង មិនព្រមទទួលស្តាប់ គំនិតគិតឃើញរបស់អ្នកដទៃ ព្រោះសំគាល់ថា របស់ខ្លួនប៉ុណ្ណោះទើបត្រឹមត្រូវប្រើបាន របស់អ្នកដទៃ ប្រើមិនបាន, កាលបានទទួលពាក្យវិភាគវិចារណ៍ ការតិះដៀលពីអ្នកដទៃ ទើបកើតសេចក្តីមិនពេញចិត្តអន្ទះអន្ទែង ក្តៅក្តួលជាងមនុស្សធម្មតា កើតសេចក្តីមិនពេញចិត្តនិងនរណាហើយ ច្រើនប្រើអំណាចនាទី

របស់ខ្លួនកំចាត់អ្នកនោះចោលឬរកផ្លូវធ្វើទុក្ខបុកម្នេញដោយប្រការផ្សេងៗ ធ្វើឱ្យជំនុំនោះៗ ក្លាយជាអាណាចក្រ នៃសេចក្តីខ្លបខ្លាច ។

**លោក-អ្នកអាន!** សម្រាប់ខ្ញុំនោះ សូម្បីខ្លួន ជាប្រធានសង្ឃ បរិហារពួកគណៈក្នុងព្រះវេឡុវនារាម ខ្ញុំក៏ព្យាយាមដាស់តឿនក្រើនរំលឹក ខ្លួនឯងជានិច្ច ទុកដាក់ថា ខ្លួនជាសាមញ្ញជនម្នាក់ ដែលភ្លាំងភ្លាត់ខុស បាន ទើបព្រមទទួលពាក្យវិភាគវិចារណ៍ ការចាប់ថ្នាក់ពីអ្នកដទៃគ្រប់ កាល ខ្ញុំបើកឱកាសឱ្យសិស្សានិសិស្សរបស់ខ្ញុំ ដាស់តឿនក្រើនរំលឹក ខ្ញុំបាន ក្នុងកាលឃើញការឆ្គាំឆ្គងភ្លាំងភ្លាត់របស់ខ្ញុំ ទើបខ្ញុំត្រូវអាស្រ័យ ព្រះសុភូតភិក្ខុឱ្យជួយជាអ្នកស៊ើបសួរគំនិតគិតឃើញយោបល់ របស់ពួក គណៈនាំមករាយការណ៍ឱ្យខ្ញុំដឹងមួយជានទៀត ដោយវិធីការគ្រប់គ្រង បែបនេះឯង ធ្វើឱ្យខ្ញុំក្លាយជាទីស្រឡាញ់គោរពរបស់ពួកគណៈ មិនមាន ថ្ងៃជួរចត់រសាំរសាយឡើយ ។

# អាវុធខាងក្នុង

**លោក-អ្នកអាន!** លោកជ្រាបច្បាស់លាស់ស្រាប់ហើយថា អាណាចក្រមគធៈនិងអាណាចក្រកោសលជាសត្រូវគ្នា ធ្លាប់ធ្វើសង្គ្រាមនឹងគ្នាជាច្រើនគ្រា ដើម្បីដណ្ដើមភាពជាធំ លើមធ្យមប្រទេស ឈ្នះចាញ់ៗ ឈ្នះគ្នាជាវៀយមក សង្គ្រាមម្ដងៗ ធ្វើឱ្យមនុស្សនិងសត្វពាហនៈរាប់ចំនួនសែនៗ ស្លាប់គរដេសរដាស ធ្វើឱ្យទ្រព្យសម្បត្តិវិនាសហិនហោចទៅរាប់ចំនួនមិនបានប្រមាណមិនអស់ កាលសាងសង្គ្រាមហើយ ទាំងចំណែកចាញ់និងចំណែកឈ្នះ ក៏វិនាសហិនហោចខ្ទេចផង់ទាំងអស់គ្នា រយៈវេលាដែលខ្ញុំមកនៅក្រុងរាជគ្រឹះនេះ ជារយៈដែលស្ងប់ចាកសង្គ្រាមតែភ្លើងពៀរ ( គំនុំចិត្ត ) នៅឆេះគុកគាក់ក្នុងហឫទ័យពួកក្សត្រ រហូតដល់មេទ័ព នាយកង នៃមគធៈរដ្ឋគ្រប់គ្នា ព្រោះក្នុងសង្គ្រាមទីបំផុត អាណាចក្រមគធជាផ្នែកបរាជ័យ មេទ័ពគ្រប់គ្នា ទើបមួម៉ៅក្ដៅចិត្តឥតរសាយ នឹងផ្ដើមប្រុងប្រៀបរៀបត្រៀមធ្វើសង្គ្រាម ដើម្បីសងសឹក តែកំហឹងនោះ បុរសរាប់ចំនួនហ្មឺននាក់បានត្រូវកេណ្ឌចូលកកាន់បន្ទាយ ជិះសេះ បានទទួលការហ្វឹកហាត់ មានការសន្សំស្បៀងនិងអាវុធយុទ្ធោបករណ៍ផ្សេងៗយ៉ាងម៉ឺងម៉ាត់ ចារបុរសអ្នកស៊ើបការសម្ងាត់ បានចាត់បញ្ជូនទៅគ្រប់ទិស ចារបុរសផ្នែកកោសលរដ្ឋ កាលស៊ើបដំណឹងបានថា មគធរដ្ឋមានទាហានប៉ុណ្ណោះនាក់ មានរថចំបាំងប៉ុណ្ណោះគ្រឿង

មានដំរី សេះ ប៉ុណ្ណោះ មានអាវុធប្រភេទនោះៗ ហើយក៏រាយការណ៍ទៅឱ្យមេទ័ពរបស់ខ្លួនដឹង បណ្ដាទ័ពនៃកោសលរដ្ឋ កាលបានដឹងថា ខាងមគធរដ្ឋ មានកម្លាំងពលច្រើនជាងខ្លួនក៏កើតក្ដៅចិត្ត ក្រែងភ្លាត់ចាញ់ក្នុងការប្រយុទ្ធ ក៏ប្រញាប់កេណ្ឌពលយោធាបន្ថែមដំរី សេះ ឡើងទៀត ដើម្បីឱ្យមានចំនួនច្រើនជាងមគធរដ្ឋ ។ ចំណែកចារបុរសរបស់មគធរដ្ឋ កាលឃើញកោសលរដ្ឋបន្ថែពលចម្បាំងច្រើនឡើង ក៏ប្រញាប់រាយ-ការណ៍ទៅឱ្យមេទ័ពឯមគធរដ្ឋដឹង បណ្ដាមេទ័ពផ្នែកមគធរដ្ឋ កាលបានដឹង ក៏ភិតភ័យ ប្រញាប់កេណ្ឌទ័ពបន្ថែមទៀតឱ្យច្រើនជាងកោសលរដ្ឋ ការប្រណាំងប្រជែងគ្នាបន្ថែមកម្លាំងសម្រាប់ច្បាំង ប្រព្រឹត្តទៅដូច្នេះមួយឆ្នាំមកហើយ ទាល់តែប្រុសកម្លោះសឹងគ្រប់គ្នាត្រូវកេណ្ឌជាទាហាន ដំរីសេះទាំអស់ប្រមូលទុកដើម្បីច្បាំង គ្រប់យ៉ាងគ្រប់ប្រការប្រព្រឹត្តទៅដើម្បីចម្បាំងទាំងអស់ ។

**លោក_អ្នកអាន!** កាលហេតុការណ៍ជាយ៉ាងដូច្នោះ ប្រជាជនទូទៅទាំងក្នុងកោសលរដ្ឋ និង មគធរដ្ឋ សឹងរអារអើមចំពោះការប្រុងប្រៀបសម្លាប់គ្នា ដែលមិនមានទីបំផុត ព្រោះភាពដ៏គួរតក់ស្លុតរន្ធត់ក្នុងសង្គ្រាមក្នុងគ្រាកន្លងមកហើយនៅច្បាស់លាស់ក្នុងសេចក្ដីទ្រទ្រង់ចាំរបស់គេ មិនមាននរណាចង់ឱ្យភាពដូច្នេះផុះឡើងទៀតឡើយ សង្គ្រាមជាអំពើឃោរឃៅយង់ឃ្នងក្រៃលែងជាងអាជ្ញាកម្មណាៗ ក្នុងលោក សេចក្ដីដឹង

ចំពោះការប្រុងប្រៀបរៀបចំ ដើម្បីសង្គ្រាំបានធំនៅក្នុងចិត្តគំនិតរបស់ប្រ-ជាជនគ្រប់គ្នា សេចក្ដីដឹងក្នុងចិត្តបានត្រូវសំដែញចេញជាសំដីនិយាយជំទាស់ និងការធ្វើការជំទាស់ផ្សេងៗ ហេតុការណ៍សឹងនឹងកើតជាចលាចលហើយ តែជួនជាមានដំណឹងល្អ បានផ្សាយទូទៅពេញមគធរដ្ឋថាឥឡូវនេះ ខាងកោសលរដ្ឋ បានបញ្ជូនគណៈទូតសន្តិភាពសូមចរចារួមគ្នា និងអាណាចក្រមគធៈ ដើម្បីរកផ្លូវការពារមិនឱ្យកើតសង្គ្រាមឡើងទៀត រវាងរដ្ឋទាំងពីរក្នុងអនាគត ផ្លូវការនៃក្រុងរាជគ្រឹះ បានឱ្យកិត្តិយសយ៉ាងខ្ពស់ចំពោះគណៈទូតសន្តិភាព ដែលមកពីក្រុងសាវត្ថី ។

ការចារចាបានប្រព្រឹត្តទៅអស់វេលាជាច្រើនថ្ងៃទីប្រជុំបានពិចារណាដល់មូលហេតុដែលនាំឱ្យកើតសង្គ្រាំ និងមានសេចក្ដីយល់ឃើញជាឯកច្ឆន្ទថា កំឡាំងច្បាំង គឺមនុស្ស និងអាវុធ ដែលម្ខាងៗ សន្សំទុកច្រើនៗ នោះឯង គឺរបស់ដុតរោលដោលរុក ឱ្យបណ្ដាមេទ័ពទាំងឡាយចង់ធ្វើសង្គ្រាំ ដូចបុរសកម្លោះ មានកម្លាំងរាងកាយរឹងប៉ឹង រមែងចង់ដាល់អ្នកនេះ អ្នកនោះ បើគ្មានយុទ្ធោបករណ៍ ឬ មានត្រឹមបន្តិចបន្តួចទោះចង់ធ្វើសង្គ្រាមខ្លាំងក្លាយ៉ាងណា ក៏មិនអាចធ្វើបាន ដូចបុរសកម្លោះខ្វះកម្លាំងដៃទាំងពីរ មិនអាចដាល់បានដូច្នោះ មានវិធីការការពារមិនឱ្យកើតសង្គ្រាម ក៏គឺការព្រមព្រៀងទាំងពីរចំណែក បន្ថយយុទ្ធោប-ករណ៍របស់ខ្លួនសល់ត្រឹមបន្តិចបន្តួច លម្មជាគ្រឿងការពារខ្លួនប៉ុណ្ណោះ

គណៈទូតទាំងពីរខាង ក៏យល់ស្របគ្នា ដោយវិធីការនេះតពីនោះ ក៏មានការចាត់តាំងគណៈកម្មការរួមដើម្បីការដក ឬបន្ថយអាវុធឡើង ។ គណៈកម្មការនេះ បានប្រជុំគ្នាមួយគ្រាហើយមួយគ្រាទៀត ដើម្បីពិចារណារកផ្លូវព្រមព្រៀងក្នុងការបន្ថយអាវុធឱ្យបានផលជាក់ស្តែង តែក៏ពិបាកនឹងព្រមព្រៀងចុះសម្រុងគ្នាបាន ព្រោះសមាជិកម្ខាង១គ្មានសេចក្តីទុកចិត្តគ្នា ម្ខាងក្រែងថាម្ខាង ប្រាប់ចំនួនយុទ្ធោបករណ៍មិនត្រង់សេចក្តីពិតតាមដែលព្រមព្រៀងគ្នា ឬបន្ថយម្ខាង គ្រាន់តែគ្រឿងបោកបញ្ឆោតអ្នកត្រួតត្រា តែទៅបន្ថែមក្នុងផ្នែកដទៃ១ ។ សេចក្តីរអែងក្រែសង្ស័យមិនទុកចិត្តគ្នានិងគ្នានេះឯង ជាមូលហេតុឱ្យការចរចារបន្ថយសព្វាវុធ ឬយុទ្ធោប-ករណ៍ ត្រូវបរាជ័យម្តងហើយ ម្តងទៀត ក្នុងខណៈដែលចរចាមិនបានផល ព្រឹត្តិការណ៍តទៅទាំងពីរចំណែក ក៏កាន់ឱកាសបន្ថែមយុទ្ធោបករណ៍របស់ខ្លួនឱ្យច្រើនក្រៃលែងឡើង ដើម្បីមិនឱ្យសៀបប្រៀបគ្នា ស្រ-មោលដ៏ខ្មៅងងឹតនៃអសុរសង្គ្រាម ក៏ចូលមកគ្របដណ្តប់ផ្សព្វផ្សាយទូទៅពេញមហាណាចក្រទាំងពីរនោះ ។

**ប្រិយមិត្តទាំងឡាយ!** ក្នុងវេលារវាងនោះឯង ឧបាសកអ្នកស្មាត់ជំនាញក្នុងរដ្ឋប្រសាសនោបាយម្នាក់ បានទៅរកខ្ញុំនាព្រះវេឡុវនា-រាម តាមប្រក្រតី គាត់ទៅស្តាប់ធម៌ក្នុងថ្ងៃធម្មស្សវនៈរាល់ថ្ងៃ ឈ្មោះរបស់គាត់គឺ **ទេវមិត្តឧបាសក** យើងបានសន្ទនាគ្នាដល់រឿងចរចាបន្ថយ

កម្លាំងចម្បាំង ដែលកំពុងនៅជជែកគ្នាក្នុងវេលានោះ ។

" **ម្នាលឧបាសក!** " ខ្ញុំផ្ដើមពោលក្នុងការសន្ទនា " ទាក់ទង និងការចរចាបន្ដយសញ្វាវុធ ដែលកំពុងប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននេះ លោកមានសេចក្ដីយល់ឃើញយ៉ាងណា? អាចមានផ្លូវស្រុះស្រួលគ្នាបាន ឬទេ?" ។

" **លោកម្ចាស់ដ៏ចំរើន !** " ឧបាសកពោលយ៉ាងប្រើគំនិត "ខ្ញុំករុណា មានសេចក្ដីឃើញថា គេអាចនឹងព្រមព្រៀងគ្នាបានក្នុងឡូកការ តែមិនអាចប្រតិបត្តិតាមខព្រមព្រៀងបាន ព្រោះមិនទុកចិត្តគ្នានៅមានសេចក្ដីក្រែងរអែងសង្ស័យគ្នាម្ខាង ក៏ក្រែងម្ខាងទៀតបញ្ឆោតខ្លួន ក្នុងទីបំផុតសំដីនិយាយទាំងពីរផ្នែក មិនអាចជឿកាន់បាន នេះជាហេតុឱ្យការចរចាយឺតយូរ និងអាចនាំទៅកាន់សេចក្ដីដួលចុះរលំរលាយក្នុងគ្រាទីបំផុត ហើយសង្គ្រាមបង្ហូរឈាម ក៏មុខជាកើតឡើងទៀត " ។

" លោកឯណេះ មានសេចក្ដីយល់ឃើញយ៉ាងណា? " ខ្ញុំបែរទៅសួរ **សុចិត្តឧបាសក** ដែលជាបុរសជរា យកចិត្តទុកដាក់ និងយល់ជ្រាលជ្រៅក្នុងផ្លូវធម៌ច្រើន ។

" **លោកម្ចាស់ដ៏ចំរើន!** ខ្ញុំព្រះករុណាជឿមាំថា ការចរចាក្នុងគ្រានេះ មិនកើតផលយ៉ាងណាទេ ព្រោះគេព្រមព្រៀងគ្នាមិនបាន

ទោះព្រមព្រៀងគ្នាបាន ក៏បន្ថយអាវុធតាមខព្រមព្រៀងមិនបាន ទោះបន្ថយអាវុធបាន សង្គ្រាមក៏នៅតែកើតឡើងនោះឯង ”។

“ បើគេបន្ថយអាវុធបានហើយ សង្គ្រាមនៅកើតទៀតឬ? គេនិងយកអ្វីមកជាកម្លាំងច្បាំង ? ” ទេវមិត្តសួរ ជាសំដីផ្ទុញផ្ទាល់

**សុចិត្តៈ** អ្នកជរាសើចយ៉ាងអារម្មណ៍ត្រជាក់ហើយពោលថា “គេសាងអាវុធថ្មីឡើងទៀត ” ។

“ សាងមិនបាន” ទេវមិត្តជំទាស់ “ បើសាងឡើងច្រើន ក៏ខុសនឹងខព្រមព្រៀងគ្នាបន្ថយសព្វាវុធយ៉ាងច្បាស់ ម្ខាងនឹងជំទាស់មិនខាន ”។

“បើគេចង់សាងហើយ មុខជាសាងបាននោះឯង ល្បងគិតមើលចុះថា អាណាចក្រកោសលធំទូលាយត្រឹមណា គេអាចទាពួនសាងក្នុងទីណាមួយក៏បាន កាលដល់គ្រាចាំបាច់ត្រូវការប្រើ គេបញ្ចេញយកមកប្រើម្តងបន្តិចៗយ៉ាងស្ងាត់ កាលបើដូច្នេះ យើងក៏មិននឹងជំទាស់គេបានទោះមានឡកឋានល្មមនឹងជំទាស់បាន ក៏មិនដឹងនឹងជំទាស់ចំពោះនរណាព្រោះការព្រមព្រៀងធ្វើសន្ធិសញ្ញា ចុះហត្ថលេខារបស់យើងថាសេចក្តីព្រមព្រៀងរវាងពីរចំណែកប៉ុណ្ណោះមិនមានអ្នកកណ្តាលដែលមានអំណាចខ្ពស់កសិណសាក្សី យើងជាអ្នកសាងសន្ធិសញ្ញាខ្លួនឯង យើងជាអ្នករក្សាសន្ធិសញ្ញានោះ និងបើយើងល្មើសសន្ធិសញ្ញាការព្រមព្រៀងនោះ

ខ្លួនឯងក៏បាន សន្និសញ្ញាព្រមព្រៀងដែលប្រាសចាកបុគ្គលទី ៣ ធានារ៉ាប់រង ក៏ដូចជាច្បាប់ដែលមិនមានរាជបុរស ចាំឃ្លាំចាប់ទោសអ្នកប្រព្រឹត្តិល្មើស មិនមានតុលាការចាំវិនិច្ឆ័យកាត់ទោសមិនមានពន្ធនាគារសម្រាប់ឃុំឃាំង ច្បាស់នោះក៏ខ្វះប្រសិទ្ធិភាពឬសេចក្តីសក្តិសិទ្ធិ មិនមាននរណាប្រតិបត្តិតាម ដូច្នោះ ទើបខ្ញុំជឿថា ការចរចាបន្ថយយុទ្ធោបករណ៍ មិនអាចបង្កើតផលល្អយ៉ាងណាឡើយ ក្រៅពីប្រើជាគ្រឿងបញ្ឆោតក្មេងៗឱ្យត្រេកអរថា មិនមានសង្គ្រាមប៉ុណ្ណោះ ” ។

“ តែបើគេអាចព្រមព្រៀងគ្នាបាន ការបន្ថយសព្វាវុធមុខជាប្រព្រឹត្តទៅបានមិនខាន” **ទេវមិត្ត** ជជែក ។

“ទោះបន្ថយបានក៏ត្រឹមមួយដងមួយគ្រា ក្នុងមិនយូរគេក៏នឹងសាងវាឡើង មកបំផ្លិចបំផ្លាញគ្នាទៀត ខ្ញុំយល់ឃើញថា អាវុធទាំងឡាយ គឺដាវ លំពែង កាំបិត ធ្នូ កាំភ្លើងទាំងនេះជាដើមត្រឹមតែជាអាវុធខាងក្រៅយើងបន្ថយឬមិនបន្ថយគឺមិនសំខាន់ អាវុធខាងក្នុងគឺ **សេចក្តីលោភ សេចក្តីក្រោធ សេចក្តីវង្វេង សេចក្តីច្រណែន សេចក្តីក្រអោងក្រអឺតប្រកាន់ខ្លួន** ការប្រកាន់ជាតិវណ្ណៈត្រកូលហើយមើលងាយមាក់ថោកគ្នា សេចក្តីឃើញដល់ខ្លួនទាំងនេះ ចាត់ថាជាអាវុធដែលសំខាន់

និងសាហាវយ៉ាងបំផុត ខ្លាំងក្លាជាងអាវុធមានដាវលំពែងជាដើមនោះ ព្រោះដាវលំពែងជារបស់គ្មានវិញ្ញាណ យើងទុកចោលនៅក្នុងទីណា ក៏នៅក្នុងទីនោះ ទៅប្រទូសរ៉ាយនរណាខ្លួនវាមិនបាន ទោះមានប៉ុន្មានភ្នំ ប៉ុន្មានសមុទ្ទ ក៏គ្មានអន្តរាយអ្វី ដូច្នេះ យើងដកបន្ថយឬមិនបន្ថយក៏មិនសំខាន់ គួរអង្គសំខាន់គឺនៅលើមនុស្សអ្នកប្រើអាវុធទាំងនោះ បើអ្នកប្រើមានចិត្តពេញដោយលោភៈ ទោសៈ មោហៈ ជាដើមគេនឹងចាប់អាវុធទាំងនោះ ទៅប្រទូសសម្លាប់កាប់សម្លេះអ្នកដទៃកើតជាសង្គ្រាមឡើងផ្ទុយទៅវិញ បើមនុស្សមានចិត្តស្ងប់រម្ងាប់ មិនធ្លាក់ជាទាសៈរបស់លោភៈ ទោសៈ មោហៈ ទោះអាវុធខាងក្រៅមានច្រើនយ៉ាងណា គេក៏មិនចាប់វាទៅប្រទូសរ៉ាយអ្នកដទៃជាដាច់ខាត ដូច្នោះ អាវុធខាងក្នុងទើបសំខាន់បំផុត បើនឹងដកឬបន្ថយ គួរដកបន្ថយអាវុធខាងក្នុង ដូចពោលហើយនោះជាមុន បើដកបន្ថយអាវុធខាងក្នុងបានហើយ អាវុធខាងក្រៅក៏នឹងសណ្តកឬថយទៅឯង តែបើមិនដកអាវុធខាងក្នុង ទោះដកអាវុធខាងក្រៅបាន ក៏បានត្រឹមមួយដងមួយគ្រា មិនយូរប៉ុន្មាន អាវុធខាងក្នុងនឹងបង្គាប់ឱ្យគេសាងអាវុធខាងក្រៅឡើងទៀត ហើយក៏បំផ្លិចបំផ្លាញគ្នាទៀត អាវុធខាងក្រៅប្រៀបដូចផ្លែឈើ អាវុធខាងក្នុងប្រៀបដូចដើមឈើ ទោះយើងយកផ្លែឈើទៅចោលអស់ បើដើមឈើនោះនៅរស់ ឆ្នាំ

ក្រោយវាក៏នឹងចេញផ្លែទៀត យើងត្រូវរង់ចាំបេះរាល់ឆ្នាំ តែបើយើងកាប់រំលើងឫសគល់ដើមឈើនោះ វាក៏អស់មានផ្លែទៀត នេះគឺសេចក្ដីយល់ឃើញរបស់ខ្ញុំ ក្នុងឋានៈជាអ្នកធម្មៈ ឬអ្នកសាសនា ” ។

“ **ម្នាលឧបាសក!** ខ្ញុំនិយាយឡើង ក្រោយពីអង្គុយស្ងៀមចាំស្ដាប់យូរហើយ “ សេចក្ដីយល់ឃើញរបស់លោក គួរស្ដាប់ណាស់ អាត្មាសូមសរសើរ ពិតមែនហើយ **សេចក្ដីលោភ សេចក្ដីក្រោធ សេចក្ដីស្រវឹងវង្វេង** ចាត់ជាអាវុធខាងក្នុង ដែលសាហាវខ្លាំងក្លាមុះមុតណាស់ សេចក្ដីលោភគឺអ្នកសាង សម័យណា សេចក្ដីលោភចូលគ្រប់គ្រងចិត្តមនុស្សណា សម័យនោះ មនុស្សក៏សាងសន្សំជាការធំ ធ្វើឱ្យរបស់ផ្សេងៗ មានចំនួនច្រើនកើនឡើង ហើយក៏នាំគ្នាហៅថាលោកចំរើន លោកលូតលាស់ ជឿនលឿន, ក្នុងសម័យណា សេចក្ដីក្រោធគឺកំហឹងចូលគ្រប់គ្រងចិត្តខ្លួន សម័យនោះ គេក៏លើកពួកប័ក្សចូលទៅបំផ្លិចបំផ្លាញជីវិតនិងទ្រព្យសម្បត្តិរបស់គ្នានិងគ្នាយ៉ាងឃោរឃៅ យ៉ាងទារុណ កាលទម្លាយបំផ្លិចបំផ្លាញឱ្យហិនហោចរាបទាបទៅហើយ ក៏ផ្ដើមសាងជាថ្មីទៀត សាងឡើងច្រើនហើយ ក៏បំផ្លិចបំផ្លាញចោលទៀត សាងឡើង បំផ្លាញទៅវិញ ដូច្នេះជានិច្ច សេចក្ដីលោភធ្វើឱ្យសាងឡើង

សេចក្ដីក្រោធ ធ្វើឱ្យបំផ្លិចបំផ្លាញ សេចក្ដីវង្វេង ធ្វើឱ្យស្រវឹងជ្រមុជជ្រមុល នៅនឹងការសាងនឹងការបំផ្លាញមិនចប់មិនហើយ ដូច្នោះអាវុធខាងក្នុងដូចពោលមកហើយនេះ ទើបសាហាវខ្លាំងក្លាណាស់ យើងគួរដកហូតបន្ថយអាវុធខាងក្នុងនេះជាមុនសិន បើដកហូតបាន អាវុធខាងក្រៅក៏គ្មានបញ្ហា តែបើដកហូតមិនបាន សង្គ្រាមមហាប្រល័យក៏នឹងកើតឡើងតទៅគ្មានទីបំផុតឡើយ ” ។

# បព្វជ្ជានិសង្ស

**លោក-អ្នកអានជាទីមេត្រី!** ថ្ងៃមួយ ខណៈដែលខ្ញុំកំពុងអង្គុយនៅលើគ្រែ ក្រោមម្លប់ឬស្សី មុខកុដិតូចរបស់ខ្ញុំនោះឯង មានបុរសកម្លោះម្នាក់ចូលមករក គេអង្គុយក្រាបថ្វាយបង្គំខ្ញុំហើយ ណែនាំខ្លួនឯងថា " ខ្ញុំព្រះករុណាឈ្មោះ **បុណ្ណមាណព** ជាបុត្រនៃត្រកូលព្រាហ្មណ៍ឈ្មោះនោះ ខ្ញុំព្រះករុណា ធ្លាប់ធម៌ក្នុងថ្ងៃធម្មស្សវនរាល់ដង កើតសេចក្តីជ្រះថ្លា ចង់បួសជាព្រះភិក្ខុក្នុងព្រះពុទ្ធសាសនា តែទើសទាល់ដោយមិនបានទទួលអនុញ្ញាតពីមាតបិតា ខ្ញុំព្រះករុណាព្យាយាមអង្វរករគាត់រាល់ថ្ងៃ តែគាត់នៅតែមិនយល់ព្រម ទើបរត់មករកព្រះគុណម្ចាស់ដើម្បីសូមឱ្យព្រះគុណម្ចាស់បំបួសចែកទាន " ។

គេជាប្រុសកម្លោះ អាយុប្រមាណ២៥ឆ្នាំ មុខមាត់ស្អាតបាត សំលៀកបំពាក់ស្អាតរៀបរយកិរិយារាបសាល្អ សំដែងថាមានត្រកូលខ្ពស់ ខ្ញុំពិចារណាមើលលក្ខណៈរបស់គេមួយសន្ទុះ ហើយពោលថា " ម្នាលមាណព ! អ្នកមានចេតនានឹងបួសពិតៗឬ? ឬបួសមួយដងមួយគ្រា?"

"ខ្ញុំព្រះករុណាតាំងចិត្តនឹងបួសពិតៗទានប្រោស!" គេឆ្លើយដោយសំដីម៉ឺងម៉ាត់ ។

" សេចក្តីពិត អ្នកកំពុងនៅក្នុងវ័យកម្លោះ ជាវ័យដែលកំពុងភ្លើតភ្លើននៅនិងអារម្មណ៍របស់លោក មិនគួរនឹងគិតចង់លះលោកមកកាន់ជីវិត

ដ៏ស្ងប់ស្ងៀមរបស់ភិក្ខុភាព អ្នកមានសេចក្ដីគិតឃើញយ៉ាងណា បានជាកាត់ចិត្តចង់បួស ? ” ។

“ ខ្ញុំព្រះករុណា សូមទូលតាមត្រង់ថា ខ្ញុំព្រះករុណាកើតសេចក្ដីនឿយណាយលោក ” ។

“ លោកធ្វើអ្វីឱ្យអ្នកឈឺចាប់ចិត្តឬទើបកើតសេចក្ដីនឿយណាយ?”

“ គ្មានឈឺចាប់ចិត្តអ្វីទេ ផ្ទុយទៅវិញ លោកបានឱ្យសេចក្ដីអភិរម្យគ្រប់យ៉ាងចំពោះខ្ញុំព្រះករុណា ត្រកូលរបស់ខ្ញុំ-ស្ដុកស្ដម្ភ ខ្ញុំ-ជាបុត្រទោល ដែលឪពុកម្ដាយតាមចិត្តគ្រប់យ៉ាង ខ្ញុំ-បានប្រើជីវិតរកសេចក្ដីសុខក្សេមក្សាន្តពីលោកគ្រប់ជ្រុងជ្រោយមកច្រើនឆ្នាំហើយ ក្នុងទីបំផុតក៏មិនឃើញសារអ្វី សុខរបស់លោកជាសុខមិនបរិសុទ្ធ ជាសុខមួយដងមួយគ្រា ខ្ញុំ-បានដឹងយល់សេចក្ដីពិតពីព្រះគុណម្ចាស់នេះឯងថា សុខផ្លូវលោក តាំងនៅលើមូលដ្ឋាន គឺចំណង់ ឬតណ្ហាចង់បាន ចង់មាន ចង់ជាអ្វីផ្សេងៗ កាលចង់ក៏ស្វែងរករបស់ផ្សេងៗ មកស្នងចំណង់ រករូបមកឱ្យភ្នែកមើល រកសំឡេងមកឱ្យត្រចៀកស្ដាប់ រកក្លិនមកឱ្យច្រមុះហិត រករសមកឱ្យអណ្ដាលិតភ្លក់ រកសម្ផស្សមកឱ្យកាយប៉ះពាល់ រកអារម្មណ៍ផ្សេងៗមកបំរើចិត្ត បើរករបស់ផ្សេងៗ មកបំរើតណ្ហាបានក៏ជាសុខ តែជាសុខត្រឹមមួយដងមួយគ្រាប៉ុណ្ណោះ ក៏កើតសេចក្ដីនឿយណាយរសាយចិត្ត ចង់បានចង់មាន ចង់ក្នុងអារម្មណ៍ថ្មីដទៃៗតទៅទៀត ហើយក៏

កក្លូរកកាយរកទៀត រកបានមកបំរុងបំរើជាសុខមួយដងមួយគ្រា ហើយក៏នឿយណាយទៀត រកថ្មីទៀត ជាយ៉ាងដូច្នេះ មិនចេះចប់ កាលពិចារណាដោយល្អិត ឃើញសេចក្ដីពិតរឿងនេះហើយ ខ្ញុំព្រះករុណា ទើបគិតនឹងរំដោះខ្លួនឯងឱ្យរួចចាកតណ្ហាទាសភាព ”

“ **ម្នាលមាណព !** គំនិតគិតត្រិះរិះរបស់អ្នក សមដោយហេតុផលហើយ មនុស្សយើងគ្រប់គ្នាធ្លាក់ជាខ្ញុំកំដររបស់តណ្ហាគ្រប់ដង្ហើមចេញចូល តណ្ហាប្រៀបដូចខ្លាសាហាវ ដែលយើងចិញ្ចឹមទុក ជាខ្លាខ្លួនធំមហិមា ដែលមានមាត់ដល់ ៦ ស៊ីអាហារដល់ ៦ ប្រភេទ មាត់ទាំង ៦ គឺ **ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត** អាហារ ៦ ប្រភេទគឺ: **រូប សំឡេង ក្លិន រស សម្ផស្ស ធម្មារម្មណ៍** តណ្ហាព្យ័ត្សនេះ ស៊ីអាហារជានិច្ចមិនចេះឆ្អែត មិនចេះល្មម ដូចភ្លើងដែលមិនឆ្អែតដោយឧស ដូចមហាសមុទ្រដែលមិនឆ្អែតដោយទឹក យើងត្រូវតស៊ូតាំងពីកើតរហូតដល់ស្លាប់ ដើម្បីរកអាហារទាំង ៦ ប្រភេទមកឱ្យតណ្ហាស៊ី ឆ្អែតហើយ វាក៏ស្ងប់ស្ងៀមមួយគ្រា ត្រង់នេះឯងយើងដូចជាបានសុខខ្លះ តែក្នុងមិនយូរវាក៏ឃ្លានទៀត និងបង្គាប់ឱ្យយើងរកអាហារឱ្យវាស៊ីទៀត បើរកមិនបាន វាក៏ញាំញីខាំខ្វាំខ្វៅយ៉ាងមិនប្រាណី តែសូម្បីដូច្នោះ មនុស្សក៏មិនស្អប់ខ្ពើមតណ្ហាដែរ ផ្ទុយទៅវិញ បែរជាស្រឡាញ់

តណ្ហាយ៉ាងចាប់ចិត្ត ដូចតណ្ហានោះជាខ្លួនរបស់ខ្លួនឯង ព្រមយំខ្លួនជាទាសៈរបស់តណ្ហាដោយសេចក្ដីពេញចិត្ត ហើយទទួលបំរើតណ្ហាដោយស្នេហាស្វាមីគារវភាព ចំណែកតណ្ហាកាលយើងយកចិត្តយកថ្លើម វាក៏នាំយើងវិលទៅវិលមកក្នុងវដ្ដសង្សារដ៏ពេញ ដោយភ្លើងទុក្ខ គឺ កើត ចាស់ ឈឺ ស្លាប់ សោកសៅ តឹងចិត្ត ឆ្អិតទ្រូងដែលមិនមានទីបំផុត ។

" **ម្នាលមាណព !** ព្រះពុទ្ធជាម្ចាស់ បានទ្រង់ពិចារណាឃើញសេចក្ដីពិតនេះ និងកើតសេចក្ដីសង្វេគស្លុតហឫទ័យ ដែលបានធ្លាក់ជាទាសៈទទួលបំរើតណ្ហាមកអស់ពេលជាយូរ ក្នុងទីបំផុត ព្រះអង្គបានសម្រេចព្រះហឫទ័យ ដែលនឹងរំដោះព្រះអង្គឱ្យរួចចាកពន្ធនាគារនៃតណ្ហា ដូចដែលអ្នកកំពុងគិតក្នុងខណៈនេះ ក្នុងទីបំផុតព្រះអង្គក៏ទ្រង់បង្ក្រាបតណ្ហាបានយ៉ាងរាបទាបដាច់ខាត ទ្រង់ប្រកាសឥស្សរភាពឱ្យដល់ព្រះអង្គឯង មិនជាទាសៈរបស់តណ្ហាតទៅទៀត ជាសេរីភាព ឥស្សរភាព យ៉ាងបរិបូណ៌ សេរីភាព ឥស្សរភាព យ៉ាងបរិបូណ៌ រួចចាកក្រញាំរបស់តណ្ហា នេះឯងជាចំណុចខ្ពស់បំផុតរបស់អ្នកបួសទូទៅ ។

" **ម្នាលមាណព !** ការគេចវៀសជៀសចាកតណ្ហានេះ ធ្វើមិនបានងាយៗ ដូចដែលយើងនិយាយគ្នាទេ ព្រោះមនុស្សចូលចិត្តថាតណ្ហានោះ គឺខ្លួនរបស់ខ្លួនយើង ហើយមិនដែលបានរិះគិតបំផ្លាញតណ្ហានោះ

ទោះបីបុគ្គលដឹងសេចក្តីពិតថា តណ្ហាគឺនាយចៅហ្វាយកំណាចឃោរឃៅ ទោះគិតបំផ្លាញចោលក៏មិនអាចធ្វើតាមគំនិតដែលគិតបានងាយៗ ព្រោះនឹងត្រូវតណ្ហាតដៃយ៉ាងខ្លាំង រហូតក្នុងទីបំផុតត្រូវជាចំណែកចាញ់ត្រឡប់ទៅជាទាសៈរបស់តណ្ហាតទៅតាមដើម ដូច្នោះទើបអាត្មាចង់ដឹងសេចក្តីតាំងចិត្តរបស់អ្នកជាមុនថា នឹងតាំងចិត្តពិតប្រាកដត្រឹមណា បើតាំងចិត្តនឹងបួសត្រឹមមួយដងមួយកាល ដើម្បីល្បងមើលក៏កុំបួសជាជាង ព្រោះការបួសគឺការយកតណ្ហាមកក្រុងឬឃុំខាំងទុក ដើម្បីឱ្យវាអត់ វានឹងបានអន់កម្លាំងចុះ ដើម្បីស្រួលក្នុងការបំផ្លាញវាក្នុងវេលាតទៅ បើយើងខាំងវាទុកឱ្យអត់លេងៗ ត្រឹមមួយដងមួយគ្រា មិនតាំងចិត្តនឹងសម្លាប់វាពិតៗ កាលយើងលែងឱ្យវាមានសេរីភាពវិញ វាក៏នឹងបែរមកសងសឹកយើងយ៉ាងធ្ងន់ " ។

" **ព្រះគុណម្ចាស់ដ៏ចំរើន !** ខ្ញុំព្រះករុណាបានកាត់ចិត្តដាច់ខាតហើយថា និងចាត់ការនឹងតណ្ហាយ៉ាងពិតប្រាកដ សូមព្រះគុណម្ចាស់មេត្តាសង្គ្រោះបំបួសខ្ញុំព្រះករុណាចែកទាន " ។

" **ម្នាលមាណព !** អ្នកជាមនុស្សម្នាក់ដែលមានសេចក្តីតាំងចិត្តពិតក្នុងការបួស បើបានបួសដូចបំណង មុខជាតាំងចិត្តប្រតិបត្តិម៉ឺងម៉ាត់ និងបើបារមីចាស់ក្លា លួមអាចនឹងបានសម្រេចមគ្គផលថ្នាក់ណាមួយ តែ

គួរស្តាយពន់ពេកដែលអ្នកមិនបានទទួលអនុញ្ញាតពីមាតាបិតា អាត្មាមិនអាចឱ្យកុលបុត្រដែលមាតាបិតា មិនទាន់អនុញ្ញាតបួសបានទេ ព្រោះខុសព្រះពុទ្ធប្បញ្ញត្តិ បើអ្នកប៉ុនប៉ងនឹងបួសពិត១ ចូរត្រឡប់ទៅអង្វរករ សូមអនុញ្ញាតអំពីមាតាបិតាជាថ្មី " ។

បុរសកម្លោះ ឈ្ងោកមុខអង្គុយស្ងៀម ដោយប្រើគំនិតយ៉ាងធ្ងន់ "ព្រះគុណម្ចាស់ដ៏ចំរើន! ខ្ញុំព្រះករុណាប្រហែលគ្មានសេចក្តីសង្ឃឹមបានទទួលអនុញ្ញាតពីមាតាបិតាទេ ព្រោះគាត់ហាមប្រាមម៉ឺងម៉ាត់ណាស់ " ។

"ក្រៅពីរូបអ្នក មាននរណាខ្លះទៀតដែលល្មមនឹងនៅគ្រប់គ្រងផ្ទះប្រតិបត្តិបំរើមាតាបិតាជំនួសអ្នក ? " ។

" គ្មានទេ ព្រះគុណម្ចាស់ " ។

"បើយ៉ាងនោះ អ្នកគួរម្ចាប់ចំណង់ដែលចង់បួសទុកមួយឡែកសិនកាលអស់បុណ្យមាតាបិតាហើយ សឹមបួសជាក្រោយ បើនៅតែគិតបួសក្នុងវេលានេះ ក៏ការលះបង់ចោលមាតបិតាឱ្យនៅដោយខ្វះអ្នកឧបមត្ថម្ភបំរើ ជាអំពើមិនសមគួរ ព្រោះមាតាបិតាជាអ្នកមានឧបការគុណយ៉ាងខ្ពស់ចំពោះបុត្រ ជាអ្នកឱ្យទ្រព្យដ៏មានតម្លៃបំផុត គឺជីវិតនិងរាងកាយចំពោះបុត្រ ជាបុព្វាចារ្យអ្នកអប់រំណែនាំប្រៀនប្រដៅបុត្រមុនគ្រូអាចារ្យទាំងអស់ ជាព្រះព្រហ្មអ្នកមានព្រហ្មវិហារធម៌គឺ មេត្តា ករុណា មុទិតា ឧបេក្ខា ចំពោះបុត្រ មិនមានពេលស្រកស្រុត ដូច្នោះបុត្រធីតា ទើបជា

អ្នកជំពាក់គុណមាតាបិតា គួរសងគុណលោកដោយប្រតិបត្តិ ចិញ្ចឹមថែទាំបំរើលោកជាដើម ” ។

“ ព្រះគុណម្ចាស់ដ៏ចំរើន! រឿងគុណឧបការៈនោះ ខ្ញុំព្រះករុណានឹកគិតជានិច្ច តែក៏មិនភ្លេចការបួស ចេះតែនឹងស្តាយដោយគ្មានឱកាសបានបួសបំពេញសមណធម៌ ដើម្បីមានសេរីភាព រួចចាកក្រញាំចក្កពត្តិនិយមអ្នករុករាន គឺតណ្ហា ” ។

“ **ម្នាលមាណព !** ការបំពេញសមណធម៌ មិនបានកម្រិតដាច់ខាតទុកសម្រាប់តែអ្នកបួសចំពួកមួយ សូម្បីជាគ្រហស្ថអ្នកគ្រប់គ្រងផ្ទះ ក៏អាប្រតិបត្តិសមណធម៌ និងសម្រេចមគ្គផលនិព្វានបាន បើមានបារមីចាស់ក្លាគ្រប់គ្រាន់ ព្រោះថាមគ្គនិងផលមិនបាននៅក្នុងវត្ត មិនបាននៅតាមល្អាងភ្នំ តែនៅនឹងខ្លួនយើងគ្រប់គ្នានោះឯង បើយើងដឹងពិតឃើញពិត យល់ច្បាស់ដោយខ្លួនឯងហើយ ក៏អាចបានសម្រេចមគ្គផលបាន ដូច្នេះសូមអ្នកសិក្សាស្រាវជ្រាវរាវរកមើលខ្លួនឯង សិក្សាឱ្យឃើញថា ខ្លួនទាំងផ្នែកនាមនិងផ្នែករូបនេះជាចំណែកផល ប្រៀបដូចផ្លែឈើដែលកើតឡើងមកហើយ មុខជាត្រូវចាស់ទុំរបេះជ្រុះពុកផុយស្អុយរលួយទៅតាមធម្មជាតិរបស់វា កាលសាច់នឹងសំបករលួយទៅហើយ គ្រាប់របស់វាសល់នៅ ខាងក្នុងគ្រាប់នោះមានជ័រនិងគុណសម្បត្តិគ្រប់យ៉ាងដែលអាចជាដើមឈើនិងផ្លែឈើបានទៀត កាលគ្រាប់នោះធ្លាក់នៅក្នុង

ភាវៈដ៏សមល្មម ក៏ដុះចេញជាដើមឈើនិងមានផ្លែទៀត ខ្លួនរបស់យើងប្រៀបដូចផ្លែឈើ វិញ្ញាណធាតុ ប្រៀបដូចគ្រាប់ក្នុងផ្លែឈើ ជ័រក្នុងគ្រាប់ប្រៀបដូចតណ្ហា ដរាបណាតណ្ហានៅមាន ដរាបនោះមនុស្សយើងក៏នៅត្រូវវិលស្លាប់វិលកើតនៅក្នុងវដ្ដសង្សារតទៅទៀតមិនមានទីបំផុត ការវិលស្លាប់វិលកើតផ្ទួនៗ ដដែលៗ ជាភាវៈដ៏គួរនឿយណាយសម្រាប់អ្នកមានបញ្ញា តែជារបស់គួរអភិរម្យសម្រាប់អ្នកនៅងងឹតដោយអវិជ្ជា " ។

" **ព្រះគុណម្ចាស់ដ៏ចំរើន !** ទោះយ៉ាងណាក្ដី ខ្ញុំព្រះករុណាក៏មិនទាន់មានឱកាសបានបួសទេ សូមព្រះគុណមេត្តាប្រោសណែនាំវិធីប្រ-តិបត្តិដើម្បីបន្ថយកិលេស ចំពោះខ្ញុំព្រះករុណាក្នុងឋានៈជាគ្រហស្ថផង "។

" **វិធីប្រតិបត្តិ** ព្រះពុទ្ធជាម្ចាស់បានទ្រង់ប្រៀនប្រដៅទុកហើយមានវិធីការកំចាត់កិលេស ៣ ថ្នាក់គឺ **សីល** បានដល់ការរក្សាកាយវាចាមិនឱ្យធ្វើអាក្រក់និយាយអាក្រក់ ព្រោះការធ្វើអាក្រក់និយាយអាក្រក់នាំសេចក្ដីក្ដៅក្រហាយមកកាន់ខ្លួន និងធ្វើចិត្តឱ្យសៅហ្មង សីលសម្រាប់ឃរាវាស ហៅថាបញ្ចសីលមានសេចក្ដីអាក្រក់ ដែលលោកហាមទុក ៥ យ៉ាង បើប្រតិបត្តិតាមបាន គ្រប់ទាំង៥ ក៏នឹងជាអ្នកមានកាយនិងចិត្តស្ងប់ត្រជាក់ត្រជំ បើមានសទ្ធាចាស់ក្លា ក៏ឱ្យរក្សាឧបោសថសីល ឬសីល ៨ ដែលមានឧប្រតិបត្តិ សម្រាប់ធ្វើឱ្យជាអ្នកស្រាលចាកកិច្ចកង្វល់ផ្សេងៗ

និងធ្វើឱ្យចិត្តស្ងប់រម្ងាប់បានល្អឡើង ។ កាលរក្សាសីលបានយ៉ាងមធ្យ័ត ហើយគប្បីប្រតិបត្តិក្នុងថ្នាក់ទី ២ ហៅថា **សមាធិ** គឺរកឱកាសរំដោះរំលៀកខ្លួនទៅនៅក្នុងទីស្ងាត់ស្ងៀមហើយហ្វឹកហាត់សង្កត់ចិត្ត មិនឱ្យរាយមាយបង្ខាប់ឱ្យចិត្តនៅនឹងនួន ឬឱ្យជាប់មាំនៅក្នុងអារម្មណ៍ជាកុសលណាមួយ ដំបូងធ្វើបាដោយលំបាកណាស់ ព្រោះចិត្តធ្លាប់គិតរាយមាយ មិននឹងនួន យើងមិនធ្លាប់បង្ខាប់វា កាលមកផ្ដើមបង្ខាប់ជាដំបូង ទើបជាការពិបាក តែកំរាថយ ព្យាយាមធ្វើរឿយៗ ក្នុងទីបំផុតក៏នឹងកើតជំនាញក្នុងការបង្ខាប់ចិត្ត កាលកើតសេចក្ដីជំនាញហើយ ចិត្តក៏នឹងស្ងប់ដោយឆាប់រហ័ស នឹងឱ្យនឹងនួនបានយូរប៉ុន្មានក៏បានតាមត្រូវការ ។ កាលអាចបង្ខាប់ចិត្តឱ្យស្ងប់ស្ងៀមបានយ៉ាងដាច់ខាតហើយ ក៏ឈ្មោះថាប្រតិបត្តិតាមថ្នាក់ទី ២ គឺសមាធិបានយ៉ាងបរិបូណ៌ហើយ តអំពីនោះ ក៏គប្បីផ្ដើមប្រ-តិបត្តិថ្នាក់ទី៣គឺ **បញ្ញា** ធម្មតាចិត្តដែលស្ងប់រមែងជាចិត្តមានកម្លាំង មានសេចក្ដីភ្លឺស្វាងក្រៃលែងជាងចិត្តដែលរាយមាយ បើបង្អោនចិត្តដែលភ្លឺស្វាងនិងមានពលានុភាពនោះ ទៅពិចារណាសិក្សាស្រាវជ្រាវក្នុងរបស់ណា រមែងកើតសេចក្ដីយល់ច្បាស់លាស់ក្នុងរបស់នោះ អាចនឹងដឹងសភាពដ៏ពិតប្រាកដនៃរបស់នោះ កាលដឹងសេចក្ដីពិតនៃរបស់នោះហើយ សេចក្ដីដឹងនោះឯង នឹងដេញកំចាត់សេចក្ដីល្ងង់ខ្លៅ សេចក្ដីវង្វេងជឿ

ងាយ សេចក្តីប្រកាន់មាំចេញចាកចិត្ត ធ្វើឱ្យចិត្តស្អាតបរិសុទ្ធឡើងបាន ច្រើនខ្លះ តិចខ្លះតាមកម្លាំងការប្រតិបត្តិរបស់យើង ” ។

“ **ព្រះគុណម្ចាស់ដ៏ចំរើន!** ពាក្យអធិប្បាយរបស់ព្រះគុណម្ចាស់ ច្បាស់លាស់ល្អណាស់ ធ្វើឱ្យខ្ញុំព្រះករុណាសំឡឹងមើលឃើញផ្លូវដែល នឹងប្រតិបតិបត្តិបានហើយ តែនៅសង្ស័យក្នុងខដែលថា កាលធ្វើសមាធិ រហូតចិត្តស្ងប់ល្អហើយ គួរនឹងបង្អោនទៅពិចារណាអ្វីមុន ? ” ។

“ **ម្នាលមាណព!** អ្នកចូរពិចារណាមើលខ្លួនឯងមុនរបស់ដទៃ ព្រោះខ្លួនយើងនេះឯង គឺរូបបំប្រួញរបស់ **សាកលចក្រវាឡ** បើដឹង ខ្លួនយើងហើយក៏អាចនឹងដឹងសាកលចក្រវាឡ ដោយអ្នកចូរពិចារណា បំបែកខ្លួនចេញយ៉ាងល្អិតទាំងចំណែករាងកាយនិងចិត្ត បំបែកដល់ទីបំផុត ហើយ ក៏ឃើញថាខ្លួនយើងនេះ មិនប្លែកពីដើមឈើភ្នំនិងសត្វទាំងឡាយ ដែលមិនទៀតទាត់ឋិតថេរ ជារបស់ដែលទ្រាំបានដោយលំបាក គ្មាន សារៈឃីនឃូរទអ្វី មិនមែនខ្លួនយើង មិនមែនខ្លួនគេ គ្រាន់តែជាវត្ថុធាតុ រូបរួមចូលគ្នាជាដុំមួយ មួយដងមួយគ្រាហើយក៏ឃ្លាតឃ្លាវលាវលាយទៅ វិញ កាលដឹងច្បាស់ឃើញពិតដូច្នេះហើយ សេចក្តីប្រកាន់មាំថា យើង ថាគេក៏បាត់ទៅ អស់សេចក្តីសង្ស័យ និងក្នុងវេលាជាមួយគ្នានេះ ក៏កើត សេចក្តីជឿមាំ ក្នុងវិធីការដែលខ្លួនប្រតិបត្តិ មិនទៅវង្វេងច្រឡំជឿងាយ

ក្នុងវិធីប្រតិបត្តិបែបដទៃ កាលមកដល់ថ្នាក់នេះហើយ អ្នកក៏ឈ្មោះថាបាន លុះដល់ភាពជាព្រះអរិយថ្នាក់ដំបូង ចិត្តរបស់អ្នកបានធ្លាក់កាន់ក្រសែនៃលោកុត្តរធម៌បែរតម្រង់ទៅកាន់ព្រះនិព្វាន ដោយមិនមានការវិលត្រឡប់មកកាន់លោកិយវិស័យ ដែលជាសមុទ្ទទុក្ខទៀត អ្នកនឹងត្រូវកើតទៀតយ៉ាងច្រើនត្រឹម ៧ ដងទៀតប៉ុណ្ណោះ តអំពីនោះ ក៏ដល់អត្តភាពដែលមិនកើតចាស់ឈឺស្លាប់ ជាសភាពបរមសុខរហូតនិរន្តរកាល ” ។

“ **ព្រះគុណជាម្ចាស់ដ៏ចំរើន!** បើយ៉ាងនោះ ក៏សំដៅសេចក្តីថា សូម្បីជាគ្រហស្ថក៏អាចប្រតិបត្តិធម៌រហូតបានសម្រេចផលបានដូចគ្នានឹងព្រះភិក្ខុសង្ឃដែរ មិនមែនឬ ? ” ។

“ យ៉ាងហ្នឹងមែនហើយ គ្រហស្ថក៏អាចសម្រេចមគ្គផលបាន ” ។

“ បើយ៉ាងនោះ ការបួសឬមិនបួស ក៏មានតម្លៃប៉ុនគ្នា ដូច្នោះចាំបួសធ្វើអ្វី ? នៅឃរាវាសមិនស្រួលជាងឬ ? ” **បុណ្ណកមាណព** ជជែក ។

“ ជាគ្រហស្ថទោះមានសិទ្ធិសម្រេចមគ្គផលបានក៏មែនពិត តែមានឱកាសនឹងប្រតិបត្តិធម៌បានតិចជាងអ្នកបួស ព្រោះគ្រហស្ថមានភារៈកិច្ចរឹតចងជុំវិញខ្លួនច្រើន មិនសូវមានវេលាគ្រប់គ្រាន់នឹងប្រតិបត្តិធម៌បានទៀងទាត់ កាលប្រតិបត្តិធម៌បានតិច ឱកាសដែលបានសម្រេចផលក៏មានតិច តែព្រះភិក្ខុជាអ្នកលះភារៈកិច្ចផ្លូវលោកគ្រប់យ៉ាងហើយ គិតតែ

ប្រតិបត្តិធម៌តែម្យ៉ាង រមែងមានឱកាសដែលនឹងបានសម្រេចមគ្គផលច្រើនជាងនិងឆាប់ជាង ការបួសជាភិក្ខុ ទើបបានប្រៀបក្នុងប្រការនេះ ” ។

“ **ព្រះគុណដ៏ចំរើន!** ខនេះឯង ធ្វើឱ្យខ្ញុំព្រះករុណាចង់បួស តែកាលមានសេចក្តីចាំបាច់បួសមិនបាន ខ្ញុំក៏នឹងព្យាយាមប្រតិបត្តិធម៌ក្នុងភេទជាគ្រហស្ថនេះឯង បានផលត្រឹមណាក៏ស្រេចតែបុណ្យបារមី ខ្ញុំព្រះករុណាសន្ទនានឹងព្រះគុណមកយូរហើយ ទើបសូមក្រាបថ្វាយបង្គំលាទៅផ្ទះវិញ ថ្ងៃក្រោយសូមមកសន្ទនទៀត ” ។

# អសុភសញ្ញា

**ប្រិយមិត្តទាំងឡាយ!** ពិតមែនតែខ្ញុំជាសមណៈ បានទទួលការសិក្សាអប់រំ, និយាយ, សំដែង, ពន្យល់ពីទោសនៃកិលេសតណ្ហា និងយល់ច្បាស់លាស់តាមពិតថា កិលេសតណ្ហា ជាប្រភពនៃទុក្ខគ្រប់ប្រភេទ ។ ការគ្រាន់តែចេះ-យល់-និយាយ-សំដែង មិនជាការតឹងតែងពេកទេ សំខាន់ទៅទៀតគឺការប្រតិបត្តិ ។ ដោយខ្ញុំនៅជាបុថុជ្ជន ជួនកាលកិលេសតណ្ហា ដុតរោលដោយរុកធ្វើទុក្ខចិត្តខ្ញុំម្តងៗដែរ តែខ្ញុំចេះតែខំអប់រំបន្ទំចិត្តប្រយុទ្ធនឹងកិលេសតណ្ហា តាមពុទ្ធមធ្យោបាយជានិច្ចមក ចិត្តក៏ស្ងប់រម្ងាប់ទៅវិញ ។

ខ្ញុំនិយាយរឿងមួយឱ្យស្តាប់ មានមួយកាលនោះ កាលកិលេសតណ្ហាគ្របសង្កត់ចិត្ត ខ្ញុំចង់ចេញចាកភេទសមណៈទៅកាន់ឃរាវាសវិស័យ ដើម្បីទៅរកកាមសុខក្នុងបញ្ចកាមគុណ គឺ: **រូប**, **សំឡេង**, **ក្លិន** **រស**, **សម្ផស្ស** សម្រាប់បំរុងបំរើ **ភ្នែក**, **ត្រចៀក**, **ច្រមុះ**, **អណ្តាត**, **កាយ**, **ចិត្ត** ព្រោះកិលេសតណ្ហានាំឱ្យគិតឃើញថា កាលភ្នែកបានឃើញរូបល្អ ត្រចៀកបានឮសំឡេងពិរោះ, ច្រមុះបានហិតស្រូបក្លិនក្រអូប, អណ្តាតបានលិតភ្លក់ជារសឆ្ងាញ់ កាយបានប៉ះសម្ផស្សជាទីពេញចិត្ត មុខជាបានសេចក្តីសប្បាយក្សេមក្សាន្តចិត្តមិនខាន, ជួនកាល

ខ្ញុំនឹងឃើញថា ពូជព្រឹក្សជាតិ ដែលមានទឹកនិងជីរជាតិចិញ្ចឹមបរិបូណ៌ រមែងចំរើនលូតលាស់ ខ្ញុំឃើញថា ជីវិតបព្វជិតក្នុងក្របខ័ណ្ឌនៃព្រះធម៌វិន័យខ្វះរបស់ទាំងនេះ ជាជីវិតស្ងួតហែងក្រៀមក្រោះ ។

**ម្យ៉ាងទៀត** អ្នកប្រាជ្ញតាំងពីបុរាណកាល រមែងពោលទុកថា បញ្ចកាមគុណ រមែងរួមនៅក្នុងស្ត្រីប៉ុណ្ណោះ គ្មានរូបណាស្មើដោយរូបស្ត្រី គ្មានសំឡេងណាស្មើដោយសំឡេងស្ត្រី គ្មានក្លិនអ្វីណាស្មើដោយក្លិនស្ត្រី មិនមានរសណាស្មើដោយរសស្ត្រី មិនមានសម្ផស្សណាស្មើដោយសម្ផស្សស្ត្រី ហើយក្រៃលែងទៅទៀត មិនមានស្ត្រីណាល្អប្រសើរស្មើស្ត្រីដែលខ្លួនស្រឡាញ់ ។

កាលបើគិតដូច្នេះ កាមគុណជាចំណែកមានជ័យជំនះ លើចិត្តខ្ញុំ បានកាត់ចិត្តថានឹងសិកក្នុងថ្ងៃណាមួយ តែពិនិត្យគិតមើលសមណភេទទៀត ខ្ញុំដូចជានៅស្តាយពេកណាស់ ។

**ល្ងាចថ្ងៃមួយ** កាលងូតទឹកជំរះកាយហើយ ដោយការអផ្សុក ខ្ញុំក៏ចេញចាកវត្តវេឡុវនទៅវាលស្រែលំហែកាយ ហើយចូលទៅកាន់ភូមិមួយនៃពួកកសិករខ្សត់ក្រ គ្រាន់តែចូលដល់បរិវេណភូមិប៉ុណ្ណោះ ខ្ញុំបានឃើញស្ត្រីកណ្តាលអាយុម្នាក់ កំពុងអង្គុយដេរប្រទេចនរណាម្នាក់នៅមុខខ្ទមដែលធ្វើដោយដីលាយអាចម៍គោនិងចំបើង កូនស្រីម្នាក់របស់នាង

អង្គុយយំនៅជិតឆ្នាំងបាយដែលដាក់លើចង្ក្រាន ខណៈដែលខ្ញុំឆ្លងកាត់ទៅនោះឯង ស្វាមីរបស់នាង បានស្ទុះចេញមកពីខ្ទម តម្រង់ទៅវាយតប់ទាត់ធាក់ប្រពន្ធគ្មានប្រណី នាងជាភរិយា ដួលត្រឡប់ត្រឡិនដេកបំរះនៅនឹងដី តែមាត់ក៏នៅមានសំឡេងជេរប្រទេចខ្លាំងជាងមុន ស្វាមីវាយតប់ភរិយាល្មមអន់កំហឹងហើយ ក៏ដើរសំដៅទៅវាលស្រែបាត់ទៅ ។

**លោក_អ្នកអានទាំងឡាយ!** កាលបានឃើញហេតុការណ៍នេះហើយ ខ្ញុំកើតសេចក្តីសង្វេគស្លុតចិត្តឡើងច្រើន ស្វាមីភរិយាគូនោះកាលមុនបានចុះសម្រុងរួមជីវិតនឹងគ្នាដោយសង្ឃឹមថាបានសេចក្តីសុខ តែកាលសភាពការណ៍ជាយ៉ាងនេះ គេនឹងមានសេចក្តីសុខដូចម្តេចកើត ?។

ខ្ញុំធ្វើដំណើរទៅរហូដល់ផ្ទះមួយខ្នងធំយ៉ាងល្អ តាំងនៅកណ្តាលភូមិ គឺជាផ្ទះព្រាហ្មណ៍មាននាទីជាមេស្រុកនោះ ដែលមានសេចក្តីសិទ្ធស្នាលនឹងខ្ញុំៗចូលទៅសួរសុខទុក្ខ តែមេស្រុកមិននៅ មានកិច្ចចូលទៅក្នុងរាជធានី ព្រាហ្មណីជាភរិយាទទួលខ្ញុំជំនួសប្តី ខ្ញុំក៏បានទទួលការសិក្សាគំនិតថ្មីបន្ថែមទៀត ព្រោះព្រាហ្មណ៍បាននិយាយរឿងការងារលំ-បាករបស់នាងនិងស្វាមីឱ្យខ្ញុំស្តាប់ តាំងពីការទារពន្ធដារអាករ និងអ្វី ៗ កូនស្រុក ការធ្វើស្រែថៃចំការ ការទាក់ទងនឹងនាយចៅហ្វាយ និងអ្វីៗដទៃៗទៀត កាលបានស្តាប់ហើយ ធ្វើឱ្យខ្ញុំគិតឃើញថា នាងកំពុង

ត្រូវចំណាង ៣០ ប្រាយចង្សូតរីតជុំវិញខ្លួន ទាល់តែកម្រើកខ្លួនមិនបាន កាលបើដូច្នេះ តើនឹងមានសេចក្ដីសុខបានយ៉ាងណា ?

**ចេញពីនោះ** ខ្ញុំបានដើរកាត់មុខផ្ទះមួយខ្នង ដែលមានសំឡេងយំរបស់ស្ត្រីម្នាក់យ៉ាងគួរខ្លោចផ្សា កាលសួរ បានសេចក្ដីថា នាងកំពុងកើតទុក្ខចុកសៀត ព្រោះស្វាមីរបស់នាងបានត្រូវពស់ចឹកស្លាប់ក្នុងពេលដែលនៅកាស់ឧសក្នុងព្រៃ កាលថ្ងៃរសៀលនេះឯង ។

ខ្ញុំក៏ចេញពីភូមិ ស្រុក ដើរទៅដោយប្រើគំនិត ព្រឹត្តិការណ៍ដែលទើបជួបប្រទះដាស់ស្មារតីខ្ញុំឡើងវិញ ខ្ញុំឃើញច្បាស់ថា " ជីវិតរបស់ឃរាវាស តែងមានលក្ខណៈដូចបានឃើញមកហើយ ក្នុងផ្ទះដំបូងដែលឃើញប្ដីប្រពន្ធឈ្លោះវាយតប់គ្នា គេទាំងពីរនាក់នោះ កាលផ្ដើមស្រឡាញ់គ្នាមុនដំបូង ឬកាលរៀបការថ្មីៗ ក៏ស្រឡាញ់គ្នាមានសេចក្ដីសុខព្រោះអំណាចសេចក្ដីស្រលាញ់ ធ្វើឱ្យគេឃើញតែក្នុងផ្នែកល្អនៃគ្នានិងគ្នា សេចក្ដីក្រែងរអែងចិត្តគ្នាធ្វើឱ្យគេប្រព្រឹត្តល្អចំពោះគ្នា លាក់ទុកផ្នែកមិនល្អបញ្ចេញតែផ្នែកល្អមកប្រើ តែមិនយូរប៉ុន្មាន កាលសេចក្ដីស្រឡាញ់ថយខ្សោយចុះ សេចក្ដីរអែងចិត្តគ្នាមានតិច ទាំងពីរផ្នែក ក៏បញ្ចេញផ្នែកមិនល្អរបស់ខ្លួនមក កាលសំឡឹងមើលគ្នា ក៏ជួបតែផ្នែកដែលមិនល្អរបស់គ្នានិងគ្នា ក្នុងទីបំផុត ក៏ធ្វើមិនល្អឱ្យគ្នាកើតជម្លោះវាយតប់គ្នា សេចក្ដី

សុខក៏អន្តរធានទៅ ដូច្នោះ សេចក្តីស្រឡាញ់ដែលជាប់ដោយកាម ទើបជាថ្នាំពិសលាយទឹកឃ្មុំ កាលលិតរសដំបូង ក៏ដូចជាផ្អែមឆ្ងាញ់ តែមិនយូរក៏នឹងត្រូវថ្នាំពិសពុល សុខអាស្រ័យកាមជាសុខបន្តិចបន្តួច តែមានទុក្ខច្រើន ជាសុខប្រភេទផ្អែមគល់ ខាងចុងជូរចត់ល្វីងហឺរ ។

កាលដែលខ្ញុំទៅផ្ទះមេស្រុក ព្រាហ្មណីបាននិយាយសេចក្តីលំបាក កង្វល់ផ្សេងៗ ឱ្យខ្ញុំស្តាប់ ជីវិតរបស់ឃរាវាស ពេញដោយការៈធ្ងន់ ត្រូវធ្វើការរកទ្រព្យចិញ្ចឹមខ្លួន-ប្រពន្ធ-កូន-មិត្ត ត្រូវមានផ្ទះនៅ មានស្រែចំការ មានមិត្តភ័ក្ត ដែលត្រូវយកចិត្តទុកដាក់ ទៅណាមកណាក៏មានចិត្តហួងហែងកង្វល់, ជីវិតឃរាវាស ប្រៀបដូចបុរសរែកភារៈដ៏ធ្ងន់ទុកលើស្មា មិនសប្បាយ មិនមានសេរីភាព ជីវិតរបស់សមណៈជាជីវិតស្រាលមានសេរីភាព ដូចបុគ្គលដាក់ភារៈធ្ងន់ចេញពីស្មាហើយ រមែងដើរទៅបានយ៉ាងសប្បាយ ។

**ក្នុងផ្ទះទី ៣** ដែលខ្ញុំបានឃើញស្ត្រីដែលកំពុងយំទួញ ព្រោះប្តីស្លាប់ នោះបង្ហាញឱ្យឃើញទុក្ខធំរបស់សត្វលោក មនុស្សមានរបស់ណា ក៏រមែងស្រឡាញ់ច្រើនក្នុងរបស់នោះ កាលរបស់នោះបាត់បង់ទៅ ក៏កើតទុក្ខ ស្រឡាញ់ច្រើនប៉ុនណា ទុក្ខក៏ប៉ុណ្ណោះ ស្រឡាញ់តិចទុក្ខក៏តិច បើមិនស្រឡាញ់សោះ ទុក្ខក៏គ្មានសោះដែរ ។

" ស្រឡាញ់ច្រើន ទុក្ខក៏ច្រើន ចំរើនណាស់
ស្រឡាញ់ខ្លះ ទុក្ខក៏ខ្លះ មិនប៉ះខ្លាំង
ស្រឡាញ់តិច ទុក្ខក៏តិច រិចទុក្ខំ
ចាំងស្រឡាញ់ ចោលស្រឡះ ខះទុក្ខអឺយ " ។

ខ្ញុំធ្វើដំណើរចូលទៅក្នុងព្រៃមួយ ប្រកបដោយដើមឈើនានាប្រភេទយ៉ាងស្តុកក្រាស់ អាកាសងងឹតនិងត្រជាក់ ខ្ញុំដើរទៅរហូតដល់កណ្តាលព្រៃ ខ្ញុំក៏ឈរឈប់នៅកន្លែងមួយ ខាងមុខខ្ញុំនោះឯង សពមនុស្សប្រុសម្នាក់ដេកនៅលើផែនដី កំពុងហើមប៉ោង ចោលក្លិនស្អុយមុតមានស្នាម ខៀវ ខ្មៅ ស តាមស្បែកនៃរាងកាយ, ផ្នែកខ្លះ ក៏មានទឹកលឿងហូរចេញមក អណ្តាតលៀនធ្លាក់ចេញមកក្រៅមាត់ មានពពុះទឹកស១ ព្រួច! ឡើងចេញពីមាត់ម្តង១ ។

ដើរបន្តិចទៅទៀត ក៏ជួបសាកសពមួយទៀត ដេកផ្កាប់មុខនិងផែនដី ជាសពដែលស្អុយរលួយពេញទីហើយ សាច់ស្បែកផ្នែកខ្លះមានស្នាមសត្វកាត់លុងស៊ី ទាញពោះវៀនចេញតាយរឡាយ ហ្វូងដង្កូវកំពុងចោះខែបរិវេណខ្នង ទាល់តែឃើញគ្រោងឆ្អឹងលៀនចេញមក ដង្កូវខ្នាតធំ១វារនៅពេញរាងកាយ ។ ភាពនេះនាំឱ្យនឹងឃើញច្បាស់ថា :

" នេះគឺចំណុចក្រោយនៃវិថីជីវិតរបស់មនុស្សគ្រប់គ្នា "

" **ជីវិតគឺការធ្វើដំណើរទៅកាន់សេចក្តីស្លាប់** " ថ្ងៃមួយដែលកន្លងទៅ គឺមួយជំហានដែលយើងឈានចូលទៅជិតសេចក្តីស្លាប់ កាលសេចក្តីស្លាប់តាមមកដល់ កាយនេះក៏នឹងដូចសាកសពដែលខ្ញុំបានឃើញនេះ មិនមានលំអ មិនគួរស្រឡាញ់ មិនគួរសរសើរ មានតែសេចក្តីស្មោកគ្រោកស្អុយរលួយដូចសពនោះ កាលនៅមានជីវិតក៏ដូចយើងទាំងអស់គ្នា យើងកាលស្លាប់ហើយ ក៏ដូចជាសាកសពនោះដែរ យ៉ាងយូរណាស់មួយរយឆ្នាំប៉ុណ្ណោះ ។

**ប្រិយមិត្តទាំងឡាយ!** ចិត្តរបស់ខ្ញុំពេលនោះ ពេញដោយសេចក្តីសង្វេគ នឿយណាយរសាយតណ្ហា រហូតឃើញខ្លួនឯងជាសាកសពផងរុយមួយហ្វូងធំហើរមករកទុំខ្ញុំ វាប្រហែលគិតថា ខ្ញុំជាសាកសពដែរ ។

ខ្ញុំត្រឡប់ទៅវត្តវិញ ទៅពេលព្រលប់ ភាពសាកសពនៅជាប់នឹងភ្នែកនឹងចិត្តខ្ញុំយ៉ាងច្បាស់លាស់ មិនអាចនឹងភ្លេចបាន ទោះសឹងនៅក្នុងកុដិ ក៏ហាក់ដូចជាកំពុងសឹងនៅក្នុងព្រៃខ្មោច យប់នោះខ្ញុំស្ទើរតែឆាន់ទឹកមិនកើត ព្រោះនាំឱ្យនឹកដល់ទឹករងៃនៃសាកសព ។ ព្រឹកឡើងពេលកំពុងដើរបិណ្ឌបាត ខ្ញុំឃើញមនុស្សដែលដើរទៅមកជាសាកសពទាំងអស់ ខ្ញុំឆាន់បាយបានបន្តិចបន្តួច ព្រោះដូចជាកំពុងឆាន់សាកសព ។ ហេតុការណ៍ដែលបានឃើញ ព្រមទាំងព្រៃខ្មោចបានផ្លាស់ចិត្តរបស់ខ្ញុំ

ពីខ្មៅទៅស ខ្ញុំឃើញថាលោកនេះមិនមែនលោកដែលគួរត្រេកអរឡើយ ចំណង់ស្នេហាដោយអំណាចរាគៈដែលគ្រប់សង្កត់ចិត្តខ្ញុំនាំឱ្យចង់សឹក ត្រូវអំណាចរបស់ព្រៃខ្មោចកំចាត់ចោលហើយ ។ ព្រៃខ្មោចនាំឱ្យខ្ញុំឃើញស្ត្រីជាគ្រោងឆ្អឹងយ៉ាងពិតប្រាកដ ។ ខ្ញុំធ្វើចិត្តឱ្យក្សេមក្សាន្តក្រេបនូវរសព្រះធម៌ បើកាមរាគកើតឡើង ក៏នឹកដល់ព្រៃខ្មោច ក៏ស្ងប់រម្ងាប់ទៅវិញ ។

| | | |
|---|---|---|
| រូបកាយនេះ | តែងជួបគ្រោះ | គ្រាំគ្រាជាក់ |
| ជាពំនាក់ | ស្នាក់ពំនឹង | នៅនៃរោគ |
| នឹងបែកធ្លាយ | រលាយធ្លុះ | បាក់រខោក |
| ជាកាយស្មោក | គ្រោកឆ្អេះឆ្អាប | ស្អុយអប្រិយ។ |
| ជាអសារ | ការបណ្ដោះ | នូវអាសន្ន |
| បញ្ឆោរជន | ឱ្យភ័ន្តភាំង | តាំងស្មារតី |
| ព្រោះជីវិត | មិត្តសត្វលោក | ក្នុងភពបី |
| រយៈខ្លី | សេចក្ដីស្លាប់ | ចាប់យកទៅ ។ |

**ឱម_ណាគ្រី**

# អវសានកថា

**លោក-អ្នកអានជាទីមេត្រី!** ដំណើរពនេចររបស់ខ្ញុំ បានទៅផ្អាកសម្រាកសិននៅក្នុងព្រះវេឡុវនារាម រហូតដល់ឆ្នាំដែលព្រះបរម-សាស្តាស្តេចរំលត់ខន្ធបរិនិព្វាន ទើបខ្ញុំត្រេចរង្គាត់ធ្វើពនេចរតទៅទៀតក្នុងលោកដ៏ទូលំទូលាយ អស់រយៈផ្លូវដ៏វែងឆ្ងាយ ។ ពេលវេលាដ៏យូរយារ ដែលខ្ញុំត្រេចចរទៅនោះ បានជួបប្រទះឆ្លងកាត់ហេតុការណ៍ទាំងល្អទាំងអាក្រក់ច្រើនសែនច្រើន ទាល់តែហួសសមត្ថភាពនឹងកត់ចងចាំទាំងអស់បាន ។ រឿងដែលខ្ញុំនិយាយថ្វាយ-ប្រគេន-ជូនមកតាំងពីដើមមកនេះ គ្រាន់តែជាភាគ១ ក្នុងភាគ៤ ប៉ុណ្ណោះ ។ លោកនេះពេញដោយអ្វីៗដែលគួរសិក្សា តែក៏គង់មិនមាននរណាសិក្សាបានរហូតចប់សព្វគ្រប់ឡើយ តែទោះសិក្សាមិនចប់ក៏ដោយ ការសន្សំការដឹង-យល់ច្រើនៗក៏ជាការល្អ, សម្រាប់ខ្ញុំវិញនោះ បើបានដឹងស្គាល់យល់រឿងរ៉ាវពិភពលោកច្រើនត្រឹមណា សេចក្តីស្រវឹងវង្វេងក្នុងបញ្ហាលោក ក៏ខ្សោយថយចុះត្រឹមណោះដែរ រហូតក្នុងទីបំផុត ខ្ញុំក្លាយជាមនុស្សមិនជាប់ជំពាក់នឹងទីកន្លែង មិនជំពាក់នឹងបុគ្គល ទោះនៅទីណាជាមួយអ្នកណា ពួកណា

កាលណា ក៏បានទាំងអស់ ចិត្តសប្បាយប៉ុនៗគ្នា ។ ការបានឆ្លងកាត់ជួបប្រទះហេតុការណ៍ទាំងល្អទាំងអាក្រក់ច្រើនៗ ធ្វើឱ្យចិត្តគំនិតរបស់ខ្ញុំក្លាយជាកំពែងដ៏រឹងប៉ឹង មិនប៉ោងឡើង កាលជួបប្រទះផ្នែកល្អ មិនទ្រោមចុះ កាលជួបប្រទះផ្នែកអាក្រក់ នរណាយកសម្បត្តិរបស់បច្ច័យអ្វីៗមកឱ្យក៏មានចិត្តជាកណ្ដាលៗ, នរណាមកឆក់លួចទៅក៏មានចិត្តជាកណ្ដាលៗហើយដែរ, នរណាមកជេរចំពោះមុខ ឬមកសរសើរលើកដំកើងចិត្តខ្ញុំក៏នៅជាកណ្ដាលៗ សប្បាយស្រួលដូចគ្នា ។

**លោក-អ្នកអានទាំងឡាយ!** ខ្ញុំនិយាយមកនេះ មិនបានសំដៅសេចក្ដីថា ខ្ញុំបានសម្រេចមគ្គផលជាន់ខ្ពស់ហើយ ទើបមានចិត្តរឹងប៉ឹងមិនញាប់ញ័រក៏ទេដែរ ខ្ញុំនៅជាបុថុជ្ជនធម្មតា តែព្រោះហេតុដែលបានជួបប្រទះប៉ះទង្គិចឆ្លងកាត់ហេតុការណ៍ផ្សេងៗ មករហូតជិនថ្នឹកនោះឯង ធ្វើឱ្យខ្ញុំចេះពិចារណាអប់រំចិត្ត មិនញាប់ញ័រគឺមិនខ្វើកតាមខ្យល់ ខ្វល់តាមរលកនៃលោកធម៌ពេកទេ ។

ខ្ញុំសូមបញ្ចប់រឿងរបស់ខ្ញុំត្រឹមនេះសិន គ្រាក្រោយបើមានឱកាសខ្ញុំនឹងនាំមកនិយាយឱ្យស្ដាប់បន្តទៅទៀត បើលោក-អ្នកអានបានស្ដាប់ជាទីមេត្រីទាំងឡាយ បានទទួលសេចក្ដីដឹងយល់ចូលចិត្តក្នុងគោលធម៌របស់

ព្រះបរមសាស្តាអំពីការនិយាយរបស់ខ្ញុំ ខ្ញុំក៏ឈ្មោះថា បានធ្វើបុណ្យកុសល ហើយ ខ្ញុំសូមឧទ្ទិសចំណែកកុសលទាំងអស់នោះ ចំពោះវិញ្ញាណក្ខន្ធនៃមាតាបិតាខ្ញុំ គ្រូបាធ្យាយន៍របស់ខ្ញុំ ដែលលោកឋិតនៅក្នុងភពណាៗក៏ដោយ សូមទទួលជ្រាបគោលបំណងល្អរបស់ខ្ញុំ ហើយអនុមោទនា នឹងបានសោយសុខតាមសមគួរដល់គតិភពនោះចុះ ។

**" ចប់ "**

WAT KHEMARARATANARAM